ការបោះឆ្នោតទូទៅនៅរដ្ថ California

ថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា ឆ្នាំ 2018

ការិយាល័យបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹករហូតដល់ម៉ោង 8:00 យប់ នៅថ្ងៃបោះឆ្នោត!

★ ★ ★ ★ ★ មគ្គុទ្ទេសក៍ផ្លូវការសម្រាប់ព័ត៌មានអ្នកបោះឆ្នោត ★ ★ ★ ★ ★

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ

ខ្ញុំឈ្មោះ Alex Padilla ជារដ្ថលេខាធិការនៃរដ្ថ California សូម បញ្ជាក់ថា វិធានការដែលបានដាក់បញ្ចូលនេះ នឹងត្រូវបានដាក់ជូនអ្នកបោះឆ្នោតនៃរដ្ថ California នៅក្នុងការបោះឆ្នោតទូទៅដែលនឹងប្រារព្ធឡើងទូទាំង រដ្ថ នៅថ្ងៃទី 6 ខែ វិច្ឆិកា ឆ្នាំ 2018 ហើយសៀវភៅមគ្គុទ្ទេសក៍នេះត្រូវបាន រៀបចំឡើងយ៉ាងត្រឹមត្រូវ ស្របតាមច្បាប់។ សាក្ខីភាពនៃហត្ថារបស់ខ្ញុំ និងត្រាដ៏អស្ចារ្យរបស់រដ្ថ ធ្វើនៅក្រុង Sacramento នៃរដ្ថ California ថ្ងៃទី 13 ខែសីហា ឆ្នាំ 2018 នេះ។

Alex Padilla, រដ្ថលេខាធិការ

កម្រងសិទ្ធិ

អ្នកបោះឆ្នោត

អ្នកមានសិទ្ធិដូចខាងក្រោម៖

1. **សិទ្ធិបោះឆ្នោត ប្រសិនបើអ្នកជាអ្នកដែលបានចុះឈ្មោះបោះឆ្នោត។** អ្នកមានលក្ខណសម្បត្តិអាចបោះឆ្នោតបាន ប្រសិនបើអ្នក៖
   - ជាពលរដ្ឋអាមេរិកដែលរស់នៅរដ្ឋ California
   - យ៉ាងហោចណាស់មានអាយុ 18 ឆ្នាំ
   - បានចុះឈ្មោះកន្លែងដែលអ្នកកំពុងរស់នៅបច្ចុប្បន្ន
   - បច្ចុប្បន្នមិនស្ថិតក្នុងពន្ធនាគាររដ្ឋ ឬពន្ធនាគារសហព័ន្ធ ឬត្រូវបានដោះលែងបណ្តោះអាសន្នចំពោះទោសបទឧក្រិដ្ឋណាមួយ
   - បច្ចុប្បន្ននេះ តុលាការមិនបានរកឃើញថាអសមត្ថភាពផ្លូវចិត្តក្នុងការបោះឆ្នោត

2. **សិទ្ធិបោះឆ្នោត ក្នុងករណីអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ ប៉ុន្តែឈ្មោះរបស់អ្នកមិនមាននៅក្នុងបញ្ជី។** អ្នកនឹងបោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន។ ការបោះឆ្នោតរបស់អ្នកនឹងត្រូវរាប់បញ្ចូល ប្រសិនបើមន្ត្រីបោះឆ្នោតកំណត់ថាអ្នកមានលក្ខណសម្បត្តិអាចបោះឆ្នោតបាន។

3. **សិទ្ធិក្នុងការបោះឆ្នោត ប្រសិនបើអ្នកស្ថិតនៅក្នុងជួររង់ចាំ ទោះជានៅពេលដែលការិយាល័យបោះឆ្នោតត្រូវបិទក៏ដោយ។**

4. **សិទ្ធិក្នុងការបោះសន្លឹកឆ្នោតសម្ងាត់** ដោយគ្មាននរណារំខានអ្នក ឬប្រាប់អ្នកពីរបៀបបោះឆ្នោត។

5. **សិទ្ធិក្នុងការទទួលបានសន្លឹកឆ្នោតថ្មី ក្នុងករណីដែលអ្នកបានធ្វើកំហុស,** ប្រសិនបើអ្នកមិនទាន់បានបោះសន្លឹកឆ្នោតរបស់អ្នកនៅឡើយ។ អ្នកអាច៖
   ស្នើមន្ត្រីបោះឆ្នោតនៅកន្លែងបោះឆ្នោត សុំសន្លឹកឆ្នោតថ្មីមួយ
   ប្តូរសន្លឹកឆ្នោតបោះតាមសំបុត្ររបស់អ្នក យកសន្លឹកឆ្នោតថ្មីនៅឯការិយាល័យបោះឆ្នោត ឬនៅឯកន្លែងបោះឆ្នោតរបស់អ្នក ឬ **បោះឆ្នោតដោយប្រើសន្លឹកឆ្នោតបណ្តោះអាសន្ន**។

6. **សិទ្ធិក្នុងការទទួលបានជំនួយបោះសន្លឹកឆ្នោតរបស់អ្នក** ពីនរណាម្នាក់ដែលអ្នកជ្រើសរើស លើកលែងតែនិយោជក ឬតំណាងសហជីពរបស់អ្នក។

7. **សិទ្ធិដើម្បីទម្លាក់សន្លឹកឆ្នោតបោះតាមសំបុត្រដែលបានបំពេញរបស់អ្នក នៅឯកន្លែងបោះឆ្នោត** ក្នុងរដ្ឋ California។

8. **សិទ្ធិក្នុងការយកសម្ភារបោះឆ្នោតជាភាសាផ្សេងក្រៅពីភាសាអង់គ្លេស**ប្រសិនបើមានមនុស្សគ្រប់គ្រាន់នៅក្នុងមណ្ឌលបោះឆ្នោតរបស់អ្នកនិយាយភាសានោះ។

9. **សិទ្ធិក្នុងការសួរសំណួរទៅមន្ត្រីបោះឆ្នោតអំពីនីតិវិធីបោះឆ្នោត** និងពិនិត្យដំណើរការបោះឆ្នោត។ ប្រសិនបើបុគ្គលដែលអ្នកសួរមិនអាចឆ្លើយសំណួររបស់អ្នកបានពួកគេត្រូវបញ្ជូនអ្នកទៅបុគ្គលដែលអាចផ្តល់ចម្លើយជូនអ្នកបាន។ ប្រសិនបើបង្ការរំខានពួកគេអាចឈប់ឆ្លើយនឹងអ្នក។

10. **សិទ្ធិក្នុងការរាយការណ៍សកម្មភាពបោះឆ្នោតខុសច្បាប់ ឬក្លែងបន្លំណាមួយ** ទៅមន្ត្រីបោះឆ្នោត ឬការិយាល័យរដ្ឋលេខាធិការ។
    - នៅលើបណ្តាញវ៉ិប www.sos.ca.gov
    - តាមទូរស័ព្ទលេខ (888) 345-4917
    - តាមអ៊ីម៉ែល elections@sos.ca.gov

ប្រសិនបើអ្នកជឿថាអ្នកត្រូវបានគេបដិសេធសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងនេះ សូមទូរស័ព្ទទៅលេខសម្ងាត់អ្នកបោះឆ្នោតដោយឥតគិតថ្លៃរបស់រដ្ឋលេខាធិការ **(888) 345-4917**។

តារាងមាតិកា

ទំព័រ

មគ្គុទ្ទេសក៍យោងរហ័ស 5

សំណើប្រជាមតិ

1 អនុញ្ញាតឲ្យប្រើប័ណ្ណកម្ចីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានជាក់លាក់។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។ 12

2 អនុញ្ញាតឲ្យប្រើប័ណ្ណកម្ចីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានដែលមានស្រាប់សម្រាប់បុគ្គលដែលមានជំងឺផ្លូវចិត្ត។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។ 18

3 អនុញ្ញាតប័ណ្ណកម្ចីអោយផ្តល់មូលនិធិសម្រាប់គម្រោងផ្គត់ផ្គង់ទឹក និងគុណភាព ទីជម្រាល ត្រី សត្វព្រៃ ការនាំផ្លូវទឹក និងការទ្រទ្រង់ និងស្តុកទុកទឹកក្រោមដី។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ លក្ខន្តិកៈផ្ទួចផ្តើម 22

4 អនុញ្ញាតឲ្យប័ណ្ណកម្ចីផ្តល់មូលនិធិដល់ការសង់មន្ទីរពេទ្យដែលផ្តល់ការថែទាំសុខភាពដល់កុមារ។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ លក្ខន្តិកៈផ្ទួចផ្តើម .. 28

5 ផ្លាស់ប្តូរសេចក្តីតម្រូវសម្រាប់ម្ចាស់អចលនទ្រព្យមួយចំនួនក្នុងការផ្ទេរមូលដ្ឋានពន្ធអចលនទ្រព្យរបស់ខ្លួនសម្រាប់អចលនទ្រព្យដាក់ជំនួស។ ការចាប់ផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។ 34

6 បំបាត់ចោលមូលនិធិការជួសជុលផ្លូវ និងគមនាគមន៍មួយចំនួន។ តម្រូវឲ្យពន្ធលើប្រេងឥន្ធនៈ និងថ្លៃរថយន្ត មួយចំនួនត្រូវបានអនុម័តដោយអង្គបោះឆ្នោត។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ 40

7 អនុលោមម៉ោងសន្សំពន្លឺថ្ងៃនៅរដ្ឋ California ទៅនឹងច្បាប់សហព័ន្ធ។ អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិប្តូររយៈពេលសន្សំពន្លឺថ្ងៃ។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។ 44

8 ធ្វើបញ្ញត្តិតម្លៃសម្រាប់ការលាងឈាមតម្រងនោមអ្នកជំងឺខាងក្រៅសម្រាប់ការព្យាបាលតម្រងនោម។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ។ 48

9 នៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2018 សំណើប្រជាមតិលេខ 9 ត្រូវបានដកចេញពីសន្លឹកឆ្នោតតាមបញ្ជារបស់តុលាការកំពូលរដ្ឋ California ។ ... 56

10 ពង្រីកអំណាចរដ្ឋាភិបាលមូលដ្ឋាន ដើម្បីអនុម័តលើការត្រួតពិនិត្យការជួលអចលនទ្រព្យជាលំនៅដ្ឋាន។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ លក្ខន្តិកៈផ្ទួចផ្តើម 58

11 តម្រូវឲ្យបុគ្គលិករថយន្តពេទ្យបន្ទាន់ផ្នែកវិស័យឯកជនអោយនៅប្រចាំការទទួលទូរស័ព្ទក្នុងកំឡុងពេលសម្រាកធ្វើការ។ លុបបំបាត់ការទទួលខុសត្រូវមួយចំនួនរបស់និយោជក។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ លក្ខន្តិកៈផ្ទួចផ្តើម 62

12 បង្កើតស្តង់ដារថ្មីសម្រាប់ការដាក់ឃាំងសត្វកសិដ្ឋានជាក់លាក់ ហាមឃាត់ការលក់ផលិតផលមិនអនុវត្តតាមច្បាប់។ លក្ខន្តិកៈ ផ្តើមប្រជាសិទ្ធិ លក្ខន្តិកៈផ្ទួចផ្តើម 68

ទិដ្ឋភាពទូទៅនៃបំណុលសញ្ញាប័ណ្ណកម្ចីរដ្ឋ 72

សេចក្តីថ្លែងនៃបេក្ខជន 75

តុលាការយុត្តិធម៌កំពូល 89

ព័ត៌មានស្តីពីអ្នកបោះឆ្នោត

កម្រងសិទ្ធិអ្នកបោះឆ្នោត..... 2
លិខិតពីរដ្ឋលេខាធិការ..... 4
ពិនិត្យមើលស្ថានភាពរបស់អ្នកតាមអ៊ីនធឺណិត..... 11
ព័ត៌មានអំពីថ្ងៃបោះឆ្នោត..... 11
អ្នកបរិច្ចាគកំពូលៗទូទាំងរដ្ឋ បេក្ខជន និង វិធានការសន្លឹកឆ្នោត... 11
ព័ត៌មានអំពីការថ្លែងការណ៍របស់បេក្ខជន..... 74
ការបោះឆ្នោតនៅក្នុងរដ្ឋ California..... 90
ការិយាល័យបោះឆ្នោតរបស់ខោនធី..... 91
ការចុះឈ្មោះបោះឆ្នោត..... 92
ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខ័ណ្ឌ..... 92
ព័ត៌មានអំពីឯកជនភាពនៃការចុះឈ្មោះបោះឆ្នោត..... 92
ក្រមស្តីពីជម្រើសរបស់អ្នកបោះឆ្នោត..... 93
សេចក្តីជូនដំណឹងសំខាន់អំពីអត្ថបទនៃសំណើច្បាប់..... 94
ជំនួយសម្រាប់អ្នកបោះឆ្នោតមានពិការភាព..... 94
រ៉ឹបសៃយ៉ត៍លទ្ធផលនៃការបោះឆ្នោតប្រចាំរដ្ឋ..... 94
កាលបរិច្ឆេទដែលត្រូវចងចាំ..... 95

ចូលមើលរ៉ឹបសៃយ៉ត៍របស់រដ្ឋលេខាធិការ ដើម្បី៖

- ការបរិច្ចាគក្នុងយុទ្ធនាការស្រាវជ្រាវ និងសកម្មភាពបញ្ជុះបញ្ជូល *cal-access.sos.ca.gov* ឬ *powersearch.sos.ca.gov*
- មើលមគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះជាភាសាផ្សេង *www.voterguide.sos.ca.gov*
- ពិនិត្យមើលស្ថានភាពនៃការចុះឈ្មោះ និងព័ត៌មាននៃការចុះឈ្មោះរបស់អ្នក *VoterStatus.sos.ca.gov*
- ស្វែងរកកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតរបស់អ្នកនៅថ្ងៃបោះឆ្នោត *www.sos.ca.gov/elections/polling-place* ឬ *VoterStatus.sos.ca.gov*
- ទទួលព័ត៌មានបោះឆ្នោតតាមសំបុត្រ *www.sos.ca.gov/elections/voter-registration/vote-mail/*
- អានព័ត៌មានមានប្រយោជន៍សម្រាប់អ្នកបោះឆ្នោតលើកដំបូង *www.sos.ca.gov/elections/voting-california*

រដ្ឋលេខាធិការ

សួស្តីពលរដ្ឋ Californians ជាទីមេត្រី

គ្មានសិទ្ធិអ្វីធំជាងសិទ្ធិក្នុងការបោះឆ្នោតនោះទេ។ ប្រជាធិបតេយ្យរបស់អាមេរិករីកចំរើននៅពេលដែលអ្នកមានសិទ្ធិបោះឆ្នោតគ្រប់គ្នាចូលរួមបោះឆ្នោត។ តាមរយៈការបោះឆ្នោត អ្នកអាចជ្រើសរើសមេដឹកនំាក្នុងមូលដ្ឋាន ថ្នាក់រដ្ឋ និងថ្នាក់ជាតិរបស់អ្នក និងធានាថាសម្លេងរបស់អ្នកត្រូវបានគេស្តាប់។ ការបោះឆ្នោតទូទៅគឺនៅថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា។ ការបោះឆ្នោតធ្វើឡើងយ៉ាងឆាប់រហ័ស និងជិតមកដល់ហើយ។ ខ្ញុំសូមលើកទឹកចិត្តអ្នកឱ្យចូលរួមក្នុងសិទ្ធិជាមូលដ្ឋាន របស់អ្នកក្នុងនាមជាពលរដ្ឋនៃសហរដ្ឋអាមេរិក។

ព័ត៌មានទំាងអស់ត្រូវបានដាក់បង្ហាញនៅទីនេះជាសេចក្តីយោងសម្រាប់អ្នក។ មគ្គុទ្ទេសក៍អ្នកបោះឆ្នោតនេះ អាចជួយអ្នកឱ្យធ្វើការ សម្រេចចិត្តបានត្រឹមត្រូវ។ វារួមបញ្ចូលទំាងការវិភាគមិនលំអៀង ទឡ្ហីករណ៍គាំទ្រ និងប្រឆំាងនឹងវិធានការបោះឆ្នោតជាច្រើន សេចក្តីប្រកាសរបស់បេក្ខជន កម្រងសិទ្ធិអ្នកបោះឆ្នោត និងព័ត៌មានសំខាន់ៗដទៃទៀត។ មគ្គុទ្ទេសក៍នេះក៏អាចរកបាននៅលើអ៊ីនធឺណិត នៅលើវ៉ិបសៃយត៍របស់រដ្ឋលេខាធិការនៃរដ្ឋ California ផងដែរ៖ *www.VoterGuide.sos.ca.gov*។

អ្នកអាចពិនិត្យមើលស្ថានភាពនៃការចុះឈ្មោះបោះឆ្នោតរបស់អ្នកបានគ្រប់ពេលដោយ ចូលទៅកាន់ *VoterStatus.sos.ca.gov*។ អ្នកអាចទាញយកកម្មវិធី VOTE CALIFORNIA របស់យើង នៅលើទូរសព្ទទំនើបរបស់អ្នក ឬថេប្លិត ហើយចូលប្រើព័ត៌មានសំខាន់ៗអំពីការបោះឆ្នោត និងរកមើលទីតាំងបោះឆ្នោតដែលនៅជិតអ្នកបំផុត។ ហើយអ្នកអាចចូលមើលគេហទំព័រ *PowerSearch.sos.ca.gov* ប្រសិនបើអ្នកចង់ដឹងបន្ថែមទៀតអំពីអ្នកដែលផ្តល់ហិរញ្ញប្បទានដល់បេក្ខជន ឬសំណើប្រជាមតិលើសន្លឹកឆ្នោត។

ប្រសិនបើអ្នកមានសំនួរអំពីរបៀបបោះឆ្នោត ឬរបៀបចុះឈ្មោះបោះឆ្នោត អ្នកអាចទាក់ទងការិយាល័យនៃរដ្ឋលេខាធិការដោយហៅទូរស័ព្ទមកកាន់លេខ (888) 345-4917 ដោយឥតគិតថ្លៃ។ ដើម្បីទទួលបានព័ត៌មានទំនាក់ទំនងជាមួយមន្ត្រីរៀបចំការបោះឆ្នោតប្រចាំខោនធីក្នុងមូលដ្ឋានរបស់អ្នក សូមចូលមើលវ៉ិបសៃយត៍របស់រដ្ឋលេខាធិការតាមអាសយដ្ឋាន៖ *www.sos.ca.gov/county-elections-offices*។

សូមអរគុណចំពោះការប្តេជ្ញាចិត្តរបស់អ្នកចំពោះអនាគតរបស់រដ្ឋ និងប្រទេសរបស់យើង។ ការបោះឆ្នោតទូទៅធ្វើនៅថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា។ សន្លឹកឆ្នោតរបស់អ្នកសំខាន់ណាស់។ សន្លឹកឆ្នោតរបស់អ្នកគឺជាសម្លេងរបស់អ្នក។ ត្រូវបានស្តាប់។ បោះឆ្នោត!

មគ្គុទ្ទេសក៍យោងឆាប់រហ័ស

សំណើប្រ.មតិ 1 អនុញ្ញាតឲ្យប្រើប័ណ្ណកម្ចីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានជាក់លាក់។ លក្ខន្តិ:អង្គនីតិបញ្ញត្តិ។

សេចក្តីសង្ខេប *ដាក់លើសន្លឹកឆ្នោតដោយអង្គនីតិបញ្ញត្តិ*

អនុញ្ញាតថវិកាចំនួន $4 ពាន់លានដុល្លារនៅក្នុង ប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅសម្រាប់កម្មវិធីលំនៅដ្ឋានដែលមានស្រាប់សម្រាប់អ្នកមានប្រាក់ចំណូលទាប អតីតយុទ្ធជន កសិករ ផ្ទះសម្បែងដែលផលិត និងលំនៅដ្ឋានចល័ត តំបន់បំពេញ និងលំនៅដ្ឋានជាត្រង់ស៊ីត។ ផលប៉ះពាល់សារពើពន្ធ៖ បង្កើនតម្លៃនៃការបង់ សងប័ណ្ណកម្ចីរដ្ឋ ជាមធ្យមប្រហែល $170 លានដុល្លារជារៀងរាល់ឆ្នាំក្នុងរយៈពេលលើសពី 35 ឆ្នាំ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រនៅលើវិធានការនេះមានន័យថា៖ អនុញ្ញាតឲ្យរដ្ឋលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅដែលមានតម្លៃទឹកប្រាក់ចំនួន $4 ពាន់លានដុល្លារដើម្បីផ្តល់មូលនិធិដល់អតីតយុទ្ធជន និងលំនៅដ្ឋានដែលមានតម្លៃសមរម្យ។

ទេ សន្លឹកឆ្នោតប្រឆាំងនៅលើវិធានការនេះមានន័យថា៖ រដ្ឋមិនអាចលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅដែលមានតម្លៃ ទឹកប្រាក់ចំនួន $4 ពាន់លានដុល្លារដើម្បីផ្តល់មូលនិធិដល់អតីតយុទ្ធជន និងលំនៅដ្ឋានដែលមានតម្លៃសមរម្យនោះទេ។

សេចក្តីសំអាង

គាំទ្រ ឆ្នោតគាំទ្រលើសំណើប្រជាមតិលេខ 1 គឺដើម្បីលំនៅដ្ឋានសមរម្យសម្រាប់អតីតយុទ្ធជន គ្រួសារអ្នកធ្វើការ មនុស្សចាស់ជនពិការ និងអ្នករស់នៅក្នុងរដ្ឋ California ដែលបាត់បង់លំនៅដ្ឋានដោយសារវិបត្តិលំនៅដ្ឋានធ្ងន់ធ្ងរនៅរដ្ឋ California។ សំណើប្រជាមតិលេខ 1 មិនបង្កើនពន្ធទេ! អតីតយុទ្ធជន កម្មវិធី Habitat for Humanity សមាជនៃមន្ត្រី California ជាន់ខ្ពស់ សម្ព័ន្ធមិត្តដើម្បីបញ្ចប់អំពើហិង្សាក្នុងគ្រួសារ និងច្រើនទៀត សុទ្ធតែឯកភាពគ្នា៖ សន្លឹកឆ្នោតគាំទ្រលើសំណើប្រជាមតិលេខ 1។

បដិសេធ ឆ្លាងនឹងសំណើប្រជាមតិលេខ 1 គឺអនុញ្ញាតឲ្យរដ្ឋខ្ចីប្រាក់ $4 ពាន់លានដុល្លារ (ដោយការលក់ប័ណ្ណកម្ចី) សម្រាប់កម្មវិធីលំនៅដ្ឋាន។ កង្វះលំនៅដ្ឋានដែលកើតមានដោយសារលំហូរមនុស្សរាប់លាននាក់មកកាន់រដ្ឋ California តម្រូវឲ្យមានដំណោះស្រាយចម្បង។ ដំណោះស្រាយអន់ដែលបានស្នើឡើងកាលពីដើមឆ្នាំនេះ (សេចក្តីព្រាងច្បាប់របស់ព្រឹទ្ធសភា 827) នឹងបានបំផ្លាញសង្កាត់ដែលមានស្រាប់។ មានវិធីសាស្ត្រល្អប្រសើរជាងនោះ។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

David Koenig
(916) 974-9411
info@vetsandaffordablehousingact.org
Vetsandaffordablehousingact.org

ប្រឆាំង

Gary Wesley
Mountain View, CA

សំណើប្រ.មតិ 2 អនុញ្ញាតឲ្យប្រើប័ណ្ណកម្ចីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានដែលមានស្រាប់សម្រាប់បុគ្គលដែលមានជំងឺផ្លូវចិត្ត។ លក្ខន្តិ:អង្គនីតិបញ្ញត្តិ។

សេចក្តីសង្ខេប *ដាក់លើសន្លឹកឆ្នោតដោយអង្គនីតិបញ្ញត្តិ*

កែប្រែច្បាប់សេវាសុខភាពផ្លូវចិត្ត (Mental Health Services Act) ដើម្បីផ្តល់មូលនិធិដល់កម្មវិធីគ្មានកន្លែងណាដូចផ្ទះ (No Place Like Home Program) ដែលផ្តល់ហិរញ្ញវត្ថុលំនៅដ្ឋាន ដល់បុគ្គលដែលមានជំងឺផ្លូវចិត្ត។ ធ្វើសច្ចាប័នច្បាប់ដែលមានស្រាប់ដែលបង្កើតកម្មវិធី No Place Like Home។ ផលប៉ះពាល់សារពើពន្ធ៖ អនុញ្ញាតឱ្យរដ្ឋប្រើប្រាក់រហូតដល់ $140 លានដុល្លារក្នុងមួយឆ្នាំពីមូលនិធិសុខភាពផ្លូវចិត្តរបស់ខោនធី ដើម្បីសងបំណុលរហូតដល់ $2 ពាន់លានដុល្លារជាប័ណ្ណកម្ចី។ សញ្ញាប័ណ្ណកម្ចីទាំងនេះនឹងផ្តល់មូលនិធិលំនៅដ្ឋានសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្តដែលគ្មានផ្ទះសម្បែង។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រនៅលើវិធានការនេះមានន័យថា៖ រដ្ឋអាចប្រើប្រាស់មូលនិធិសុខភាពផ្លូវចិត្តដែលមានស្រាប់នៅក្នុងខោនធីដើម្បីបង់ថ្លៃលំនៅដ្ឋានសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្តដែលគ្មានផ្ទះសម្បែង។

ទេ សន្លឹកឆ្នោតប្រឆាំងនៅលើវិធានការនេះមានន័យថា៖ សមត្ថភាពរបស់រដ្ឋក្នុងការប្រើប្រាស់មូលនិធិសុខភាពផ្លូវចិត្តដែលមានស្រាប់នៅក្នុងខោនធីដើម្បីបង់ថ្លៃលំនៅដ្ឋានសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្តដែលគ្មានផ្ទះសម្បែង នឹងអាស្រ័យលើការសម្រេចចិត្តរបស់តុលាការនៅពេលអនាគត។

សេចក្តីសំអាង

គាំទ្រ ទ្រលើសំណើប្រជាមតិលេខ 2៖ គាំទ្រដល់លំនៅដ្ឋាន និងការព្យាបាលមនុស្សគ្មានទីលំនៅដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរ។ សំណើប្រជាមតិលេខ 2 នឹងមិនបង្កើនពន្ធទេ។ វានឹងជួយមនុស្សតាមចិញ្ចើមថ្នល់ និងធ្វើឲ្យពួកគេទទួលបានសេវាសុខភាពផ្លូវចិត្ត និងការព្យាបាលការផ្តាច់ការញៀនយ៉ាងទូលំទូលាយ។ អ្នកតស៊ូមតិសម្រាប់អ្នកគ្មានលំនៅដ្ឋាន បុគ្គលិកសង្គមកិច្ច វេជ្ជបណ្ឌិត អ្នកសង្គ្រោះបន្ទាន់យល់ព្រម៖ គាំទ្រលើសំណើប្រជាមតិលេខ 2។

បដិសេធ ងនឹងសំណើប្រជាមតិ *ដែលយកប្រាក់រហូតដល់* $5.6 ពាន់លានដុល្លារ ពីអ្នកជំងឺផ្លូវចិត្តធ្ងន់ធ្ងរដើម្បីយកទៅផ្តល់មូលនិធិប័ណ្ណកម្ចី ក្នុងការកសាងលំនៅដ្ឋានដោយ *គ្មាន* ការព្យាបាល នឹងបង្ខំឲ្យមានមនុស្សកាន់តែច្រើនទៀតគ្មានទីលំនៅ។ វាមិនចាំបាច់ទេ ព្រោះកាលពីឆ្នាំមុនច្បាប់បានអនុញ្ញាតឲ្យខោនធីប្រើប្រាស់មូលនិធិ ច្បាប់សេវាកម្មសុខភាពផ្លូវចិត្ត (Mental Health Services Act, MHSA) សម្រាប់លំនៅដ្ឋានដោយមិនចាំបាច់ខ្ចីប្រាក់ទេ។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

David Koenig
(916) 974-9411
info@CAyesonprop2.org
CAyesonprop2.org

ប្រឆាំង

Gigi R. Crowder
NAMI Contra Costa
550 Patterson Blvd.
Pleasant Hill, CA
(510) 990-2670
gigi@namicontracosta.org
www.namicontracosta.org

មគ្គុទ្ទេសក៍យោងរហ័ស

សំណើប្រ.មតិ 3

អនុញ្ញាតប័ណ្ណកម្ចីអោយផ្តល់មូលនិធិសម្រាប់គម្រោងផ្គត់ផ្គង់ទឹក និងគុណភាពទីជម្រាល ត្រី សត្វព្រៃ ការនាំផ្លូវទឹក និងទ្រទ្រង់ និងការស្តុកទុកទឹកក្រោមដី។ លក្ខន្តិក:ផ្ទួចផ្ដើម

សេចក្ដីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

អនុញ្ញាតឱ្យប្រើ $8.877 ពាន់លានដុល្លារនៅក្នុង ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅរបស់រដ្ឋសម្រាប់គម្រោង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ។ ផលប៉ះពាល់សារពើពន្ធ៖ បង្កើនចំណាយរបស់រដ្ឋក្នុងការសងប័ណ្ណកម្ចីជាមធ្យមចំនួន $430 លានដុល្លារជារៀងរាល់ឆ្នាំក្នុងរយៈពេលលើសពី 40 ឆ្នាំ។ ការសន្សំរបស់រដ្ឋាភិបាលមូលដ្ឋានសម្រាប់គម្រោង ពាក់ព័ន្ធនឹងទឹក ទំនងមានចំនួនជាមធ្យម ពីរ បី រយលានដុល្លារ ក្នុងមួយឆ្នាំក្នុងរយៈពេលពីរ បី ទសវត្សរ៍ខាងមុខនេះ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រលើវិធានការនេះមានន័យថា ៖ រដ្ឋអាចលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅក្នុងតម្លៃជាទឹកប្រាក់ $8.9 ពាន់លានដុល្លារ ដើម្បីផ្ដល់មូលនិធិទៅលើគម្រោងទឹកស្អាត និងបរិស្ថានផ្សេងៗ។

ទេ សន្លឹកឆ្នោតប្រឆាំងលើវិធានការនេះមានន័យថា ៖ រដ្ឋមិនអាចលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅក្នុងតម្លៃជាទឹកប្រាក់ $8.9 ពាន់លានដុល្លារ ដើម្បីផ្ដល់មូលនិធិទៅលើគម្រោងទឹកស្អាត និងបរិស្ថានផ្សេងៗនោះទេ។

សេចក្ដីសំអាង

គាំទ្រ ទ្រ។ *គាំទ្រលើលេខ 3* ធានាបានទឹកដែលមានសុវត្ថិភាព ដែលអាចទុកចិត្តបាន និងស្អាតសម្រាប់រដ្ឋ California។ *សូមគាំទ្រលេខ 3* ផ្ដល់នូវទឹកទទួលទានដែលមានសុវត្ថិភាព ការជួសជុលទំនប់ទឹកដែលមិនមានសុវត្ថិភាព ផ្ដល់ការការពារចំពោះគ្រោះរាំងស្ងួត កែលម្អគុណភាពទឹកនៅតាមសមុ៉ីទ្រ ឈូងសមុទ្រ និងទន្លេ ព្រមទាំងមានការស្តាក់ទឹកទុកសម្អាតទឹក និងប្រើប្រាស់ទឹកភ្លៀងឡើងវិញផងដែរ។ *សូមគាំទ្រលេខ 3* ផ្ដល់នូវទឹកសម្រាប់មនុស្ស កសិដ្ឋាន និងបរិស្ថាន។

បដិសេធ ឆ្លងសំណើប្រជាមតិលេខ 3។ វាផ្ដល់នូវប្រាក់ដ៏ច្រើនទៅដល់ស្ថាប័ន។ នោះជាគំនិតរួម។ ប៉ុន្តែវានឹងមិននាំឲ្យថយចុះទឹកថ្មីដែលអាចប្រើប្រាស់បានទេ។ ការបង់ការប្រាក់នៅលើប័ណ្ណកម្ចីនឹងកើនទ្វេដងទៅលើចំនួនដែលត្រូវបង់ឲ្យម្ចាស់ប័ណ្ណកម្ចី។ សូមគិតអំពីវា . . . ឲ្យបានច្បាស់លាស់។ សូមបោះឆ្នោតប្រឆាំង។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

Jerry Meral
P.O. Box 1103
Inverness, CA 94937
(415) 717-8412
jerrymeral@gmail.com

ប្រឆាំង

John F. Takeuchi
Central Solano Citizen/
Taxpayer Group
P.O. Box 3532
Fairfield, CA 94533
(707) 422-4491
taksan@comcast.net
www.thetaxwatchers.org

សំណើប្រ.មតិ 4

អនុញ្ញាតឲ្យប័ណ្ណកម្ចីផ្ដល់មូលនិធិដល់ការសង់មន្ទីរពេទ្យដែលផ្ដល់ការថែទាំសុខភាពដល់កុមារ។ លក្ខន្តិក:ផ្ទួចផ្ដើម

សេចក្ដីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

អនុញ្ញាតចំនួនទឹកប្រាក់ $1.5 ពាន់លានដុល្លារក្នុងប័ណ្ណកម្ចី ត្រូវសងមកវិញពីមូលនិធីទូទៅរបស់រដ្ឋ ដើម្បីផ្ដល់ មូលនិធិសម្រាប់ការសាងសង់ ការពង្រីក ជួសជុលអ និង បំពាក់សម្ភារៈ មន្ទីរពេទ្យកុមារដែលមាន គុណសម្បត្តិគ្រប់គ្រាន់។ ផលប៉ះពាល់សារពើពន្ធ៖ បង្កើនចំណាយរដ្ឋក្នុងការ សងប័ណ្ណកម្ចីជាមធ្យមប្រហែល $80 លានដុល្លាជា រៀងរាល់ឆ្នាំលើសពី 35 ឆ្នាំ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រលើវិធានការនេះមានន័យថា ៖ រដ្ឋអាចលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅក្នុងតម្លៃជាទឹកប្រាក់ $1.5 ពាន់លានដុល្លារ ដើម្បីផ្ដល់មូលនិធិទៅលើគម្រោងសាងសង់ ការពង្រីក ការកែលម្អ និងការបំពាក់ឧបករណ៍នៅតាមមន្ទីរពេទ្យដែលព្យាបាលកុមារ។

ទេ សន្លឹកឆ្នោតប្រឆាំងលើវិធានការនេះមានន័យថា ៖ រដ្ឋមិនអាចលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅក្នុងតម្លៃជាទឹកប្រាក់ $1.5 ពាន់លានដុល្លារ ដើម្បីផ្ដល់មូលនិធិទៅលើគោលបំណងទាំងនេះទេ។

សេចក្ដីសំអាង

គាំទ្រ ទ្រដល់មន្ទីរពេទ្យកុមាររបស់រដ្ឋ California ផ្ដល់នូវការថែទាំឯកទេសដល់កុមារជាង 2 លាននាក់ជារៀងរាល់ឆ្នាំដែលមានជំងឺមហារីកកោសិការាងកណ្ដៀរ ការបណ្ដុះសរីរាង្គ— ទោះជាគ្រួសាររបស់ពួកគេអាចបង់ប្រាក់បានប៉ុន្មានក៏ដោយ។ កុមារ 85% ដែលមានជំងឺមហារីកគ្រាប់ឈាមត្រូវបានព្យាបាលជាសះស្បើយ។ សំណើប្រជាមតិលេខ 4 បង្កើនសមត្ថភាពផ្ដល់បច្ចេកវិទ្យាចុងក្រោយបង្អស់ និងពង្រីកការស្រាវជ្រាវជំងឺកុមារដើម្បីព្យាបាលកុមារឲ្យបានកាន់តែច្រើន។

បដិសេធ ឆ្លងនឹងសំណើប្រជាមតិលេខ 4 នឹងអនុញ្ញាតឲ្យរដ្ឋខ្ចីប្រាក់ $1.5 ពាន់លានដុល្លារសម្រាប់ការសាងសង់ និងការពង្រីកមន្ទីរពេទ្យកុមារ "ដែលមិនស្វែងរកប្រាក់ចំណេញ" ដោយការលក់ប័ណ្ណកម្ចីដែលមិនតម្រូវឲ្យមានការប្រាក់។ យើងគួរតែពិនិត្យមើលរូបភាពជារួម និងសួរអំពីរបៀបកែលម្អលទ្ធផលនៃការថែទាំសុខភាពនៅក្នុងរដ្ឋ California។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

គាំទ្រដល់មន្ទីរពេទ្យកុមារ —
គាំទ្រសំណើប្រជាមតិលេខ 4
YesOnProposition4.org

ប្រឆាំង

Gary Wesley
Mountain View, CA

មគ្គុទ្ទេសក៍យោងរហ័ស

5 សំណើប្រ.មតិ ផ្លាស់ប្តូរតម្រូវការសម្រាប់ម្ចាស់អចលនទ្រព្យមួយចំនួនក្នុងការផ្ទេរមូលដ្ឋានពន្ធអចលនទ្រព្យរបស់ខ្លួនសម្រាប់អចលនទ្រព្យដាក់ជំនួស។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ និងលក្ខន្តិកៈ។

សេចក្តីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

លុបបំបាត់តម្រូវការផ្ទេរមួយចំនួនសម្រាប់ម្ចាស់ផ្ទះអាយុលើសពី 55ឆ្នាំ ម្ចាស់ផ្ទះដែលមានពិការភាពធ្ងន់ធ្ងរ និងទ្រព្យសម្បត្តិកខ្វក់ឬខូចខាតដោយមហន្តរាយ។ ផលប៉ះពាល់សារពើពន្ធ៖ សាលារៀននិងរដ្ឋាភិបាល មូលដ្ឋាននីមួយៗនឹងខាតបង់ពន្ធលើអចលនទ្រព្យ ប្រចាំឆ្នាំចំនួនជាង $100 លានដុល្លារដែលនឹងកើនឡើងដល់ប្រហែល $1 ពាន់លានដុល្លារក្នុង មួយឆ្នាំ។ ការកើនឡើងស្រដៀងគ្នានេះដែរនៅក្នុងការចំណាយរបស់រដ្ឋដើម្បី បំពេញមកវិញនូវការខាតបង់ពន្ធ អចលនទ្រព្យសាលា។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រលើវិធានការនេះមានន័យថា៖ ម្ចាស់ផ្ទះ*ទាំងអស់* ដែលមានអាយុលើសពី 55 ឆ្នាំ (ឬបំពេញលក្ខខណ្ឌផ្សេងទៀត) នឹងមានសិទ្ធិសន្សំប្រាក់ពន្ធអចលនទ្រព្យ នៅពេលពួកគេផ្លាស់ទីទៅនៅផ្ទះផ្សេង។

ទេ សន្លឹកឆ្នោតប្រឆាំងនឹងវិធានការនេះមានន័យថា៖ ម្ចាស់ផ្ទះ*មួយចំនួន* ដែលមានអាយុលើសពី 55 ឆ្នាំ (ឬបំពេញលក្ខខណ្ឌផ្សេងទៀត) នឹងបន្តមានសិទ្ធិសន្សំប្រាក់ពន្ធអចលនទ្រព្យ នៅពេលពួកគេផ្លាស់ទីទៅនៅផ្ទះផ្សេង។

សេចក្តីសំអាង

គាំទ្រ ប្រ.មតិលេខ 5 លុបបំបាត់ "ការពិន័យលើការផ្លាស់ទីលំនៅ" ដែលបច្ចុប្បន្នប៉ះពាល់ដល់មនុស្សចាស់ (អាយុលើសពី 55 ឆ្នាំ) និងជនពិការធ្ងន់ធ្ងរនៅរដ្ឋ Californians។ ការគាំទ្រមានន័យថាជួយដល់មនុស្សចាស់ និងជនពិការ ដើម្បីអាចទិញលំនៅដ្ឋានថ្មី និងមិនប្រឈមនឹងការពិន័យលើពន្ធអចលនទ្រព្យ។ ការបោះឆ្នោតគាំទ្រនឹងជួយឲ្យមនុស្សចាស់ និងជនពិការផ្លាស់ទីទៅរស់នៅជិតក្រុមគ្រួសារ ឬទិញផ្ទះបានកាន់តែងាយស្រួល និងកាន់តែមានសុវត្ថិភាព។

បដិសេធ ប្រជាមតិលេខ 5 នឹងមិនអនុញ្ញាតឲ្យកសាងលំនាំដ្ឋានថ្មីណាមួយ ឬជួយដល់អ្នកទិញផ្ទះដំបូងឡើយ។ វានឹងកាត់បន្ថយរហូតដល់ $1 ពាន់លានដុល្លារលើចំណូលក្នុងមូលដ្ឋានពីសាលារដ្ឋ ផ្នែកអគ្គីភ័យ នគរបាល ការថែទាំសុខភាព និងសេវាកម្មផ្សេងៗទៀតសម្រាប់ការមិនបង់ពន្ធ សម្រាប់អ្នកមាននៅ California និងជួយដល់អ្នករៀបចំ—អត្ថប្រយោជន៍លើផ្នែកអចលនទ្រព្យសាជីវកម្ម។ NoProp5.com

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

Cary Davidson
គាំទ្រលើគណៈកម្មការ 5
515 S. Figueroa Street, #1110
Los Angeles, CA 90071
(888) 384-8467
info@propertytaxfairness.com
voteyesonprop5.com

ប្រឆាំង

ប្រឆាំងនឹងសំណើប្រជាមតិលេខ 5
1510 J Street, Suite 210
Sacramento, CA 95814
(916) 443-7817
info@NoProp5.com
NoProp5.com

6 សំណើប្រ.មតិ បំបាត់ចោលមូលនិធិការជួសជុលផ្លូវ និងគមនាគមន៍មួយចំនួន។ តម្រូវឲ្យពន្ធលើប្រេងឥន្ធនៈ និងថ្លៃរថយន្ត មួយចំនួនអនុម័តដោយអង្គបោះឆ្នោត។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ

សេចក្តីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

លុបចោលច្បាប់ពន្ធគមនាគមន៍ឆ្នាំ 2017 និងថ្លៃឈ្នួលសម្រាប់ការជួលជុលផ្លូវ និងគមនាគមន៍សាធារណៈ។ ផលប៉ះពាល់សារពើពន្ធ៖ ការថយចុះប្រាក់ចំណូលចំនួន $5.1 ពាន់លានដុល្លារពីពន្ធប្រេងឥន្ធនៈ និងពន្ធរថយន្តរបស់រដ្ឋដែលសំខាន់ក្នុងការបង់សម្រាប់ការថែទាំមហាវិថីនិងជួសជុលផ្លូវក៏ដូចជា កម្មវិធីត្រង់ស៊ីតផងដែរ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រលើវិធានការនេះមានន័យថា៖ ពន្ធលើប្រេងឥន្ធនៈ និងយានយន្តដែលបានអនុម័តនាពេលថ្មីៗនេះដោយអង្គនីតិបញ្ញត្តិនឹងត្រូវបានលុបចោលវិញ ដែលវានឹងកាត់បន្ថយការផ្តល់មូលនិធិសម្រាប់ការថែទាំមហាវិថី និងផ្លូវថ្នល់ ក៏ដូចជាការជួសជុលនិងកម្មវិធីត្រង់ស៊ីតផងដែរ។ អង្គនីតិបញ្ញត្តិនឹងតម្រូវឲ្យទទួលបានសន្លឹកឆ្នោតលើសលុបដើម្បីអនុម័តច្បាប់ថ្មី ឬការបង្កើនពន្ធលើប្រេងឥន្ធនៈ និងយានយន្តនៅពេលអនាគត។

ទេ សន្លឹកឆ្នោតប្រឆាំងនឹងវិធានការនេះមានន័យថា៖ ពន្ធលើប្រេងឥន្ធនៈ និងយានយន្តដែលបានអនុម័តនាពេលថ្មីៗនេះដោយអង្គនីតិបញ្ញត្តិនឹងបន្តមានប្រសិទ្ធភាព ដើម្បីបង់ប្រាក់សម្រាប់ការថែទាំមហាវិថី និងផ្លូវថ្នល់ រួមទាំងការជួលជុលនិងកម្មវិធីត្រង់ស៊ីតផងដែរ។ អង្គនីតិបញ្ញត្តិនឹងបន្តមិនទាមទារឲ្យអ្នកបោះឆ្នោតអនុម័តចំពោះច្បាប់ថ្មី ឬការតំឡើងពន្ធលើប្រេងឥន្ធនៈ និងរថយន្តក្នុងពេលអនាគត។

សេចក្តីសំអាង

គាំទ្រ បោះឆ្នោតគាំទ្រ លេខ 6 ដើម្បីបញ្ចុះតម្លៃប្រេងនិងហ្គាសភ្លាមៗ។ អ្នករស់នៅក្នុងរដ្ឋ California កំពុងជួបការលំបាកដោយសារការចំណាយថ្លៃរស់នៅខ្ពស់។ បោះឆ្នោតគាំទ្រនៅលើសំណើប្រជាមតិលេខ 6 ដើម្បីដកចេញការបង្កើនពន្ធលើហ្គាសនិងយានយន្តដែលមិនត្រឹមត្រូវ និងទាមទារឲ្យមានការបោះឆ្នោតសម្រាប់ការបង្កើនពន្ធនៅពេលអនាគត។ បោះឆ្នោតគាំទ្រលើ សំណើប្រជាមតិលេខ 6 សម្រាប់ការបញ្ចុះតម្លៃប្រេង!

បដិសេធ ឆ្លាងនឹងអ្នកពន្ធ ត់អគ្គិភ័យអាជីពនៅ California, សមាគមអ្នកល្បាតមហាវិថីនៃរដ្ឋ California, សង្គមអាមេរិកនៃវិស្វករស៊ីវិល និងអ្នកសង្គ្រោះបឋមមិនលើកទឹកចិត្តចំពោះសំណើប្រជាមតិលេខ 6 ទេ ព្រោះវាបង្ករគ្រោះថ្នាក់ដល់សុវត្ថិភាពនៃស្ពាន និងផ្លូវ។ សំណើប្រជាមតិលេខ 6 លុបបំបាត់ប្រាក់ $5 ពាន់លានដុល្លារក្នុងមួយឆ្នាំ នៅក្នុងមូលនិធិគមនាគមន៍ក្នុងមូលដ្ឋាន បញ្ឈប់មនុស្សរាប់ពាន់នាក់ពីការទទួលបានសុវត្ថិភាពចរាចរ ការកាត់បន្ថយការកកស្ទះ និងគម្រោងកែលម្អផ្លូវថ្នល់នៅគ្រប់សហគមន៍ California ។ www.NoProp6.com

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

ផ្តល់សម្លេងដល់អ្នកបោះឆ្នោត—
គាំទ្រលេខ 6
www.GiveVotersAVoice.com

ប្រឆាំង

ប្រឆាំងនឹងសំណើប្រជាមតិលេខ 6 ៖ បញ្ឈប់ការវាយប្រហារលើសុវត្ថិភាពស្ពាន និងផ្លូវថ្នល់
1121 L Street, Suite 910
Sacramento, CA 95814
(800) 958-1194
info@NoProp6.com
www.NoProp6.com

មគ្គុទ្ទេសក៍យោងរហ័ស

សំណើប្រ.មតិ 7 អនុលោមម៉ោងសន្សំពន្លឺថ្ងៃនៅរដ្ឋ CALIFORNIA ទៅនឹងច្បាប់សហព័ន្ធ។ អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិប្តូររយៈពេលសន្សំពន្លឺថ្ងៃ។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។

សំណើប្រ.មតិ 8 ធ្វើបញ្ញត្តិតម្លៃសម្រាប់ការលាងឈាមតម្រងនោមអ្នកជំងឺខាងក្រៅសម្រាប់ការព្យាបាលតម្រងនោម។ លក្ខន្តិកៈផ្តួចផ្តើម

សេចក្តីសង្ខេប *ដាក់លើសន្លឹកឆ្នោតដោយអង្គនីតិបញ្ញត្តិ*

ផ្តល់លទ្ធភាពដល់អង្គនិតិបញ្ញត្តិក្នុងការប្តូររយៈពេលសន្សំពន្លឺថ្ងៃដោយការបោះឆ្នោតពីរភាគបី ប្រសិនបើការប្តូរនោះស្របតាមច្បាប់សហព័ន្ធ។ ផលប៉ះពាល់សារពើពន្ធ៖ វិធានការនេះមិនមានឥទ្ធិពលសារពើពន្ធដោយផ្ទាល់នោះទេ ដោយសារតែការប្តូរ ម៉ោងសន្សំពន្លឺថ្ងៃអាស្រ័យលើសកម្មភាពនាពេលអនាគតដោយអង្គនិតិបញ្ញត្តិនិងរដ្ឋាភិបាល សហព័ន្ធ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស សន្លឹកឆ្នោតគាំទ្រនៅលើវិធានការនេះមានន័យថា ៖ អង្គនីតិបញ្ញត្តិដែលមានសម្លេងគាំទ្រពីរភាគបីអាចផ្លាស់ប្តូរម៉ោងសន្សំពន្លឺថ្ងៃ ប្រសិនបើការផ្លាស់ប្តូរនោះត្រូវបានអនុញ្ញាតដោយរដ្ឋាភិបាលសហព័ន្ធ។ ប្រសិនបើមិនមានការផ្លាស់ប្តូរដោយអង្គនីតិបញ្ញត្តិទេ រដ្ឋ California នឹងរក្សាទុករយៈពេលសន្សំពន្លឺថ្ងៃបច្ចុប្បន្ន (ដើមខែមីនា ដល់ដើមខែវិច្ឆិកា)។

ទេ សន្លឹកឆ្នោតប្រឆាំងនឹងវិធានការនេះមានន័យថា៖ រដ្ឋ California នឹងរក្សាទុករយៈពេលសន្សំពន្លឺថ្ងៃបច្ចុប្បន្ន។

សេចក្តីសំអាង

គាំទ្រ ដល់សំណើប្រជាមតិលេខ 7 នឹងបញ្ចប់ការផ្លាស់ប្តូរម៉ោងពីរដងក្នុងមួយឆ្នាំ ដែលអ្នកស្រាវជ្រាវវេជ្ជសាស្ត្រនិងអ្នកសេដ្ឋកិច្ចយល់ស្របគ្នាថាគឺជាគ្រោះថ្នាក់ចំពោះសុខភាពនិងផលិតភាពរបស់កុមារនៅសាលារៀន កម្លាំងការងារ និងមនុស្សចាស់។ ការបោះឆ្នោតគាំទ្រលើសំណើប្រជាមតិលេខ 7 នឹងរក្សាកូនៗ កន្លែងធ្វើការ និងផ្លូវរបស់យើងឲ្យមានសុវត្ថិភាព។

បដិសេធ ងនឹងសំណើប្រជាមតិលេខ 7 អនុញ្ញាតឲ្យមានម៉ោងសន្សំពន្លឺថ្ងៃជាអចិន្ត្រៃយ៍ និងត្រូវមានការអនុញ្ញាតពីរដ្ឋសហព័ន្ធ។ វានឹងភ្លឺនៅពេលល្ងាចក្នុងរដូវក្តៅ ដូចជាពេលនេះអញ្ចឹង ប៉ុន្តែនៅរដូវរងា វានឹងងងឹតនៅពេលព្រឹកមួយម៉ោងបន្ថែមទៀត ដូច្នេះកុមារនឹងទៅសាលារៀននៅពេលមេឃងងឹត។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

បោះឆ្នោត បាទ/ចាស
លើសំណើប្រជាមតិលេខ 7
YesProp7@gmail.com
www.YesProp7.info

ប្រឆាំង

សមាជិកព្រឹទ្ធសភា Hannah-Beth Jackson

សេចក្តីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

តម្រូវឱ្យមានការបង្វិលប្រាក់សងវិញ និងការពិន័យ ប្រសិនបើមានការទារថ្លៃឈ្នួលលើសដែនកំណត់។ តម្រូវឱ្យមានរបាយការណ៍ប្រចាំឆ្នាំជូនរដ្ឋ។ ហាមឃាត់ក្លីនិកពីការបដិសេធមិនព្យាបាលអ្នកជំងឺដោយផ្អែកលើប្រភពបង់ប្រាក់។ ផលប៉ះពាល់សារពើពន្ធ៖ ឥទ្ធិពលប្រចាំឆ្នាំរួមលើ រដ្ឋាភិបាលរដ្ឋនិងមូលដ្ឋានចាប់ពីផលប៉ះពាល់ជាវិជ្ជមានក្នុងកម្រិតទាបរាប់លានដុល្លារដល់ផលប៉ះពាល់អវិជ្ជមានសុទ្ធរាប់លានដុល្លា។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស សម្លេងគាំទ្រនៅលើវិធានការនេះមានន័យថា ៖ ក្លីនិកលាងឈាមនឹងកំណត់ប្រាក់ចំណូលរបស់ពួកគេទៅតាមរូបមន្ត ហើយអាចតម្រូវឲ្យបង់ប្រាក់បង្វិលទៅភាគីមួយចំនួន (ជាពិសេសក្រុមហ៊ុនធានារ៉ាប់រងសុខភាព) ដែលបង់ប្រាក់សម្រាប់ការព្យាបាលដោយការលាងឈាម។

ទេ សន្លឹកឆ្នោតប្រឆាំងលើវិធានការនេះមានន័យថា ៖ ក្លីនិកលាងឈាម នឹងមិនកំណត់ប្រាក់ចំណូលទៅតាមរូបមន្តទេ ហើយក៏មិនចាំបាច់បង់ប្រាក់បង្វិលដែរ។

សេចក្តីសំអាង

គាំទ្រ ដល់ការលាងឈាម ដែលជាការព្យាបាលចំពោះការគំរាមកំហែងដល់ជីវិត ប៉ុន្តែជីវកម្មលាងឈាមធំៗដែលកំពុងរកប្រាក់ចំណេញបានយ៉ាងច្រើន មិនបានធ្វើការ វិនិយោគគ្រប់គ្រាន់ទៅលើអនាម័យមូលដ្ឋាន និងលើការថែទាំអ្នកជំងឺនោះទេ។ សូមបោះឆ្នោតបាទ/ចាសដល់លេខ 8 ដើម្បីគាំទ្រការវិនិយោគលើការថែទាំអ្នកជំងឺប្រកបដោយគុណភាព និងបញ្ឈប់ការគិតថ្លៃខ្ពស់ដែលនាំឲ្យមានការចំណាយខ្ពស់ចំពោះពលរដ្ឋនៅ California ។ គណបក្សប្រជាធិបតេយ្យ California អតីតយុទ្ធជន មេធាវីផ្នែកថែទាំសុខភាព និងអ្នកដឹកនាំសាសនាឯកភាព៖ www.YesOn8.com

បដិសេធ ងលើសំណើប្រជាមតិលេខ 8 ត្រូវបានជំទាស់ដោយគិលានុប្បដ្ឋាកវេជ្ជបណ្ឌិត អ្នកជំងឺរាប់ពាន់នាក់ ដោយសមាគមគិលានុប្បដ្ឋាកអាមេរិក\ California, សមាគមវេជ្ជសាស្ត្រនៃ California, មហាវិទ្យាល័យអាមេរិកនៃគ្រូពេទ្យសង្គ្រោះបន្ទាន់របស់ CA ព្រោះវានឹងនាំឲ្យមានការបិទក្លីនិកលាងឈាមជាច្រើននៅក្នុងរដ្ឋ California—កាត់បន្ថយលទ្ធភាពទទួលបានការថែទាំដែលនាំឲ្យជីវិតអ្នកជំងឺលាងឈាមប្រឈមនិងគ្រោះថ្នាក់ និងធ្វើឲ្យមានការបង្កើនចំណាយកាន់តែច្រើនលើអ្នកបង់ពន្ធនៅរដ្ឋ California។ សូមបោះឆ្នោត ទេ។ www.NoProp8.com

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

Suzanne Jimenez
បាទ/ចាសនៅលើលេខ 8
777 S. Figueroa Street,
Ste. 4050
Los Angeles, CA 90017
(888) 501-8119
info@YesOn8.com
www.YesOn8.com

ប្រឆាំង

ទេលើសំណើប្រជាមតិលេខ 8៖
បញ្ឈប់ការលាងឈាមគ្រោះថ្នាក់
(888) 663-9997
info@NoProp8.com
www.NoProp8.com

មគ្គុទ្ទេសក៍យោងរហ័ស

នៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2018 សំណើប្រជាមតិលេខ 9 ត្រូវបានដកចេញពីសន្លឹកឆ្នោតតាមបញ្ជារបស់តុលាការកំពូលរដ្ឋ California ។

សំណើប្រ.មតិ 10 ពង្រីកអំណាចរដ្ឋាភិបាលមូលដ្ឋាន ដើម្បីអនុម័តលើការត្រួតត្រាពិនិត្យការជួលអចលនទ្រព្យជាលំនៅដ្ឋាន។ លក្ខន្តិក:ផ្ទួចផ្ដើម

សេចក្ដីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

លុបចោលច្បាប់របស់រដ្ឋដែលបច្ចុប្បន្ននេះដាក់ កម្រិតលើវិសាលភាពនៃគោលនយោបាយគ្រប់គ្រងការជួលដែលទីក្រុង និងមូលដ្ឋានមានយុត្តាធិការ ផ្សេងៗទៀតអាចដាក់មកលើអចលនទ្រព្យជាលំនៅដ្ឋាន។ ផលប៉ះពាល់សារពើពន្ធ៖ សក្តានុពលនៃការកាត់ បន្ថយប្រាក់ចំណូលសុទ្ធរបស់រដ្ឋ និងមូលដ្ឋានរាប់សិបលានដុល្លារក្នុងមួយឆ្នាំក្នុងរយៈពេលវែង។ អាស្រ័យលើសកម្មភាពរបស់សហគមន៍មូលដ្ឋាន ការបាត់បង់ប្រាក់ចំណូលអាចមានចំនួនតិចជាង ឬទំនងជាច្រើនជាង។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រនៅលើវិធានការនេះមានន័យថា៖ ច្បាប់រដ្ឋ*នឹងមិន*កំណត់ថាទីក្រុង និងខោនធីអាចមានច្បាប់គ្រប់គ្រងការជួលប្រភេទអ្វីឡើយ។

ទេ សន្លឹកឆ្នោតប្រឆាំងនឹងវិធានការនេះមានន័យថា៖ ច្បាប់រដ្ឋ*នឹងមិន*កំណត់ថាទីក្រុង និងខោនធីអាចមានច្បាប់គ្រប់គ្រងការជួលប្រភេទអ្វីឡើយ។

សេចក្ដីសំអាង

គាំទ្រ ទ្រសំណើប្រជាមតិលេខ 10 ដើម្បីស្តារអំណាចក្នុងការបង្កើតការគ្រប់គ្រងការជួលនៅក្នុងសហគមន៍មូលដ្ឋាន ដោយដាក់ដែនកំណត់ត្រឹមត្រូវប្រចាំឆ្នាំលើម្ចាស់ផ្ទះ ថាអាចដំឡើងថ្លៃឈ្នួលផ្ទះបានប៉ុន្មាន។ វាជួយរក្សាអ្នកជួលផ្ទះឲ្យនៅផ្ទះ ជាជាងបង្ខំពួកគេឲ្យចាកចេញ ឬក្លាយជាមនុស្សគ្មានទីជម្រក។ *លេខដប់ ការពារអ្នកជួល។*
អ្នកគាំទ្រ៖ គណបក្សប្រជាធិបតេយ្យ CALIFORNIA, សមគមគិលានុប្បដ្ឋាក California, សមាគមគ្រូបង្រៀននៅ Californian, ACLU of California, Housing Californiaបណ្តាញការពារការជនៀសចេញ SEIU សម្ព័ន្ធទីក្រុងជាតិ សន្និបាតភាពជាអ្នកដឹកនាំគ្រីស្ទីនភាគខាងត្បូងនៃ California ភាគខាងត្បូង។

បដិសេធ ងសំណើប្រជាមតិលេខ 10 នឹងធ្វើឲ្យវិបត្តិលំនៅដ្ឋានកាន់តែអាក្រក់ថែមទៀត មិនមែនប្រសើរឡើងទេ។ មេធាវីផ្នែកលំនៅដ្ឋានដែលមានតម្លៃសមរម្យបានឯកភាពថា សំណើប្រជាមតិលេខ 10 គឺផ្ដល់ផលអាក្រក់ទាំងអ្នកជួលនិងម្ចាស់ផ្ទះ វាអនុញ្ញាតឲ្យមានការកំណត់បញ្ញត្តិសម្រាប់ផ្ទះដែលមានសមាជិកគ្រួសារតិចនិងធ្វើឲ្យអ្នកការិយាធិបតេយ្យទទួលបន្ទុកលើផ្នែកលំនៅដ្ឋាន ដោយឲ្យពួកគេមានសិទ្ធិបន្ថែមប្រាក់ឈ្នួលផ្ទះ។ សូមបោះឆ្នោតប្រឆាំងនឹងលេខ 10!

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

បាទ/ចាសលើសំណើប្រជាមតិលេខ 10—សម្ព័ន្ធសម្រាប់លំនៅដ្ឋានដែលមានតម្លៃសមរម្យ
(424) 307-5278
team@VoteYesOnProp10.org
www.VoteYesOnProp10.org

ប្រឆាំង

ទេទៅលើសំណើប្រជាមតិលេខ 10—ការផ្ទួចផ្ដើមគំនិតមិនល្អដែលនឹងធ្វើឲ្យវិបត្តិលំនៅដ្ឋានកាន់តែអាក្រក់ឡើង
(530) 586-4940
info@Prop10Flaws.com
www.Prop10Flaws.com

មគ្គុទ្ទេសក៍យោងរហ័ស

សំណើប្រ.មតិ 11

តម្រូវឲ្យបុគ្គលិករថយន្តពេទ្យបន្ទាន់ផ្នែកវិស័យឯកជននៅប្រចាំការទទួលទូរស័ព្ទ ក្នុងកំឡុងពេលសម្រាកធ្វើការ។ លុបបំបាត់ការទទួលខុសត្រូវមួយចំនួនរបស់និយោជក។ លក្ខន្តិក:ផ្ទួចផ្ដើម

សេចក្ដីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

ច្បាប់ដែលអនុញ្ញាតអោយនិយោជិតធ្វើការគិតម៉ោងឈប់សម្រាកដោយមិននៅប្រចាំការទទួលទូរស័ព្ទនឹងមិនអនុវត្តចំពោះបុគ្គលិកសង្គ្រោះបន្ទាន់ផ្នែកវិស័យឯកជននោះទេ។ ផលប៉ះពាល់សារពើពន្ធ៖ ទំនងជាផលប្រយោជន៍សារពើពន្ធទៅរដ្ឋាភិបាលក្នុងមូលដ្ឋាន (នៅក្នុងទម្រង់មានតម្លៃទាបនិងទទួលប្រាក់ចំណូលខ្ពស់) មានសក្តានុពលក្នុងចំនួនរាប់សិបលានដុល្លារជារៀងរាល់ឆ្នាំ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រនៅលើវិធានការនេះមានន័យថា ៖ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជនអាចបន្តការអនុវត្តរបស់ពួកគេដោយមានអ្នកសង្គ្រោះបឋម (EMTs) និងភ្នាក់ងារគិលានសង្គ្រោះប្រចាំការនៅពេលហូបអាហារ និងនៅម៉ោងសម្រាកដើម្បីឆ្លើយតបនឹងការហៅតាមលេខ 911។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជននឹងអាចប្តូរកាលវិភាគសម្រាប់ហូបអាហារនិងម៉ោងសម្រាកដែលត្រូវបានរំខានដោយការហៅតាមលេខ 911។

ទេ ឆ្នាំង។ ការបោះឆ្នោតប្រឆាំងលើវិធានការនេះមានន័យថា ៖ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជនត្រូវគោរពតាមច្បាប់ការងារសម្រាប់ឧស្សាហកម្មនេះ។ អាស្រ័យលើការសម្រេចនាពេលថ្មីៗនេះរបស់តុលាការ ច្បាប់ទាំងនេះនឹងតម្រូវឲ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជន ផ្តល់ឲ្យអ្នកសង្គ្រោះបឋម និងភ្នាក់ងារគិលានសង្គ្រោះនូវការហូបអាហារនៅម៉ោងផ្សេង និងម៉ោងសម្រាកដែលមិនអាចរំខានដោយការហៅតាមលេខ 911។

សេចក្ដីសំអាង

គាំទ្រ ទ្រនឹងធ្វើឲ្យរដ្ឋ California ប្រឈមនឹងគ្រោះមហន្តរាយជាញឹកញាប់។ សំណើប្រជាមតិលេខ 11 ធានាថាអ្នកសង្គ្រោះបឋម និងភ្នាក់ងារគិលានសង្គ្រោះត្រូវបានបង់ប្រាក់ឲ្យ ដើម្បីអាចទាក់ទងពួកគេបានអំឡុងពេលឈប់សម្រាក ដើម្បីសង្គ្រោះជីវិតផ្តល់ការបណ្តុះបណ្តាលឲ្យពួកគេដែលត្រូវតាមស្តង់ដារ ភ្នាក់ងារគ្រប់គ្រងគ្រោះអាសន្នសហព័ន្ធ (Federal Emergency Management Agency, FEMA) និងការគ្រប់ដណ្ដប់លើសុខភាពផ្លូវចិត្ត ជាចំបាច់។ នៅក្នុងការសង្គ្រោះបន្ទាន់ មនុស្សអាចរស់ ឬស្លាប់ក្នុងរយៈពេលតែប៉ុន្មានវិនាទីតែប៉ុណ្ណោះ ។ សូមគាំទ្រលេខ 11! វាជាសុភវិនិច្ឆ័យ។

បដិសេធ សំណើប្រជាមតិលេខ 11 មិនទទួលបានទឡ្លីករណ៍ប្រឆាំងទេ។

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

Californians for Emergency Preparedness and Safety
2350 Kerner Boulevard, Suite 250
San Rafael, CA 94901
(916) 836-4301
info@YESon11.org
www.YESon11.org

ប្រឆាំង

មិនមានព័ត៌មានទំនាក់ទំនងត្រូវបានផ្ដល់ជូនទេ។

សំណើប្រ.មតិ 12

បង្កើតស្តង់ដារថ្មីសម្រាប់ការដាក់ឃាំងសត្វកសិដ្ឋានជាក់លាក់ ហាមឃាត់ការលក់ផលិតផលមិនអនុវត្តតាមច្បាប់។ លក្ខន្តិក:ផ្ទួចផ្ដើម។

សេចក្ដីសង្ខេប *ដាក់នៅលើសន្លឹកឆ្នោតដោយហត្ថលេខាទាមទារ*

បង្កើតតម្រូវការអប្បបរមាសម្រាប់ការដាក់ឃាំង សត្វកសិដ្ឋានជាក់លាក់។ ហាមឃាត់ការលក់សាច់និងផលិតផលស៊ុតពីសត្វ ដែលត្រូវបានបង្ខាំងដោយមិនអនុវត្តតាមច្បាប់។ ផលប៉ះពាល់សារពើពន្ធ៖ សក្តានុពលនៃការថយចុះចំណូលពន្ធរដ្ឋលើប្រាក់ចំណូលពីអាជីវកម្មកសិដ្ឋាន ទំនងជាច្រើនជាងប៉ុន្មានលានដុល្លារក្នុងមួយឆ្នាំឡើយ។ រដ្ឋចំណាយប្រាក់រហូតដល់ $10 លានដុល្លារ ក្នុងមួយឆ្នាំដើម្បីអនុវត្តវិធានការនេះ។

តើសំឡេងឆ្នោតអ្នកមានន័យយ៉ាងណា

បាទ/ចាស់ សន្លឹកឆ្នោតគាំទ្រលើវិធានការនេះមានន័យថា ៖ នឹងមានលក្ខខណ្ឌទាមទារថ្មីតិចតួចបំផុតចំពោះកសិករ ក្នុងការផ្ដល់លំហបន្ថែមសម្រាប់មាន់ពង ជ្រូកពូជ និងកូនគោសម្រាប់យកសាច់។ អាជីវកម្មនៅរដ្ឋ California នឹងត្រូវបានហាមឃាត់ការលក់ស៊ុត ឬសាច់ជ្រូកមិនទាន់ចម្អិន ឬសាច់កូនគោដែលមកពីគោក្នុងក្រោលដែលមិនមានលក្ខណៈសម្រាប់យកសាច់ស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។

ទេ សន្លឹកឆ្នោតប្រឆាំងនឹងវិធានការនេះមានន័យថា ៖ លក្ខខណ្ឌតម្រូវការក្នុងការផ្ដល់លំហអប្បបរមាបច្ចុប្បន្នសម្រាប់ការឃុំមាន់ពង ជ្រូកផើម និងកូនគោចិញ្ចឹមសម្រាប់យកសាច់ នឹងបន្តអនុវត្ត។ ការហាមឃាត់បច្ចុប្បន្នលើអាជីវកម្មនៅក្នុងរដ្ឋ California ដែលលក់ស៊ុតដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវស្តីពីលំហសម្រាប់មាន់ នឹងបន្តមានប្រសិទ្ធភាព។

សេចក្ដីសំអាង

គាំទ្រ ទ្រ។ ការឃុំឃាំងកូនគោ ជ្រូកបង្ការ និងមាន់កំពុងពងនៅក្នុងទ្រុងតូចគឺជាអំពើឃោរឃៅ។ ផលិតផលបានមកពីសត្វរងទុក្ខវេទនាទាំងនេះប៉ះពាល់ដល់សុវត្ថិភាពអាហារ។ សូមគាំទ្រសំណើប្រជាមតិលេខ 12 ៖ គ្រូពេទ្យបសុសត្វនៅរដ្ឋ California ជិត 500 នាក់, ASPCA, សង្គមមនុស្សធម៌នៃសហរដ្ឋអាមេរិក, គ្រួសារកសិករ និងទីជម្រកសត្វនៅរដ្ឋ California មជ្ឈមណ្ឌលអាហារសុវត្ថិភាពសុទ្ធតែគាំទ្រប្រជាមតិនេះ។

បដិសេធ ភាពសាហាវយង់ឃ្នង នេះក្បត់ចំពោះឧស្សាហកម្មស៊ុត សត្វ និងអ្នកបោះឆ្នោត។ ពលរដ្ឋ California បានបោះឆ្នោតដើម្បីប្រឆាំងនឹងការចិញ្ចឹមសត្វក្នុងទ្រុងកាលពីឆ្នាំ 2015។ វិធានការឃោរឃៅនេះធ្វើឲ្យការចិញ្ចឹមសត្វក្នុងទ្រុងមានភាពស្របច្បាប់យ៉ាងហោចណាស់ដល់ឆ្នាំ2022!ហើយមាន់មានទំហំត្រឹមតែមួយហ្វីតបួនជ្រុងតែប៉ុណ្ណោះ។ បោះឆ្នោត *ប្រឆាំង* ទៅនឹងភាពឃោរឃៅលើសត្វក្នុងកសិដ្ឋានដោយការបោះឆ្នោត *ប្រឆាំង*នឹងសំណើប្រជាមតិលេខ 12 ។
www.StopTheRottenEggInitiative.org

សម្រាប់ព័ត៌មានបន្ថែម

គាំទ្រ

Crystal Moreland
Prevent Cruelty California Coalition
119 North Fairfax Ave. #613
Los Angeles, CA 90036
(323) 937-0600
info@preventcrueltyca.com
preventcrueltyca.com

ប្រឆាំង

Bradley Miller
ពលរដ្ឋ California ប្រឆាំងនឹងភាពឃោរឃៅ ការដាក់ទ្រុង និងការក្លែងបន្លំ
P.O. Box 3577
San Rafael, CA 94912
(855) NO CAGES (662-2437)
INFO@NoOnProposition12.org
www.NoOnProposition12.org

សូមពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នកនៅលើអ៊ីនធឺណិត

សូមមើលទំព័រស្ថានភាព **My Voter Status** នៅលើវិបសាយរបស់រដ្ឋលេខាធិការតាមអាសយដ្ឋាន ***VoterStatus.sos.ca.gov*** ដែលអ្នកអាចពិនិត្យមើលស្ថានភាពអ្នកបោះឆ្នោតរបស់អ្នក ស្វែងរកកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតរបស់អ្នក និងព័ត៌មានជាច្រើនទៀត។

ប្រើប្រាស់ **My Voter Status** ដើម្បី ៖

- មើលថា អ្នកបានចុះឈ្មោះដើម្បីបោះឆ្នោតហើយឬនៅ បើបានចុះរួចហើយ តើនៅក្នុងខោនធីមួយណា
- ពិនិត្យមើលចំណង់ចំណូលចិត្តគណបក្សនយោបាយអាទិភាពរបស់អ្នក
- ស្វែងរកទីកន្លែងបោះឆ្នោតរបស់អ្នក
- រកមើលមណ្ឌលបោះឆ្នោត (សម្រាប់អ្នកបោះឆ្នោតដែលរស់នៅក្នុងខោនធី **Madera, Napa, Nevada, Sacramento,** និង **San Mateo)**
- ស្វែងរកព្រឹត្តិការណ៍បោះឆ្នោតនាអនាគតនៅក្នុងមូលដ្ឋានរបស់អ្នក
- ទទួលបានមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោត (**VIG**) តាមអ៊ីម៉ែលមុនការបោះឆ្នោតទូទាំងរដ្ឋនីមួយៗ
- ស្វែងរកព័ត៌មានទាក់ទងសម្រាប់ការិយាល័យការបោះឆ្នោតខោនធីរបស់អ្នក
- សូមពិនិត្យមើលស្ថានភាពបោះឆ្នោតតាមសំបុត្រ ឬ សន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នក

ព័ត៌មានថ្ងៃបោះឆ្នោត

កន្លែងបោះឆ្នោត និងមណ្ឌលបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹកដល់ម៉ោង 8:00 យប់នៅថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា។ ប្រសិនបើអ្នកបានមកតម្រង់ជួរមុនម៉ោង 8:00 យប់អ្នកនៅតែអាចបោះឆ្នោតបាន។ ដើម្បីស្វែងរកកន្លែងបោះឆ្នោត ឬមណ្ឌលបោះឆ្នោតរបស់អ្នក ៖

ពិនិត្យមើលមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោត ដែលមន្ត្រីរៀបចំការបោះឆ្នោតប្រចាំខោនធីបានផ្ញើទៅអ្នក

ទូរសព្ទទៅលេខ **(888) 345-4917**

តាមអ៊ីនធឺណិតតាមអាសយដ្ឋាន *www.sos.ca.gov/elections/polling-place* **ឬ** *VoterStatus.sos.ca.gov*

សរសេរអត្ថបទ *Vote* ទៅ **GOVOTE (468683)**

ទាញយកកម្មវិធី **"Vote California"** សម្រាប់ទូរសព្ទទំនើប (អាចរកបាននៅតាម **iOS** និង **Android stores)**

អ្នកបរិច្ចាគកំពូលៗទូទាំងរដ្ឋ បេក្ខជន និងវិធានការសន្លឹកឆ្នោត

នៅពេលគណៈកម្មការ (មនុស្សម្នាក់ ឬក្រុមមនុស្សដែលទទួលប្រាក់ ឬចំណាយប្រាក់ក្នុងគោលបំណងជះឥទ្ធិពលលើអ្នកបោះឆ្នោតឲ្យគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬវិធានការនៃសន្លឹកឆ្នោត) គាំទ្រ ឬប្រឆាំងនឹងវិធានការនៃសន្លឹកឆ្នោត ឬបេក្ខជន និងរកប្រាក់បានយ៉ាងតិច $1 លានដុល្លារ គណៈកម្មការត្រូវតែរាយការណ៍អ្នកបរិច្ចាគកំពូលៗរបស់ខ្លួនចំនួន 10 នាក់ ទៅគណៈគណកម្មការអនុវត្តន៍នយោបាយយុត្តិធម៍រដ្ឋ **California (California Fair Political Practices Commission, FPPC)**។ គណៈកម្មការត្រូវធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះកំពូលទាំង 10 នៅពេលមានការផ្លាស់ប្តូរ។

បញ្ជីទាំងនេះអាចរកបាននៅលើវ៉ិបសៃយត៍របស់ FPPC
http://www.fppc.ca.gov/transparency/top-contributors.html

សំណើប្រជាមតិ

1 ផ្តល់ការអនុញ្ញាតប័ណ្ណកម្ចីដើម្បីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានជាក់លាក់។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — **បានរៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័រ'រដ្ឋលេខាធិការនៅ *http://voterguide.sos.ca.gov*។

- អនុញ្ញាតឱ្យប្រើប័ណ្ណកម្ចីកាតព្វកិច្ចទូទៅចំនួន $4 ពាន់លានដុល្លារដើម្បីផ្តល់មូលនិធិដល់កម្មវិធីលំនៅដ្ឋានដែលមានស្រាប់។
- រាប់បញ្ចូល $1.5 ពាន់លានដុល្លារសម្រាប់កម្មវិធីលំនៅដ្ឋានសម្រាប់ពហុគ្រួសារ (Multifamily Housing Program) ដែលមានប្រាក់ ចំណូលទាបចំនួន $1 ពាន់លានដុល្លារសម្រាប់ ប្រាក់កម្ចី ដើម្បីជួយដល់អតីតយុទ្ធជនទិញ កសិដ្ឋាននិងលំនៅដ្ឋានចំនួន $450 លានដុល្លារ សម្រាប់គម្រោងសាងសង់ លំនៅដ្ឋានដែលមានលំនៅដ្ឋានជាត្រង់ស៊ីតចំនួន $300 លានដុល្លារសម្រាប់ កម្មវិធីលំនៅដ្ឋានរបស់ កសិករ (farmworker housing program) និង ចំនួន $300 លានដុល្លារសម្រាប់ផ្ទះផលិត និងផ្ទះចល័ត។
- ផ្តល់ជំនួយលំនៅដ្ឋានសម្រាប់អ្នកទិញ ហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ និងជំនួយផ្ទូផ្ទងដើម្បីពង្រីក ស្តុកលំនៅដ្ឋានដែលមានតម្លៃសមរម្យ។
- អនុប្បទានប្រាក់ចំណូលពីមូលនិធិទូទៅដើម្បីសងបំណុលកម្ចី សម្រាប់កម្មវិធីដែលមានស្រាប់ដែលគ្មានប្រាក់ចំណូល ឬប្រាក់ចំណូលមិនគ្រប់គ្រាន់។

សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់ការវិភាគអង្គនិតិបញ្ញត្តិនៃរដ្ឋសុទ្ធ និងផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលក្នុងតំបន់៖

- បង្កើនតម្លៃនៃការបង់ សងប័ណ្ណកម្ចីរដ្ឋ ជាមធ្យមប្រហែល $170 លានជារៀងរាល់ឆ្នាំលើសពី 35 ឆ្នាំ។ មូលនិធិប័ណ្ណកម្ចីទាំងនេះនឹងត្រូវបានប្រើដើម្បីផ្តល់លំនៅដ្ឋានមានតម្លៃសមរម្យ។

ការប៉ាន់ស្មានចំណាយលើប័ណ្ណកម្ចីរបស់រដ្ឋ	
បានអនុញ្ញាតលើការខ្ចីថ្មី	$4 ពាន់លានដុល្លារ
ថ្លៃប្រចាំឆ្នាំជាមធ្យម សម្រាប់បង់សងប័ណ្ណកម្ចី	$170 លានដុល្លារ
អំឡុងពេលនៃការសងវិញទំនងជា	35 ឆ្នាំ
ប្រភពនៃការសងវិញ	ប្រាក់ចំណូលពន្ធទូទៅ

ការបោះឆ្នោតចុងក្រោយដឹកនាំដោយអង្គនីតិបញ្ញត្តិនៅ ច្បាប់ព្រឹទ្ធសភា (Senate Bill, SB) 3 (សំណើប្រជាមតិ 1) (ជំពូក 365, លក្ខន្តិកៈឆ្នាំ 2017)

ព្រឹទ្ធសភា៖ **បាទ/ចាស 30** **ទេ 8**

រដ្ឋសភា៖ **បាទ/ចាស 56** **ទេ 21**

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

លំនៅដ្ឋានគឺមានតម្លៃថ្លៃនៅ California។

លំនៅដ្ឋាននៅ California មានតម្លៃថ្លៃជាងភាគច្រើននៃប្រទេសផ្សេងទៀតជាយូរមកហើយ។ ខណៈពេលដែលកត្តាជាច្រើនមានតួនាទីក្នុងការចំណាយលើលំនៅដ្ឋានខ្ពស់របស់ California អ្វីដែលសំខាន់បំផុតនោះគឺការខ្វះខាតលំនៅដ្ឋានជាពិសេសនៅក្នុងសហគមន៍ឆ្នេរសមុទ្រ។ កង្វះខាតលំនៅដ្ឋានមានន័យថាគ្រួសារដែលមានបំណងចង់រស់នៅក្នុងរដ្ឋនេះប្រកួតប្រជែងសម្រាប់លំនៅដ្ឋានដែលមានកំណត់។ ការប្រកួតប្រជែងនេះបង្កើនតម្លៃផ្ទះ និងការជួល។ សព្វថ្ងៃផ្ទះជាមធ្យមរបស់ California មានតម្លៃ 2.5 ដងជាមធ្យម។

ការជួលប្រចាំខែជាមធ្យមនៅCalifornia គឺប្រហែល 50 ភាគរយខ្ពស់ជាងនៅទូទាំងប្រទេស។

ការកសាងលំនៅដ្ឋានមួយចំនួនមូលនិធិកម្មវិធីលំនៅដ្ឋានរបស់រដ្ឋ។ ក្នុងរយៈពេលជាច្រើនឆ្នាំមានផ្ទះនិងផ្ទះល្វែងប្រហែល 100,000 ត្រូវបានសាងសង់នៅ California។ ភាគច្រើននៃលំនៅដ្ឋានទាំងនេះត្រូវបានសាងសង់ទាំងស្រុងដោយប្រាក់ដុល្លារឯកជន។ ក៏ប៉ុន្តែ អ្នកខ្លះទទួលបានជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាលសហព័ន្ធ រដ្ឋ ឬរដ្ឋាភិបាលមូលដ្ឋាន។ ក្នុងករណីទាំងនេះរដ្ឋផ្តល់ជូនរដ្ឋាភិបាលមូលដ្ឋានមិនរកប្រាក់ចំណេញ និងអ្នកអភិវឌ្ឍន៍ឯកជនដែលមានជំនួយឥតសំណងឬប្រាក់កម្ចីដែលមានតម្លៃទាបដើម្បីផ្តល់មូលនិធិដល់ផ្នែកមួយនៃ ថ្លៃដើមសាងសង់របស់ផ្ទះសម្បែង។ ជាទូទៅលំនៅដ្ឋានដែលបានសាងសង់ជាមួយនឹងមូលនិធិទាំងនេះត្រូវតែលក់ ឬជួលឱ្យពលរដ្ឋរស់នៅ California ដែលមានប្រាក់ចំណូលទាប។ ផ្នែកមួយនៃផ្ទះសម្បែងដែលបានកសាងដោយមូលនិធិរដ្ឋត្រូវបានទុកចោលសម្រាប់ពលរដ្ឋរស់នៅ California។ ខណៈពេលដែលរដ្ឋជាប្រវត្តិសាស្ត្រមិនបានផ្តល់មូលនិធិបន្តសម្រាប់កម្មវិធីលំនៅដ្ឋានទាំងនេះ California ទទួលបានប្រហែល$2 ពាន់លាន ដុល្លារជារៀងរាល់ឆ្នាំពីរដ្ឋាភិបាលសហព័ន្ធដើម្បីគាំទ្រដល់គម្រោងទាំងនេះ។

កម្មវិធីឥណទានលំនៅដ្ឋានសម្រាប់អតីតយុទ្ធជន។ កម្មវិធីកម្ចីឥណទានលំនៅដ្ឋាន អតីតយុទ្ធជនផ្តល់ប្រាក់កម្ចីទិញផ្ទះដល់អតីតយុទ្ធជនដែលមានសិទ្ធិ រួមទាំងអតីតយុទ្ធជនដែលមិនអាចមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រាក់កម្ចីទិញផ្ទះ។ ក្រោមកម្មវិធីនេះ រដ្ឋលក់ប័ណ្ណកម្ចីទូទៅដល់វិនិយោគិនហើយប្រើប្រាស់មូលនិធិដើម្បីផ្តល់ប្រាក់កម្ចីដល់អតីតយុទ្ធជនដើម្បីទិញផ្ទះ។ អតីតយុទ្ធជនចូលរួមទូទាត់សងរដ្ឋសម្រាប់ប្រាក់កម្ចីទិញផ្ទះទាំងនេះ។ មូលនិធិទាំងនេះត្រូវបានប្រើដើម្បីសងប័ណ្ណកម្ចី។

សេចក្តីស្នើច្បាប់

ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅថ្មីសម្រាប់លំនៅដ្ឋាន។ វិធានការនេះអនុញ្ញាតឱ្យរដ្ឋលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅចំនួន $4 ពាន់លានដុល្លារសម្រាប់កម្មវិធីលំនៅដ្ឋានផ្សេងៗ។ (សម្រាប់ព័ត៌មានបន្ថែមអ

រូបភាពលេខ 1

ការស្នើសុំប្រើប្រាស់មូលនិធិប័ណ្ណកម្ចី
(ខ្ទង់លាន)

ប្រភេទ	ចំនួន
កម្មវិធីលំនៅដ្ឋានរដ្ឋ	
កម្មវិធីលំនៅដ្ឋានពហុគ្រួសារតម្លៃសមរម្យ	$1,800
កម្មវិធីហេដ្ឋារចនាសម្ព័ន្ធ	450
កម្មវិធីម្ចាស់លំនៅដ្ឋាន	450
កម្មវិធីលំនៅដ្ឋានរបស់កសិករ	300
សរុបរង	($3,000)
កម្មវិធីលំនៅដ្ឋានអតីតយុទ្ធជន	
ប្រាក់កម្ចីទិញអតីតយុទ្ធជន	$1,000
សរុប	**$4,000**

ពីការប្រើប័ណ្ណកម្មីរបស់រដ្ឋសូមមើល "ទិដ្ឋភាពទូទៅនៃបំណុលប័ណ្ណកម្មីរបស់រដ្ឋ" នៅផ្នែកខាងក្រោយក្នុងមគ្គទេសក៍នេះ។)

ការប្រើមូលនិធិ

ដូចបានបង្ហាញក្នុងរូបភាពទី 1, វិធានការនេះផ្តល់នូវការផ្តល់មូលនិធិប័ណ្ណកម្មីសម្រាប់កម្មវិធីផ្ទះជាច្រើន ដែលត្រូវបានពិពណ៌នាដូចខាងក្រោមនៅក្នុងលម្អិតបន្ថែមទៀត។

កម្មវិធីលំនៅដ្ឋានរដ្ឋ។ វិធានការនេះផ្តល់ $3 ពាន់លានដុល្លារសម្រាប់កម្មវិធីលំនៅដ្ឋានរដ្ឋជាច្រើន។ ដំណើរការពីការលក់ប័ណ្ណកម្មីនឹងត្រូវផ្តល់ជូនអ្នកស្នើសុំកម្មវិធី—រដ្ឋាភិបាលមូលដ្ឋាន អង្គការមិនស្វែងរកប្រាក់ចំណេញ និងអ្នកអភិវឌ្ឍឯកជន—តាមរយៈតាមរយៈដំណើរការប្រកួតប្រជែងគ្រប់គ្រងដោយរដ្ឋ។

- ***កម្មវិធីលំនៅដ្ឋានពហុគ្រួសារដែលមានតម្លៃសមរម្យ។*** វិធានការនេះផ្តល់ប្រាក់ $1.8 ពាន់លានដុល្លារដើម្បីសាងសង់ ឬជួសជុលគម្រោងលំនៅដ្ឋានជួល។ ដូចជាសំណង់អាផាតមិន។ កម្មវិធីទាំងនេះជាទូទៅផ្តល់ឱ្យរដ្ឋាភិបាលមូលដ្ឋានអង្គការមិនស្វែងរកប្រាក់ចំណេញ និងអ្នកអភិវឌ្ឍន៍ឯកជនដែលមានប្រាក់កម្មីការប្រាក់ទាបដើម្បីផ្តល់មូលនិធិផ្នែកនៃការចំណាយលើការសាងសង់។ ជាការផ្លាស់ប្តូរ គម្រោងត្រូវរក្សាទុនសម្រាប់គ្រួសារដែលមានចំណូលទាបសម្រាប់រយៈពេលមួយ 55 ឆ្នាំ។
- ***កម្មវិធីហេដ្ឋារចនាសម្ព័ន្ធ។*** វិធានការនេះផ្តល់ប្រាក់ចំនួន $450 លានដុល្លារដល់កម្មវិធីដែលកសាងលំនៅដ្ឋាននៅតាមតំបន់ទីក្រុងដែលមានស្រាប់ និងនៅក្បែរការដឹកជញ្ជូនសាធារណៈ។ មូលនិធិនេះក៏នឹងផ្តល់ប្រាក់កម្មីនិងជំនួយឥតសំណងសម្រាប់គម្រោងជាច្រើនដែលគាំទ្រដល់លំនៅដ្ឋានដូចជាសួនច្បារ និងទឹកប្រព័ន្ធលូបង្ហូរទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។
- ***កម្មវិធីម្ចាស់ផ្ទះ។*** វិធានការនេះផ្តល់ឱ្យចំនួន $450 លានដុល្លារដើម្បីលើកទឹកចិត្តម្ចាស់ផ្ទះសម្រាប់អ្នកទិញផ្ទះដែលមានប្រាក់ចំណូលទាប និងមធ្យម។ ភាគច្រើននៃថវិកាត្រូវបានប្រើដើម្បីផ្តល់ជំនួយទូទាត់ដល់អ្នកទិញផ្ទះលើកដំបូងតាមរយៈការប្រាក់កម្មី ឬប្រាក់ជំនួយទាប។ លើសពីនេះទៀតវិធានការនេះផ្តល់ថវិកាដើម្បីជួយគ្រួសារដែលមានប្រាក់ចំណូលទាប និងមធ្យមដើម្បីសាងសង់ផ្ទះផ្ទាល់ខ្លួន។
- ***កម្មវិធីលំនៅដ្ឋានរបស់កសិករ។*** វិធានការនេះផ្តល់ $300 លានដុល្លារនិងជំនួយឥតសំណងប្រាក់កម្មីដើម្បីសាងសង់លំនៅដ្ឋានសម្រាប់កសិករ។ មូលនិធិកម្មវិធីគួរតែប្រើសម្រាប់ទាំងការជួល និងផ្ទះដែលកាន់កាប់ដោយម្ចាស់ផ្ទះ។

កម្មវិធីលំនៅដ្ឋានអតីតយុទ្ធជន។ វិធានការនេះក៏ផ្តល់ $1 ពាន់លានដុល្លារសម្រាប់ជំនួយប្រាក់កម្មីទិញផ្ទះដល់អតីតយុទ្ធជន។ អតីតយុទ្ធចនទូទៅប្រើកម្មីទាំងនេះដើម្បីទិញលំនៅដ្ឋានគ្រួសារ ខុនដូ កសិដ្ឋាន និងផ្ទះចល័ត។

ឥទ្ធិពលនៃសារពើពន្ធ

តម្លៃប័ណ្ណកម្មីសម្រាប់កម្មវិធីលំនៅដ្ឋានរដ្ឋ។ វិធានការនេះនឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់រហូតដល់ទៅ $3 ពាន់លានដុល្លារដោយលក់ប័ណ្ណកម្មីកាតព្វកិច្ចទូទៅដល់វិនិយោគិន ដែលនឹងត្រូវសងដោយការប្រាក់ពីមូលនិធិទូទៅរបស់រដ្ឋ។ តម្លៃប័ណ្ណកម្មីទាំងនេះនឹងអាស្រ័យលើកត្តាផ្សេងៗ—ដូចជាអត្រាការប្រាក់ក្នុងប្រសិទ្ធភាពនៅពេលដែលពួកគេត្រូវបានលក់ ពេលវេលានៃការលក់ប័ណ្ណកម្មី

និងរយៈពេលដែលត្រូវសងពួកគេ។ យើងប៉ាន់ស្មានថាការចំណាយចំពោះអ្នកបង់ពន្ធដើម្បីសងបំណុលនឹងមានជាមធ្យម **ប្រហែល $170 លានដុល្លារជារៀងរាល់ឆ្នាំសម្រាប់រយៈពេល 35 ឆ្នាំ**—សរុបចំនួន $5,9 ពាន់លានដុល្លារដើម្បីសងទាំងដើម ($3 ពាន់លានដុល្លារ) និងការប្រាក់ ($2,9 ពាន់លានដុល្លារ)។ ចំនួនទឹកប្រាក់នេះគឺប្រហែលមួយភាគដប់នៃ 1 ភាគរយនៃមូលនិធិថវិកាទូទៅរបស់រដ្ឋ។

តម្លៃប័ណ្ណកម្ចីសម្រាប់កម្មវិធីលំនៅដ្ឋានអតីតយុទ្ធជន។ វិធានការនេះនឹងអនុញ្ញាតឱ្យរដ្ឋខ្ចីរហូតដល់ $1 ពាន់លានដុល្លារដោយលក់បំណុលកាតព្វកិច្ចទូទៅដល់វិនិយោគិន។ អតីតយុទ្ធជនចូលរួមក្នុងកម្មវិធីកម្ចីទិញផ្ទះនឹងធ្វើឱ្យការទូទាត់ប្រចាំខែដល់រដ្ឋ។ អនុញ្ញាតឱ្យរដ្ឋសងបំណុល។ ការទូទាត់ទាំងនេះតែងតែគ្របដណ្តប់ចំនួនទឹកប្រាក់ដែលជំពាក់លើតម្លៃប័ណ្ណ មានន័យថាកម្មវិធីនេះតែងតែដំណើរការដោយគ្មានការចំណាយដោយផ្ទាល់ដល់រដ្ឋ។

តើមនុស្សប៉ុន្មាននាក់ដែលវិធានការអាចជួយបាន? ថវិកាពីវិធានការនេះជាទូទៅនឹងត្រូវបានប្រើរួមគ្នាជាមួយប្រាក់រដ្ឋាភិបាលដទៃទៀតដើម្បីផ្តល់ជំនួយលំនៅដ្ឋាន។ ក្នុងករណីជាច្រើន វិធានការនេះនឹងអនុញ្ញាតឱ្យរដ្ឋទទួលបានមូលនិធិបន្ថែមពីសហព័ន្ធ សម្រាប់ លំនៅដ្ឋានដែលមានតម្លៃសមរម្យ។ សរុបទៅ មូលនិធិប័ណ្ណកម្ចី នេះនឹងផ្តល់ការឧបត្ថម្ភធនប្រចាំឆ្នាំដល់គ្រួសារកសិករចម្រុះរហូតដល់ 30,000 និងគ្រួសារកសិករចំនួន 7,500 គ្រួសារ។ មូលនិធិក៏នឹងផ្តល់នូវជំនួយទូទាត់អ្នកទិញផ្ទះហប្រហែល 15,000 នាក់ និងប្រាក់កម្ចីទិញផ្ទះដល់អតីតយុទ្ធជនប្រហែល 3,000 នាក់។ ក្នុងករណីមួយចំនួនដូចជាសម្រាប់កម្មវិធីផ្តល់ប្រាក់កម្ចីចុះពលរដ្ឋរស់នៅ California អាចចាប់ផ្តើមទទួលបានផលប្រយោជន៍យ៉ាងឆាប់រហ័សពីមូលនិធិប័ណ្ណកម្ចី។ ក្នុងករណីផ្សេងទៀតដូចជាសម្រាប់ការសាងសង់លំនៅដ្ឋានពហុគ្រួសារដែលមានតម្លៃសមរម្យវាអាចចំណាយពេលច្រើនឆ្នាំសម្រាប់ពលរដ្ឋរស់នៅ California ទទួលបានប្រយោជន៍ពីវិធានការនេះ។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីចូលប្រើអ្នករួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មាធិការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 1 ★

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 1 មានន័យថា ជំនឿពីវិបត្តិលំនៅដ្ឋានដែលប៉ះទង្គិចដែលកំពុងបំផ្លាញដល់ពលរដ្ឋ California និងការនាំនូវការខូចបង់ធ្ងន់ធ្ងរបំផុតរបស់វាលើអតីតយុទ្ធជន គ្រួសារប្រឹងប្រែងធ្វើការ ជនចាស់ជរា និងជនពិការ។

សំណើប្រជាមតិ 1 គឺជាសំណើប្រជាមតិតែមួយគត់ដែលដោះស្រាយដោយផ្ទាល់លើការខ្វះខាតលំនៅដ្ឋានដោយសាងសង់ផ្ទះដែលមានតម្លៃកាន់តែសមរម្យបន្ថែមទៀត—ដោយគ្មានការបង្កើនពន្ធ។

បោះឆ្នោតគាំទ្រ លើ 1 មានន័យថា លំនៅដ្ឋានសម្រាប់អតីតយុទ្ធជន និងការផ្តល់ជំនួយដល់អ្នកទាំងនោះដែលកំពុងតស៊ូបំផុតដោយ៖

- ការវិនិយោគ $1 ពាន់លានដុល្លារដើម្បីជួយដល់អតីតយុទ្ធឱ្យអាចលៃលកទិញផ្ទះបាន
- សាងសង់លំនៅដ្ឋានបន្ទាន់ថ្មីសម្រាប់កុមារ និងគ្រួសារដែលគ្មានផ្ទះសម្បែង
- ការសាងសង់លំនៅដ្ឋានពហុគ្រួសារសម្រាប់គ្រួសារធ្វើការ និងការបង្កើតឱកាសភាពជាម្ចាស់ផ្ទះ
- ការបង្កើតលំនៅដ្ឋានគាំទ្រថ្មីសម្រាប់ជនពិការ និងជាជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ

"ជាមួយគ្នា យើងអាចបង្កើតលំនៅដ្ឋានដែលអាចលៃលកទិញបានដើម្បីជួយអ្នកដែលត្រូវការជំនួយ រួមទាំងយុវជនអតីតជាកូនចិញ្ចឹម និងពលរដ្ឋចាស់ជរាដែលមានប្រាក់ចំណូលទាប។"—*សមាជិកព្រឹទ្ធសភា។ Jim Beall, សំណើប្រជាមតិ 1 អ្នកនិពន្ធ, ប្រធានគណៈកម្មាធិការលំនៅដ្ឋាន និងដឹកជញ្ជូននៃព្រឹទ្ធភា។*

ការផ្តល់ឱ្យអតីតយុទ្ធជននូវលំនៅដ្ឋាន

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 1 មានន័យថា ការប្តេជ្ញា $1 ពាន់លានដុល្លារតែឯកឯងសម្រាប់លំនៅដ្ឋាន របស់អតីតយុទ្ធជនដោយផ្តល់ជូនលំនៅដ្ឋានថ្មី និងឱកាសភាពជាម្ចាស់កម្មសិទ្ធិសម្រាប់អតីតយុទ្ធជននៅក្រោមកម្មវិធីកម្ចីទិញផ្ទះ CalVet ដែលបានជួយអតីតយុទ្ធជនចំនួន 423,000 នាក់ និងក្រុមគ្រួសាររបស់ពួកគេ។ សំណើប្រជាមតិ 1 ផ្តល់អតីតយុទ្ធជនដោយជួយពួកគេឱ្យមានផ្ទះមួយ បន្ទាប់ពីពួកគេត្រឡប់ពីបម្រើសេវាកម្ម។

California មានអតីតយុទ្ធជនដែលគ្មានផ្ទះសម្បែងច្រើនបំផុត នៅក្នុងប្រទេស ហើយភាពគ្មានផ្ទះសម្បែងគឺត្រូវបានរំពឹងថាកើនឡើងក្នុងពេលទស្សវត្សរ៍ក្រោយនេះក្នុងចំណោមអតីតយុទ្ធជនដែលបានបម្រើការងារនៅក្នុងប្រទេសអ៊ីរ៉াক់ និងអាហ្វហ្គានីស្ថាន។ អតីតយុទ្ធជនដែលរងគ្រោះពីបញ្ហាវេជ្ជសាស្ត្រ និងសុខភាពផ្លូវចិត្តដែលទ្រាំទ្រពីការបំពេញការងាររបស់ពួកគេ គឺស្ថិតក្នុងហានិភ័យខ្ពស់សម្រាប់ភាពគ្មានផ្ទះសម្បែងរយៈពេលយូរអង្វែង។

"ផ្ទះសុវត្ថិភាព ស្ថិតស្ថេរ ដែលអាចលៃលកទិញបាន គឺជារបៀបដែលយើងអាចផ្តល់ពេលពេញមួយជីវិតនៃការគាំទ្រសម្រាប់អតីតយុទ្ធជននៃគ្រប់ជំនាន់ និងក្រុមគ្រួសាររបស់ពួកគេ។ លំនៅដ្ឋានដែលអាចលៃលកទិញបានសម្រាប់អតីតយុទ្ធជនបើកឱកាសឱ្យចូលរួមក្នុង សុបិនអាមេរិក ដែលការលះបង់របស់ពួកគេបានធ្វើឱ្យវាអាចទៅរួច។"—*Gerald G. Wilson, អតីតមេបញ្ជាការរដ្ឋ អតីតយុទ្ធជនពិការអាមេរិក, នាយកដ្ឋានរដ្ឋ California*។

ក្រុមគ្រួសារដែលប្រឹងប្រែងធ្វើការរស់នៅកន្លែងដែលពួកគេធ្វើការ

សំណើប្រជាមតិ 1 នឹងសាងសង់ផ្ទះដែលអាចលៃលកទិញបានសម្រាប់មនុស្ស ដែលប្រឹងប្រែងធ្វើការ ដូចជាជំនួយការគិលានុបដ្ឋាក ស្ទ្រីនហាងលក់គ្រឿងទេស និងជំនួយការខាងបង្រៀន ដើម្បីឱ្យពួកគេអាចរស់នៅក្នុងសហគមន៍ដែលពួកគេធ្វើការ ខណៈពេលនៅតែមានប្រាក់សម្រាប់គ្រឿងទេស និងការថែទាំកូន។

ការបន្ធូរបន្ថយវិបត្តិភាពគ្មានផ្ទះសម្បែង

សំណើប្រជាមតិ 1 នឹងដោះស្រាយហានិភ័យភាពគ្មានផ្ទះសម្បែងក្នុងសង្កាត់របស់យើង។ ក្រុមគ្រួសារដែលត្រូវបានរុញទោដល់គែមហិរញ្ញវត្ថុគឺកំពុងរស់នៅក្នុងរថយន្ត ដែលពីរដង និងសូម្បីតែបីដងក្នុងលំនៅដ្ឋានដ៏ចង្អៀតណែន។ ក្រុមគ្រួសារដែលគ្មានជម្រើសផ្សេងត្រលប់មកកាន់ជម្រកដែលសន្ធប់យក។

លំនៅដ្ឋានដែលមានសុវត្ថិភាពល្មមអាចលៃលកទិញបានសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ

"អំពើហិង្សាក្នុងគ្រួសារកើតឡើងក្នុងទីបិទជិត ជារឿយៗមិនត្រូវបានឃើញ ដែលបង្ខំឱ្យជនរងគ្រោះជាច្រើននាក់ និងកូនៗរបស់ពួកគេរស់នៅក្នុងលក្ខខណ្ឌមិនមានសុវត្ថិភាព។ ជម្រកគ្រាមានអាសន្នមិនអាចបំពេញបានតាមតម្រូវការឡើយ ហើយវិបត្តិលំនៅដ្ឋានធ្វើឱ្យកាន់តែធ្ងន់ធ្ងរឡើងដល់ការប៉ះទង្គិចផ្លូវចិត្ត។ សមត្ថភាពក្នុងការរស់នៅក្នុងផ្ទះមានស្ថេរភាពដែលល្មមអាចទិញបាន នាំមកនូវសុវត្ថិភាព និងការដោះស្រាយសម្រាប់អ្នកនៅរស់រាន និងក្រុមគ្រួសាររបស់ពួកគេ។"—*Kathy Moore, ភាពជាដៃគូ California ដើម្បីបញ្ចប់អំពើហិង្សាក្នុងគ្រួសារ*។

ការលើកស្ទួយសេដ្ឋកិច្ច

សំណើប្រជាមតិ 1 ត្រូវបានរំពឹងថាបង្កើតការងាររាប់សែន និងជួយលើកស្ទួយសេដ្ឋកិច្ចរបស់ California។ បណ្តាថ្នាក់ដឹកនាំអាជីវកម្មនិយាយថា បោះឆ្នោតគាំទ្រ លើ 1 ពីព្រោះ California ត្រូវតែចាប់ផ្តើមសាងទីកន្លែងកាន់តែល្មមអាចទិញបានសម្រាប់កម្លាំងពលកម្មរបស់យើង និងរក្សារដ្ឋឱ្យកាន់តែប្រកួតប្រជែងខាងសេដ្ឋកិច្ច។

ការគាំទ្រទូលំទូលាយ

អតីតយុទ្ធជន អ្នករស់នៅសម្រាប់មនុស្សធម៌ អ្នករស់រានពីអំពើហិង្សាក្នុងគ្រួសារ ជនចាស់ជរា ថ្នាក់ដឹកនាំអាជីវកម្ម និងការថែទាំសុខភាព យល់ស្រប៖ សំណើប្រជាមតិ 1 ជួយសាងសង់លំនៅដ្ឋានដែលល្មមអាចទិញបានដែលបណ្តាសហគមន៍របស់យើងត្រូវការ។

www.vetsandaffordablehousingact.org

GERALD G. WILSON, អតីតមេបញ្ជាការរដ្ឋ
អតីតយុទ្ធជនពិការអាមេរិក, នាយកដ្ឋាន California

SHARON ELLIS, ប្រធាន
Habitat for Humanity California

GARY PASSMORE, ប្រធាន
សមាជនៃព្រឹទ្ធាចារ្យរដ្ឋ California

★ ទឡ្ហីករណ៍តបត ដើម្បីគាំទ្រសំណើប្រជាមតិលេខ 1 ★

នៅក្រោម សំណើប្រជាមតិ 1, $4 ពាន់លានដុល្លារដែលនឹងត្រូវបានខ្ចីដោយការលក់ប័ណ្ណកម្ចីនឹងទៅកាន់កម្មវិធីចម្រុះគ្នាជាច្រើនដែលអាច ឬមិនអាចទទួលបានការគាំទ្រសម្រាប់ការប្រើប្រាស់។

កម្មវិធីនេះគឺមានបំណងក្នុងការបន្ធូរភាពខ្វះខាតលំនៅដ្ឋានក្នុងរដ្ឋ California សម្រាប់ចំនួនប្រជាជនមានកម្រិតខ្លាំង។ ដំណោះស្រាយធំជាងគេគឺត្រូវការឱ្យមាន។ តោះយើងសួរបេក្ខជនសម្រាប់ការិយាល័យរដ្ឋពីអ្វីដែលពួកគេស្នើសុំ។

ការស្នើសុំដ៏អាក្រក់ខ្លាំង

កាលពីដើមឆ្នាំនេះ នីតិប្រតិបត្តិសាជីវកម្មក្នុងរដ្ឋ California

បានរុញយុត្តាធិការដ្ឋ *(សេចក្តីព្រាងច្បាប់ព្រឹទ្ធសភា 827)* ឱ្យច្រៀកក្រុង និងខោនធីនៃអាជ្ញាធរឱ្យបញ្ឈប់អ្នកអភិវឌ្ឍធំៗពីការសាងសង់អាផាត់មិន និងខ្ទុនដូកមួស្ខ្ពស់ក្នុងសង្កាត់នីមួយៗនៅក្នុងចម្ងាយកន្លះម៉ាយល៍នៃបណ្តាញហាប់ប្តូរជើងធ្វើដំណើរ ឬមួយភាគបួនម៉ាយល៍នៃចំណតឡានក្រុងដែលជារឿយៗបន្ថែមដែលមានស្រាប់ ឬនៅពេលក្រោយ។

នៅក្រោមសេចក្តីព្រាងច្បាប់ សូម្បីចំណុចចំណតនៅនឹងកន្លែងមិនអាចតម្រូវឱ្យមានផងដែរ។

ឧទាហរណ៍ ជាង 90% នៃ San Francisco នឹងទទួលរងនូវការដាក់ឱ្យកើនឡើងខ្ពស់បែបនេះ។

ត្រូវបានព្រមាន៖ ទោះបីជា សេ *ចក្តីព្រាងច្បាប់ព្រឹទ្ធសភា 827* មិនត្រូវបានអនុម័តក្នុងខែមេសា, *SB 827* (ឬសេចក្តីព្រាងច្បាប់ស្រដៀងគ្នាមួយ) អាចត្រូវបានចេញ និងចុះហត្ថលេខាចូលជាច្បាប់ បន្ទាប់ពីការបោះឆ្នោតនៅខែវិច្ឆិកា ឆ្នាំ 2018 នេះ និងមុនពេលអ្នកដឹងអំពីវា។

នោះច្បាប់ដែលបានស្នើអាចត្រូវបានបញ្ឈប់ដោយប្រជាមតិទូទាត់រដ្ឋមួយប៉ុណ្ណោះ (ញត្តិ និងការបោះឆ្នោះពេលក្រោយ)។

នេះគឺជាទ្រឹស្តីល្អប្រសើរជាង៖

ក្នុងការបំពេញលំនៅដ្ឋានដែលសមស្រប ប៉ុន្តែដាក់កំហិតក្នុងន័យផ្សេងដល់មណ្ឌលអាជីវកម្មថ្មីចំពោះទីកន្លែងដែលមានទីទំនេរសម្រាប់លំនៅដ្ឋានថ្មីនៅក្បែរ។

បុគ្គលិកជាច្រើនអាចដើរ លោត ជិះស្គី ឬជិះកង់មកធ្វើការបាន។

GARY WESLEY

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 1 ★

នេះគឺជាវិធានការប័ណ្ណកម្មីកាតព្វកិច្ចទូទៅមួយទៀត
វាស្នើសុំការអនុញ្ញាតពីអ្នកបោះឆ្នោតសម្រាប់រដ្ឋ California
ដើម្បីខ្ចីប្រាក់បន្ថែមដោយលក់ "ប័ណ្ណកម្មី" ដែលនឹងត្រូវការឱ្យទូទាត់សងវិញជាមួយការប្រាក់ (*អាចនឹងត្រូវបង់សងតាមរយៈពន្ធអចលនទ្រព្យខ្ពស់ជាង*) ,ជាធម្មតាក្នុងរយៈពេលជាច្រើនទសវត្សរ៍។ ខ្ញុំនិយាយថា *"អាច"* ពីព្រោះពេលខ្លះ ការដំណើរការប័ណ្ណកម្មីគឺត្រូវបានប្រើសម្រាប់ផ្តល់ហិរញ្ញវត្ថុ ប៉ុន្តែត្រូវបានទូទាត់សងដោយអ្នកទទួលកម្មវិធី ដូចជាម្ចាស់កម្មសិទ្ធិ នៅក្រោមអតីតកម្មវិធីកម្មីផ្ទះ-កសិដ្ឋាន Cal-Vet។

វិធានការប័ណ្ណកម្មីមានសំណួរជាច្រើន៖

1. តើរដ្ឋាភិបាលជំពាក់ប្រាក់ប៉ុន្មានហើយ?
2. តើការចំណាយសរុបដែលបានរំពឹងទុកពីវិធានការនេះ មកលើសាធារណៈមានចំនួនប៉ុន្មាន?
3. តើមានការបញ្ជាក់អំពីការប្រើប្រាស់ប្រាក់ដែលបានស្នើសុំនោះឬទេ?
4. តើការប្រើប្រាស់ដែលបានស្នើត្រូវបានផ្តល់ហេតុផលត្រឹមត្រូវ—ដែលបានផ្តល់របស់ផ្សេងដែលអាចត្រូវការ ឬចង់បាន?
5. តើអ្នកបោះឆ្នោតនឹងបន្តផ្តល់ហិរញ្ញប្បទានលើគម្រោងតាមរយៈការបង់ពន្ធអចលនទ្រព្យកាន់តែច្រើនឬទេ នៅពេលប្រព័ន្ធពន្ធអចលនទ្រព្យរបស់រដ្ឋ Californiaមិនមានភាពត្រឹមត្រូវ?

ប្រព័ន្ធពន្ធអចលនទ្រព្យរបស់ CALIFORNIA គឺមិនស្មើភាព

ក្នុងឆ្នាំ 1978, អ្នកបោះឆ្នោត California
បានអនុម័តការផ្តួចផ្តើមរបស់អ្នកបោះឆ្នោត ក្រោយមកត្រូវបានស្គាល់ថាជា
សំណើប្រជាមតិ 13។

ការផ្តួចផ្តើមគំនិតបានបន្ថែមមាត្រាទៅលើរដ្ឋធម្មនុញ្ញនៃរដ្ឋ California
ដែលបានរារាំងដល់ *"ការវាយតម្លៃឡើងវិញ"* នៃអចលនទ្រព្យ លើកលែងតែ និងរហូតដល់ការផ្លាស់ប្តូរអចលនទ្រព្យមានការផ្តល់
ឬត្រូវបានកសាងឡើងវិញច្រើន។

សំណើប្រជាមតិ 13
បានការពារម្ចាស់អចលនទ្រព្យពីការបង្កើនពន្ធដ៏ច្រើនដោយផ្អែកលើតម្លៃអចលនទ្រព្យខ្ពស់ជាង; តែទោះបីជាយ៉ាងណា
វាក៏បានបង្កើននូវប្រព័ន្ធមួយផងដែរដែលម្ចាស់កម្មសិទ្ធិថ្មីៗទូទាត់ 10–20 ដងច្រើនជាងអ្នកជិតខាងរបស់ពួកគេដែលអចលនទ្រព្យរបស់ពួកគេមានតម្លៃដូចគ្នា ប៉ុន្តែត្រូវបានទទួលកាលពីពេលយូរយារមកហើយ។

លើសពីនេះ ដោយសារតែអចលនទ្រព្យអាជីវកម្មអាចជា
និងគឺត្រូវបានដាក់ជួលជារឿយៗ (ជំនួសឱ្យការលក់) សំណើប្រជាមតិ 13 បាននាំទៅរកការកាន់ប្តូរយ៉ាងច្រើននូវបន្ទុកពន្ធអចលនទ្រព្យជារួមពីអាជីវកម្មទៅម្ចាស់កម្មសិទ្ធិ។

អ្នកគាំទ្រនូវវិធានការសន្ទឹកឆ្នោតគួរតែទទួលរងបន្ទុកនៃការពន្យល់ពីមូលហេតុ
ដែលវាមានតម្លៃក្នុងការគាំទ្រ—បើថ្លៃចំណាយពេញ
គ្រឿងជំនួសដែលអាចរកបាន និងអ្នកដទៃត្រូវការ និងចង់បាន។

ក្នុងករណីនេះ អ្នកស្នើគួរប្រើប្រាស់ ការតបតដើម្បីឆ្លើយទៅនឹងសំណួរ 1–5 ខាងលើ។

GARY WESLEY

★ ទឡ្ហីករណ៍តបត ដើម្បីប្រឆាំងសំណើប្រជាមតិលេខ 1 ★

សំណើប្រជាមតិ 1 គឺចាំបាច់ទាំងស្រុងដើម្បីដោះស្រាយវិបត្តិលំនៅដ្ឋានដ៏ធ្ងន់ធ្ងររបស់ California។

អតីតយុទ្ធ ក្រុមគ្រួសារធ្វើការ មនុស្សដែលជួបប្រទះភាពគ្មានផ្ទះសម្បែង ជនចាស់ជរា ជនពិការ ស្ត្រីដែលរត់គេចពីអំពើហិង្សាក្នុងគ្រួសារ
និងអ្នកដទៃជាច្រើនទៀត គឺកំពុងតែតស៊ូនឹងការលៃលកលើថ្លៃចំណាយសម្រាប់លំនៅដ្ឋាន។

អតីតយុទ្ធដែលត្រលប់មកស្រុកកំណើតបន្ទាប់ពីបម្រើសេវាកម្មប្រទេសរបស់យើងមិនអាចស្វែងរកទីកន្លែងមួយដែលពួកគេអាចល្មមលៃលកចំណាយដើម្បីរស់នៅបាន។

មនុស្សដែលធ្វើការ ដូចជាជំនួយការគិលានុបដ្ឋាក
និងស្មៀនហាងលក់គ្រឿងទេស និងអ្នកចូលនិវត្តន៍ចាស់ៗជាងដែលមានប្រាក់ចំណូលថេរ តស៊ូរាល់ខែដើម្បីស្ថិតនៅក្នុងផ្ទះរបស់ពួកគេ។

យើងយ៉ាងសាមញ្ញត្រូវតែបន្ថែមលំនៅដ្ឋានមានសុវត្ថិភាពដែលល្ម
មអាចទិញបានបន្ថែមទៅសម្រាប់ពលរដ្ឋ California ទាំងនេះ—
ហើយថាវាគឺជាអ្វីដែលសំណើប្រជាមតិ 1 នឹងធ្វើ។

បោះឆ្នោតគាំទ្រ លើ សំណើប្រជាមតិ 1 នឹងបន្ថែមលំនៅដ្ឋានដែលមានសុវត្ថិភាពល្មមអាចចំណាយបាន—ដោយមិនបង្កើនពន្ធ

កុំធ្វើឱ្យប្រព្រឹត្តខុស។ សំណើប្រជាមតិ 1 គឺមិនមែនជាពន្ធលើអចលនទ្រព្យ។

$1 ពាន់លានដុល្លារនៃ សំណើប្រជាមតិ 1 គឺត្រូវបានបម្រុងទុកសម្រាប់កម្មីទិញផ្ទះដែលល្មមអាចចំណាយបានសម្រាប់អតីតយុទ្ធជន
និងក្រុមគ្រួសាររបស់ពួកគេ ដែលពួកគេនឹងទូទាត់សងតាមពេល។
ការផ្លាស់កម្មសិទ្ធិនៃ សំណើប្រជាមតិ 1 នឹងត្រូវបានគ្រប់ដណ្តប់ដោយមូលនិធិរដ្ឋដែលមានស្រាប់។

សំណើប្រជាមតិ 1 នឹងអនុញ្ញាតឱ្យ California ផ្តល់អនុភាពមូលនិធិលំនៅដ្ឋានសហព័ន្ធ៖ សឹងតែ $3 ឱ្យផ្ទូផ្ទងរាល់ប្រាក់ដុល្លារនីមួយៗដែលយើងវិនិយោគ ពី សំណើប្រជាមតិ 1។

សំណើប្រជាមតិ 1 នឹងសាងសង់លំនៅដ្ឋាន និងសង្គ្រោះជីវិត

California គឺជាលំនៅដ្ឋានសម្រាប់សឹងតែមួយភាគបួននៃចំនួនប្រជាជ
នគ្មានផ្ទះសម្បែងសរុបរបស់រដ្ឋ ប្រទេសជាតិនិងចំនួនច្រើនបំផុតនៃអតីតយុទ្ធជន និងយុវជនដែលកំពុងប្រឈមនឹងភាពគ្មានផ្ទះសម្បែងតែឯង។
យើងអាចធ្វើឱ្យប្រសើរឡើងបាន។

សំណើប្រជាមតិ 1 នឹងជួយសម្រាលវិបត្តិនៃភាពគ្មានផ្ទះសម្បែង ហើយនឹងផ្តល់ឱ្យអតីតយុទ្ធជនរបស់យើងនូវការចូលទៅកាន់ផ្ទះដែលមានសុវត្ថិភាពល្មមអាចទិញបាន។

បោះឆ្នោតគាំទ្រលើ សំណើប្រជាមតិ 1 ដើម្បីដោះស្រាយវិបត្តិលំនៅដ្ឋានដ៏ធំធេងរបស់ Californiaនិងជួយធានាថា ផ្ទះដែលមានសុវត្ថិភាពល្មមអាចទិញបាន
គឺនៅក្នុងការរកបានសម្រាប់ពលរដ្ឋ California ទាំងអស់។

KATHY MOORE, នាយកប្រតិបត្តិ
ភាពជាដៃគូ California ដើម្បីបញ្ចប់អំពើហិង្សាក្នុងគ្រួសារ
DEBORAH JOHNSON, ប្រធាន
មូលដ្ឋានគ្រឹះជំនួយអតីតយុទ្ធជន California
JENNIFER HARK DIETZ, LCSW, នាយកប្រតិបត្តិ
មនុស្សដែលជួយអ្នកគ្មានផ្ទះសម្បែង (PATH)

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

សំណើប្រជាមតិ 2 អនុញ្ញាតឲ្យប្រើប័ណ្ណកម្ចីផ្តល់មូលនិធិដល់កម្មវិធីជំនួយលំនៅដ្ឋានដែលមានស្រាប់សម្រាប់បុគ្គលដែលមានជំងឺផ្លូវចិត្ត។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — **បានរៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័រ'រដ្ឋលេខាធិការនៅ *http://voterguide.sos.ca.gov*។

- ផ្តល់សច្ចាប័នច្បាប់ដែលមានស្រាប់ បង្កើតកម្មវិធី No Place Like Home ដែលផ្តល់ហិរញ្ញប្បទានដល់ផ្ទះអចិន្ត្រៃយ៍សម្រាប់បុគ្គលដែលមានជំងឺផ្លូវចិត្ត ដែលគ្មានផ្ទះសម្បែង ឬស្ថិតក្នុង ហានិភ័យសម្រាប់ភាពគ្មានផ្ទះសម្បែងរ៉ាំរ៉ៃស្របទៅនឹងច្បាប់ Mental Services Health Services Act ដែលត្រូវបានអនុម័តដោយអង្គអ្នកបោះឆ្នោត។
- ផ្តល់សច្ចាប័នលើកាចេញមូលធនប័ត្រដែលមានទឹកប្រាក់រហូតដល់ $2 ពាន់លានដុល្លារ ក្នុងប័ណ្ណកម្ចីដែលបានអនុម័តពីមុន ដើម្បីផ្តល់ហិរញ្ញប្បទានដល់កម្មវិធី No Place Like Home។
- កែប្រែច្បាប់ Mental Services Health Services Actដើម្បីផ្តល់សិទ្ធិផ្ទេរប្រាក់រហូតដល់ $140 លានដុល្លារ ជារៀងរាល់ឆ្នាំ ពីមូលនិធិសេវាសុខភាពផ្លូវចិត្ត ដែលមានស្រាប់ទៅកាន់កម្មវិធី No Place Like Home ដែលគ្មាន ការតម្លើងពន្ធឡើយ។

សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់ការវិភាគអង្គនិតិបញ្ញត្តិនៃរដ្ឋសុទ្ធនិងផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលក្នុងតំបន់៖

- អនុញ្ញាតឱ្យរដ្ឋប្រើដល់ទៅ $140 លានដុល្លារ ក្នុងមួយឆ្នាំនៃមូលនិធិសុខភាពផ្លូវចិត្តខោនធីដើម្បីសងដល់ទៅ $2 ពាន់លានដុល្លារក្នុងប័ណ្ណកម្ចី។ ប័ណ្ណកម្ចីទាំងនេះនឹងផ្តល់មូលនិធិដល់លំនៅ ដ្ឋានសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្តដែលគ្មានផ្ទះសម្បែង។

ការបោះឆ្នោតចុងក្រោយដឹកនាំដោយអង្គនីតិបញ្ញត្តិនៅ ច្បាប់រដ្ឋសភា (Assembly Bill, AB) 1827 (សំណើប្រជាមតិ 2) (ជំពូក 41, លក្ខន្តិកៈឆ្នាំ 2018)

ព្រឹទ្ធសភា៖	**បាទ/ចាស 35**	**ទេ 0**
រដ្ឋសភា៖	**បាទ/ចាស 72**	**ទេ 1**

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

ខោនធីសេវាសុខភាពផ្លូវចិត្ត។ ខោនធីមានទំនួលខុសត្រូវចម្បងសម្រាប់ការផ្តល់ការថែទាំសុខភាពផ្លូវចិត្តសម្រាប់អ្នកដែលខ្វះការធានារ៉ាប់រងឯកជន។ ខោនធីផ្តល់ការព្យាបាលផ្លូវចិត្ត ប្រឹក្សាព្យាបាលនៅមន្ទីរពេទ្យ និងសេវាសុខភាពផ្លូវចិត្តផ្សេងទៀត។ ខោនធីខ្លះក៏រៀបចំជំនួយពីរប្រភេទផ្សេងគ្នាសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្ត— ដូចជាលំនៅដ្ឋាន ការព្យាបាលការរំលោភបំពានសារធាតុញៀន និងសេវាកម្មការងារ។

ក្រមសេវាសុខភាពផ្លូវចិត្ត។ ក្នុងឆ្នាំ 2004, អ្នកបោះឆ្នោត California បានអនុម័ត សំណើប្រជាមតិ 63, ក៏បានស្គាល់ថាជាក្រមសេវាសុខភាពផ្លូវចិត្ត។ ក្រមផ្តល់មូលនិធិសម្រាប់សេវាសុខភាពផ្លូវចិត្តខោនធីផ្សេងៗដោយបង្កើនពន្ធលើប្រាក់ចំណូលដែលបានបង់ដោយអ្នកដែលមានចំណូលលើសពី $1 លានដុល្លារ។ ពន្ធលើប្រាក់ចំណូលកើនឡើងពី $1.5 ពាន់លានដល់ $2.5 ពាន់លានដុល្លារ ក្នុងមួយឆ្នាំ។

កម្មវិធីគ្មានកន្លែងណាដូចជាលំនៅដ្ឋាន (No Place Like Home) ។ កាលពីឆ្នាំ 2016 អង្គនីតិបញ្ញត្តិបានបង្កើតកម្មវិធីគ្មានកន្លែងណាដូចជាលំនៅដ្ឋាន ដើម្បីកសាងលំនៅដ្ឋានស្តារនីតិសម្បទាសម្រាប់អ្នកដែលមានជំងឺផ្លូវចិត្តដែលគ្មានលំនៅដ្ឋាន ឬហានិភ័យនៃការគ្មានលំនៅដ្ឋាន។ គម្រោងរដ្ឋដើម្បីចំណាយសម្រាប់លំនៅដ្ឋាននៅដោយខ្ចីដល់ទៅ $2 ពាន់លានដុល្លារ។ រដ្ឋអាចខ្ចីប្រាក់នេះដោយការល

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ **បន្ត**

ក់ប័ណ្ណកម្ចី ដែលអាចសងវិញជាមួយការប្រាក់ជាង 30 ឆ្នាំ ដោយប្រើប្រាក់ចំណូលពីក្រមសេវាសុខភាពផ្លូវចិត្ត។ នេះមានន័យថាមូលនិធិតុចអាចរកបានសម្រាប់សេវាសុខភាពផ្លូវចិត្តខ្ពស់ធ្ងន់ធ្ងរ ជាងនេះ។ មូលនិធិក្រមសេវាសុខភាពផ្លូវចិត្តមិនលើសពី $140 លានដុល្លារអាចត្រូវប្រើសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានក្នុងឆ្នាំណាមួយ។ ការបង់ថ្លៃប័ណ្ណកម្ចីអាចប្រហែលជា $120 លានដុល្លារឆ្នាំធម្មតា។

តម្រូវការអនុម័តតុលាការសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋាន។
មុនពេលអាចលក់ប័ណ្ណកម្ចីទាំងនេះ រដ្ឋត្រូវតែស្នើឱ្យតុលាការអនុម័តគម្រោងរបស់រដ្ឋដើម្បីបង់ថ្លៃគ្មានកន្លែងណាដូចជាលំនៅដ្ឋាន។ តុលាការត្រូវតែសម្រេចបញ្ហារសំខាន់ពីរ៖

- ថាតើការប្រើដុល្លារក្រមសេវាសុខភាពផ្លូវចិត្តដើម្បីបង់ថ្លៃគ្មានកន្លែងណាដូចជាលំនៅដ្ឋានជាមួយអ្វីដែលអ្នកបោះឆ្នោតចង់បានពេលពួកគេបានអនុម័តក្រមសេវាសុខភាពផ្លូវចិត្ត។
- ថាតើអ្នកបោះឆ្នោតត្រូវការអនុម័តប័ណ្ណកម្ចីគ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ (រដ្ឋធម្មនុញ្ញរដ្ឋតម្រូវឱ្យអ្នកបោះឆ្នោតអនុម័តលើប្រភេទខ្ចីប្រាក់រដ្ឋមួយចំនួន។)

ការសម្រេចចិត្តតុលាការនេះគឺកំពុងរង់ចាំ។

សេចក្តីស្នើច្បាប់

វិធានការអនុញ្ញាតឱ្យរដ្ឋវនុវត្តគ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ ជាពិសេស វិធានការ៖

- ***អនុម័តការប្រើមូលនិធិសេវាសុខភាពផ្លូវចិត្តសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។*** វិធានការនិយាយថាមូលនិធិសេវាសុខភាពផ្លូវចិត្តអាចបានសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ មូលនិធិក្រមសេវាសុខភាពផ្លូវចិត្តមិនលើសពី $140 លានដុល្លារអាចត្រូវប្រើសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានក្នុងឆ្នាំណាមួយ។
- ***អនុញ្ញាតការខ្ចី $2 ពាន់លានដុល្លារ។*** វិធានការអនុញ្ញាតឱ្យរដ្ឋលក់ប័ណ្ណកម្ចីដល់ទៅ $2 ពាន់លានដុល្លារសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ ប័ណ្ណកម្ចី នឹងត្រូវបង់ថ្លៃជាច្រើនឆ្នាំជាមួយមូលនិធិក្រមសេវាសុខភាពផ្លូវចិត្ត។

ជាមួយវិធានការនេះ រដ្ឋនឹងមិនត្រូវការការអនុម័តរបស់តុលាការទៀតលើបញ្ហាបានពិភាក្សាខាងលើដើម្បីអនុវត្តកម្មវិធីគ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។

ឥទ្ធិពលនៃសារពើពន្ធ

ឥទ្ធិពលលើសារពើពន្ធអាស្រ័យលើការសម្រេចចិត្តតុលាការ។ ឥទ្ធិពលលើសារពើពន្ធនៃវិធានការដោយអាស្រ័យថាតើ ឬតុលាការបានអនុម័តគម្រោងរបស់រដ្ឋដើម្បីបង់ថ្លៃសម្រាប់គ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ ប្រសិនបើតុលាការបានអនុម័តគម្រោងរបស់រដ្ឋ វិធានការមិនមានឥទ្ធិពលលើសារពើពន្ធតិចតួច។ នេះព្រោះរដ្ឋនឹងបានទៅមុខជាមួយគ្មានកន្លែងណាដូចជាលំនៅដ្ឋានទេនៅគ្រប់ករណី ។ ប្រសិនបើតុលាការបានបដិសេធគម្រោងរបស់រដ្ឋ រដ្ឋនឹងមិនអាចទៅមុខជាមួយគ្មានកន្លែងណាដូចជាលំនៅដ្ឋានទេ។ វិធានការនឹងអនុញ្ញាតនឹងអនុញ្ញាតឱ្យរដ្ឋធ្វើដូចនេះ។

ចូលមើល http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/ **សម្រាប់បញ្ជីនៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីចូលប្រើអ្នករួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មាធិការ។**

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 2 ★

គាំទ្រ សំណើប្រជាមតិ 2 ផ្តល់នូវដំណោះស្រាយដ៏ល្អប្រសើរ ដើម្បីជួយដល់ពលរដ្ឋដែលងាយរងគ្រោះបំផុត និងគ្មានផ្ទះសម្បែងនៅក្នុងរដ្ឋ California។ សំណើប្រជាមតិ 2 សាងសង់លំនៅដ្ឋាន និងផ្តល់សេវាសុខភាពផ្លូវសតិសម្រាប់ពលរដ្ឋ-ជាគន្លឹះក្នុងការកាត់បន្ថយភាពគ្មានផ្ទះសម្បែងដែលបង្កភាពស្មុគស្មាញដោយសារជំងឺផ្លូវសតិ។

ពលរដ្ឋជាង 134,000 នាក់កំពុងតែរស់នៅតាមដងផ្លូវ ប្រមូលផ្ទុំគ្នានៅលើចិញ្ចើមថ្នល់ ដេកនៅតាមផ្លូវជាតិ និងតាមដងស្ទឹង។ មួយភាគបីនៃពលរដ្ឋដែលរស់នៅក្នុងស្ថានភាពគ្មានសុវត្ថិភាពទាំងនេះ កំពុងរស់នៅជាមួយជំងឺផ្លូវសតិដែលមិនបានព្យាបាល។

ជារៀងរាល់ឆ្នាំ ពលរដ្ឋរាប់រយនាក់ដែលរស់នៅជាមួយជំងឺផ្លូវសតិធ្ងន់ធ្ងរ បានស្លាប់នៅក្នុងការភាពឈឺចាប់ និងភាពឯកោ។ ការស្លាប់ទាំងនេះអាចទប់ស្កាត់បាន។

សំណើប្រជាមតិ 2 ដោះស្រាយវិបត្តិសុខភាពសាធារណៈដែលកំពុងញាំញីភូមិដ្ឋានបស់យើង អាជីវកម្មរបស់យើង ក្រុមពន្លត់អគ្គិភ័យ និងសេវាសង្គ្រោះបន្ទាន់របស់យើង។ វាបន្តផ្តល់អារម្មណ៍ជាសហគមន៍សម្រាប់យើង ហើយផ្តោតលើការជួយសង្គ្រោះជីវិតអ្នកដែលងាយរងគ្រោះបំផុតក្នុងចំណោមពួកយើង។

គ្មានទីកន្លែងណាដូចផ្ទះទេ

គាំទ្រសំណើប្រជាមតិ 2 មានន័យថាការសាងសង់លំនៅដ្ឋានគាំទ្រអចិន្ត្រៃយ៍ចំនួន 20,000 នៅក្រោមកម្មវិធី "គ្មានទីកន្លែងណាដូចផ្ទះទេ" ។ វាអនុញ្ញាតឱ្យមានការថែទាំដោយមានការសម្របសម្រួលផ្នែកសុខភាពផ្លូវសតិ និងសេវាប្រើប្រាស់សារធាតុញៀន ការថែទាំសុខភាព អ្នកគ្រប់គ្រងសំណុំរឿង ការអប់រំ និងបណ្តុះបណ្តាលការងារ ដើម្បីជួយពលរដ្ឋឱ្យទទួលបានការព្យាបាល និងស្ថិរភាពលំនៅដ្ឋានដែលពួកគេត្រូវការ។

ការស្រាវជ្រាវជាច្រើនទសវត្សរ៍បង្ហាញថា ការផ្តល់ទីកន្លែងមានស្ថិរភាពដល់មនុស្សដើម្បីរស់នៅ រួមជាមួយនឹងសេវាសុខភាពផ្លូវសតិ បានលើកកម្ពស់សុខភាព និងការរស់នៅដោយស្មើភាព។ ការសម្របសម្រួលនៃការផ្តល់ជូនទាំងនេះត្រូវបានគេស្គាល់ថាជាកលំនៅដ្ឋានគាំទ្រជាអចិន្ត្រៃយ៍ ការសិក្សាបង្ហាញថា ការផ្តល់លំនៅដ្ឋានគាំទ្រនេះកាត់បន្ថយយ៉ាងសំខាន់ដល់ការចំណាយលើសុខភាពសាធារណៈ និងកាត់បន្ថយជំងឺ។

ការពង្រឹងភាពជាដៃគូដើម្បីជួយដល់ពលរដ្ឋដែលត្រូវការជំនួយ

គាំទ្រសំណើប្រជាមតិ 2 នឹងជួយបង្កើត និងពង្រឹងភាពជាដៃគូរវាងវេជ្ជបណ្ឌិត ការអនុវត្តច្បាប់ សុខភាពផ្លូវសតិ និងអ្នកផ្តល់សេវាដល់ពលរដ្ឋដែលគ្មានផ្ទះសម្បែង ដើម្បីជួយធានាថាការគាំពារដែលត្រូវបានសម្របសម្រួល និងរៀបចំឡើងដើម្បីបំពេញតាមតម្រូវការរបស់ពលរដ្ឋម្នាក់ៗដែលទទួលរងជំងឺផ្លូវសតិ និងភាពគ្មានផ្ទះសម្បែង ឬអ្នកដែលមានហានិភ័យខ្ពស់នៃភាពគ្មានផ្ទះសម្បែង។

បើគ្មានមូលដ្ឋានគ្រឹះនៃផ្ទះសម្បែងដែលមានស្ថេរភាពមួយ ដែលផ្សារភ្ជាប់ទៅនឹងសុខភាពផ្លូវសតិទេនោះទេ ពលរដ្ឋដែលមានជំងឺផ្លូវចិត្តធ្ងន់ធ្ងរមិនអាចធ្វើការណាត់ជួបជាមួយវេជ្ជបណ្ឌិត និងស្វែងរកសេវាប្រឹក្សាយោបល់ឯកទេសបានឡើយ ដែលជាញឹកញាប់ពួកគេមកដល់ក្នុងបន្ទប់សង្គ្រោះបន្ទាន់ជាជម្រើសចុងក្រោយ។

"ជំងឺផ្លូវសតិមិនចាំបាច់ជាទោសទណ្ឌនៃភាពអស់សង្ឃឹម និងភាពមិនប្រក្រតីអស់មួយជីវិតឡើយ។ លំនៅដ្ឋានគាំទ្រផ្តល់នូវស្ថិរភាពដែលពលរដ្ឋត្រូវការ នៅពេលពួកគេជាឡើងវិញពីជំងឺផ្លូវសតិធ្ងន់ធ្ងរដែលមិនបានព្យាបាល។ វាជួយឱ្យពួកគេឱ្យឈប់រស់នៅតាមផ្លូវ ហើយរស់នៅជាមួយសេចក្តីថ្លៃថ្នូរ។"-*Darrell Steinberg អ្នកនិពន្ធច្បាប់ស្តីពីសេវាសុខភាពផ្លូវសតិ។*

សំណើប្រជាមតិ 2 មិនមែនជាពន្ធទេ

សំណើប្រជាមតិ 2 មិននាំមកនូវការចំណាយលៃដល់អ្នកបង់ពន្ធទេយើងគ្រាន់តែត្រូវការការយល់ព្រមពីអ្នកបោះឆ្នោតដើម្បីរកដំណោះស្រាយងាយស្រួល ហើយផ្តោតលើការកសាងលំនៅដ្ឋានគាំទ្រសម្រាប់អ្នកដែលគ្មានផ្ទះសម្បែង និងត្រូវការសេវាសុខភាពផ្លូវសតិ។ ការផ្តល់ថវិការបស់រដ្ឋនេះត្រូវបានកំណត់ទុកជាយូរមកហើយសម្រាប់ប្រភេទសេវាសុខភាពផ្លូវសតិដែលមានឯកទេស និងសេវាកម្មលំនៅដ្ឋានទាំងនេះ។

ការជួយពលរដ្ឋដែលទទួលរងជំងឺផ្លូវសតិធ្ងន់ធ្ងរ និងភាពគ្មានផ្ទះសម្បែងគឺមិនមែនជាការងាយស្រួលនោះទេ។ ប៉ុន្តែរួមគ្នា យើងអាចជួយទប់ស្កាត់កុំឱ្យមានការស្លាប់កាន់តែច្រើននៅតាមដងផ្លូវរបស់យើង និងផ្តល់ការអន្តរាគមន៍ដ៏សំខាន់ដោយការកសាងលំនៅដ្ឋានគាំទ្រដោយភ្ជាប់មកជាមួយនឹងសេវាព្យាបាល និងថែទាំសុខភាពផ្លូវសតិ។

ចូលរួមជាមួយវេជ្ជបណ្ឌិត អ្នកជំនាញសុខភាពផ្លូវសតិ មន្ត្រីសុវត្ថិភាពសាធារណៈ អ្នកគាំពារសហគមន៍ និងអ្នកគ្មានផ្ទះសម្បែង នឹងពលរដ្ឋជាច្រើនទៀតក្នុងការបោះឆ្នោតគាំទ្រ សំណើប្រជាមតិ 2 ។

ZIMA CREASON ប្រធាន
អង្គការសុខភាពផ្លូវសតិអាមេរិកនៃរដ្ឋ California (MHAC)

CHIEF DAVID SWING ប្រធាន
សមាគមមេបញ្ជាការប៉ូលិសរដ្ឋ California

DR. SERGIO AGUILAR-GAXIOLA អតីតសមាជិក
ក្រុមប្រឹក្សាសុខភាពផ្លូវសតិប្រឹក្សាយោបល់ជាតិនៃវិទ្យាស្ថានជាតិសុខភាពផ្លូវសតិ

★ការឆ្លើយតបទៅនឹងទឡ្ហីករណ៍ក្នុងការគាំទ្រសំណើប្រជាមតិ 2★

សមាជិកគ្រួសារក្នុងភាពជាដៃគូជាមួយសហគមន៍សុទ្ធចិត្ត ពិតជារស់នៅក្នុងសោកនាដកម្មដូចដែលបានរៀបរាប់ដោយអ្នកដែលគាំទ្រ។ យើងតស៊ូដើម្បីរកការព្យាបាល និងការគាំទ្រលំនៅដ្ឋានសម្រាប់មនុស្សជាទីស្រឡាញ់ដែលត្រូវបានកំណត់គោលដៅដោយសំណើប្រជាមតិនេះ។

យើងគាំទ្រការស្វែងរកជម្រើសល្អអំពីការសាងសង់លំនៅដ្ឋានដើម្បីបញ្ចប់ភាពគ្មានផ្ទះសម្បែង ប៉ុន្តែជំទាស់សំណើប្រជាមតិ2 ព្រោះវាយកប្រាក់រាប់ពាន់លានដុល្លារចេញពីមនុស្សជាទីស្រឡាញ់របស់យើង និងអ្នកអភិវឌ្ឍន៍ដែលផ្តល់រង្វាន់ អ្នកកាន់សញ្ញាបត្រ និងអ្នកការិយាធិបតេយ្ស។ គិតត្រឹមឆ្នាំ 2017 ផ្នែកមួយនៃសំណើប្រជាមតិ 63 ដែលបានកំណត់ដោយខោនធីនីមួយៗដែលមានការចូលរួមពីសហគមន៍ត្រូវតែផ្តល់ថវិកាសាងសង់លំនៅដ្ឋានគាំទ្រសម្រាប់អ្នកដែល *មានជំងឺផ្លូវសតិធ្ងន់ធ្ងរ*។ យើងបានជំទាស់យ៉ាងខ្លាំង ហើយការដកប្រាក់មិនសមហេតុផលរហូតដល់ទៅ $ 5.6 ពាន់លានដុល្លារនៃមូលនិធិព្យាបាលដែលត្រូវការបំផុតសម្រាបប័ណ្ណកម្ចី ($ 140 លាននាក់ជារៀងរាល់ឆ្នាំអស់រយៈពេលសែសិបឆ្នាំ) និងបានផ្តល់ទឹកប្រាក់ $ 100 លានពួកការិយាធិបតេយ្យដែលទទួលសាងសង់លំនៅដ្ឋានរបស់រដ្ឋដែលមិនមិនយល់ពីបញ្ហាប្រឈមរបស់អ្នកដែលរស់នៅជាមួយនឹង *ជំងឺផ្លូវសតិធ្ងន់ធ្ងរ*។

រដ្ឋាភិបាលសហព័ន្ធគំរាមកាត់បន្ថយការផ្តល់មូលនិធិព្យាបាល ដូច្នេះ យើងមិនមានលទ្ធភាពចំណាយមូលនិធិ MHSA ណាមួយដើម្បីដោះស្រាយបញ្ហាឱ្យបានល្អប្រសើរនៅថ្នាក់ខោនធីឡើយ។ ការកាត់បន្ថយមូលនិធិ MHSA ដែលចាំបាច់សម្រាប់ការព្យាបាលនឹងជាកំហុសឆ្គងដ៏ធំធេងនិងរួមចំណែកដល់៖

ការធ្វេសប្រហែសនិងការបាត់បង់ធនធានក្នុងការព្យាបាល។

បណ្តាលឱ្យបុគ្គលកាន់តែច្រើនដែលមាន *ជំងឺផ្លូវសតិធ្ងន់ធ្ងរ និង* បាត់បង់លំនៅដ្ឋានហើយធ្វើឱ្យពួកគេកាន់តែច្រើនថែមទៀតត្រូវជាប់គុក និងរស់នៅតាមដងផ្លូវ។

តាមរយៈការចូលរួមរបស់ភាគីពាក់ព័ន្ធ ខោនធីបានដឹងរួចទៅហើយថាតើកន្លែងណាដែលត្រូវទទួលបានលំនៅដ្ឋានល្អបំផុតសម្រាប់ទទួលបានសេវាកម្មសំខាន់ៗ។ សំណើប្រជាមតិ 2 កាត់បន្ថយការចូលរួមក្នុងមូលដ្ឋាននិងកំណត់ទុកមុននូវតុល្យភាពរវាងការព្យាបាលនិងតម្រូវការលំនៅដ្ឋាន។

ការព្យាបាលទប់ស្កាត់ភាពគ្មានផ្ទះសម្បែង។ បោះឆ្នោត លេខ លើ សំណើប្រជាមតិ 2 ដើម្បីចៀវាងកំហុសដ៏ធ្ងន់ធ្ងរ និងអមនុស្សធម៌!

CHARLES MADISON, ប្រធាន
សម្ព័ន្ធជាតិស្តីពីជំងឺផ្លូវចិត្ត (National Alliance on Mental Illness, NAMI) Contra Costa

GIGI R. CROWDER, L.E., នាយកប្រតិបត្តិ
NAMI Contra Costa

DOUGLAS W. DUNN, ប្រធាន
គណៈកម្មការនីតិប្ញញត្តិ NAMI Contra Costa

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ឍីករណ៍ប្រឆាំងសំណើប្រជាមតិ 2 ★

សូមបោះឆ្នោត "ប្រឆាំង" នឹងច្បាប់ "គ្មានទីកន្លែងណាដូចផ្ទះ" ដែលគួរតែត្រូវបានហៅថា "ច្បាប់ពង្រឹងការិយាធិបតេយ្យ និងអ្នកអភិវឌ្ឍន៍" ពីព្រោះអ្នកទាំងនោះគឺជាក្រុមដែលយើងគិតថានឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងគេបំផុត ខណៈដែលអ្នកមានជំងឺផ្លូវសតិធ្ងន់ធ្ងរកំពុងរងផលប៉ះពាល់។

សមាជិក NAMI Contra Costa ភាគច្រើនជាសមាជិកគ្រួសារដែលមាន "ការប្រថុយប្រថានខ្ពស់" ហេតុនេះហើយបានជាពួកគេគាំពារពលរដ្ឋដែលមាននឹងជំងឺផ្លូវសតិធ្ងន់ធ្ងរ ដែលប្រឆាំងនឹងច្បាប់នេះ។ ជាពិសេសក្នុងលក្ខខណ្ឌនៃការកាត់បន្ថយជំនួយរដ្ឋហត្ថ NPLH គឺ *ធ្វើឱ្យខូចប្រយោជន៍* ដោយសារតែវាបានចំណាយ *ប្រាក់រាប់ពាន់លានដុល្លារ* នៅក្នុងមូលនិធិព្យាបាលដែលសំណើប្រជាមតិអ្នកបោះឆ្នោត 63 គិតដល់ជំងឺផ្លូវសតិយ៉ាងធ្ងន់ធ្ងរកាលពីដប់បួនឆ្នាំមកហើយ។ ប្រសិនបើត្រូវបានអនុម័ត្រ យើងពិតជាមានជំនឿយ៉ាងមុតមាំថា NPLH នឹងធ្វើឱ្យមានភាពគ្មានផ្ទះសម្បែងកាន់តែច្រើន ដោយជម្រុញពលរដ្ឋដែលមានជំងឺមានផ្លូវសតិធ្ងន់ធ្ងរទៅរោគសញ្ញាកាន់តែធ្ងន់ធ្ងរ ដែលអាចបង្កើនចំនួនអ្នករស់នៅតាមដងផ្លូវកាន់តែច្រើន។

សំណើប្រជាមតិ 2 គឺ៖

- *ចំណាយច្រើន-រហូតដល់ $5.6 ពាន់លានដុល្លារ* ($140 លានដុល្លារ x 40 សម្រាប់ប័ណ្ណកម្ចីរយៈពេល 40 ឆ្នាំ) ដើម្បីរៃអង្គាសប្រាក់ $2 ពាន់លានដុល្លារសម្រាប់គម្រោងសាងសង់លំនៅដ្ឋាន។ ថវិកាទាំងនេះនឹងមិនធ្លាក់ទៅលើលំនៅដ្ឋានទាំងអស់ឡើយ ដោយសារពួកប្រជាធិปไตយដែលគាំទ្រតែការិយាធិបតេយ្យពាក់ព័ន្ធការសាងសង់នៅនៅដ្ឋានគម្រោងលំនៅដ្ឋានបានធានារួចហើយថា ទឹកប្រាក់$100 លានដុល្លារ (5% នៃ $2 ពាន់លានដុល្លារ) ដែលត្រូវបានទទួលស្គាល់ថាលើសពីតម្រូវការខ្ពាំងណាស់ក្នុងការអនុវត្តកម្មវិធីនេះ និងបានព្រមព្រៀងរវាងក្រុមពួកគេថានឹងប្រើទឹកប្រាក់ទាំង $140 លានដុល្លារក្នុងមួយឆ្នាំ ជា "ការចំណាយរដ្ឋបាល" ទោះបីពួកគេត្រូវការថវិកានោះ ដើម្បីសងប័ណ្ណកម្ចីឬមិនត្រូវការក៏ដោយ។ ការឧបត្ថម្ភធនសម្រាប់អ្នកអភិវឌ្ឍន៍ (ប្រាក់កម្ចីភាគហ៊ុនពន្យារពេលការប្រាក់ទាបដែលអ្នកអភិវឌ្ឍន៍នឹងប្រើប្រាស់ដើម្បីសាងសង់ និងទិញលំនៅដ្ឋាននៅរដ្ឋ Californiaដែលមានទឹកប្រាក់2 ពាន់លានដុល្លាររួមទាំងការឧបត្ថម្ភធនប្រតិបត្តិការរហូតដល់ 50%) មានប្រសិទ្ធភាពក្នុងការចំណាយសាធារណៈកាន់តែច្រើន។
- *មិនចាំបាច់ទេ* ព្រោះអង្គនីតិប្បញ្ញត្តិបានអនុញ្ញាតឱ្យចំណាយសម្រាប់ការសាងសង់លំនៅដ្ឋានសម្រាប់អតិថិជនពលរដ្ឋដែលមានជំងឺផ្លូវសតិធ្ងន់ធ្ងររបស់ខ្លួនក្នុងសំណើប្រជាមតិ 63 2017 ក្នុង AB 727 ។ ខោនធីដែលអាចប្រមូលថវិកាមូលធននៃច្បាប់ស្តីពីសេវាសុខភាពផ្លូវសតិរហូតដល់ទៅដប់ឆ្នាំ ហើយឥឡូវនេះអាច "ចំណាយ" ទាំងការសាងសង់លំនៅដ្ឋាន និងការបង់ប្រាក់ការឧបត្ថម្ភធនជួលសម្រាប់ពលរដ្ឋទាំងនេះ។ ខោនធីទាំងនោះមិនចាំបាច់ចំណាយប្រាក់ *រាប់ពាន់លានដុល្លារ* លើការប្រាក់ប័ណ្ណកម្ចីការចំណាយរដ្ឋបាលដែលមិនចាំបាច់ និងការឧបត្ថម្ភធនរបស់អ្នកអភិវឌ្ឍន៍ក្នុងការធ្វើដូច្នេះទេ។ ខោនធីទាំងនោះដឹងពីការព្យាបាលជំងឺផ្លូវសតិរបស់ពលរដ្ឋរបស់ពួកគេ និងតម្រូវការផ្សេងទៀតព្រមទាំងលំនៅដ្ឋានដែលមានរួចហើយ។ មានតែពួកគេប៉ុណ្ណោះដែលអាចកំណត់ថាតើថវិកា MHSA របស់ពួកគេត្រូវបានគេប្រើប្រាស់យ៉ាងដូចម្តេចដើម្បីចំណាយសម្រាប់ព្យាបាល ឬកសាងលំនៅដ្ឋាននៅក្នុងតំបន់របស់ពួកគេ។
- *មិនមានអ្វី* ត្រូវដោះស្រាយឧបសគ្គផ្នែកច្បាប់ជាប្រព័ន្ធទេ ដូចជាការការពាររបស់រដ្ឋដែលមានកម្រិតប្រឆាំងនឹងការកំណត់តំបន់ដែលរឹតត្បិតដែលធ្វើឱ្យមានការលំបាកក្នុងការសាងសង់លំនៅដ្ឋានគាំទ្រសម្រាប់ក្រុមដូចជាក្រុមដែលមានជំងឺផ្លូវសតិធ្ងន់ធ្ងរជាដើម។ អ្នកជ្រើតខាងជារឿយៗខំប្រឹងតស៊ូណាស់ដើម្បីកុំឱ្យពួកគេចាកចេញ។ វាជាការមិនសមហេតុផលឡើយក្នុងការចំណាយប្រាក់រាប់ពាន់លានលើការប្រាក់និងការចំណាយដើម្បីខ្ចីប្រាក់ដែលយកមកទុកចោលដោយសារតែការជំទាស់នៅមូលដ្ឋានចំពោះគម្រោងលំនៅដ្ឋានគាំទ្រដែលមានអ្នកជួលជាអ្នកដែលមានជំងឺផ្លូវសតិធ្ងន់ធ្ងរនោះ។

អ្នកបោះឆ្នោតដែលបានគាំទ្រសំណើប្រជាមតិ63
ខ្ចីប្រាក់ដើម្បីព្យាបាលដែល *ទប់ស្កាត់* ភាពគ្មានផ្ទះសម្បែងក្នុងឆ្នាំ 2004 ។
នោះហើយជាកន្លែងដែលវាគួរតែធ្វើ។

CHARLES MADISON, ប្រធាន
NAMI Contra Costa

GIGI R. CROWDER, L.E., នាយកប្រតិបត្តិ
NAMI Contra Costa

DOUGLAS W. DUNN, ប្រធាន
គណៈកម្មការនីតិប្បញ្ញត្តិ **NAMI Contra Costa**

★ការឆ្លើយតបទៅនឹងទឡ្ឍីករណ៍ប្រឆាំងនឹងសំណើប្រជាមតិ 2★

ជំងឺផ្លូវសតិមានផលប៉ះពាល់ដល់គ្រួសារជាច្រើន។
នៅពេលដែលមិនបានព្យាបាល វាក៏អាចប្រជែងធ្ងន់ធ្ងរជាមួយសហគមន៍ Californiaក្នុងទម្រង់នៃភាពគ្មានផ្ទះសម្បែង។

ការគ្មានផ្ទះសម្បែងធ្វើឱ្យជំងឺផ្លូវសតិកាន់តែធ្ងន់ធ្ងរ ធ្វើឱ្យការព្យាបាលកាន់តែពិបាកសម្រាប់អ្នកដែលមានតម្លៃការដ៏ធំបំផុត។ ពលរដ្ឋដែលរស់នៅតាមដងផ្លូវ នៅតាមមាត់ទ្វារ និងសួនច្បារ ត្រូវការជំនួយឥឡូវនេះ។ នោះហើយជាមូលហេតុលដែលសំណើប្រជាមតិ2 គឺមានសារៈសំខាន់ខ្លាំងណាស់។

គាំទ្រនៅសំណើប្រជាមតិ 2 នឹងជួយដោះស្រាយភាពគ្មានផ្ទះសម្បែង-និងសន្សំសំចៃប្រាក់

សំណើប្រជាមតិ 2 បង្កើតលំនៅដ្ឋានមានសុវត្ថិភាពដែលភ្ជាប់នឹងការព្យាបាលសុខភាពផ្លូវសតិនិងការព្យាបាលការញៀនថ្នាំ។

សំណើប្រជាមតិ2 ពង្រឹងភាពជាដៃគូរវាងវេជ្ជបណ្ឌិត ការអនុវត្តច្បាប់ និងអ្នកផ្តល់សេវាកម្មដល់អ្នកដែលគ្មានផ្ទះសម្បែងដែលប្រឈមនឹងឧបសគ្គនៃការថែទាំប្រកបដោយប្រសិទ្ធភាពចំពោះអ្នកដែលមានជំងឺផ្លូវសតិ និងការប្រើប្រាស់សារធាតុញៀន។

សំណើប្រជាមតិ2 នាំមកនូវការមិនចំណាយដល់អ្នកជាប់ពន្ធ។ ផ្ទុយទៅវិញ វារុករកដំណោះស្រាយងាយស្រួល ដូច្នេះសហគមន៍អាចប្រើថវិកាដែលមានស្រាប់ដើម្បីដោះស្រាយបញ្ហាបន្ទាន់នៃភាពគ្មានផ្ទះសម្បែងនៅពេលឥឡូវនេះ។

ការសិក្សាបង្ហាញថា សំណើប្រជាមតិ 2 នឹងជួយអ្នកដែលគ្មានផ្ទះសម្បែងជាបន្តបន្ទាប់ដែលរស់នៅជាមួយជំងឺផ្លូវសតិធ្ងន់ធ្ងរឱ្យអស់ពីតាមដងផ្លូវ។

ការសិក្សាឆ្នាំ 2018 របស់ RAND បានរកឃើញថា វិធីសាស្ត្រនៃសំណើប្រជាមតិ2នេះចាប់ផ្តើមទទួលបានជោគជ័យនៅក្នុងខោនធី Los Angeles បន្ទាប់ពីរយៈពេលតែមួយឆ្នាំគត់:

- *ពលរដ្ឋដែលគ្មានផ្ទះសម្បែង 3,500 នាក់ឈប់រស់នៅ* តាមផ្លូវ
- *96%* នៃអ្នកចូលរួមក្នុងការសិក្សា *បានចូលរួមក្នុងកម្មវិធី* យ៉ាងហោចណាស់មួយឆ្នាំ
- *អ្នកបង់ពន្ធសន្សំប្រាក់បានជាង $6.5 លានដុល្លារ* ក្នុងរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ
- *អ្នកចូលរួមបានទស្សនា បន្ទប់សង្គ្រោះបន្ទាន់ (Emergency Room, ER) 70% តិចជាង* សន្សំសំចៃប្រាក់លើការចំណាយលើការថែទាំសុខភាព និងបន្ថយបន្ទុកលើអ្នកឆ្លើយតបគ្រោះអាសន្ន

ស្វែងយល់បន្ថែម សូមចូលទៅមើល *CAYesonProp2.org* ។

បោះឆ្នោតគាំទ្រសំណើប្រជាមតិ2: ផ្តល់លំនៅដ្ឋានដែលមានសុវត្ថិភាពនិងគាំទ្រសម្រាប់អ្នកគ្មានផ្ទះសម្បែង និងសេវាកម្មសម្រាប់អ្នកដែលគ្មានផ្ទះសម្បែងដែល បង្ហាញដើម្បីជួយដល់អ្នកដែលមានជំងឺផ្លូវសតិនៅតាមដងផ្លូវ។

DR. AIMEE MOULIN, ប្រធាន
ជំពូក **California**នៃមហាវិទ្យាល័យអាមេរិកនៃគ្រូពេទ្យសង្គ្រោះបន្ទាន់

BRIAN K. RICE, ប្រធាន
ភ្នាក់ងារពន្លត់អគ្គិភ័យអាជីពនៅ**California**

JANLEE WONG, MSW, នាយកប្រតិបត្តិ
សមាគមជាតិនៃបុគ្គលិកការងារសង្គមកិច្ច- ជំពូក **Californa**

ទឡ្ឍីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

សំណើប្រជាមតិ

3 អនុញ្ញាតឱ្យប្រើប័ណ្ណកម្ចីដើម្បីផ្តល់ថវិកាដល់គម្រោងសម្រាប់ការផ្គត់ផ្គង់ទឹក និងគុណភាពទឹក ទីជម្រាល ធនធានត្រី សត្វព្រៃ លំហូរទឹក ព្រមទាំងនិរន្តរភាពទឹកក្រោមដី និងការស្តុកទុក។ លក្ខន្តិកៈផ្តួចផ្តើម។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — បានរៀបចំដោយអគ្គមេធាវី

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័ររដ្ឋលេខាធិការនៅ *http://voterguide.sos.ca.gov*។

- អនុញ្ញាតឱ្យប្រើប័ណ្ណកម្ចីកាតព្វកិច្ចទូទៅរបស់រដ្ឋចំនួន $8.877 ពាន់លានដុល្លារ សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន $3.03 ពាន់លានដុល្លារសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងគុណភាពទឹក $2.895 ពាន់លានដុល្លារសម្រាប់ការលើកកំពស់ទីកជម្រាល និងធនធានជលផល $940 លានដុល្លារ សម្រាប់ការការពារទីជម្រក$855 លានដុល្លារ សម្រាប់ការបញ្ជូនលំហូរទឹក និង $685 លានដុល្លារ សម្រាប់និរន្តរភាពទឹកក្រោមដី / ការស្តុកទុក និង $472 លានដុលារសម្រាប់ការជួសជុលហាងស្តុកទឹក/ទំនប់ទឹក។
- អនុឬទានប្រាក់ពីមូលនិធិទូទៅ ដើម្បីសងប័ណ្ណកម្ចី។
- តម្រូវឱ្យមានគម្រោងមួយចំនួនដើម្បីផ្តល់មូលនិធិដែលផ្ទ្ផ្ទង់ពីប្រភពក្រៅពីរដ្ឋ។ ផ្តល់អាទិភាពដល់សហគមន៍ក្រីក្រ។

សេចក្តីសង្ខេបនៃការប៉ាន់ប្រមាណរបស់ការវិភាគអង្គនិតិបញ្ញត្តិនៃរដ្ឋសុទ្ធ និងផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលក្នុងតំបន់ៈ

- ការចំណាយរបស់រដ្ឋកើនឡើងដើម្បីសងប័ណ្ណកម្ចី ដែលជាមធ្យមប្រហែល $430 លានដុល្លារក្នុងមួយឆ្នាំ ក្នុងរយៈពេល 40 ឆ្នាំខាងមុខ។
- ប្រាក់សន្សំរបស់រដ្ឋាភិបាលមូលដ្ឋាន ដែលទំនងមានចំនួនជាមធ្យម ពីរ-បីរយលានដុល្លារក្នុងមួយឆ្នាំ ក្នុងរយៈពេលពីរ-បីទសវត្សរ៍ខាងមុខនេះ។

ការប៉ាន់ស្មានចំណាយលើប័ណ្ណកម្ចីរបស់រដ្ឋ	
បានអនុញ្ញាតលើការខ្ចីថ្មី	$8.9 ពាន់លានដុល្លារ
ថ្លៃប្រចាំឆ្នាំជាមធ្យម សម្រាប់បង់សងប័ណ្ណកម្ចី	$430 លានដុល្លារ
អំឡុងពេលនៃការសងវិញទំនងជា	40 ឆ្នាំ
ប្រភពនៃការសងវិញ	ចំណូលពន្ធដែលរកឃើញជាទូទៅ

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

ពលរដ្ឋ California ទទួលបានទឹកពីប្រភពជាច្រើន។ ទឹកភាគច្រើនដែលប្រើសម្រាប់ផឹក និងធ្វើកសិកម្មនៅរដ្ឋ California បានមកពីទឹកភ្លៀង និងការរលាយព្រិល។ ទឹកភ្លៀង និងព្រិលរលាយហូរចូលទៅក្នុងស្ទឹង បឹង និងទន្លេដែលភាគច្រើនមានប្រភពចេញមកពីភ្នំ។ តំបន់ដែលជាប្រភពរបស់ស្ទឹង បឹង និងទន្លេទាំងនេះត្រូវបានចាត់ទុកថាជា "ទីជម្រាល"។ រដ្ឋ California បានសាងសង់ទំនប់ អាងស្តុកទឹក និងប្រឡាយនានាដើម្បីរក្សាទឹក និងបញ្ជូនទឹកនៅជុំវិញរដ្ឋ។ ទឹកត្រូវបានបូមចេញពីក្រោមដី (ដែលគេហៅថា "ទឹកក្រោមដី") ជាពិសេសក្នុងឆ្នាំដែលស្ងួតដែលមិនមានភ្លៀង និងព្រិលធ្លាក់ច្រើន។ មួយចំណែកតូចមួយនៃទឹករបស់រដ្ឋបានមកពីប្រភពផ្សេងទៀត ដូចជាការសម្អាត និងប្រើឡើងវិញនូវទឹកសំណល់ដែលគ្រួសារ និងអាជីវកម្មបង្ហូរចូលទៅក្នុងលូ (ដែលគេហៅថាជា "ការកែឆ្នៃទឹក") ។

ការចំណាយលើទឹកភាគច្រើនគឺធ្វើឡើងដោយរដ្ឋាភិបាលមូលដ្ឋាន។ ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន-ជាទូទៅទីភ្នាក់ងារទឹករបស់សង្កាត់ ក្រុង និងខោនធី-ផ្តល់មូលនិធិដល់គម្រោងភាគច្រើនដែលផ្តល់ទឹកស្អាតសម្រាប់ប្រជាជនទទួលទាន ផ្គត់ផ្គង់ទឹកសម្រាប់ការងារកសិកម្ម និងការពារសហគមន៍ពីទឹកជំនន់។ ទីភ្នាក់ងារទាំងនេះចំណាយប្រាក់ប្រហែល $25 ពាន់លានដុល្លារជារៀងរាល់ឆ្នាំ លើប្រភេទនៃសកម្មភាពដែលពាក់ព័ន្ធនឹងទឹកទាំងនេះ។ ប្រជាពលរដ្ឋបង់ថ្លៃមួយផ្នែកធំលើការចំណាយនេះ នៅពេលដែលពួកគេបង់វិក័យប័ត្រទឹក និងទឹកសម្ពុយ។

រដ្ឋក៏ចំណាយលើទឹកដែរ ព្រមទាំងគម្រោងបរិស្ថានផ្សេងៗ។ រដ្ឋផ្តល់ប្រាក់ជំនួយ និងប្រាក់កម្ចីដល់ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋានដើម្បីជួយចំណាយផ្នែកខ្លះនៃគម្រោងទឹករបស់ពួកគេ។ រដ្ឋក៏ចំណាយលើគម្រោងកែលម្អបរិស្ថានធម្មជាតិ រួមទាំងការការពារទីជម្រកត្រី បក្សី និងសត្វព្រៃផ្សេងៗទៀត។ ក្នុងករណីជាច្រើន រដ្ឋជាជាងរដ្ឋាភិបាលមូលដ្ឋានផ្តល់ថវិកាភាគច្រើន សម្រាប់គម្រោងបរិសានទាំងនេះ។ ពេលខ្លះនាយកដ្ឋានរបស់រដ្ឋអនុវត្តគម្រោងបរិស្ថានដោយខ្លួនឯង ហើយពេលខ្លះពួកគេផ្តល់ប្រាក់ជំនួយដល់រដ្ឋាភិបាលមូលដ្ឋាន អង្គការមិនស្វែងរកប្រាក់ចំណេញ និងអង្គការផ្សេងទៀតសម្រាប់គម្រោងទាំងនេះ។ នៅប៉ុន្មានឆ្នាំថ្មីៗនេះ រដ្ឋបានចំណាយថវិកាប្រហែល $4 ពាន់លានដុល្លារក្នុងមួយឆ្នាំ ដើម្បីគាំទ្រគម្រោងទឹកស្អាត និងបរិស្ថាន។

ប័ណ្ណកម្ចីដែលអនុម័តដោយអ្នកបោះឆ្នោតគឺជាប្រភពទូទៅមួយនៃការផ្តល់មូលនិធិរបស់រដ្ឋសម្រាប់គម្រោងទាំងនេះ។ រដ្ឋច្រើនតែប្រើប័ណ្ណកម្ចីកាតព្វកិច្ចទូទៅ និងមូលនិធិទូទៅរបស់រដ្ឋដើម្បីទូទាត់គម្រោងទឹក និងបរិស្ថាន។ ប័ណ្ណកម្ចីកាតព្វកិច្ចទូ

ទៅគឺជាវិធីមួយដើម្បីខ្ចីប្រាក់។ អ្នកបោះឆ្នោតផ្តល់ការអនុញ្ញាតដល់រដ្ឋដើម្បីលក់ប័ណ្ណកម្ចីដល់អ្នកវិនិយោគ ហើយរដ្ឋនេះប្រើប្រាស់ប្រាក់នោះជាថវិកាបុរេប្រទានសម្រាប់គម្រោង។ បន្ទាប់មករដ្ឋនឹងសងទៅអ្នកវិនិយោគវិញរួមទាំងការប្រាក់ ជាបណ្តើរៗ ដោយប្រើមូលនិធិទូទៅ - គណនីប្រតិបត្តិការមេរបស់រដ្ឋ ដែលមូលនិធិនេះក៏ត្រូវចំណាយសម្រាប់ការអប់រំ ពន្ធនាគារ ការថែទាំសុខភាព និងសេវាផ្សេងៗទៀត។ (សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើប័ណ្ណកម្ចីរបស់រដ្ឋ សូមមើល "ទិដ្ឋភាពទូទៅនៃបំណុលប័ណ្ណកម្ចីរបស់រដ្ឋ" នៅផ្នែកខាងក្រោយក្នុងមគ្គុទេសក៍នេះ។)

ចាប់តាំងពីឆ្នាំ 2000 មក អ្នកបោះឆ្នោតបានអនុម័តប័ណ្ណកម្ចីកាតព្វកិច្ចទូទៅ ប្រមាណ $31 ពាន់លានដុល្លារ នៅក្នុងការបោះឆ្នោតទូទាំងរដ្ឋ ដើម្បីចំណាយលើប្រភេទផ្សេងៗនៃគម្រោងទឹក និងបរិស្ថាន។ នៅមានទឹកប្រាក់ប្រហែលមួយភាគបីនៃចំនួនទឹកប្រាក់នេះ សម្រាប់ទូទាត់គម្រោងថ្មីៗ គិតត្រឹមខែមិថុនា ឆ្នាំ 2018 ។ នេះរួមបញ្ចូលទាំងថវិកាចំនួន $4 ពាន់លានដុល្លារ ដែលត្រូវបានអនុម័តដោយអ្នកបោះឆ្នោតតាមរយៈសំណើប្រជាមតិលេខ 68 នៅក្នុងខែមិថុនា ឆ្នាំ 2018 ។

សេចក្ដីស្នើច្បាប់

ប័ណ្ណកម្ចីចំនួន 8.9 ពាន់លានដុល្លារសម្រាប់គម្រោងទឹក និងបរិស្ថាន។ សំណើប្រជាមតិនេះអនុញ្ញាតឱ្យរដ្ឋលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅថ្មីចំនួន $8.9 ពាន់លានដុល្លារ សម្រាប់គម្រោងទឹក និងបរិស្ថាននានា។ មូលនិធិទាំងនេះស្ថិតក្នុងប្រភេទធំៗចំនួនប្រាំមួយដូចបានបង្ហាញក្នុងរូបទី 1 ។

នៅក្នុងប្រភេទធំៗទាំងនេះ សំណើប្រជាមតិនេះរួមបញ្ចូលប្រភេទរងចំនួនប្រហែល 100 សម្រាប់របៀបដែលត្រូវចំណាយថវិកាក្នុងចំនួនជាក់លាក់ទៅលើគោលដៅជាក់លាក់ណាមួយរបស់រដ្ឋ ឬលើគម្រោងជាក់លាក់។ ប្រភេទចំណាយធំៗនៃសំណើប្រជាមតិនេះរួមមាន៖

- ***ដីតំបន់ជម្រាល ($2.5 ពាន់លានដុល្លារ)។*** ប្រភេទនេះផ្តល់ថវិកាដល់គម្រោងនានា ដើម្បីកែលម្អស្ថានភាពដីនៅតំបន់ទីជម្រាល ដែលរួមមានព្រៃឈើ វាលស្មៅ តំបន់ដីសើម និងតំបន់ដែលនៅជិតទន្លេ។ គម្រោងដែលទទួលបានថវិកាត្រូវតែការពារ ឬលើកកម្ពស់ការផ្គត់ផ្គង់ និងគុណភាពទឹកដែលបានមកពីតំបន់ទាំងនេះ។ គម្រោងជាច្រើនក្នុងចំណោមគម្រោងទាំងនេះនឹងមានអត្ថប្រយោជន៍ផ្នែកបរិស្ថាន ដូចជាការកែលម្អជម្រកសម្រាប់ត្រី និងសត្វព្រៃ ឬបន្ថយហានិភ័យនៃការឆេះព្រៃ។ ប្រភេទថវិកានេះរួមបញ្ចូលទាំងប្រភេទរងចំនួនប្រហែល 50 ដែលមានតម្រូវការពិសេស រួមទាំងការចំណាយក្នុងចំនួនជាក់លាក់នៅក្នុងតំបន់ជាក់លាក់របស់រដ្ឋ។ ឧទាហរណ៍ សំណើប្រជាមតិនេះផ្តល់ថវិកាចំនួន 250 លានដុល្លារសម្រាប់ព្រៃឈើនៅក្នុងភ្នំ Sierra Nevada និង $200 លានដុល្លារសម្រាប់សមុទ្រ Salton នៅរដ្ឋ California ភាគខាងត្បូង។
- ***ការផ្គត់ផ្គង់ទឹក ($2.1 ពាន់លានដុល្លារ) ។*** ថវិកានេះគឺសម្រាប់គម្រោងដែលនឹងបង្កើនបរិមាណទឹកដែលអាចរកបានសម្រាប់ប្រជាជនប្រើប្រាស់។ វារួមបញ្ចូលទាំងថវិកាសម្រាប់ការប្រមូល និងសម្អាតទឹកភ្លៀង ($550 លានដុល្លារ) ការសម្អាតទឹកផឹក ($500 លានដុល្លារ) និងការកែច្នៃទឹកសំណល់ ($400 លានដុល្លារ) ។ សំ

រូបភាពលេខ 1

ការប្រើប្រាស់មូលនិធិប័ណ្ណកម្ចីសំណើប្រជាមតិលេខ 3
(ខ្នង់លាន)

ប្រភេទ	សកម្មភាពចម្បង	ចំនួន
តំបន់ទីជម្រាល	ការពារ ស្តារ និងលើកកម្ពស់សុខភាពនៃទីជម្រាលក្នុងតំបន់ជាក់លាក់របស់រដ្ឋដើម្បីបង្កើនបរិមាណ និងគុណភាពទឹក។	$2,495
ការផ្គត់ផ្គង់ទឹក	កែលម្អ និងបង្កើន៖ ការផ្គត់ផ្គង់ទឹកស្អាត និងប្រព្រឹត្តកម្មទឹកសំណល់ ការកែច្នៃទឹក ការប្រមូល និងការសម្អាតទឹកភ្លៀង និងការអភិរក្សទឹក។	2,130
ជម្រកត្រី និងសត្វព្រៃ	កែលម្អជម្រកសម្រាប់ត្រី និងសត្វព្រៃ រួមទាំងការស្តារឡើងវិញនូវស្ទឹង បឹង និងតំបន់ដីសើម ឱ្យស្ថិតក្នុងស្ថានភាពធម្មជាតិកាន់តែប្រសើរ។	1,440
ការកែលម្អបរិក្ខាទឹក	ធ្វើការតភ្ជាប់ និងជួសជុលទំនប់ទឹក ប្រឡាយ និងអាងស្តុកទឹកដែលមានស្រាប់។	1,227
ទឹកក្រោមដី	សម្អាត បញ្ចូលទឹកទៅក្រោមដីវិញ និងគ្រប់គ្រងទឹកក្រោមដី។	1,085
ការការពារទឹកជំនន់	កាត់បន្ថយហានិភ័យទឹកជំនន់ រួមទាំងការពង្រីកតំបន់លិចទឹក និងការជួសជុលអាងស្តុកទឹក។	500
សរុប		**$8,877**

ការវិភាគដោយអ្នកវិភាគច្បាប់

ណើប្រជាមតិនេះក៏ផ្តល់ថវិកាសម្រាប់សកម្មភាពអភិរក្សទឹកដែលបន្ថយបរិមាណប្រើប្រាស់ទឹក ($300 លានដុល្លារ) ផងដែរ។ នេះអាចរួមបញ្ចូលទាំងការចំណាយមួយចំនួនសម្រាប់ប្រជាជនក្នុងការដំឡើងបង្គន់ដែលប្រើទឹកតិច ឬផ្លាស់ប្តូរស្មៅដាំរបស់ពួកគេទៅរុក្ខជាតិដែលប្រើទឹកតិច។

- ***សត្វព្រៃត្រី និងជម្រកសត្វព្រៃ ($1.4 ពាន់លានដុល្លារ)។*** ប្រភេទនេះផ្តល់ថវិកាដល់គម្រោងនានាដើម្បីកែលម្អជម្រកត្រី និងសត្វព្រៃ។ ប្រភេទនៃគម្រោងទាំងនេះអាចរាប់បញ្ចូលទាំងការបង្កើនបរិមាណទឹកដែលហូរទៅតំបន់ដីសើម ឬទន្លេ ក៏ដូចជាការទិញដីគ្មានដីដែលមិនបានអភិវឌ្ឍន៍ ដើម្បីរក្សាវាទុកឱ្យនៅក្នុងស្ថានភាពធម្មជាតិ។ សំណើប្រជាមតិនេះផ្តោតទៅលើការផ្តល់ថវិកាមួយចំនួនសម្រាប់គម្រោង ដើម្បីជួយដល់ប្រភេទសត្វមួយចំនួនរួមទាំងត្រី នៅក្នុងតំបន់ Central Valley ($400 លានដុល្លារ) ត្រីសាល់ម៉ុន និងត្រីទឹកសាប Steelhead ($300 លានដុល្លារ) និងបក្សីដែលផ្លាស់ទី($280 លានដុល្លារ) ។
- ***ការកែលម្អបរិក្ខាទឹក ($1.2 ពាន់លានដុល្លារ)។*** ថវិកានេះសម្រាប់គម្រោងជាក់លាក់ចំនួនបួន ដើម្បីកែលម្អលទ្ធភាពទទួលបានទឹកនៅក្នុងតំបន់មួយចំនួនរបស់រដ្ឋ។ គម្រោងទាំងនេះរួមមាន៖ (1) ការជួសជុលប្រឡាយ Madera និង Friant-Kern ដែលជាកម្មសិទ្ធរបស់សហព័ន្ធនៅក្នុងតំបន់ Central Valley ($750 លានដុល្លារ) (2) ការកសាងប្រឡាយ និងប្រភេទគម្រោងផ្សេងៗទៀតដែលតភ្ជាប់អាងស្តុកទឹកទៅនឹងសហគមន៍ក្នុងតំបន់តំបន់ San Francisco Bay ($250 លានដុល្លារ) (3) ការជួសជុលទំនប់ Oroville ដែលជាកម្មសិទ្ធិរបស់រដ្ឋនៅក្នុងខោនធី Butte ($200 លានដុល្លារ) និង (4) ការធ្វើផែនការកែលម្អសម្រាប់ North Bay Aqueduct ដែលបម្រើដល់ទីក្រុង Solano និងខោនធី Napa ($5 លានដុល្លារអាមេរិក) ។
- ***ទឹកក្រោមដី ($1.1 ពាន់លានដុល្លារ) ។*** ប្រភេទនេះផ្តល់ថវិកាដល់គម្រោងនានាដែលទាក់ទងនឹងការរក្សាទឹកក្រោមដី ដើម្បីធានាថាទឹកក្រោមដីនឹងបន្តមាននៅក្នុងឆ្នាំខាងមុខ។ វារួមបញ្ចូលសកម្មភាពដើម្បីសម្អាតទឹកក្រោមដី ដោយយកសារធាតុអំបិលចេញ ដើម្បីឱ្យវាអាចប្រើបានកាន់តែប្រសើរ ($400 លានដុល្លារ) ។ ថវិកាក៏នឹងត្រូវបានប្រើសម្រាប់គម្រោងដែលជួយឱ្យទឹកជ្រាបចូលទៅក្នុងដីវិញ ដើម្បីឱ្យវាអាចប្រើនៅពេលអនាគត (ដែលគេស្គាល់ថាជា "ការបញ្ចូលទឹកទៅក្រោមដីវិញ") ។
- ***ការការពារទឹកជំនន់ ($500 លានដុល្លារ)*** មូលនិធិនេះគឺសម្រាប់គម្រោងដែលកាត់បន្ថយហានិភ័យពីទឹកជំនន់។ គម្រោងទាំងនេះអាចរួមបញ្ចូលទាមងការពង្រីកតំបន់លិចទឹក (ដែលជាតំបន់លាតសន្ធឹងដ៏ធំសម្រាប់រំដោះទឹកជំនន់ ដោយមិនបង្ករគ្រោះថ្នាក់ច្រើន) និងជួសជុលអាងស្តុកទឹក។ គម្រោងទាំងនេះមួយចំនួននឹងផ្តល់ផលប្រយោជន៍ផ្សេងទៀត ដូចជាការកែលម្អជម្រកត្រី និងសត្វព្រៃ ការបង្កើនការផ្គត់ផ្គង់ទឹក និងការបង្កើនឱកាសកែកម្សាន្ត។ មូលនិធិមួយនេះចំនួនគឺសម្រាប់គម្រោងនៅក្នុងតំបន់ជាក់លាក់របស់រដ្ឋ ដែលរួមមានតំបន់ Central Valley ($200 លានដុល្លារ) និងតំបន់ San Francisco Bay ($200 លានដុល្លារ)។

បែងចែកថវិកាភាគច្រើនត្រូវបានបែងចែកតាមរយៈប្រាក់ជំនួយ។ សំណើប្រជាមតិនេះផ្តល់ថវិកាដល់ដប់ពីរនាយកដ្ឋានផ្សេងៗគ្នារបស់រដ្ឋ។ សំណើប្រជាមតិនេះបានបន្តប្រើថវិកាប័ណ្ណកម្ចីសម្រាប់នាយកដ្ឋានផ្សេងៗគ្នាទាំងនេះ ដែលខុសពីប័ណ្ណកម្ចីផ្នែកទឹក និងបរិស្ថានភាគច្រើន។ នេះមានន័យថារដ្ឋសភានឹងមិនចំណាយថវិកានេះនៅក្នុងថវិកាប្រចាំឆ្នាំរបស់រដ្ឋទេ។ ផ្ទុយទៅវិញ នាយកដ្ឋានទាំងនេះនឹងទទួលបានថវិកាដោយស្វ័យប្រវត្តិ នៅពេលពួកគេត្រៀមខ្លួនរួចរាល់ដើម្បីចំណាយ។ នាយកដ្ឋានទាំងនេះនឹងចំណាយថវិកាមួយចំនួនដើម្បីអនុវត្តគម្រោងដោយខ្លួនឯង។ ទោះជាយ៉ាងណាក៏ដោយ ថវិកាស្ទើរតែទាំងអស់នឹងត្រូវបានផ្តល់ជាជំនួយដល់ទីភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាន កុលសម្ព័ន្ធឥណ្ឌា អង្គការមិនស្វែងរកប្រាក់ចំណេញ និងក្រុមហ៊ុនទឹកឯកជន សម្រាប់គម្រោងជាក់លាក់នានា។ សម្រាប់ប្រភេទរងនៃថវិកាមួយចំនួន - ជាពិសេសប្រភេទដែលទាក់ទងនឹងការបង្កើន ឬការពារការផ្គត់ផ្គង់ទឹក អ្នកទទួលប្រាក់ជំនួយនឹងត្រូវផ្តល់ប្រាក់យ៉ាងហោចណាស់ $1 ដុល្លារពីក្នុងថវិកាមូលដ្ឋានសម្រាប់ $1 ដុល្លារដែលពួកគេទទួលបាន។ ***ផ្តល់ថវិកាដល់ "សហគមន៍*** ដែលជួបការលំបាក"។ សំណើប្រជាមតិនេះមានតម្រូវការជាច្រើនដើម្បីជួយដល់សហគមន៍ដែលជួបការលំបាក (អ្នកដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប) ។ សម្រាប់ប្រភេទរងនៃការចំណាយមួយចំនួន សំណើប្រជាមតិនេះតម្រូវឱ្យធ្វើការចំណាយថវិកាលើគម្រោងដែលផ្តល់អត្ថប្រយោជន៍ដល់សហគមន៍ទាំងនេះ។ ដូចគ្នានេះដែរ ក្នុងករណីជាច្រើន សហគមន៍ដែលជួបការលំបាកដែលទទួលបានប្រាក់ជំនួយ នឹងមិនចាំបាច់បង់ចំណែកនៃការចំណាយដូចដែលបានរៀបរាប់ខាងលើនេះទេ។

ផ្តល់នូវមូលនិធិឧស្ម័នផ្ទះកញ្ចក់ (GHG) សម្រាប់គម្រោងទឹក។ ក្រៅពីប័ណ្ណកម្ចី $8.9 ពាន់លានដុល្លារនេះ សំណើប្រជាមតិក៏ផ្លាស់ប្តូររបៀបដែលរដ្ឋត្រូវចំណាយថវិកាដែលមានស្រាប់មួយចំនួន ទាក់ទងនឹងនិធិ GHGs ។ រដ្ឋបានអនុម័តច្បាប់ដើម្បីកាត់បន្ថយការឡើងកំដៅផែនដី ដោយកំណត់ចំនួននិធិ GHGs ដែលត្រូវបានបញ្ចេញនៅក្នុងរដ្ឋ California។

ការវិភាគដោយអ្នកវិភាគច្បាប់

បន្ត

កិច្ចខិតខំប្រឹងប្រែងទាំងនេះ រួមបញ្ចូលទាំងកម្មវិធី "កំហិតការបំភាយ និង ពាណិជ្ជកម្ម" ដែលតម្រូវឱ្យក្រុមហ៊ុន និងទីភ្នាក់ងាររដ្ឋាភិបាលមួយចំនួនទិញការអនុញ្ញាតពីរដ្ឋដើម្បីបញ្ចេញ GHG ។ កម្មវិធីនេះបណ្តាលឱ្យទីភ្នាក់ងារទឹកមួយចំនួនត្រូវបង់ថ្លៃអគ្គីសនីខ្ពស់ជាងមុន ក្នុងការដំណើរការផ្នែកខ្លះនៃប្រព័ន្ធចែកចាយទឹករបស់ពួកគេ ដូចជាម៉ាស៊ីនបូមទឹក និងរោងចក្រប្រព្រឹត្តកម្មទឹក។ សំណើប្រជាមតិនេះតម្រូវឱ្យផ្តល់ថវិកាមួយផ្នែកដែលរដ្ឋទទួលបានពីការលក់លិខិតអនុញ្ញាតទៅឱ្យទីភ្នាក់ងារទឹកចំនួនបួនគឺក្រសួងធនធានទឹករបស់រដ្ឋ ទីភ្នាក់ងារទឹកក្រុងនៃ California ភាគខាងត្បូង ទីភ្នាក់ងារទឹក Contra Costa Water និងអាជ្ញាធរទឹក San Luis និង Delta Mendota ។ ចំនួនថវិកានេះស្មើនឹងការចំណាយបន្ថែមលើថ្លៃអគ្គិសនីដែលទាក់ទងនឹងកម្មវិធីរបស់រដ្ឋដើម្បីកាត់បន្ថយ GHGs បស់ភ្នាក់ងារនីមួយៗ។ យើងប៉ាន់ប្រមាណថាការចំណាយទាំងនេះអាចមានសរុបរាប់សិបលាន ដុល្លារជារៀងរាល់ឆ្នាំ។ (នៅក្នុងឆ្នាំកន្លងទៅនេះ រដ្ឋបានទទួលថវិកាចំនួន $3 ពាន់លានដុល្លារពីការលក់លិខិតអនុញ្ញាត) ។ ភ្នាក់ងារទាំងនោះត្រូវបានតម្រូវឱ្យចំណាយថវិកាដែលពួកគេទទួលបានលើសកម្មភាពនានាដូចជាកម្មវិធីអភិរក្សទឹកជាដើម។ ដូច្នេះ រដ្ឋនឹងលែងមានថវិកាទាំងនេះដើម្បីចំណាយលើសកម្មភាពផ្សេងទេ។

ផលប៉ះពាល់សារពើពន្ធ

ថ្លៃប័ណ្ណកម្ចីរដ្ឋ។ សំណើប្រជាមតិនេះនឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់ចំនួន $8.9 ពាន់លានដុល្លារ តាមរយៈការលក់ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅបន្ថែមដល់អ្នកវិនិយោគ។ អ្នកវិនិយោគទាំងនេះនឹងត្រូវបានសងរួមទាំងប្រាក់ ដោយប្រើប្រាក់ចំណូលពន្ធរបស់មូលនិធិទូទៅរបស់រដ្ឋ។ ការចំណាយនៃប័ណ្ណកម្ចីនេះអាស្រ័យលើកត្តាផ្សេងៗ ដូចជាអត្រាការប្រាក់នៅពេលលក់ ពេលវេលានៃការលក់ប័ណ្ណកម្ចី និងរយៈពេលដែលត្រូវទូទាត់សង។ យើងប៉ាន់ស្មានថាការចំណាយទៅឱ្យអ្នកបង់ពន្ធរបស់រដ្ឋដើម្បីទូទាត់សងប័ណ្ណកម្ចីនេះនឹងមានទឹកប្រាក់សរុបចំនួន $17.3 ពាន់លានដុល្លារ ដែលត្រូវសងទាំងប្រាក់ដើម ($8.9 ពាន់លានដុល្លារ) និងការប្រាក់ ($8.4 ពាន់លានដុល្លារ) ។ វានឹងនាំឱ្យមានការចំណាយជាមធ្យម **ប្រមាណ $430 លានដុល្លារ ជារៀងរាល់ឆ្នាំ ក្នុងរយៈពេល 40 ឆ្នាំខាងមុខនេះ។** ចំនួននេះគឺប្រហែលមួយភាគបីនៃថវិកា 1 ភាគរយ នៃថវិកាទូទៅបច្ចុប្បន្នរបស់រដ្ឋ។

ចំណាយក្នុងស្រុក និងការសន្សំដើម្បីបញ្ចប់គម្រោង។ ភាគច្រើននៃមូលនិធិប័ណ្ណកម្ចីនេះនឹងត្រូវបានប្រើ សម្រាប់គម្រោងរដ្ឋាភិបាលក្នុងស្រុក។ ការផ្តល់ថវិការបស់រដ្ឋសម្រាប់គម្រោងក្នុងមូលដ្ឋាននឹងមានឥទ្ធិពលលើថវិកាផ្ទាល់ខ្លួនរបស់រដ្ឋាភិបាលមូលដ្ឋានក្នុងការចំណាយលើគម្រោងទាំងនេះ។ ក្នុងករណីជាច្រើន ប័ណ្ណកម្ចីរដ្ឋនឹងកាត់បន្ថយការចំណាយក្នុងមូលដ្ឋាន។ ឧទាហរណ៍ វានឹងកើតឡើងក្នុងករណីដែលប័ណ្ណកម្ចីរដ្ឋបានជំនួសប្រាក់ដែលរដ្ឋាភិបាលក្នុងតំបន់នឹងចំណាយលើគម្រោងនានា។

ទោះយ៉ាងណាក៏ដោយ ក្នុងករណីមួយចំនួន ថវិការដ្ឋអាចបង្កើនការចំណាយសរុបទៅលើគម្រោងដោយរដ្ឋាភិបាលមូលដ្ឋាន។ ឧទាហរណ៍ រដ្ឋាភិបាលមូលដ្ឋានមួយចំនួនអាចនឹងសម្រេចចិត្តសាងសង់គម្រោងបន្ថែម ឬគម្រោងធំជាងមុខខ្លាំង ប្រសិនបើពួកគេមានថវិការដ្ឋ។ ចំពោះគម្រោងទាំងនេះមួយចំនួន - ដូចជានៅពេលដែលប័ណ្ណកម្ចីតម្រូវឱ្យមានចំណែកនៃការចំណាយរបស់រដ្ឋាភិបាលមូលដ្ឋាន - រដ្ឋាភិបាលមូលដ្ឋាននឹងទទួលបានការចំណាយបន្ថែមមួយចំនួន។

នៅលើសមតុល្យ យើងប៉ាន់ប្រមាណថាសំណើប្រជាមតិនេះនឹងនាំឱ្យមានការសន្សំប្រាក់ដល់រដ្ឋាភិបាលមូលដ្ឋានដើម្បីបំពេញគម្រោងដែលទទួលបានការឧបត្ថម្ភពីមូលប័ត្រនេះ។ ការសន្សំទាំងនេះអាចមានជាមធ្យមពីរយលានដុល្លារជារៀងរាល់ឆ្នាំ ក្នុងរយៈពេលពីរបីទសវត្សរ៍ខាងមុខនេះ។ ចំនួនទឹកប្រាក់ពិតប្រាកដនឹងអាស្រ័យលើគម្រោងជាក់លាក់ដែលរដ្ឋាភិបាលមូលដ្ឋានជ្រើសរើស និងចំណែកនៃការចំណាយលើគម្រោងរបស់ពួកគេ។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ សូមចូលទៅ *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីមើលអ្នកផ្តល់វិភាគទានកំពូលចំនួន 10 របស់គណកម្មាធិការនេះ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍ គាំទ្រសំណើប្រជាមតិ 3 ★

សំណើប្រជាមតិ 3 បំពេញសេចក្ដីត្រូវការបន្ទាន់ ដែលសំខាន់របស់រដ្ឋ Californiaដើម្បីធានានូវការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាព អាចទុកចិត្តបាន និងស្អាតដោយ

- **កែលម្អការត្រៀមបម្រុងគ្រោះរាំងស្ងួតរយៈពេលវែង**
- **ផ្ដល់ទឹកពិសារដែលមានសុវត្ថិភាពជូនពលរដ្ឋ California រាប់លាននាក់ រួមមានជាអាទិ៍ ពលរដ្ឋនៅតាមបណ្ដាសហគមន៍ដែលជួបប្រទះការលំបាក**
- **បង្កើនលំហូរច្រោះទឹកពីភ្នំ ដែលយើងអាចត្រងយក និងប្រើប្រាស់បាន**
- **ជួសជុលព្រែកជីកមានស្រាប់ ដែលស្រោចស្រពដំណាំស្បៀងរបស់យើង**
- **ជួសជុលទំនប់ Oroville និងទំនប់ផ្សេងៗដើម្បីរក្សាឲ្យពលរដ្ឋមានសុវត្ថិភាព និងទប់ទឹកបានកាន់តែច្រើន**
- **កែលម្អគុណភាពទឹកនៅក្នុងទឹកក្រោមដី ទន្លេ បឹង និងស្ទឹង**
- **ប្រើប្រាស់ទឹកបន្សុទ្ធដែលបានកែច្នៃឡើងវិញសម្រាប់ឧស្សាហកម្ម និងទេសភាព**

យើងត្រូវតែធានាសុវត្ថិភាពការផ្គត់ផ្គង់ទឹកអនាគតរបស់រដ្ឋយើងដោយការ

វិនិយោគឥតឈប់ឈរនៅក្នុងការអភិរក្សទឹក ការកែច្នៃឡើងវិញ ព្រែកជីក បំពង់នាំប្រេងឬឧស្ម័ន និងសម្ភារៈរូបវន្តស្តុកទឹក។

"California ត្រូវតែត្រៀមខ្លួនសម្រាប់គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ចៀសមិនរួចនៅពេលក្រោយ ដែលនឹងរឹតតែធ្ងន់ធ្ងរឡើងៗដោយសារការប្រែប្រួលអាកាសធាតុ។ សំណើប្រជាមតិ 3 ធ្វើឲ្យរដ្ឋ California ត្រៀមខ្លួនសម្រាប់ការប្រែប្រួលការផ្គត់ផ្គង់ទឹក គុណភាពទឹក និងគ្រោះទឹកជំនន់។ វានិវិនិយោគនៅក្នុងការអភិរក្ស និងការកែច្នៃទឹកឡើងវិញ។"—*Betty Andrews, វិស្វករធនធានទឹក*

"សំណើប្រជាមតិ 3 នឹងកែលម្អគុណភាពទឹកនៅក្នុងមហាសមុទ្រ បឹង ទន្លេ និងស្ទឹងរបស់យើង ហើយការពារជម្រកធម្មជាតិសម្រាប់ត្រី សត្វស្លាប និងសត្វព្រៃនៅរដ្ឋ California ។"—*សាស្ត្រាចារ្យ Peter Moyle, អ្នកវិទ្យាសាស្ត្រជីវិទ្យា*

"គ្រោះមហន្តរាយធម្មជាតិ នឹងធ្វើឲ្យការផ្គត់ផ្គង់ទឹករបស់យើងប្រឈម និងហានិភ័យ។ តាមរយៈការកែលម្អសម្ភារៈរូបវន្តផ្គត់ផ្គង់ទឹករបស់យើង សំណើរប្រជាមតិ 3 នឹងការពារពលរដ្ឋ California ពីការរញ្ជួយដី ភ្លើងឆេះព្រៃ គ្រោះទឹកជំនន់ និងការហូរច្រោះដីពីភ្នំ។ វាក៏នឹងផ្ដល់អត្ថប្រយោជន៍ជាច្រើនផងដែរ រួមមានជាអាទិ៍ ទឹកសម្រាប់ត្រី និងជម្រកសត្វព្រៃ កសិដ្ឋាន ទីក្រុង និងការកម្សាន្ត។"—*David Guy, ភាគខាងជើង California Water Association*

"California ត្រូវតែប្រើប្រាស់ប្រភពទឹកទាំងអស់ដើម្បីការផ្គត់ផ្គង់ទឹកដែលអាចទុកចិត្តបាន និងគុណភាពទឹកដែលប្រសើរឡើង។"—*Charley Wilson, ភាគខាងត្បូង California Water Coalition*

"គុណភាពទឹកនៃទន្លេ បឹង ឆកសមុទ្រ និងមហាសមុទ្ររបស់យើងនឹងត្រូវបានកែលម្អដោយសំណើប្រជាមតិ 3."—*David Lewis, Save The Bay*

"យើងត្រូវតែត្រងយកទឹកភ្លៀង ព្រិល និងប្រើប្រាស់វាសម្រាប់ការផ្គត់ផ្គង់ទឹក និងបញ្ចៀសសំរាមពីការហូរចូលទៅក្នុងទន្លេ និងមហាសមុទ្ទ។"—*Juliana Gonzalez, Ph.D., អ្នករៀបចំផែនការធនធានទឹក*

"ការការពារ និងស្តារទីជម្រាលជួយកែលម្អការផ្គត់ផ្គង់ទឹក និងគុណភាពទឹក។"—*Esther Feldman, Community Conservation Solutions*

"ការខូចខាតពីគ្រោះទឹកជំនន់ និងការហូរច្រោះ នឹងត្រូវបានកាត់បន្ថយ ខណៈដែលស្ទឹង និងទន្លេនឹងត្រូវបានកែលម្អជាមួយនឹងទេសភាព និងផ្លូវដើរពណ៌បៃតង។"—*Ann Riley, Ph.D., អ្នករៀបចំផែនការធនធានទឹក*

"វិធានការនេះនឹងជួយការពារការផ្គង់ផ្គង់ស្បៀងក្នុងស្រុករបស់យើង ដូច្នេះយើងអាចបន្ត្ររីករាយនឹងផ្លែឈើស្រស់ អង្ករ ទឹកដោះគោ និងផលិតផលកសិដ្ឋានផ្សេងៗដែលដាំក្នុងស្រុក។"—*Carol Chandler, អ្នកដាំផ្លែភីចទទឹក*

"សំណើប្រជាមតិ 3 នឹងកែលម្អគុណភាពនៃទីជម្រាលរបស់យើង ដោយជួយការពារភ្លើងឆេះព្រៃដែលមានការអន្តរាយ និងធើ្បងឡើងវិញពីភ្លើងឆេះព្រៃកន្លងមក។"—*Barbara Balen, Mountain Counties Water Resources Association*

"បរិស្ថាន និងសេដ្ឋកិច្ចរដ្ឋ Californiaពឹងផ្អែកទៅលើការផ្គត់ផ្គង់ទឹកដែលស្អាត និងអាចទុកចិត្តបាន។ ហេតុដូច្នេះហើយបណ្ដាអង្គការបរិស្ថាន និងអាជីវកម្មនានាដូចជា សភាពាណិជ្ជកម្មកាលីហ្វញ៉ា, ក្រុមប្រឹក្សាតំបន់ឆ្នេរ, Ducks Unlimited, Silicon Valley Leadership Group, Natural Heritage Institute, និង Valley Industry and Commerce Association គាំទ្រសំណើប្រជាមតិ 3។"—*Alan Zaremberg, សភាពាណិជ្ជកម្ម*

"សត្វព្រៃ និងសហគមន៍រដ្ឋ Californiaពឹងផ្អែកទៅលើទឹកស្អាតដែលអាចទុកចិត្តបាន។ សំណើប្រជាមតិ 3 ផ្ដល់ទឹកពិសាដែលមានសុវត្ថិភាព និងការធ្ងរស្រាលពីគ្រោះរាំងស្ងួតរយៈពេលវែង ដោយសម្អាតតួទឹកកខ្វក់ ស្តារព្រៃឈើ និងតំបន់ដីសើមឡើងវិញ និងកែលម្អទីកន្លែងចិញ្ចឹមត្រី និងជម្រកទឹក។" —*Collin O'Mara, សហព័ន្ធសត្វព្រៃជាតិ*

មណ្ឌលទឹកក្នុងស្រុកគាំទ្រសំណើប្រជាមតិ 3 ពីព្រោះវាផ្ដល់នូវទឹកពិសាដែលមានសុវត្ថិភាព អាចទុកចិត្តបាន និងស្អាត។

បាទ/ចាស៎ លើសំណើប្រជាមតិ 3!

DYAN WHYTE, អ្នកវិទ្យាសាស្ត្រគុណភាពទឹក
JANET SANTOS COBB
California Wildlife Foundation
ROBERTO RAMIREZ, **វិស្វករធនធានទឹក**

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 3 ★

"ធានានូវការផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាព អាចទុកចិត្តបាន និងស្អាត" ទឡ្ហីករណ៍របស់អ្នកគាំទ្រ។ ប៉ុន្តែលុយដែលបានគ្រវែងចោលតាមសំណើដ៏ច្រើន នឹងមិនបង្កើតបាននូវទឹកថ្មីមួយតំណក់ណាឡើយ។

ទឹកថ្មីបានមកពីលើមេឃ—ទឹកភ្លៀងនៅលើដីទំនាប និងព្រិលនៅលើភ្នំ។ វិធីតែម្យ៉ាងគត់ក្នុងការប្រមូល និងស្តុកទឹកភ្លៀង និងព្រិលដែលរលាយគឺ ទំនប់នៅកន្លែងសមស្របនៅលើទន្លេធំៗរបស់យើង។ សំណើប្រជាមតិ 3 មិនផ្ដល់មូលនិធិដល់ទំនប់សូម្បីតែមួយ។

មិនត្រឹមតែប៉ុណ្ណោះទេ ទំនប់ថែមទាំងត្រូវចាក់បំពេញបន្ថិចម្តងៗដោយដីល្បប់ (ថ្ម និងធូលី)។ ឆ្លងកាត់មួយរយៈពេល វាមានសមត្ថភាពស្តុកទឹកកាន់តែតិចទៅៗ ហើយមានគ្រោះថ្នាក់ ប្រសិនបើវាខូច ហើយត្រូវចំណាយពេល និងលុយក្នុងការសម្អាតដីល្បប់ចេញ។ ទំនប់ចាស់ៗមួយចំនួនត្រូវបានកម្ទេចចោលដោយសារតែហេតុផលទាំងនោះ។ សំណើប្រជាមតិ 3 ផ្ដល់លុយដើម្បីសម្អាតដីល្បប់ចេញពីទំនប់មួយ—មួយប៉ុណ្ណោះ។ ផ្នែកផ្សេងៗនៃវិធានការនេះ ហាមប្រាមជាពិសេសទៅលើការប្រើប្រាស់ថវិកាក្នុងការសម្អាតដីល្បប់—ការរឹតត្បិតដែលមិសមហេតុផល ប្រសិនបើយើងកំពុងព្យាយាមស្តុកទឹក។

សំណើប្រជាមតិ 3 អះអាងថានឹងដោះស្រាយបញ្ហាមួយក្នុងចំណោមបញ្ហាធំៗរបស់រដ្ឋ California—កង្វះទឹកដ៏រ៉ាវ៉ៃរបស់យើង។ កុំយល់ច្រឡំ។ គ្មានអ្វីមួយនៅក្នុងវិធានការដែលនឹងសម្រេចកិច្ចការនោះបានឡើយ។ ជាទូទៅ វាគឺជាគ្រោងការណ៍មួយក្នុងការប្រមូលលុយយ៉ាងច្រើនដោយការប្រាក់ពិសេស។

យើង កូនយើង និងចៅយើង នឹងត្រូវសងវា។

JANET S. ROBERTS, ប្រធាន
Central Solano Citizen/Taxpayer Group
ROBERT D. JARVIS, អនុប្រធាន
Central Solano Citizen/Taxpayer Group
MURRAY T. BASS, សមាជិក
Central Solano Citizen/Taxpayer Group

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

អនុញ្ញាតឱ្យប្រើប័ណ្ណកម្ចីដើម្បីផ្តល់ថវិកាដល់គម្រោងសម្រាប់ការផ្គត់ផ្គង់ទឹក និងគុណភាពទឹក ទីជម្រាល ធនធានត្រី សត្វព្រៃ លំហូរទឹក ព្រមទាំងនិរន្តរភាពទឹកក្រោមដី និងការស្តុកទុក។ លក្ខន្តិកៈផ្ទួចផ្ដើម។

★ ទឡ្ហីករណ៍ ប្រឆាំងសំណើប្រជាមតិ 3 ★

តើសំណើប្រជាមតិ 3 មើលទៅដូចជាធ្លាប់ឃើញទេ? វាគួរតែអញ្ជឹង។

យើងបានឃើញវិធានការទាក់ទងនឹងទឹកនៅលើសន្លឹកឆ្នោតខែមិថុនា ដែលមានពាក្យស្រដៀងគ្នានេះ។ តាមពិតទៅ ចាប់តាំងពីឆ្នាំ 1996 មក ធ្លាប់មានវិធានការប័ណ្ណកម្ចី ទូទាំងរដ្ឋចំនួនប្រាំបី ដែលប្រើប្រាស់ប្រាក់ចំពោះបញ្ហាទឹក។ កន្លងមក ចំនួនទឹកប្រាក់សរុបមានជាង 29 ពាន់លាន ដុល្លារ!

តើយើងមានអ្វីខ្លះដើម្បីបង្ហាញសម្រាប់ប្រាក់ទាំងអស់នោះ? គ្មានអ្វីមួយសំខាន់ជាងទឹកសម្រាប់ពួកយើងឡើយ។

California គឺជាវាលខ្សាច់។ បើគ្មានទំនប់ប្រមូលទឹកភ្លៀង និងព្រិលដែលរលាយមកពីភ្នំទេនោះ ក៏គ្មានកសិកម្មយ៉ាងផលនៅ Central Valley ដែរ។ ទីក្រុងនានារបស់យើងប្រហែលជាបំណែកមួយនៃប្រជាជនបច្ចុប្បន្ន។

ទោះមានគ្រោះរាំងស្ងួតមួយទសវត្សរ៍ហើយក៏ដោយ គ្មានមួយសេនណានៃទឹកប្រាក់ $29 ពាន់លាននោះត្រូវបានចំណាយទៅលើការសាងសង់ទំនប់ថ្មីទេ។ បរាជ័យនៃមហន្តរាយយ៉ាងលឿននៅទំនប់ Oroville Dam នៅភាគខាងជើងនៃរដ្ឋ Californiaកាលពីឆ្នាំមុនបង្ហាញថា រដ្ឋនេះពុំបានថែទាំទំនប់ដែលមានស្រាប់របស់ខ្លួនឡើយ។

ជំនួសឲ្យគម្រោងទាំងឡាយដែលនឹងត្រងយក ឬរក្សាទុកនូវភ្លៀងទឹកកកព្រិលដ៏មានតម្លៃដែលរដ្ឋ California ទទួលបាន មន្ត្រីផ្តល់ការប្រាក់ពិសេស និងចាក់ចោលលុយរាប់លានដុល្លារទៅក្នុងសួនច្បារ ផ្លូវដើរឡើងភ្នំ សត្វព្រៃ—ហាក់ដូចជានុយត្រីបន្ដិចបន្ដួចនៅក្នុងទន្លេ Sacramento River—ហើយពុំមែនជាការដោះស្រាយកង្វះខាតទឹករបស់រដ្ឋនោះឡើយ។ ពាក់កណ្ដាលនៃទឹកនៅក្នុងទន្លេ យើងហូរចូលទៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក។

អ្នកនយោបាយបានព្យាយាមបង្ហាញថាពួកគេមានភាពហ្មត់ចត់ចំពោះការអភិរក្សទឹក។ ពួកគេបានអនុម័តច្បាប់ដែលតម្រូវឲ្យទីក្រុងនានាចាត់វិធានការម៉ឹងម៉ាត់ទៅលើអ្នកដែលធ្វើឲ្យទឹករបស់យើងកខ្វក់។ នៅចុងឆ្នាំ 2020 យើងនឹងត្រូវបានកំណត់ឲ្យប្រើប្រាស់ទឹកត្រឹម 55 ហ្គាឡុងសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ សម្រាប់ការប្រើប្រាស់ក្នុងលំនៅដ្ឋាន។ ហើយត្រូវប្រាកដថាយើងទទួលបានសារនេះ ការអនុញ្ញាតធ្លាក់ចុះមកនៅត្រឹម 50 ហ្គាឡុងនៅឆ្នាំ 2030។

តើមានអ្វីកើតឡើងចំពោះដើមឈើ និងទេសភាពរបស់យើង?

ប្រសិនបើអ្នកមិនមានទេសភាពខៀវស្រងាត់នៅក្នុងទីធ្លាអគាររបស់អ្នក ហើយយល់ថាបញ្ហាមិនប៉ះពាល់ដល់អ្នកនោះ សូមបើកចុះទៅតាមផ្លូវ I-5 នៅ San Joaquin Valley។ អ្នកនឹងឃើញផ្ទៃដីទំនេរធំៗ ដែលកសិករពុំមានទឹកដើម្បីរក្សាឲ្យដើមឈើ និងដំណាំរបស់ពួកគេរស់បានទេ។ កសិដ្ឋានដែលចិញ្ចឹមប្រជាជនភាគច្រើនរងការប៉ះទង្គិចពីគោលនយោបាយទឹកដែលជំរុញដោយនយោបាយ និងខ្វះការប្រមើលទុកជាមុន។

តើអ្នកគាំទ្រសំណើប្រជាមតិ 3 ចង់ចំណាយប្រាក់ $8.9 ពាន់លានដោយរបៀបណា? ភាគច្រើនគឺដូចពីមុន។

អ្នកអាចអានសេចក្ដីលម្អិត ប៉ុន្ដែសូមកត់ចំណាំថា—ជាថ្មីម្ដងទៀត—គ្មានមួយសេនណាសម្រាប់ទំនប់ថ្មីឡើយ។ ច្រើនជាង $4 ពាន់លានបន្ដិច—ស្ទើរពាក់កណ្ដាល—នឹងបានទៅ "បណ្ដាសហគមន៍ដែលជួបប្រទះការលំបាក" ដោយគ្មានការពន្យល់ប្រាប់ថាតើពួកគេជានរណា ឬពួកគេនៅឯណាឡើយ។

តោះយើងចូលមកដល់រឿងសំខាន់វិញ។ *តើយើងនឹងត្រូវចំណាយប្រាក់ប៉ុន្មាន?*

អ្នកពូកែគិតលេខប៉ាន់ស្មានថា ការប្រាក់នៅលើប័ណ្ណកម្ចីនឹងកើនឡើងស្ទើរតែពីរដងនៃទឹកប្រាក់សរុបដែលត្រូវទូទាត់សងអ្នកឲ្យខ្ចីវិញ។ ម្យ៉ាងវិញទៀត ការសង "ប្រាក់កម្ចី" ចំនួន $8.9 ពាន់លាន ដុល្លារ នឹងធ្វើឲ្យរដ្ឋត្រូវចំណាយ—ពោលគឺអ្នកជាប់ពន្ធរបស់យើង—ប្រហែល $17.3 ពាន់លាន។ វាមានចំនួនជាមធ្យមប្រហែល $433 លានក្នុងមួយឆ្នាំ សម្រាប់រយៈពេល 40 ឆ្នាំ។ នោះមានន័យថា ពន្ធកាន់តែច្រើនថែមទៀត!

តើយើងចង់ផ្ដល់ជូនអ្នកនយោបាយនូវប្រាក់ $9 ពាន់លានដុល្លារថែមទៀតដើម្បីធ្វើកិច្ចការដដែលៗ ដែលពុំបានផ្ដល់ទឹកមួយតំណក់ដល់ពួកយើងមែនទេ? ចុះលុយដែលចេញពីហោប៉ៅរបស់យើងវិញ?

សូមគិតអំពីវា។ ទេ លើសំណើប្រជាមតិ 3!

JANET S. ROBERTS, ប្រធាន
Central Solano Citizen/Taxpayer Group

ROBERT D. JARVIS, អនុប្រធាន
Central Solano Citizen/Taxpayer Group

MURRAY T. BASS, សមាជិក
Central Solano Citizen/Taxpayer Group

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 3 ★

"សំណើប្រជាមតិ 3 ការពារបណ្ដាសហគមន៍ដែលជួបប្រទះការលំបាក ដោយផ្ដល់មូលនិធិសម្រាប់ទឹកពិសាដែលស្អាត មានសុវត្ថិភាព។ សំណើប្រជាមតិ 3 ផ្ទាស់ទីយើងឲ្យកាន់តែខិតទៅរកការធានាថាពលរដ្ឋ Californiaគ្រប់រូបមានសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានទឹកស្អាត។"
—*Susana de Anda, Community Water Center*

ប័ណ្ណកម្ចីផ្ដល់ហិរញ្ញប្បទានដល់សាលារៀន មន្ទីរពេទ្យ និងទឹកស្អាត ដូចការដែលយើងប្រើទ្រព្យបញ្ចាំដើម្បីទិញផ្ទះដែរ។ ចំណាត់ថ្នាក់ប័ណ្ណកម្ចីរបស់រដ្ឋ Californiaខ្លាំងជាងគេបំផុតប៉ុន្មានឆ្នាំកន្លងមក។ នេះគឺជាពេលវេលាដ៏ល្អក្នុងការវិនិយោគ។

សំណើប្រជាមតិ 3 នឹងជួសជុលទំនប់ Oroville Dam។

"ការស្តារទីជម្រាលតាមភ្នំ និងទីក្រុងរបស់យើង នឹងកែលម្អសមត្ថភាពស្តុកទឹករបស់វា និងគុណភាពទឹកដែលវាផលិត។ នេះគឺជាវិធីគន្លឹះដែលយើងអាចត្រងយកទឹកភ្លៀង ព្រិល ដែលអាចនឹងបាត់បង់។ ពលរដ្ឋគ្រប់រូបចាប់ពីអ្នករស់នៅក្នុងខោនធីតាមជនបទ រហូតដល់អ្នករស់នៅក្នុងទីក្រុងនឹងទទួលអត្ថប្រយោជន៍។"—*Cindy Montanez, TreePeople*

"ភាពសម្បូរណ៍ផ្នែកកសិកម្មរបស់រដ្ឋ Californiaរួមមានជាអាទិ៍ ផ្លែឈើ និងបន្លែស្រស់ ទឹកដោះគោ ទំពាំងបាយជូររបស់យើង ព្រមទាំងដំណាំរាប់រយមុខផ្សេងទៀត ពឹងផ្អែកទៅលើការផ្គត់ផ្គង់ទឹកលើដី និងទឹកក្នុងដីដែលអាចទុកចិត្តបាន និងមានតុល្យភាព។ សំណើប្រជាមតិ 3 នឹងផ្ដល់ការផ្គត់ផ្គង់នោះផង និងការពារបរិស្ថានផង។"—*Joy Sterling, Iron Horse Vineyards*

សំណើប្រជាមតិ 3 ផ្ដល់ទឹកគ្រប់គ្រាន់សម្រាប់គ្រួសារ កសិករលក្ខណៈគ្រួសារ 3 លានគ្រួសារ និងត្រី និងសត្វព្រៃរបស់រដ្ឋ California។

ការប្រែប្រួលអាកាសធាតុនឹងធ្វើឲ្យគ្រោះរាំងស្ងួតដែលចៀសមិនរួចនៅពេលក្រោយកាន់តែធ្ងន់ធ្ងរថែមទៀត។ សំណើប្រជាមតិ 3 ធ្វើឲ្យរដ្ឋ California ត្រៀមខ្លួនសម្រាប់គ្រោះរាំងស្ងួតដោយពុំមានការដំឡើងពន្ធ។

"សំណើប្រជាមតិ 3 បង្កើតការងារល្អទូទាំងរដ្ឋ California ដោយកសាង និងប្រតិបត្តិគម្រោងទឹកដែលត្រូវការខ្លាំងបំផុត។"—*Bill Whitney, អគ្គារដ្ឋ និងក្រុមប្រឹក្សាជំនួញសំណង់ Contra Costa*

សំណើប្រជាមតិ 3 ស្តារទីជម្រាលឡើងវិញ និងកាត់បន្ថយគ្រោះអគ្គីភ័យ។

"យើងដឹងថា California ងាយរងគ្រោះពីគ្រោះរាំងស្ងួតយ៉ាងណា។ ប័ណ្ណកម្ចីធ្វើការវិនិយោគដោយប្រុងប្រយ័ត្នដើម្បីការពារការផ្គត់ផ្គង់ទឹករបស់យើង និងស្តារជម្រកសត្វព្រៃឡើងវិញ។"
—*ព្រឹទ្ធសភា Dianne Feinstein*

បាទ/ចាស៎ លើសំណើប្រជាមតិ 3!

PHIL ANGELIDES, អតីតរតនាករដ្ឋ California

HOWARD PENN
ផែនការនិងសម្ព័ន្ធការអភិរក្ស

JEANNE PINCHA-TULLEY, ប្រធានផ្នែកអគ្គីភ័យ

សំណើប្រជាមតិ

4 អនុញ្ញាតឲ្យប័ណ្ណកម្ចីផ្តល់មូលនិធិដល់ការសាងសង់មន្ទីរពេទ្យ ដែលផ្តល់ការថែទាំសុខភាពដល់កុមារ។ លក្ខន្តិកៈផ្ទួចផ្តើម។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — **រៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះ អាចរកបាននៅលើវ៉ិបសៃយ៍តរបស់រដ្ឋលេខាធិការតាមអាសយដ្ឋាន *http://voterguide.sos.ca.gov*។

- **អនុញ្ញាតចំនួន $1.5 ពាន់លានដុល្លារក្នុងប័ណ្ណកម្ចី ត្រូវបង់សងមកវិញពីមូលនិធិទូទៅរបស់រដ្ឋដើម្បីផ្តល់មូលនិធិសម្រាប់ការសាងសង់ ការពង្រីក ជួលជុលលំអ និងបំពាក់សម្ភារៈមន្ទីរពេទ្យកុមារដែលមានគុណសម្បត្តិគ្រប់គ្រាន់។**
- **កំណត់ 72 ភាគរយនៃមូលនិធិទៅឲ្យមន្ទីរពេទ្យមានគុណសម្បត្តិដែលមិនស្វែងរកប្រាក់ចំណេញឯកជន ដែលផ្តល់សេវាទូលំទូលាយដល់កុមារដែលមានសិទ្ធិទទួលបានកម្មវិធីរដ្ឋាភិបាល និងកុមារដែលមានតម្រូវការសុខភាពពិសេស ដែលមានសិទ្ធិទទួលបានសេវាកម្មកម្មវិធីកុមាររដ្ឋ California (California Children's Services Program), 18 ភាគរយនៃមូលនិធិទៅកាន់មន្ទីរពេទ្យថែទាំកុមារចាំបាច់ទូទៅនៅសាកលវិទ្យាល័យ California, និង 10 ភាគរយ នៃមូលនិធិទៅឲ្យមន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញសាធារណៈ និងឯកជនដែលផ្តល់សេវាដល់កុមារដែលមានសិទ្ធិទទួលបានសេវាសម្រាប់កម្មវិធីកុមាររដ្ឋ California។**

សេចក្តីសង្ខេប ការប៉ាន់ស្មានរបស់អ្នកវិភាគច្បាប់ អំពីផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- **បង្កើនចំណាយនៃការបង់សងប័ណ្ណកម្ចីរដ្ឋ ជាមធ្យម ប្រហែល $80 លានប្រចាំឆ្នាំក្នុងរយៈពេល 35 ឆ្នាំក្រោយ។**

ការប៉ាន់ស្មានថ្លៃប័ណ្ណកម្ចីរដ្ឋ	
បានអនុញ្ញាតនូវការខ្ចីថ្មី	$1.5 ពាន់លានដុល្លារ
ថ្លៃប្រចាំឆ្នាំជាមធ្យម សម្រាប់បង់សងប័ណ្ណកម្ចី	$80 លានដុល្លារ
អំឡុងពេលនៃការសងវិញទំនងជា	35 ឆ្នាំ
ប្រភពនៃការសងវិញ	ចំណូលពន្ធទូទៅ

ការវិភាគដោយអ្នកវិភាគច្បាប់

ជីវប្រវត្តិ

មន្ទីរពេទ្យកុមារ។ ច្បាប់រដ្ឋកំណត់អត្តសញ្ញាណមន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញឯកជនចំនួនប្រាំបី និងកម្មវិធីសម្រាប់កុមារនៅទីតាំងមជ្ឈមណ្ឌលវេជ្ជសាស្ត្រសិក្សារបស់សាកលវិទ្យាល័យ University of California (UC) ថាជា "មន្ទីរពេទ្យកុមារ។" មន្ទីរពេទ្យកុមារផ្តោតលើការព្យាបាលទារក និងកុមារដែលមានជំងឺ ឬរបួសធ្ងន់ធ្ងរ ឬស្ថានភាពសុខភាពរ៉ាំរ៉ៃស្មុគស្មាញ ដែលត្រូវការការថែទាំឯកទេស។ កុមារជាច្រើនដែលទទួលសេវានៅក្នុងមន្ទីរពេទ្យទាំងនេះ សុទ្ធតែមកពីគ្រួសារដែលមានប្រាក់ចំណូលទាប។ មន្ទីរពេទ្យកុមារទទួលមូលនិធិពីប្រភពនានាជាច្រើន។ មួយភាគធំនៃមូលនិធិរបស់មន្ទីរពេទ្យកុមារ បានមកពីកម្មវិធី Medicaid របស់សហព័ន្ធ-រដ្ឋ (ហៅថា Medi-Cal នៅរដ្ឋ California) ដែលផ្តល់ការចេញថ្លៃថែទាំសុខភាពជូនកុមារមានប្រាក់ចំណូលទាបនៅក្នុងរដ្ឋ។ មន្ទីរពេទ្យកុមារក៏ទទួលមូលនិធិពីការចេញថ្លៃធានារ៉ាប់រងសុខភាពលក្ខណៈពាណិជ្ជកម្ម កម្មវិធីចេញថ្លៃថែទាំសុខភាពផ្សេងៗរបស់រដ្ឋាភិបាល និងការផ្តល់វិភាគទានពីឯកជនផងដែរ។

កម្មវិធីសេវាកម្មកុមាររដ្ឋ California (CCS)។ កម្មវិធី CCS គឺជាកម្មវិធីចេញថ្លៃថែទាំសុខភាពថ្នាក់រដ្ឋ-មូលដ្ឋាន ដែលបង់ថ្លៃសម្រាប់ការព្យាបាលឯកទេស និងសេវាផ្សេងៗសម្រាប់កុមារដែលមានស្ថានភាពសុខភាពរ៉ាំរ៉ៃស្មុគស្មាញ រួមមានជាអាទិ៍ កុមារជាច្រើនដែលទទួលការព្យាបាលនៅមន្ទីរពេទ្យកុមារ។ (កុមារភាគច្រើននៅក្នុងកម្មវិធី CCS ក៏ត្រូវបានចុះឈ្មោះនៅក្នុង Medi-Cal ផងដែរ។) រដ្ឋអនុញ្ញាតឲ្យមន្ទីរពេទ្យ និងអ្នកផ្តល់សេវាវេជ្ជសាស្ត្រផ្សេងទៀតទទួលការបង់ថ្លៃសម្រាប់ការព្យាបាលកុមារនៅក្នុងកម្មវិធី CCS។

មន្ទីរពេទ្យផ្សេងទៀតក៏ព្យាបាលកុមារដែរ។ មន្ទីរពេទ្យផ្សេងទៀតនៅរដ្ឋ California ដែលពុំត្រូវបានកំណត់អត្តសញ្ញាណជាពិសេសថាជាមន្ទីរពេទ្យកុមារនៅក្នុងច្បាប់រដ្ឋ ក៏ផ្តោតលើការធ្វើឲ្យមានកម្រិតខុសប្លែកគ្នាទៅលើការថែទាំសុខភាពកុមារផងដែរ។ ឧទាហរណ៍ មន្ទីរពេទ្យមួយចំនួនមានក្រុម ឬមជ្ឈមណ្ឌលដែលមានឯកទេសក្នុងការព្យាបាលកុមារ។ មន្ទីរពេទ្យទាំងនេះ តែងតែទទួលបានការអនុញ្ញាតឲ្យព្យាបាលកុមារនៅក្នុងកម្មវិធី CCS ។

ប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅ។ រដ្ឋខ្ចីប្រាក់ដើម្បីបង់ថ្លៃគម្រោងទុនរយៈពេលវែង ដោយចេញប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅ។ ការបង់សងប័ណ្ណកម្ចីទាំងនេះ ត្រូវបានធានាដោយអំណាចពន្ធជាទូទៅរបស់រដ្ឋ។ រដ្ឋបង់សងប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅពីមូលនិធិទូទៅ ដែលជាគណនីប្រតិបត្តិការចម្បងរបស់រដ្ឋ។ (សម្រាប់ព័ត៌មានបន្ថែមអំពីការប្រើប្រាស់ប័ណ្ណកម្ចីរបស់រដ្ឋ សូមមើល "ទិដ្ឋភាពទូទៅនៃបំណុលប័ណ្ណកម្ចីរបស់រដ្ឋ" បន្ទាប់ទៀតនៅក្នុងមគ្គុទ្ទេសក៍នេះ។)

វិធានការប័ណ្ណកម្ចីរបស់មន្ទីរពេទ្យកុមារពីមុនមក។ ពីមុនមក អ្នកបោះឆ្នោតបានអនុម័តវិធានការពីរទូទាំងរដ្ឋ ដែលអនុញ្ញាតឲ្យរដ្ឋចេញប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅ ដើម្បីបង់ថ្លៃគម្រោងទុននៅមន្ទីរពេទ្យកុមារ។ ប័ណ្ណកម្ចីទាំងនេះត្រូវបានប្រើប្រាស់សម្រាប់គម្រោងផ្សេងៗជាច្រើន រួមមានជាអាទិ៍ ការសាងសង់អគារថ្មីៗ និងការកែលម្អអគារដែលមានស្រាប់។ នៅឆ្នាំ 2004 សំណើប្រជាមតិ 61 បានផ្តល់មូលនិធិ $750 លាន នៅក្នុងប័ណ្ណកម្ចី។ នៅឆ្នាំ 2008 សំណើប្រជាមតិ 3 បានផ្តល់ $980 លាន នៅក្នុងប័ណ្ណកម្ចី។ មានមន្ទីរពេទ្យត្រឹមតែ 13 ប៉ុណ្ណោះ ដែលត្រូវបាន កំណត់អត្តសញ្ញាណជាពិសេសថាជាមន្ទីរពេទ្យកុមារនៅក្នុងច្បាប់រដ្ឋ ដែលមានសិទ្ធិទទួលមូលនិធិក្រោមវិធានការទាំងនេះពីមុនមក។ គិតត្រឹមខែឧសភា ឆ្នាំ 2018 ភាគច្រើននៃការផ្តល់មូលនិធិពីវិធានការពីរពីមុនមក ត្រូវបានប្រើប្រាស់សម្រាប់គម្រោងនានា ដែលមូលនិធិសេសសល់ត្រូវបានរំពឹងថានឹងប្រើប្រាស់ពេញលេញនៅត្រឹមចុងរដូវក្តៅឆ្នាំ 2018។

សំណើ

អនុញ្ញាតប័ណ្ណកម្ចីបន្ថែមសម្រាប់មន្ទីរពេទ្យកុមារ។ វិធានការនេះអនុញ្ញាតឲ្យរដ្ឋលក់ប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅ $1.5 ពាន់លានបន្ថែមទៀតសម្រាប់គម្រោងកែលម្អទុននៅ (1) មន្ទីរពេទ្យកុមារចំនួន 13 និង (2) មន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញសាធារណៈ និងឯកជនផ្សេងទៀត ដែលព្យាបាលកុមារដែលមានសិទ្ធិទទួលបានកម្មវិធី CCS ។ ដូចមានបង្ហាញនៅក្នុងរូបភាពលេខ 1, វិធានការនេះផ្តល់ 72 ភាគរយនៃមូលនិធិប័ណ្ណកម្ចី—ប្រហែល $1.1 ពាន់លាន—ជូនមន្ទីរពេទ្យកុមារមិនស្វែងរកប្រាក់ ចំណែកឯកជនចំនួនប្រាំបី។ មន្ទីរពេទ្យនីមួយៗក្នុងចំណោមមន្ទីរពេទ្យទាំងប្រាំបីនេះ អាចដាក់ពាក្យសុំចំណែកស្មើគ្នានៃមូលនិធិនេះ។ វិធានការនេះផ្តល់ 18 ភាគរយនៃមូលនិធិប័ណ្ណកម្ចី—$270 លាន—

រូបភាពលេខ 1

មន្ទីរពេទ្យដែលមានសិទ្ធិទទួលបានមូលនិធិប័ណ្ណកម្ចី
(ក្នុងចំនួនរាប់លាន)

មន្ទីរពេទ្យកុមារមិនស្វែងរកប្រាក់ចំណេញឯកជន—72 ភាគរយនៃមូលនិធិ	**$1,080**
មន្ទីរពេទ្យកុមារ និងមជ្ឈមណ្ឌលស្រាវជ្រាវ, Oakland	$135
មន្ទីរពេទ្យកុមារ Los Angeles	135
មន្ទីរពេទ្យកុមារខោនធី Orange	135
មន្ទីរពេទ្យកុមារ Earl and Loraine Miller (Long Beach)	135
មន្ទីរពេទ្យកុមារបស់សាកលវិទ្យាល័យ Loma Linda University	135
មន្ទីរពេទ្យកុមារ Lucile Packard នៅ Stanford	135
មន្ទីរពេទ្យកុមារ Rady, San Diego	135
មន្ទីរពេទ្យកុមារ Valley (Madera)	135
មន្ទីរពេទ្យកុមាររបស់សាកលវិទ្យាល័យ University of California—18 ភាគរយនៃមូលនិធិ	**$270**
មន្ទីរពេទ្យកុមារ Mattel នៅសាកលវិទ្យាល័យ University of California, Los Angeles	$54
មន្ទីរពេទ្យកុមាររបស់សាកលវិទ្យាល័យ University of California, Irvine	54
University of California, មន្ទីរពេទ្យកុមារ Davis	54
University of California, មន្ទីរពេទ្យកុមារ San Diego	54
University of California, មន្ទីរពេទ្យកុមារ San Francisco	54
មន្ទីរពេទ្យផ្សេងទៀត—10 ភាគរយនៃមូលនិធិ	**$150**
មន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញសាធារណៈ ឬឯកជនប្រហែល 150 មន្ទីរពេទ្យ ដែលផ្តល់សេវាជូនកុមារដែលមានសិទ្ធិទទួលបានកម្មវិធី សេវាកុមាររដ្ឋ California។	$150
ចំនួនសរុប	**$1,500**

ជូនមន្ទីរពេទ្យកុមារចំនួនប្រាំរបស់ UC ។ មន្ទីរពេទ្យនីមួយៗរបស់ UC អាចដាក់ពាក្យសុំចំណែកស្មើគ្នានៃមូលនិធិនេះ។ វិធានការនេះ ធ្វើឲ្យមានលទ្ធភាពប្រើប្រាស់បាននូវមូលនិធិប័ណ្ណកម្ចី 10 ភាគរយដែលនៅសេសសល់—$150 លាន—ជូនមន្ទីរពេទ្យមិនស្វែងរកប្រាក់ចំណេញសាធារណៈ ឬឯកជនផ្សេងទៀតប្រហែល 150 មន្ទីរពេទ្យ ដែលផ្តល់សេវាជូនកុមារដែលមានសិទ្ធិទទួលបានកម្មវិធី CCS។ វិធានការនេះពុំបែងចែកដោយឡែកនូវចំណែកជាក់លាក់នៃចំណែកនៃមូលនិធិប័ណ្ណកម្ចីនេះសម្រាប់មន្ទីរពេទ្យនីមួយៗឡើយ។

ការប្រើប្រាស់មូលនិធិ។ វិធានការនេះអនុញ្ញាតឲ្យមានការរៃអង្គាសលុយពីការលក់ប័ណ្ណកម្ចី ដែលនឹងត្រូវប្រើសម្រាប់គោលបំណងផ្សេងៗជាច្រើន រួមមានជាអាទិ៍ "ការសាងសង់ ការពង្រីក ការធ្វើម៉ូដែលថ្មី ការកែលម្អ ការបំពាក់គ្រឿងសង្ហារឹម ការបំពាក់គ្រឿងបរិក្ខារ ការផ្តល់ហិរញ្ញប្បទាន ឬការផ្តល់ហិរញ្ញប្បទានសារឡើងវិញ សម្រាប់មន្ទីរពេទ្យដែលមានសិទ្ធិនៅក្នុងរដ្ឋ។" វិធានការនេះ តម្រូវថាមូលនិធិដែលបានផ្តល់ជូន មិនត្រូវលើសពីចំណាយសរុបនៃគម្រោងឡើយ ហើយគម្រោងដែលបានទទួលមូលនិធិត្រូវតែបញ្ចប់នៅក្នុង "រយៈពេលសមស្រប។"

ដំណើរការដាក់ពាក្យសុំ។ មន្ទីរពេទ្យកុមារដែលមានសិទ្ធិទទួលបានមូលនិធិប័ណ្ណកម្ចីក្រោមវិធានការនេះ នឹងដាក់ពាក្យសុំមូលនិធិទៅកាន់អាជ្ញាធរហិរញ្ញប្បទានសម្ភារៈរូបវន្តសុខាភិបាលរដ្ឋ California (CHFFA) ដែលជាទីភ្នាក់ងារមានស្រាប់របស់រដ្ឋ។ CHFFA នឹងសម្រេចថាតើ ត្រូវផ្តល់ជំនួយឥតសំណងដោយផ្អែកលើកត្តាជាច្រើ

នដែរឬយ៉ាងណា។ កត្តាមួយចំនួនទាំងនេះរួមមានជាអាទិ៍ ថាតើ៖

- ជំនួយឥតសំណងនឹងរួមចំណែកឆ្ពោះទៅរកការពង្រីក ឬការកែលម្អលទ្ធភាពទទួលបានការថែទាំសុខភាពសម្រាប់កុមារដែលមានសិទ្ធិទទួលបានកម្មវិធីធានារ៉ាប់រងសុខភាពរដ្ឋាភិបាល ឬអ្នកដែលមានប្រាក់ចំណូលទាបមិនទាន់មាន ឬមិនមានការធានារ៉ាប់រងដែរឬទេ។
- ជំនួយឥតសំណងនឹងរួមចំណែកដល់ការកែលម្អលទ្ធផលនៃការថែទាំសុខភាពកុមារ ឬអ្នកជំងឺដែលជាកុមារដែរឬទេ។
- មន្ទីរពេទ្យដែលដាក់ពាក្យសុំ នឹងលើកកម្ពស់កម្មវិធីបង្រៀន ឬស្រាវជ្រាវវិជ្ជាពេទ្យកុមារដែរឬទេ។

ផលប៉ះពាល់សារពើពន្ធ

ចំណាយបង់សងប័ណ្ណកម្ចីរដ្ឋ។ វិធានការនេះនឹងអនុញ្ញាតឲ្យរដ្ឋខ្ចីប្រាក់ $1.5 ពាន់លាន ដោយលក់ប័ណ្ណកម្ចីកាតព្វកិច្ចជាទូទៅជូនអ្នកវិនិយោគ ដែលនឹងទទួលបានការបង់សងវិញជាការប្រាក់ ដោយប្រើចំណូលពន្ធទូទៅរបស់រដ្ឋ។ ចំណាយនៃប័ណ្ណកម្ចីទាំងនេះ នឹងអាស្រ័យទៅលើកត្តាផ្សេងៗជាច្រើន—ដូចជា អត្រាការប្រាក់ដែលមានប្រសិទ្ធភាពនៅពេលលក់វា ការកំណត់ពេលវេលានៃការលក់ប័ណ្ណកម្ចី និងថេរវេលាដែលត្រូវបង់សងមកវិញ។ យើងប៉ាន់ស្មានថា ចំណាយសម្រាប់អ្នកជាប់ពន្ធក្នុងការបង់សងប័ណ្ណកម្ចីនឹងមានចំនួនសរុប $2.9 ពាន់លាន ដើម្បីបង់ផ្តាច់ប្រាក់ដើម ($1.5 ពាន់លាន) និងការប្រាក់ ($1.4 ពាន់លាន)។ ការនេះនឹងបណ្តាលឲ្យមានចំណាយបង់សងវិញជាមធ្យម **ប្រហែល $80 លាន ប្រចាំឆ្នាំ ក្នុងរយៈពេល 35 ឆ្នាំក្រោយ**។ ចំនួនទឹកប្រាក់នេះតិចជាងមួយភាគដប់នៃ 1 ភាគរយនៃថវិកាមូលនិធិទូទៅបច្ចុប្បន្នរបស់រដ្ឋ។ ចំណាយរដ្ឋបាលដែលបង់ពីមូលនិធិប័ណ្ណកម្ចី នឹងត្រូវបានកំណត់ឲ្យស្មើនឹងចំណាយជាក់ស្តែងរបស់ CHFFAឬ 1 ភាគរយនៃមូលនិធិប័ណ្ណកម្ចីដែលទោះជាយ៉ាងណាគឺតិចជាង។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីទទួលបានអ្នកចូលរួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មាធិការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិលេខ 4 ★

មានមន្ទីរពេទ្យកុមារដែលមិនស្វែងរកប្រាក់ចំណេញនៅ California ចំនួនប្រាំបីនិងមន្ទីរពេទ្យកុមាររបស់សាកលវិទ្យាល័យ California ចំនួនប្រាំ។ *កុមារដែលឈឺធ្ងន់ធ្ងរទទួលបានការព្យាបាលឯកទេសជាន់ខ្ពស់នៅក្នុងមន្ទីរពេទ្យកុមារនៃរដ្ឋ Californiaជាងពីរលានដងក្នុងមួយឆ្នាំ ។ ទោះគ្រួសារអាចបង់ប្រាក់បានប៉ុន្មានក៏ដោយ។*

កុមារដែលមានបញ្ហាសុខភាពស្មុគ្រស្មាញ និងជំងឺគំរាមកំហែងដល់ជីវិត។ មហារីក។ គោលិការាងកណ្ដៀវ។ គីសលើសួត។

យើងធ្វើការបណ្តុះសរីរាង្គកុមារទាំងអ
ស់ 97% វះកាត់បេះដូងកុមារ 96% និង
ព្យាបាលជំងឺមហារីកកុមារទាំងអស់ 76% ។

ជាមួយនឹងការស្រាវជ្រាវរកឃើញថ្មីៗ បច្ចេកវិទ្យាសង្គ្រោះជីវិតថ្មីៗ អ្នកឯកទេសកុមារល្អៗបំផុត ការព្យាបាលកើតឡើងរាល់ថ្ងៃនៅក្នុងមន្ទីរពេទ្យ'កុមារនៃរដ្ឋ California'។ បច្ចុប្បន្ននេះ កុមារ 85% ដែលមានជំងឺមហារីកគ្រាប់ឈាមបានចាកចេញពីមន្ទីរពេទ្យយើងដោយជាសះស្បើយពីជំងឺ។

ក្នុងនាមជាមជ្ឈមណ្ឌលស្រាវជ្រាវកុមារលំដាប់ទីមួយ យើងកំពុងរកឃើញវិធីសាស្ត្រដើម្បីធ្វើឲ្យកុមារគ្រប់រូបនៅ California មានសុខភាពល្អ ដោយមិនចាំបាច់ដើរចូលមន្ទីរពេទ្យរបស់យើង។

ដោយសារតែភាពជោគជ័យរបស់យើង តម្រូវការមកលើពួកយើងក៏រីកចម្រើនផងដែរ។ *យើងបានក្លាយជាមជ្ឈមណ្ឌលប្រចាំតំបន់ ហើយកុមារត្រូវបានបញ្ជូនមកពួកយើងពីមន្ទីរពេទ្យផ្សេងៗទៀតនៅក្នុងរដ្ឋ California ។*

សំណើប្រជាមតិលេខ 4 ស្នើសុំឲ្យអ្នកបោះឆ្នោតពិចារណាលើការវិនិយោគតិចជាង $40 ក្នុងមួយឆ្នាំសម្រាប់អ្នកជំងឺម្នាក់ដែលយើង មើលឃើញ . . . លុយនឹងជួយពួកយើងកសារសមត្ថភាពបានកាន់តែច្រើនដើម្បីព្យាបាលកុមារកាន់តែច្រើននៅ California ។

កាលពី 14 ឆ្នាំមុន ពលរដ្ឋ California បានគាំទ្រប័ណ្ណកម្ចីដំបូងរបស់យើង។ យើងមានកិត្តិយសដែលទទួលបានការទុកចិត្តតាំងពីពេលនោះមក។ ទឹកប្រាក់ទាំងអស់ត្រូវបានចំណាយលើសំណង់អគារថ្មី ការធ្វើឲ្យមានភាពទំនើបឡើងលើអគារចាស់ៗ ការបន្ថែមគ្រែកាន់តែច្រើន និងការទិញបច្ចេកវិទ្យាល្អបំផុត និងទំនើបបំផុត . . . ដើម្បីព្យាបាលកុមារឲ្យបានកាន់តែច្រើន។

ការិយាល័យរតនាគារប្រចាំរដ្ឋគ្រប់គ្រងរាល់ប្រាក់មូលនិធិប័ណ្ណកម្ចី ប៉ុន្តែក៏បានសច្ចារចំពោះមុខគណៈកម្មការសុខាភិបាលនៃព្រឹទ្ធសភា និងសភាថា "កម្មវិធីនេះនឹងមានភាពជោគជ័យយ៉ាងពិសេសផងដែរ។"

យើងមានមោទនភាពចំពោះក្នុងវិជ្ជាជីវៈដែលយើងបានធ្វើ។ ក្នុងនាមជាមនុស្ស យើងមានបុព្វសិទ្ធិក្នុងការមើលឃើញចំណុចខ្លាំងរបស់កុមារស្លូតត្រង់ សេចក្ដីស្រលាញ់នៅក្នុងគ្រួសាររបស់ពួកគេ ការប្ដេជ្ញាចិត្តរបស់បុគ្គលិកយើង ការមានសន្ដានចិត្តល្អរបស់សប្បុរសជន និងភាពជោគជ័យនៅក្នុងស្មារតីរបស់មនុស្ស។

យើងអញ្ជើញអ្នកឲ្យចូលរួមជាមួយអ្នកបោះឆ្នោតរាប់លាននាក់នៅរដ្ឋ California ដែលបានគាំទ្រដល់មន្ទីរពេទ្យកុមារ។

យើងទាំងអស់គ្នាអាចបោះឆ្នោតបាទ/
ចាសដល់សំណើប្រជាមតិលេខ 4—អគារដើម្បីព្យាបាលកុមារកាន់តែច្រើន។

JAMES STEIN, វេជ្ជបណ្ឌិត វះកាត់កុមារ
MARIA MINON, វេជ្ជបណ្ឌិត នាយកបុគ្គលិកសុខាភិបាល
ROBERTO GUGIG, វេជ្ជបណ្ឌិត, ផ្នែកក្រពះពោះវៀនកុមារ

★ ទឡ្ហីករណ៍តបត ដើម្បីគាំទ្រសំណើប្រជាមតិលេខ 4 ★

ជាច្រើនទសវត្សមកហើយ ខ្ញុំបានផ្ដល់ទឡ្ហីករណ៍ប្រឆាំងនឹងវិធានការសន្លឹកឆ្នោត ដើម្បីធានាថា អ្នកបោះឆ្នោតទទួលបានការពិចារណាតបតមួយចំនួន។

ប្រព័ន្ធពន្ធអចលនទ្រព្យដែលមិនត្រឹមត្រូវ

ការជំទាស់មួយទៅនឹងវិធានការណាមួយដែលស្នើសុំដំឡើងពន្ធអចលនទ្រព្យគឺថា ប្រព័ន្ធពលអចលនទ្រព្យនៅក្នុងរដ្ឋ California គឺមិនត្រឹមត្រូវទេ (ដូចមានពន្យល់នៅក្នុងទឡ្ហីករណ៍បឋម)។

ការផ្លាស់ប្ដូរប្រព័ន្ធដើម្បីធ្វើឲ្យវាកាន់តែត្រឹមត្រូវ

ប្រព័ន្ធពន្ធអចលនទ្រព្យរបស់យើងអាចមានការផ្លាស់ប្ដូរ ឧទាហរណ៍ ដើម្បីប៉ាន់ប្រមាណឡើងវិញតាមកាលកំណត់លើអចលនទ្រព្យពិតប្រាកដ ប៉ុន្តែបញ្ចុះអត្រាពន្ធដោយស្វ័យប្រវត្តិ ដើម្បីឲ្យចំណូលពីពន្ធទូទៅមិនកើនឡើងដោយសារតែតម្លៃអចលនទ្រព្យកើនឡើង។

ជាការពិត ការលំបាកមួយក្នុងការធ្វើការផ្លាស់ប្ដូរណាមួយគឺថា មនុស្សផ្សេងគ្នា និងអាជីវកម្មផ្សេងគ្នា មានផលប្រយោជន៍ដាច់ណាត់ផ្សេងគ្នាក្នុងការរក្សាទុកស្ថានភាពដដែល។

ការពិនិត្យមើលកាន់តែទូលំទូលាយលើការកែលម្អការថែទាំសុខភាពចំពោះវិធានការជាក់លាក់នេះ (ការខ្ចីប្រាក់ដើម្បីឧបត្ថម្ភបន្ថែមដល់មន្ទីរពេទ្យកុមារ) ខ្ញុំផ្ដល់យោបល់ថា យើងពិនិត្យមើលការកែលម្អប្រព័ន្ធថែទាំសុខភាពរួមជាមុនសិន។

ទោះបីជាមានអ្នកជំនាញឆ្នើមជាច្រើនផ្ដល់ការថែទាំសុខភាពនៅក្នុងសហរដ្ឋអាមេរិក (និងនៅ California) ក៏ដោយ សហរដ្ឋអាមេរិកបានចំណាយច្រើនបំផុត ប៉ុន្តែស្ថិតឆ្ងាយពីចំណាត់ថ្នាក់កំពូលអន្តរជាតិចំពោះលទ្ធផលថែទាំសុខភាព លើសពីនេះ ពលរដ្ឋ California រាប់លាននាក់មិនមាន សូម្បីតែការគ្របដណ្ដប់លើការថែទាំសុខភាពលំដាប់មូលដ្ឋាន។

ការស្នើសុំបេក្ខជនដែលឈរឈ្មោះដើម្បីការិយាល័យរដ្ឋ ប្រហែលជាបេក្ខជនដែលឈរឈ្មោះសម្រាប់ការិយាល័យរដ្ឋនៅក្នុងខែវិច្ឆិកា—រួមទាំងសម្រាប់តំណែងអភិបាល—មានគំនិតខ្លះ ៗអំពីការកែលម្អលើការថែទាំសុខភាពនៅក្នុងរដ្ឋ California ។ តោះយើងសួរ។

GARY WESLEY

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិលេខ 4 ★

នេះជាវិធានការប័ណ្ណកម្មីកាតព្វកិច្ចទូទៅមួយទៀត។ វាស្នើសុំការអនុញ្ញាតពីអ្នកបោះឆ្នោត ដើម្បីអាចឲ្យរដ្ឋ California ខ្ចីប្រាក់កាន់តែច្រើនតាមរយៈការលក់ "ប័ណ្ណកម្មី" ដែលត្រូវសងជាមួយនឹងការប្រាក់ (*អាចធ្វើឡើងតាមរយៈការបង្កើនពន្ធអចលនទ្រព្យ*) ដែលមានរយៈពេលច្រើនទសវត្ស។

ខ្ញុំនិយាយថា "*អាច*" ព្រោះពេលខ្លះទ្រព្យនៃប័ណ្ណកម្មីត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់ហិរញ្ញប្បទាន ប៉ុន្តែត្រូវបានសងវិញតាមរយៈអ្នកទទួលកម្មវិធី—ដូចជាម្ចាស់ផ្ទះនៅក្រោមកម្មវិធីកម្មីទិញផ្ទះ-កសិដ្ឋាន Cal-Vet កាលពីមុន។

វិធានការប័ណ្ណកម្មីផ្តល់នូវសំណួរជាច្រើន៖

1. តើរដ្ឋាភិបាលជំពាក់ប្រាក់ប៉ុន្មានហើយ?
2. តើការចំណាយសរុបដែលបានរំពឹងទុកពីវិធានការនេះមកលើសាធារណៈមានចំនួនប៉ុន្មាន?
3. តើមានការបញ្ជាក់អំពីការប្រើប្រាស់ប្រាក់ដែលបានស្នើសុំនោះឬទេ?
4. តើការប្រើប្រាស់ដែលបានស្នើសុំត្រូវបានផ្តល់យុត្តិកម្មឬទេ—ដោយបានគិតពិចារណាអំពីកិច្ចការផ្សេងទៀតដែលចាំបាច់ ឬចង់បាន?
5. តើអ្នកបោះឆ្នោតនឹងបន្តផ្តល់ហិរញ្ញប្បទានលើគម្រោងតាមរយៈការបង់ពន្ធអចលនទ្រព្យកាន់តែច្រើនឬទេ នៅពេលប្រព័ន្ធពន្ធអលចនទ្រព្យរបស់រដ្ឋ Californiaមិនមានភាពត្រឹមត្រូវ?

ប្រព័ន្ធពន្ធអចលនទ្រព្យរបស់រដ្ឋ*CALIFORNIA*
មិនមានភាពត្រឹមត្រូវ

កាលពីឆ្នាំ 1978 អ្នកបោះឆ្នោតនៃរដ្ឋ California បានអនុម័តលើការផ្តួចផ្តើមគំនិតរបស់អ្នកបោះឆ្នោត ដែលនៅពេលនោះគេហៅថា សំណើប្រជាមតិលេខ 13។ ការផ្តួចផ្តើមគំនិតបានបន្ថែមមាត្រាទៅលើរដ្ឋធម្មនុញ្ញនៃរដ្ឋ California ដែលបានរារាំងដល់ *"ការវាយតម្លៃឡើងវិញ"* នៃអចលនទ្រព្យ លើកលែងតែ និងរហូតដល់ការផ្លាស់ប្តូរអចលនទ្រព្យមានការផ្តល់ ឬត្រូវបានកសាងឡើងវិញច្រើន។

សំណើប្រជាមតិលេខ 13 បានការពារម្ចាស់អចលនទ្រព្យពីការបង្កើនពន្ធច្រើន ដោយអាស្រ័យលើតម្លៃអចលនទ្រព្យកាន់តែខ្ពស់ ទោះយ៉ាងណា វាក៏បានបង្កើតប្រព័ន្ធមួយដែលម្ចាស់ផ្ទះថ្មី បង់ប្រាក់ 10–20 ដងច្រើនជាង អ្នកជិតខាងដែលមានអចលនទ្រព្យតម្លៃដូចគ្នា ប៉ុន្តែបានទទួលកាន់កាប់ជាយូរមកហើយ។

លើសពីនេះ ដោយហេតុថា អចលនទ្រព្យអាជីវកម្មអាចឬតែងត្រូវបានជួល (ជាជាងលក់) ដូច្នេះសំណើប្រជាមតិលេខ 13 បាននាំឲ្យមានការផ្លាស់ប្តូរយ៉ាងធំទៅលើបន្ទុកពន្ធអចលនទ្រព្យរួម ពីអាជីវកម្មទៅម្ចាស់ផ្ទះ។

អ្នកគាំទ្រសំណើវិធានការសន្លឹកឆ្នោតគួរតែទទួលបន្ទុកក្នុងការពន្យល់អំពីមូលហេតុដែលគួរតែផ្តល់ការគាំទ្រ—ផ្តល់ការចំណាយពេញលេញ ជម្រើសដែលមាន និងតម្រូវការឬការចង់បានផ្សេងទៀត។

ក្នុងករណីនេះ អ្នកស្នើគួរប្រើប្រាស់ការតបតដើម្បីឆ្លើយទៅនឹងសំណួរ 1–5 ខាងលើ។

GARY WESLEY

★ ទឡ្ហីករណ៍តបត ដើម្បីប្រឆាំងសំណើប្រជាមតិលេខ 4 ★

សំណើប្រជាមតិលេខ 4 ជួយកុមារឈឺជាង 2 លាននាក់ជារៀងរាល់ឆ្នាំ។ វាមិនពាក់ព័ន្ធនឹងពន្ធអចលនទ្រព្យ ឬសំណើប្រជាមតិលេខ 13 ទេ។ យើងបានសួរអ្នកជំនាញ ហើយនេះជាអ្វីដែលគេបាននិយាយ ៖

Joe Harn, El Dorado សវនករ-អ្នកគ្រប់គ្រងប្រចាំខោនធី ថ្លែងថា

គ្មានប្រាក់មួយដុល្លារណាសម្រាប់សំណើប្រជាមតិលេខ 4 បានមកពីពន្ធអចលនទ្រព្យទេ។ គ្មានប្រាក់មួយដុល្លារណាសម្រាប់ប័ណ្ណកម្មីមន្ទីរពេទ្យពីមុនណាមួយ បានមកពីពន្ធអចលនទ្រព្យទេ។ រតនាគាររដ្ឋ អ្នកគ្រប់គ្រងរដ្ឋ អ្នកវាយតម្លៃប្រចាំខោនធី ឬអ្នកប្រមូលពន្ធគ្រប់រូប (ទោះនៅក្នុងគណបក្សណាក៏ដោយ) សុទ្ធតែធ្វើសក្ខីយកម្មចំពោះការពិតនេះ។ ខ្ញុំត្រូវបានទទួលស្គាល់ថាជាសវនករ-អ្នកគ្រប់គ្រងដែលអភិរក្សបំផុត និងមានកណ្តាប់ដៃម៉ឺងម៉ាត់បំផុតនៅក្នុងខោនធីនៃរដ្ឋ California ។ អ្នកអាចការពារសំណើប្រជាមតិលេខ 13 និងបោះឆ្នោតគាំទ្រដល់សំណើប្រជាមតិលេខ 4 ។

Jon Coupal, ប្រធានសមាគមអ្នកបង់ពន្ធ **Howard Jarvis** មានប្រសាសន៍ថា

សំណើប្រជាមតិលេខ 13 បានការពារម្ចាស់ផ្ទះអស់រយៈពេលជាង 40 ឆ្នាំមកហើយ។ វិធានការនេះមិនគំរាមកំហែងដល់ការការពារម្ចាស់ផ្ទះនៅរដ្ឋ California ដែលមានលទ្ធភាព ដោយសារតែសំណើប្រជាមតិលេខ 13 ទាល់តែសោះ។

សូមបោះឆ្នោតគាំទ្រសំណើប្រជាមតិលេខ 4 ។

ANN-LOUISE KUHNS, ប្រធាន
សមាគមមន្ទីរពេទ្យកុមារនៃរដ្ឋ California

សំណើប្រជាមតិ

5 ផ្លាស់ប្តូរលក្ខខណ្ឌតម្រូវសម្រាប់ម្ចាស់អចលនទ្រព្យដើម្បីផ្ទេរមូលដ្ឋានពន្ធអចលនទ្រព្យរបស់ពួកគេ ទៅជាអចលនទ្រព្យជំនួស។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ និងលក្ខន្តិក:

ចំណងជើង និងសេចក្តីសង្ខេប — **រៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកបាននៅលើវិបសាយរបស់រដ្ឋលេខាធិការតាមអាសយដ្ឋាន *http://voterguide.sos.ca.gov*។

- លុបបំបាត់តម្រូវការបច្ចុប្បន្ន ដូចខាងក្រោម សម្រាប់ម្ចាស់ផ្ទះដែលមានអាយុលើសពី 55 ឆ្នាំ ឬមានពិការធ្ងន់ធ្ងរ ក្នុងការផ្ទេរមូលដ្ឋានពន្ធអចលនទ្រព្យ របស់ពួកគេទៅកន្លែងស្នាក់នៅជំនួសវិញ៖ អចលនទ្រព្យដែលជំនួសមានតម្លៃស្មើឬតិចជាងលំនៅដ្ឋានជំនួសស្ថិតនៅក្នុងខោនធីជាក់លាក់ ហើយការផ្ទេរនោះកើតឡើងតែម្តងប៉ុណ្ណោះ។
- ដកចេញនូវតម្លៃជំនួសនិងកិច្ចតម្រូវទីតាំងដូចគ្នាចំពោះការផ្ទេរសម្រាប់ទ្រព្យដែលត្រូវកខ្វក់ឬបំផ្លាញដោយគ្រោះមហន្តរាយ។
- តម្រូវឲ្យមានការសម្របសម្រួលលើមូលដ្ឋានពន្ធអចលនទ្រព្យជំនួសអាស្រ័យលើតម្លៃអចលនទ្រព្យថ្មី។

សេចក្តីសង្ខេបរបស់អ្នកវិភាគច្បាប់អំពីការប៉ាន់ស្មាននៃផលប៉ះពាល់សារពើពន្ធរបស់រដ្ឋ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ៖

- សាលារៀន និងរដ្ឋាភិបាលមូលដ្ឋានផ្សេងទៀតប្រហែលជានឹងបាត់បង់ប្រាក់ជាង $100 លានដុល្លារក្នុងមួយឆ្នាំ លើចំណូលពន្ធអចលនទ្រព្យនៅក្នុងពីរឬបីឆ្នាំដំបូង ហើយក្នុងឆ្នាំបន្តបន្ទាប់មានប្រហែល $1 ពាន់លានដុល្លារក្នុងមួយឆ្នាំ (ក្នុងប្រាក់ដុល្លារសព្វថ្ងៃនេះ)។ ការកើនឡើងស្រដៀងគ្នានេះដែរនៅក្នុងការចំណាយរបស់រដ្ឋដើម្បី បំពេញមកវិញនូវការខាតបង់ពន្ធអចលនទ្រព្យសាលា។

ការវិភាគដោយអ្នកវិភាគច្បាប់

ជីវប្រវត្តិ

រដ្ឋាភិបាលក្នុងតំបន់ប្រមូលពន្ធលើម្ចាស់អចលនទ្រព្យ។ រដ្ឋាភិបាលមូលដ្ឋានរដ្ឋ California - ទីក្រុង, ខោនធី, សាលារៀននិងពន្ធមណ្ឌលពិសេស ការប្រមូលពន្ធលើទ្រព្យសម្បត្តិផ្អែកលើតម្លៃទ្រព្យសម្បត្តិរបស់ពួកគេ។ ពន្ធអចលនទ្រព្យគឺជាប្រភពចំណូលធំសម្រាប់រដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលរកបានជាង $60 ពាន់លានដុល្លារក្នុងមួយឆ្នាំ។

ការគណនាវិក្កយបត្រពន្ធទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ។ វិក្កយបត្រពន្ធទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិនីមួយៗគឺស្មើនឹងតម្លៃត្រូវបង់ពន្ធលើអចលនទ្រព្យរបស់ខ្លួន គុណនឹងអត្រាពន្ធ។ ជាធម្មតា អត្រាពន្ធអចលនទ្រព្យរបស់ម្ចាស់កម្មសិទ្ធិគឺ 1.1 ភាគរយ។ នៅក្នុងឆ្នាំដែលអចលនទ្រព្យត្រូវបានទិញ តម្លៃជាប់ពន្ធគឺជាតម្លៃអចលនទ្រព្យនោះ បន្ទាប់ពីនោះ តម្លៃត្រូវបង់ពន្ធអចលនទ្រព្យត្រូវបានកែតម្រូវសម្រាប់អតិផរណារហូតដល់ 2 ភាគរយរាល់ឆ្នាំ។ នេះបន្តរហូតដល់ពេលអចលនទ្រព្យត្រូវបានលក់ហើយម្តងទៀតវាត្រូវបានបង់ពន្ធនូវតម្លៃដែលបានទិញវា។

អ្នកផ្ទាស់ទីលំនៅតែងប្រឈមមុខនឹងសេចក្តីស្នើច្បាប់ដំឡើងពន្ធទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ។ តម្លៃទីផ្សារនៃផ្ទះភាគច្រើន (អ្វីដែលគេអាចលក់បាន) កើនឡើងលឿនជាង 2 ភាគរយក្នុងមួយឆ្នាំ។ នេះមានន័យថា តម្លៃនៃផ្ទះជាប់ពន្ធភាគច្រើនគឺតិចជាងតម្លៃទីផ្សាររបស់វា។ ដោយសារតែហេតុនេះ នៅពេលម្ចាស់ផ្ទះទិញផ្ទះផ្សេង តម្លៃទិញផ្ទះថ្មីតែងលើសពីតម្លៃដែលត្រូវបង់ពន្ធនៃផ្ទះកាលពីមុនរបស់អ្នកទិញ (សូម្បីតែពេលផ្ទះមានតម្លៃទីផ្សារប្រហាក់ប្រហែលគ្នាក៏ដោយ)។ នេះនាំឲ្យតម្លៃពន្ធអចលនទ្រព្យខ្ពស់ជាងមុនសម្រាប់អ្នកទិញផ្ទះ។

ការវិភាគដោយអ្នកវិភាគច្បាប់ បន្ត

វិធានពិសេសសម្រាប់ម្ចាស់ផ្ទះមួយចំនួន។ ក្នុងករណីខ្លះ វិធានពិសេសអនុញ្ញាតឲ្យម្ចាស់ផ្ទះដែលមានផ្ទះស្រាប់ផ្លាស់ទីទៅផ្ទះផ្សេងដោយមិនចាំបាច់បង់ពន្ធអចលនទ្រព្យខ្ពស់ជាងមុន។ វិធានពិសេសទាំងនេះអនុវត្តចំពោះម្ចាស់អចលនទ្រព្យដែលមានអាយុលើសពី 55 ឆ្នាំ ឬមានពិការភាពធ្ងន់ធ្ងរ ឬអចលនទ្រព្យរបស់ពួកគេបានរងការប៉ះពាល់ ឬការខូចខាតដោយគ្រោះធម្មជាតិ។ (យើងហៅម្ចាស់ផ្ទះទាំងនេះថាជា "ម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិ។") នៅពេលផ្លាស់ទីទៅផ្ទះថ្មីនៅក្នុងខោនធីដដែល ម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិអាចផ្ទេរតម្លៃផ្ទះមានស្រាប់របស់ខ្លួនដែលជាប់ពន្ធ ទៅផ្ទះផ្សេង ប្រសិនបើតម្លៃទីផ្សារនៃផ្ទះថ្មីគឺដូចគ្នា ឬតិចជាងផ្ទះដែលមានស្រាប់។ ទន្ទឹមនេះ រដ្ឋាភិបាលនៃខោនធីអាចអនុញ្ញាតឲ្យម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិផ្ទេរតម្លៃផ្ទះដែលជាប់ពន្ធរបស់ពួកគេទៅផ្ទះនៅក្នុងខោនធីពីផ្ទះនៅក្នុងខោនធីផ្សេងបាន។ ខោនធីដប់ដែលអនុញ្ញាតការផ្ទេរដូច្នេះ។ លើកលែងតែនៅក្នុងករណីតិចតួច ម្ចាស់ផ្ទះដែលមានអាយុលើសពី 55 ឆ្នាំ ឬមានពិការធ្ងន់ធ្ងរអាចផ្ទេរតម្លៃជាប់ពន្ធរបស់ពួកគេតែម្តងនៅក្នុងជីវិតរបស់ពួកគេ។ ប្រអប់នៅជិត ("អ្វីកើតឡើងនៅក្រោមច្បាប់បច្ចុប្បន្ន?") មានឧទាហរណ៍អំពីរបៀបដំណើរការរបស់វិធានទាំងនេះ។

ពន្ធរបស់ពួកគេនៅលើការទិញផ្ទះ។ ទីក្រុងនិងខោនធីប្រមូលពន្ធពីការផ្ទេរកម្មសិទ្ធិផ្ទះ និងអចលនទ្រព្យផ្សេងទៀត។ ទូទាំងរដ្ឋ ពន្ធលើការផ្ទេរកម្មសិទ្ធិបានប្រមូលប្រាក់ប្រហែល $1 ពាន់លានដុល្លារសម្រាប់ទីក្រុង និងខោនធី។

ខោនធីគ្រប់គ្រងពន្ធអចលនទ្រព្យ។ អ្នកវាយតម្លៃប្រចាំខោនធីកំណត់តម្លៃអចលនទ្រព្យដែលជាប់ពន្ធ។ ទូទាំងរដ្ឋ ការចំណាយរបស់ខោនធីសម្រាប់ការិយាល័យអ្នកវាយតម្លៃ មានទឹកប្រាក់សរុបប្រហែល $600 លានដុល្លារក្នុងមួយឆ្នាំ។

ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួននៅរដ្ឋ California ។ រដ្ឋប្រមូលពន្ធលើចំណូលផ្ទាល់ខ្លួន ទៅលើចំណូលរកបាននៅក្នុងរដ្ឋ។ ប្រាក់ចំណូលដែលត្រូវបង់ពន្ធអាចរួមមានប្រាក់ចំណេញពីការលក់ផ្ទះ។ ពន្ធលើប្រាក់ចំណូលផ្ទាល់ខ្លួនរកបានប្រាក់ជាង $80 ពាន់លានដុល្លារក្នុងមួយឆ្នាំ។

សំណើ

ពង្រីកវិធានពិសេសសម្រាប់ម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិ។ វិធាននេះធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់រដ្ឋ ដើម្បីពង្រីកវិធានពិសេសដែលផ្តល់ការសន្សំប្រាក់ពន្ធអចលនទ្រព្យទៅឲ្យម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិ នៅពេលពួកគេទិញផ្ទះផ្សេង។

តើមានអ្វីកើតឡើងនៅក្រោមច្បាប់បច្ចុប្បន្ន?

ប្តីឬប្រពន្ធដែលមានអាយុ 55 ឆ្នាំម្នាក់បានទិញផ្ទះរបស់ពួកគេកាលពី 30 ឆ្នាំមុនក្នុងតម្លៃ $110,000 ដុល្លារ។ នៅពេលនេះ តម្លៃជាប់ពន្ធផ្ទះរបស់គេគឺ $200,000 ($110,000 បង្កើនចំនួន 2 ក្នុងមួយឆ្នាំ រយៈពេល 30 ឆ្នាំ)។ វិក្កយបត្រពន្ធអចលនទ្រព្យប្រចាំឆ្នាំរបស់ពួកគេគឺ $2,200 (1.1 ភាគរយនៃតម្លៃជាប់ពន្ធ)។ ឥឡូវនេះ ផ្ទះរបស់ពួកគេអាចលក់បាន $600,000។ ប្តី ឬប្រពន្ធនេះកំពុងពិចារណាផ្លាស់ទីទៅផ្ទះមួយឬពីរផ្សេងទៀត។

- ***ផ្ទះថ្លៃជាងមុន។*** ជម្រើសដំបូងគឺត្រូវផ្លាស់ទីទៅផ្ទះដែលមានតម្លៃ $700,000។ ការផ្លាស់ទីលំនៅបែបនេះមិនមានលក្ខណសម្បត្តិសម្រាប់វិធានពិសេសទេ ព្រោះផ្ទះថ្មីគឺថ្លៃជាងផ្ទះចាស់។ ប្រសិនបើប្តីប្រពន្ធនេះធ្វើការផ្លាស់ប្តូរបែបនេះ តម្លៃជាប់ពន្ធនៃផ្ទះថ្មីគឺ $700,000 (តម្លៃទិញផ្ទះ)។ វិក្កយបត្រពន្ធអលចនទ្រព្យរបស់ពួកគេនឹងកើនឡើងដល់ $7,700។
- ***ផ្ទះថោកជាងមុន។*** ជម្រើសទីពីរគឺត្រូវផ្លាស់ទីទៅផ្ទះដែលមានតម្លៃ $450,000 ។ ក្នុងករណីនេះ វិធានពិសេសនឹងអនុវត្ត។ តម្លៃជាប់ពន្ធសម្រាប់ផ្ទះថ្មីរបស់ពួកគេគឺ $200,000 (ដូចផ្ទះចាស់ដែរ)។ វិក្កយបត្រពន្ធអលចនទ្រព្យរបស់ពួកគេនឹងនៅ $2,200 ដដែល។

ចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2019 ទៅ វិធានការ ៖

- ***អនុញ្ញាតឲ្យផ្លាស់ទីទៅកន្លែងណាក៏បាន នៅក្នុងរដ្ឋ។*** ម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិអាចផ្ទេរតម្លៃផ្ទះជាប់ពន្ធមានស្រាប់របស់ពួកគេទៅផ្ទះមួយទៀតនៅកន្លែងណាក៏បាននៅក្នុងរដ្ឋ។
- ***អនុញ្ញាតឲ្យទិញផ្ទះដែលថ្លៃជាងមុន។*** ម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិអាចផ្ទេរតម្លៃផ្ទះមានស្រាប់ដែលជាប់ពន្ធ (ដោយមានការកែតម្រូវខ្លះៗ) ទៅផ្ទះដែលកាន់តែថ្លៃ។ តម្លៃជាប់ពន្ធដែលបានផ្ទេរពីផ្ទះមានស្រាប់ទៅផ្ទះថ្មីត្រូវបានកែតម្រូវពីក្រោមឡើងលើ។ តម្លៃជាប់ពន្ធលើផ្ទះថ្មីគឺច្រើនជាងតម្លៃជាប់ពន្ធរបស់ផ្ទះពីមុនប៉ុន្តែតិចជាងតម្លៃទីផ្សារនៃផ្ទះថ្មី។ ឧទាហរណ៍គឺមានបង្ហាញនៅក្នុងប្រអប់នៅជិត (“អ្វីកើតឡើងនៅក្រោមសំណើប្រជាមតិ លេខ 5?”)។
- ***កាត់បន្ថយពន្ធសម្រាប់ផ្ទះទិញថ្មីដែលមានតម្លៃតិចជាង។*** នៅពេលម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិផ្លាស់ទីទៅផ្ទះដែលមានតម្លៃតិចជាង តម្លៃជាប់ពន្ធដែលបានផ្ទេរពីផ្ទះមានស្រាប់ទៅផ្ទះថ្មីត្រូវបានកែតម្រូវចុះក្រោម។ ឧទាហរណ៍គឺមានបង្ហាញនៅក្នុងប្រអប់នៅជិត (“អ្វីកើតឡើងនៅក្រោមសំណើប្រជាមតិលេខ 5?”)។
- ***ដកដែនកំណត់លើចំនួនដងដែលម្ចាស់ផ្ទះអាចប្រើប្រាស់វិធានពិសេស។*** មិនមានដែនកំណត់លើចំនួនដងម្ចាស់ផ្ទះដែលមានលក្ខណសម្បត្តិអាចផ្ទេរតម្លៃជាប់ពន្ធរបស់ពួកគេទេ។

តើអ្វីកើតឡើងនៅក្រោមសំណើប្រជាមតិ 5?

ដោយប្រើប្តីប្រពន្ធដូចគ្នាពីឧទាហរណ៍មុននេះ ផ្ទះបច្ចុប្បន្នរបស់ពួកគេមានតម្លៃដែលជាប់ពន្ធចំនួន $200,000 ហើយតម្លៃទីផ្សារគឺ $600,000។ បើពួកគេផ្លាស់ទីលំនៅ តម្លៃជាប់ពន្ធនៃផ្ទះថ្មីរបស់ពួកគេគឺ៖

- ***ផ្ទះថ្លៃជាងមុន។*** បើប្តីប្រពន្ធទិញផ្ទះតម្លៃ $700,000 ដូច្នេះតម្លៃដែលជាប់ពន្ធនៃផ្ទះថ្មីគឺ $300,000 (ដូចបានបង្ហាញខាងក្រោម)។ វិក្កយបត្រពន្ធអចលនទ្រព្យប្រចាំឆ្នាំរបស់ពួកគេគឺ $3,300។ នេះនឹងច្រើនជាងអ្វីដែលពួកគេបានបង់នៅផ្ទះមុនរបស់ពួកគេ ($2,200) ប៉ុន្តែតិចជាងខ្លាំងជាងអ្វីដែលពួកគេនឹងទូទាំងនៅក្រោមច្បាប់បច្ចុប្បន្ន ($7,700)។

$$\underset{\text{[តម្លៃជាប់ពន្ធរបស់ផ្ទះថ្មី]}}{\$300{,}000} = \underset{\text{[តម្លៃជាប់ពន្ធពីមុនរបស់ផ្ទះ]}}{\$200{,}000} + \underset{\text{[}\$700{,}000 \text{ តម្លៃទីផ្សាររបស់ផ្ទះថ្មី} - \$600{,}000 \text{ តម្លៃទីផ្សាររបស់ផ្ទះមុន]}}{\$100{,}000}$$

- ***ផ្ទះធូរថ្លៃជាង។*** បើប្តីប្រពន្ធទិញផ្ទះតម្លៃ $450,000 តម្លៃជាប់ពន្ធនៃផ្ទះថ្មីគឺ $150,000 (ដូចបានបង្ហាញខាងក្រោម)។ វិក្កយបត្រពន្ធអចលនទ្រព្យប្រចាំឆ្នាំរបស់ពួកគេគឺ $1,650។ នេះនឹងតិចជាងអ្វីដែលពួកគេបានបង់នៅផ្ទះមុនរបស់ពួកគេ និងអ្វីដែលពួកគេនឹងទូទាំងនៅក្រោមច្បាប់បច្ចុប្បន្ន ($2,200)។

$$\underset{\text{[តម្លៃជាប់ពន្ធរបស់ផ្ទះថ្មី]}}{\$150{,}000} = \underset{\text{[តម្លៃជាប់ពន្ធពីមុនរបស់ផ្ទះ]}}{\$200{,}000} \times \underset{\text{[}\$450{,}000 \text{ តម្លៃទីផ្សាររបស់ផ្ទះថ្មី} \div \$600{,}000 \text{ តម្លៃទីផ្សាររបស់ផ្ទះមុន]}}{75\%}$$

ផលប៉ះពាល់សារពើពន្ធ

មានការកាត់បន្ថយចំណូលពីពន្ធអចលនទ្រព្យចំពោះរដ្ឋាភិបាលក្នុងមូលដ្ឋាន។ វិធានការអាចមានឥទ្ធិពលច្រើនទៅលើចំណូលពីពន្ធអចលនទ្រព្យ៖

- ***មានការកាត់បន្ថយពន្ធពីមនុស្សដែលបានផ្លាស់ទីលំនៅដដែល។*** ឥឡូវនេះ ម្ចាស់ផ្ទះប្រហែល 85,000 នាក់ដែលមានអាយុច្រើនជាង 55 ឆ្នាំ ផ្លាស់ទីទៅផ្ទះផ្សេងក្នុងមួយឆ្នាំៗ ដោយមិនមានការអនុគ្រោះពន្ធអចលនទ្រព្យ។ អ្នកផ្លាស់ទីលំនៅទាំងនេះភាគច្រើនត្រូវបង់ពន្ធអចលនទ្រព្យកាន់តែខ្ពស់។ នៅក្រោមវិធានការនេះ ពន្ធលើអចលនទ្រព្យរបស់ពួកគេនឹងទាបជាងមុនច្រើន។ នេះនឹងកាត់បន្ថយចំណូលពីពន្ធអចលនទ្រព្យ។
- ***ពន្ធអាចកាន់តែខ្ពស់ជាងមុនពីតម្លៃផ្ទះដែលថ្លៃជាងមុន និងអគារផ្ទះកាន់តែច្រើន។*** វិធានការ

ការវិភាគដោយអ្នកវិភាគច្បាប់

នេះនឹងធ្វើឲ្យមនុស្សកាន់តែច្រើនលក់ផ្ទះ
របស់ពួកគេ និងទិញផ្ទះផ្សេងវិញដោយសារតែ
ការអនុគ្រោះពន្ធសម្រាប់ពួកគេក្នុងការធ្វើដូ
ច្នោះ។ ចំនួនអ្នកផ្លាស់ទីលំនៅអាចកើនឡើងប្រ
ហែលពីរឬបីម៉ឺននាក់។ មនុស្សកាន់តែច្រើនដែ
លមានចំណាប់អារម្មណ៍លើការទិញនិងលក់ផ្ទះ
នឹងមានឥទ្ធិពលខ្លះមកលើតម្លៃផ្ទះ និងអគារផ្ទះ។
ការកើនតម្លៃផ្ទះ និងអគារផ្ទះនឹងនាំឲ្យមានចំណូ
លពន្ធអលចនទ្រព្យកាន់តែច្រើន។

ការបាត់បង់ចំណូលពីមនុស្សដែលបាន
ផ្លាស់ទី នឹងធំជាងការចំណេញពីតម្លៃផ្ទះ
និងអគារផ្ទះដែលមានតម្លៃថ្លៃជាង។ នេះមានន័យថា
វិធានការនឹងកាត់បន្ថយពន្ធអចលនទ្រព្យសម្រា
ប់រដ្ឋាភិបាលក្នុងមូលដ្ឋាន។ ក្នុងពីរឬបីឆ្នាំដំបូង
សាលារៀននិងរដ្ឋាភិបាលក្នុងមូលដ្ឋានផ្សេ
ងទៀត ប្រហែលជានឹងបាត់បង់ចំណូលជាង
$100 លានដុល្លារក្នុងមួយឆ្នាំ។ យូរទៅ
ការបាត់បង់ទាំងនេះនឹងកើនឡើង នាំឲ្យសាលារៀន
និងរដ្ឋាភិបាលក្នុងមូលដ្ឋានផ្សេងទៀតបាត់បង់ប្រាក់
ប្រហែល $1 ពាន់លានដុល្លារ ក្នុងមួយឆ្នាំ (ក្នុងប្រា
ក់ដុល្លារបច្ចុប្បន្ននេះ)។

***ការចំណាយរបស់រដ្ឋកាន់តែច្រើនសម្រាប់
សាលារៀន។*** ច្បាប់បច្ចុប្បន្នតម្រូវឲ្យរដ្ឋផ្តល់
មូលនិធិកាន់តែច្រើនទៅដល់សាលារៀនមួ
យចំនួនធំដើម្បីគ្របដណ្តប់លើការបាត់បង
ពន្ធអចលនទ្រព្យរបស់ពួកគេ។ ជាលទ្ធផល
ការចំណាយរបស់រដ្ឋសម្រាប់សាលារៀន
នឹងកើនឡើង **ជាង $100 លានដុល្លារ** ក្នុងមួយឆ្នាំ
នៅពីរឬបីឆ្នាំដំបូង។ យូរទៅ ការចំណាយកាន់តែ
ច្រើនរបស់រដ្ឋលើសាលារៀន នឹងកើនឡើងរហូតដល់
ប្រហែល $1 ពាន់លានដុល្លារ ក្នុងមួយឆ្នាំ ក្នុង
ទឹកប្រាក់ដុល្លារបច្ចុប្បន្ននេះ។ (នេះគឺតិចជាង 1
ភាគរយនៃថវិការបស់រដ្ឋ។)

បង្កើនចំណូលពីពន្ធផ្ទេរកម្មសិទ្ធិអចលនទ្រព្យ។
វិធានការនេះនឹងបង្កើនការលក់ផ្ទះ ហើយវាក៏នឹងប
ង្កើនពន្ធផ្ទេរកម្មសិទ្ធិអចលនទ្រព្យដែលបានប្រមូ
លដោយក្រុង និងខោនធីផងដែរ។ ការកើនចំណូ
លនេះអាចនឹងមានចំនួនប្រហែលរាប់សិបលានដុល្លារ
ក្នុងមួយឆ្នាំ។

បង្កើនចំណូលពីពន្ធលើប្រាក់ចំណូល។
ដោយហេតុថា វិធានការនេះនឹងបង្កើនចំនួនផ្ទះលក់
ក្នុងមួយឆ្នាំៗ វានឹងអាចបង្កើនចំនួនអ្នកបង់ពន្ធដែល
ត្រូវបង់ពន្ធលើប្រាក់ចំណូលបានមកពីប្រាក់ចំណេ
ញក្នុងការលក់ផ្ទះរបស់ពួកគេផងដែរ។ នេះប្រហែ
លបង្កើនចំណូលពន្ធលើប្រាក់ចំណូលរបស់រដ្ឋចំនួនប្រ
ហែលរាប់សិបលានដុល្លារក្នុងមួយឆ្នាំ។

ការចំណាយរដ្ឋបាលកាន់តែខ្ពស់សម្រាប់ខោនធី។
អ្នកវាយតម្លៃប្រចាំខោនធីនឹងត្រូវបង្កើតដំណើរការ
ដើម្បីគណនាតម្លៃផ្ទះជាប់ពន្ធដែលបានគ្រប់ដណ្តប់
ដោយវិធានការនេះ។ នេះនឹងនាំឲ្យមានការចំណាយ
មួយដងសម្រាប់អ្នកវាយតម្លៃប្រចាំខោនធីក្នុងទឹក
ប្រាក់ **រាប់សិបលានដុល្លារ** ឬច្រើនជាងនេះ ដោយ
មានការកើនថ្លៃចំណាយជាបន្តបន្ទាប់តិចតួច។

**ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជី
នៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ
ឬជំទាស់វិធានការនេះ។ ចូលទៅកាន់ *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html*
ដើម្បីចូលទៅកាន់អ្នករួមវិភាគទានកំពូលទាំង
10 របស់គណៈកម្មាធិការ។**

**ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការ
រដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការតាមលេខ
(888) 345-4917 ឬអ្នកអាចអ៊ីម៉ែល
vigfeedback@sos.ca.gov ហើយច្បាប់ចម្លងមួយនឹងត្រូវបាន
ផ្ញើជូនអ្នកដោយឥតគិតថ្លៃ។**

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិលេខ 5 ★

សំណើប្រជាមតិលេខ 5 ផ្តល់ដល់មនុស្សចាស់ទាំងអស់ (អាយុ 55 ឆ្នាំឡើង) និងជនដែលមានពិការភាពធ្ងន់ធ្ងរនូវសិទ្ធិដើម្បីផ្លាស់ទីលំនៅដោយមិនមានការពិន័យ

សំណើប្រជាមតិលេខ5 ដែលជាការផ្តួចផ្តើមគំនិតសម្រាប់ភាពត្រឹមត្រូវចំពោះពន្ធអចលនទ្រព្យ លុបបំបាត់ "ការពិន័យលើការផ្លាស់ទីលំនៅ" ដែលមានស្រាប់នាពេលបច្ចុប្បន្ន ដើម្បីការពារមនុស្សចាស់ (អាយុ 55 ឆ្នាំឡើង) និងជនដែលមានពិការភាពធ្ងន់ធ្ងរដែលចង់ផ្លាស់ទីលំនៅទៅផ្ទះដែលកាន់តែមានសុវត្ថិភាព ងាយស្រួល ឬជិតក្រុមគ្រួសាររបស់ពួកគេ។ សំណើប្រជាមតិលេខ5 កំណត់កម្រិតពិន័យពន្ធអចលនទ្រព្យដែលពួកគេអាចនឹងប្រឈម ប្រសិនបើពួកគេទិញផ្ទះមួយទៀត នៅក្នុងខោនធីណាមួយនៃរដ្ឋ។

សំណើប្រជាមតិលេខ 5 លុបបំបាត់ឧបសគ្គក្នុងការផ្លាស់ទីលំនៅសម្រាប់មនុស្សចាស់ (អាយុ 55 ឆ្នាំឡើង)

មនុស្សចាស់រាប់លាននាក់ដែលរស់នៅ California រស់នៅក្នុងផ្ទះដែលមិនសមរម្យចំពោះតម្រូវការរបស់ពួកគាត់—វាអាចធំពេក មានជណ្តើរច្រើនពេក ឆ្ងាយពេកពីក្រុមគ្រួសារ និងមនុស្សជាទីស្រលាញ់ជាដើម។ នៅក្រោមសំណើប្រជាមតិលេខ5 ម្ចាស់ផ្ទះដែលមានវ័យចាស់ (អាយុ 55 ឆ្នាំឡើង) នឹងអាចផ្ទេរតម្លៃផ្ទះជាប់ពន្ធបច្ចុប្បន្នរបស់ពួកគេបាន ទោះពួកគេផ្ទេរទៅនៅទីណាក៏ដោយនៅក្នុងរដ្ឋ។

សំណើប្រជាមតិលេខ 5 ពង្រឹងភាពអង់អាចដល់អ្នកចូលនិវត្តដែលមានចំណូលថេរ

អ្នកចូលនិវត្តភាគច្រើនដែលមានចំណូលថេរ ជាញឹកញាប់បានមកពីប្រាក់ចូលនិវត្តន៍ និង/ប្រាក់សង្គមកិច្ច។ សំណើប្រជាមតិលេខ5 លុបបំបាត់លទ្ធភាពនៃការបង្កើនពន្ធអចលនទ្រព្យ 100%, 200%, ឬសូម្បីតែ 300% ដែលគ្រូបង្រៀន អ្នកពន្លត់អគ្គិភ័យ ប៉ូលិស និងអ្នកចូលនិវត្តផ្សេងទៀតត្រូវតែបង់ប្រាក់ ប្រសិនបើពួកគេចង់លក់ផ្ទះបច្ចុប្បន្នរបស់ពួកគេ ដើម្បីទិញផ្ទះនៅកន្លែងផ្សេងទៀតនៅរដ្ឋ California ។

សំណើប្រជាមតិលេខ 5 ការពារប្រឆាំងនឹងមូលដ្ឋានពន្ធអចលនទ្រព្យ "ការពិន័យលើការផ្លាស់ទីលំនៅ"

នៅក្រោមច្បាប់ California បច្ចុប្បន្ន ពន្ធអចលនទ្រព្យត្រូវបានកាត់ទុកក្នុងភាគរយតូចមួយនៃតម្លៃអចលនទ្រព្យនៅពេលទិញ។ នេះត្រូវបានគេស្គាល់ថាជា "មូលដ្ឋានពន្ធអចលនទ្រព្យ"។ លើសពីនេះ មានការកម្រិតតិចតួចអំពីការបង្កើនពន្ធអចលនទ្រព្យប្រចាំឆ្នាំ។ មនុស្សចាស់ និងជនដែលមានពិការភាពធ្ងន់ធ្ងរដែលមានចំណូលថេរ និងមិនអាចមានលទ្ធភាពបង់ពន្ធអចលនទ្រព្យធំៗ បាន។ ប៉ុន្តែប្រសិនបើពួកគេជ្រើសរើសផ្លាស់ទីលំនៅទៅផ្ទះថ្មី "មូលដ្ឋានពន្ធ" របស់ពួកគេកើនឡើងយ៉ាងខ្លាំង ដោយសារការកើនតម្លៃផ្ទះនៅប៉ុន្មានទសវត្សចុងក្រោយនេះ។ សំណើប្រជាមតិលេខ5 ការពារពលរដ្ឋ California ទាំងនេះពី "ការពិន័យលើការផ្លាស់ទីលំនៅ" ដោយអនុញ្ញាតឲ្យពួកគេរក្សាបាននូវមូលដ្ឋានពន្ធទាបជាង និងត្រឹមត្រូវជាង។

សំណើប្រជាមតិលេខ 5 ពង្រឹកអត្ថប្រយោជន៍នៃសំណើប្រជាមតិលេខ 13 នាំឲ្យមានស្ថេរភាពពន្ធ និងភាពស្ងប់ចិត្ត

សំណើប្រជាមតិលេខ5 លុបបំបាត់ "ការពិន័យលើការផ្លាស់ទីលំនៅ" ដែលមាននៅថ្ងៃនេះ ដែលរួមចំណែកដល់កង្វះលំនៅដ្ឋាននៅក្នុងរដ្ឋ California។ ដូចគ្នានឹងសំណប្រជាមតិ 13 (1978) ដែលបានបង្ការមនុស្សចាស់រាប់លាននាក់ពីការកាត់ប្រាក់ពន្ធពីផ្ទះរបស់ពួកគាត់ សំណើប្រជាមតិលេខ 5 នឹងជួយមនុស្សរាប់លាននាក់ថែមទៀត នាពេលបច្ចុប្បន្ននេះ។ សំណើប្រជាមតិលេខ5 នឹងជួយកាត់បន្ថយកង្វះខាតលំនៅដ្ឋានហើយនឹងនាំមកនូវស្ថេរភាព និងសន្តិភាពក្នុងចិត្តសម្រាប់គ្រួសារថ្នាក់កណ្តាល និងគ្រួសារអ្នកធ្វើការរាប់លានគ្រួសារទូទាំងរដ្ឋ California ។

សំណើប្រជាមតិលេខ 5 ពង្រឹងភាពអង់អាចដល់ជនដែលមានពិការភាពធ្ងន់ធ្ងរដែលជាប់នៅក្នុងផ្ទះដែលមិនសមរម្យ

ជនដែលមានពិការភាពធ្ងន់ធ្ងរជាច្រើននៅក្នុងរដ្ឋ California រស់នៅក្នុងផ្ទះដែលលែងមានសុវត្ថិភាព ឬលែងងាយស្រួលសម្រាប់ពួកគេទៀតហើយ ប៉ុន្តែពួកគេមិនមានលទ្ធភាពផ្លាស់ប្តូរទីលំនៅទេ ដោយសារពន្ធអចលនទ្រព្យអាចកើនឡើងខ្លាំងប្រសិនបើពួកគេទិញផ្ទះថ្មីនៅកន្លែងផ្សេងក្នុងរដ្ឋ California ។ ករណីនេះនៅតែអាចកើតមានឡើង ទោះបីពួកគេផ្លាស់ទីទៅរស់នៅផ្ទះដែលមិនសូវថ្លៃក៏ដោយ។ នៅក្រោមសំណើប្រជាមតិលេខ5 ម្ចាស់ផ្ទះដែលមានពិការភាពធ្ងន់ធ្ងរនឹងអាចផ្លាស់ទីលំនៅទៅផ្ទះដែលកាន់តែសមរម្យដោយមិនទទួល "ការពិន័យលើការផ្លាស់ទីលំនៅ។"

PENNY LILBURN, នាយកប្រតិបត្តិ
Highland Senior Center

KYLE MILES, មេបញ្ជាការ
AMVETS នាយកដ្ឋាន **California**

SUSAN CHANDLER, ប្រធាន
Californians for Disability Rights, Inc.

★ ទឡ្ហីករណ៍តបត ដើម្បីគាំទ្រសំណើប្រជាមតិលេខ 5 ★

សំណើប្រជាមតិលេខ 5 មិនជួយដល់មនុស្សចាស់ដែលមានចំណូលទាបភាគច្រើនទេ ប៉ុន្តែវាជួយដល់ផលប្រយោជន៍អចលនទ្រព្យសាជីវកម្មដែលផ្តល់មូលនិធិទៅវា។

អត្ថប្រយោជន៍អចលនទ្រព្យនៅពីក្រោយសំណើប្រជាមតិលេខ 5 គឺកំពុងតែព្យាយាមបន្លាចមនុស្សចាស់ជាមួយនឹងការភ្ញកកុហក។ ច្បាប់បច្ចុប្បន្នអនុញ្ញាត *រួចហើយ* ដល់អ្នកបង់ពន្ធដែលជាមនុស្សចាស់ និងជនដែលមានពិការភាពធ្ងន់ធ្ងរ ដើម្បីរក្សាការលើកលែងពន្ធអចលនទ្រព្យនៅពេលពួកគេផ្លាស់ទីលំនៅ។ សំណើប្រជាមតិលេខ 5 គឺប្លែកពីគេ—វាជាការសម្រាកពន្ធថ្មីសម្រាប់អ្នកមានចំណូលខ្ពស់បំផុត ដែលបន្តទិញផ្ទះធំៗ និងថ្លៃៗ បន្ទាប់ពីមានអាយុ 55 ឆ្នាំ។

"Gary Passmore ប្រធានសមាជ California សម្រាប់មនុស្សចាស់ ថ្លែងថា" តើហេតុអ្វីបានជាផលប្រយោជន៍អចលនទ្រព្យប្រើប្រាស់មនុស្សចាស់ និងជនដែលមានពិការភាពជាវត្ថុបញ្ចាំដើម្បីលក់ ផ្ទះថ្លៃជាងមុន ។មនុស្សចាស់បានចូលនិវត្តរួចហើយ នៅផ្ទះសមធម៌របស់ពួកគេ ដោយមិនមាន 'ការពិន័យលើការផ្លាស់ទីលំនៅ។' ពួកគេប្រឈិតវាឡើង។ ប្រឆាំងសំណើប្រជាមតិលេខ 5!"

សំណើប្រជាមតិលេខ 5 ធ្វើឲ្យការការពារអគ្គីភ័យ ការថែទាំសុខភាព និងសាលារៀនរបស់យើង មានហានិភ័យ ព្រោះវាស្រូបយកប្រាក់ $1 ពាន់លានដុល្លារពីក្រុង និងខោនធី។

ពលរដ្ឋវ័យក្មេងនៅ California មានការពិបាកក្នុងការទិញផ្ទះដំបូងរបស់ពួកគេ។ មនុស្សចាស់ ជនដែលមានពិការភាពនិងគ្រួសារជាច្រើនមិនអាចមានលទ្ធភាពរកអាផាតមិនដែលមានសុវត្ថិភាពបានទេ។ វាជាការខុសឆ្គងដែលមានអត្ថប្រយោជន៍អចលនទ្រព្យនៅពីក្រោយវិធានការនេះ ដែលធ្វើឲ្យលំនៅដ្ឋានកាន់តែថ្លៃឡើងៗ។

Melinda Dart គ្រូបង្រៀនបឋមចូលនិវត្តថ្លែងថា"ក្នុងនាមជាគ្រូបង្រៀនចូលនិវត្ត ខ្ញុំបារម្ភអំពីការបង់ប្រាក់កម្ចីទិញផ្ទះ និងកំពុងរក្សាទុកប្រាក់ចូលនិវត្តន៍ខ្លះៗសម្រាប់កូនរបស់ខ្ញុំ។ សំណើប្រជាមតិលេខ 5 នឹងមិនជួយខ្ញុំទាល់តែសោះ ហើយវាមិនគួរនិយាយថា វាជួយខ្ញុំទេ។

សំណើប្រជាមតិលេខ 5 ត្រូវបានជំទាស់ដោយគ្រូបង្រៀន គិលានុដ្ឋាក អ្នកពន្លត់អគ្គីភ័យ និងមេធាវីសម្រាប់មនុស្សចាស់និងលំនៅដ្ឋាន ព្រោះថាវាជាការបោកប្រាក់។ សូមចូលរួមជាមួយយើងក្នុងការបោះឆ្នោតប្រឆាំងនឹងលេខ 5 ។

NAN BRASMER, ប្រធាន
សម្ព័ន្ធ California សម្រាប់ជនជាតិអាមេរិកដែលចូលនិវត្ត

HELEN HUTCHISON, ប្រធាន
សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រីនៃCalifornia

TIM GAGE, អតីតនាយក
នាយកដ្ឋានហិរញ្ញវត្ថុ California

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិលេខ 5 ★

ប្រឆាំងនឹងសំណើប្រជាមតិលេខ 5

យើងជំរុញឲ្យបោះឆ្នោតប្រឆាំងនឹងសំណើប្រជាមតិលេខ 5 សម្រាប់ហេតុផលសាមញ្ញមួយ។ យើងមានវិបត្តិធ្ងន់ធ្ងរចំពោះលំនៅដ្ឋានដែលអាចទិញបាននៅរដ្ឋ California ហើយសំណើប្រជាមតិលេខ 5 នឹងមិនបានធ្វើអ្វីដើម្បីជួយសម្រាលវិបត្តិនេះទេ

អ្វីដែលសំណើប្រជាមតិលេខ 5 នឹងធ្វើ ៖

- សំណើប្រជាមតិលេខ 5 នឹងបន្តដំឡើងការចំណាយលើលំនៅដ្ឋាន។
- សំណើប្រជាមតិលេខ 5 អាចនាំឲ្យបាត់បង់ប្រាក់រាប់រយលានដុល្លារ ហើយក្នុងនោះ $1 ពាន់លានដុល្លារ លើប្រាក់ចំណូលក្នុងមូលដ្ឋានសម្រាប់សាលារៀនរដ្ឋផងដែរ។
- សំណើប្រជាមតិលេខ 5 នឹងធ្វើឲ្យបាត់បង់ចំណាយលើសេវាកម្មក្នុងមូលដ្ឋាន រួមមានអគ្គីភ័យ ប៉ូលិស និងការថែទាំសុខភាព រហូតដល់ $1 ពាន់លានដុល្លារ។
- សំណើប្រជាមតិលេខ 5 ផ្តល់នូវការសម្រាកពន្ធដ៏ធំសម្រាប់អ្នកមាននៅរដ្ឋ California ។
- សំណើប្រជាមតិលេខ 5 ធ្វើឲ្យធ្លាក់ចុះឧស្សាហកម្មអចលនទ្រព្យ ដែលជាអ្នកឧបត្ថម្ភតែមួយគត់នៃការផ្តួចផ្តើមគំនិត។

យើងជំរុញឲ្យបោះឆ្នោតប្រឆាំងនឹងសំណើប្រជាមតិលេខ 5 ដោយសារវាមិនបានបំពេញនូវចំនុចខាងក្រោម៖

- វាមិនសាងសង់អគារថ្មីណាមួយទេ។
- វាមិនជួយដល់អ្នកទិញផ្ទះដំបូងទេ។
- វាមិននាំឲ្យថ្លៃឈ្នួលផ្ទះចុះថោកទេ។
- វាមិនដោះស្រាយការឥតមានផ្ទះសម្បែងឡើយ។

មេធាវីផ្នែកលំនៅដ្ឋានបញ្ជាក់ច្បាស់ ៖ **Shamus Roller** មកពីគម្រោងច្បាប់លំនៅដ្ឋានជាតិ និងជាជើងឯកសម្រាប់លំនៅដ្ឋានដែលមានតម្លៃសមរម្យថ្លែងថា "សំណើប្រជាមតិលេខ 5 មិនធ្វើអ្វីដើម្បីលំនៅដ្ឋានតម្លៃសមរម្យទេ ហើយថែមទាំងធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើងថែមទៀតផង។" ។

សម្រាប់រយៈពេល 30 ឆ្នាំចុងក្រោយនេះ ម្ចាស់ផ្ទះវ័យចំណាស់ដែលផ្លាស់ទីលំនៅទៅផ្ទះតូចជាង និងថោកជាង អាចយកពន្ធអចលនទ្រព្យបច្ចុប្បន្នរបស់ពួកគេទៅជាមួយពួកគេ ដែលជាការលើកទឹកចិត្តដើម្បីទុកផ្ទះធំជាង និងថ្លៃជាងសម្រាប់គ្រួសារវ័យក្មេង។ ម្ចាស់ផ្ទះទាំងនេះអាចធ្វើដូច្នេះបាន *ម្តង* នៅក្នុងមួយជីវិតរបស់ពួកគេ។ នេះជាការបន្តសំណើប្រជាមតិលេខ 13។

ប៉ុន្តែសំណើប្រជាមតិលេខ 5 ផ្លាស់ប្តូរសមីការនេះ។ ប្រសិនបើវាត្រូវបានអនុម័ត ម្ចាស់ផ្ទះដែលមានអាយុលើស 55 ឆ្នាំ អាចប្រើប្រាស់ការសម្រាកពន្ធរបស់ពួកគេ ដើម្បីបន្តការទិញផ្ទះថ្លៃជាង ម្តងហើយ ម្តងទៀត នៅកន្លែងណាក៏បាននៅក្នុងរដ្ឋ California ។ ទន្ទឹមនេះ អ្នកទិញផ្ទះដែលមានវ័យក្មេង លើកដំបូង ដែលមានចំណូលតិចតួច នឹងប្រឈមមុខនឹងតម្លៃផ្ទះកាន់តែខ្ពស់ ហើយអ្នកជួលនឹងកាន់តែពិបាកក្លាយជាម្ចាស់ផ្ទះ។

អ្នកវិភាគច្បាប់ California មិនមានបក្សថ្លែងថា សំណើប្រជាមតិលេខ 5 នឹងបណ្តាលឲ្យខាតបង់ប្រាក់ចំណូលយ៉ាងច្រើននៅថ្នាក់មូលដ្ឋាន។ នោះជាមូលហេតុដែលអ្នកពន្លត់អគ្គីភ័យ គ្រូបង្រៀន និងគិលានុបដ្ឋាកសុទ្ធតែនិយាយថា ប្រឆាំងនឹងសំណើប្រជាមតិលេខ 5 ។ ការផ្តួចផ្តើមគំនិតនេះនឹងនាំឲ្យមានការកាត់បន្ថយសេវាសាធារណៈសំខាន់ៗ រួមមានការការពារអគ្គីភ័យ ការការពាររបស់ប៉ូលិស និងការថែទាំសុខភាពជាដើម។ មូលនិធិសាលារដ្ឋមានប្រភពសំខាន់មកពីពន្ធអចលនទ្រព្យក្នុងមូលដ្ឋាន។ សំណើប្រជាមតិលេខ 5 មានន័យថា មានប្រាក់ចំណូលក្នុងមូលដ្ឋានតិចសម្រាប់សាលារដ្ឋរបស់យើង។

"ការពន្លត់ភ្លើងឆេះព្រៃដែលប៉ះពាល់ដល់សហគមន៍របស់យើងប៉ុន្មានឆ្នាំកន្លងមកនេះ តម្រូវឲ្យមានការប្រើធនធានក្នុងមូលដ្ឋានកាន់តែច្រើន—មិនមែនកាន់តែតិចទេ—។ **Brian Rice**, ប្រធានសមាគមអ្នកពន្លត់អគ្គិភ័យជំនាញ California "យើងមិនអាចប្រើប្រាស់សំណើប្រជាមតិលេខ 5" បានទេ ។

អ្នកដែលមានផលប្រយោជន៍ពីផ្នែកអចលនទ្រព្យ ដែលចង់ប្រើប្រាស់សំណើប្រជាមតិលេខ 5 នៅលើសន្លឹកឆ្នោត បានសម្រេចចិត្តទាញយកផលចំណេញពីអ្នកដទៃ។ ហេតុអ្វី? អ្នកត្រូវសួរពួកគេ។ ប៉ុន្តែយើងគិតថា វាត្រូវតែពាក់ព័ន្ធនឹងផលចំណេញរបស់ពួកគេ។

យើងមិនអាចប្រើប្រាស់សំណើប្រជាមតិលេខ 5 បានទេ។
សូមចូលរួមជាមួយយើង និងបោះឆ្នោតប្រឆាំង។

ស្វែងយល់បន្ថែមដោយចូលមើល *www.noprop5.com*

CAROL KIM, សមាជិកក្រុមប្រឹក្សាភិបាល
សមាគមអ្នកបង់ពន្ធថ្នាក់កណ្តាល

SHAMUS ROLLER, នាយកប្រតិបត្តិ
គម្រោងច្បាប់លំនៅដ្ឋានជាតិ

GARY PASSMORE, ប្រធាន
សមាជនៃព្រឹទ្ធាចារ្យរដ្ឋ California

★ ទឡ្ហីករណ៍តបត ដើម្បីប្រឆាំងសំណើប្រជាមតិលេខ 5 ★

សំណើប្រជាមតិលេខ 5 ជួយពលរដ្ឋ CALIFORNIA
ដែលចង់មានឱកាសផ្លាស់ទីលំនៅ

សំណើប្រជាមតិលេខ 5 ដែលជា *គំនិតផ្តួចផ្តើមសម្រាប់ភាពត្រឹមត្រូវលើពន្ធអចលនទ្រព្យ*លុបបំបាត់ "ការពិន័យលើការផ្លាស់ទីលំនៅ" ដែលបច្ចុប្បន្នប៉ះពាល់ដល់មនុស្សចាស់ (អាយុ 55 ឆ្នាំឡើង) និងជនដែលមានពិការភាពធ្ងន់ធ្ងរដែលរស់នៅរដ្ឋ California ដែលមានអារម្មណ៍ថា ជាប់នៅក្នុងផ្ទះ ហើយលែងចង់បាន ឬដែលមិនត្រឹមត្រូវសម្រាប់តម្រូវការរបស់ពួកគេ។

សំណើប្រជាមតិលេខ 5 អនុញ្ញាតឲ្យពលរដ្ឋវ័យចំណាស់នៅ California លក់ផ្ទះបច្ចុប្បន្នរបស់ពួកគេ និងទិញលំនៅដ្ឋានបឋមថ្មី—ដោយមិនប្រឈមនឹង "ការពិន័យលើការផ្លាស់ទីលំនៅ" ពន្ធអចលនទ្រព្យ។ សំណើប្រជាមតិលេខ 5 ធ្វើឲ្យកាន់តែមានតម្រូវការកាន់តែធំលើលំនៅដ្ឋានសម្រាប់គ្រួសារផ្សេងទៀត រួមទាំងអ្នកទិញនិងអ្នកជួលផ្ទះលើកដំបូងផងដែរ។

សំណើប្រជាមតិលេខ 5 មិនដំឡើងការចំណាយលើលំនៅដ្ឋានទេ។

ការផ្តួចផ្តើមគំនិតនេះមិនដំឡើងការចំណាយលើលំនៅដ្ឋានទេ។

សំណើប្រជាមតិលេខ 5 មិនយកមូលនិធិពីសុវត្ថិភាពសាធារណៈទេ

ការផ្តួចផ្តើមគំនិតនេះមិនយកមូលនិធិចេញពីនាយកដ្ឋានប៉ូលិស ឬថែទាំសុខភាពទេ។

សំណើប្រជាមតិលេខ 5 មិនយកមូលនិធិពីសាលារដ្ឋទេ។

ការផ្តួចផ្តើមគំនិតនេះមិនយកមូលនិធិចេញពីសាលារៀនរដ្ឋទេ។

អ្នកសេដ្ឋកិច្ចឈានមុខគេនៅ CALIFORNIAថ្លែងថា សំណើប្រជាមតិលេខ 5 នឹងបង្កើនចំណូលរដ្ឋ

ការពិនិត្យមើលផ្នែកសេដ្ឋកិច្ចលើសំណើប្រជាមតិលេខ 5 ដែលបានធ្វើដោយអ្នកសេដ្ឋកិច្ចល្បីពីររូបនៅក្នុងរដ្ឋ បានសន្និដ្ឋានថា ការអនុញ្ញាតឲ្យមនុស្សចាស់ជនដែលមានពិការភាពធ្ងន់ធ្ងរ និងជនរងគ្រោះដោយគ្រោះមហន្តរាយផ្លាស់ទីលំនៅ នឹងបង្កើនចំណូលពន្ធ និងផ្តល់មូលនិធិកាន់តែច្រើនសម្រាប់សេវាសាធារណៈដែលចាំបាច់បំផុត។

ប្រសិនបើមនុស្សចាស់អាចផ្លាស់ទីលំនៅទៅផ្ទះថ្មីទីមួយបាន ដែលសាកសមនឹងតម្រូវការរបស់ពួកគាត់ជាងមុន (ដូចជាបន្ថយទំហំក្រោយពេលកូនៗចេញពីផ្ទះ) នោះផ្ទះរបស់ពួកគាត់នឹងរកប្រាក់ចំណូលពន្ធបានកាន់តែច្រើន នៅពេលលក់ទៅអ្នកទិញថ្មី។

MARILYN MARKHAM, សមាជិកក្រុមប្រឹក្សាភិបាល
សម្ពន្ធមេធាវីសម្រាប់មនុស្សចាស់នៅ California

TOM CAMPBELL, Ph.D., សាស្ត្រាចារ្យសេដ្ឋកិច្ច

MICHAEL C. GENEST, អតីតនាយក
នាយកដ្ឋានហិរញ្ញវត្ថុរដ្ឋ California

សំណើប្រជាមតិ 6 បំបាត់ចោលមូលនិធិការជួសជុលផ្លូវ និងគមនាគមន៍មួយចំនួន។ តម្រូវឲ្យមានពន្ធប្រេងឥន្ធនៈ និងថ្លៃរថយន្តមួយចំនួន ត្រូវបានអនុម័តដោយអង្គបោះឆ្នោត។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — **រៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័ រ របស់រដ្ឋលេខាធិការតាមអាសយដ្ឋាន *http://voterguide.sos.ca.gov*។

- លុបចោលច្បាប់ពន្ធស្តីពីគមនាគមន៍ និងមាត្រាថ្លៃឈ្នួលឆ្នាំ 2017ដែលចំណាយសម្រាប់ការជួសជុល និងការកែលម្អផ្លូវ ថ្នល់ក្នុងមូលដ្ឋាន មហាវិថីរដ្ឋ និងគមនាគមន៍សាធារណៈ។
- តម្រូវឱ្យអង្គនិតិបញ្ញត្តិដាក់វិធានការណាមួយឱ្យប្រើ ពន្ធឬ ថ្លៃឈ្នួលកំណត់ជាក់លាក់ អំពីប្រេងឥន្ធនៈ ឬប្រេងម៉ាស៊ូតឬ សិទ្ធិពិសេសដើម្បីប្រតិបត្តិរថយន្ត មួយនៅលើផ្លូវសាធារណៈ ទៅឱ្យអង្គបោះឆ្នោត សម្រាប់ការយល់ព្រម។

សេចក្តីសង្ខេបការវាយតម្លៃនៃការវិភាគរបស់អង្គ នីតិបញ្ញត្តិនៃ ផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋា ភិបាលមូលដ្ឋាន និងរដ្ឋ៖

- បន្ថយចំណូលរដ្ឋកំពុងទទួលចំនួន $5.1 ពាន់ លានដុល្លារ ពីការលុបបំបាត់ពន្ធប្រេងឥន្ធនៈ និង រថយន្តដែលអនុម័តដោ យអង្គនិតិបញ្ញត្តិឆ្នាំ 2017 ។ ចំណូលទាំងនេះជាចម្បងនឹង ត្រូវចំណាយ សម្រាប់ការថែទាំមហាវិថីនិងជួសជុលផ្លូវក៏ដូច ជា កម្មវិធីផ្លូវឆ្លងកាត់ផងដែរ។
- លក្ខខណ្ឌតម្រូវដែលអ្នកបោះឆ្នោតយល់ព្រមថ្ម ី ឬបង្កើន លើពន្ធប្រេងឥន្ធនៈ និងរថយន្តដែលត្រូវបាន អនុម័តដោយអង្គនីតិបញ្ញត្តិនាពេលអនាគត អាចនាំអោយចំណូលចុះទាបពីពន្ធនោះ ពុំនោះទេ ប្រាក់នោះ ប្រហែលពុំអាចមានសម្រាប់ប្រើប្រាស់។

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

ការអនុម័តពន្ធរដ្ឋ

លក្ខខណ្ឌតម្រូវផ្អែកច្បាប់។ ក្រោមរដ្ឋធម្មនុញ្ញ អង្គនីតិបញ្ញត្តិអាចអនុម័តពន្ធថ្មី ឬបង្កើនពន្ធមានស្រាប់ដោយសំឡេងពីរភាគបីតែប៉ុណ្ណោះ។ (អង្គនីតិបញ្ញត្តិអាចអ នុម័តច្បាប់ប្រភេទផ្សេងៗដោយសំឡេងភាគច្រើនធម្មតា។) សោហ៊ុយរដ្ឋមួយចំនួ នដែលហៅថាថ្លៃឈ្នួល (ដូចជា ថ្លៃឈ្នួលអាជ្ញាប័ណ្ណរថយន្ត) ស្ថិតក្រោមនិយមន័ យពន្ធរបស់រដ្ឋធម្មនុញ្ញ។

លក្ខខណ្ឌនៃការអនុម័តដោយអ្នកបោះឆ្នោត។ អង្គនីតិបញ្ញត្តិមិនចាំបាច់ ទទួលបានការអនុម័តដោយអ្នកបោះឆ្នោតសម្រាប់ពន្ធថ្មី ឬពន្ធដែលបាន បង្កើនដែលខ្លួនអនុម័ត។ អ្នកបោះឆ្នោត—តាមរយៈដំណើរការផ្តួចផ្តើម— អាចអនុម័តពន្ធថ្មី ឬបង្កើនពន្ធដែលមានស្រាប់ដោយមិនចាំបាច់មានការចូលរួ មពីអង្គនីតិបញ្ញត្តិក៏បានដែរ។

ពន្ធរដ្ឋលើប្រេងឥន្ធនៈ និងរថយន្ត

ពន្ធលើប្រេងឥន្ធនៈ។ រដ្ឋគិតថ្លៃអាករពិសេសទៅលើសាំង និងប្រេងម៉ាស៊ូត។ ពន្ធទាំងនេះត្រូវបានកំណត់ទៅតាមមួយហ្គាឡុង។ រដ្ឋក៏គិតថ្លៃពន្ធលើការលក់សាំង និងប្រេងម៉ាស៊ូតផងដែរ។ ពន្ធទាំងនេះត្រូវ បានកំណត់ជាភាគរយនៃតម្លៃប្រេងឥន្ធនៈ។ ជាទូទៅ រដ្ឋធម្មនុញ្ញតម្រូវឲ្យចំ ណូលដែលបានមកពីពន្ធលើប្រេងឥន្ធនៈទាំងនេះត្រូវចំណាយទៅលើមហាវិ ថី ផ្លូវថ្នល់ និងផ្លូវឆ្លងកាត់។

ពន្ធលើរថយន្ត។ ច្បាប់រដ្ឋតម្រូវឲ្យម្ចាស់រថយន្តបង់ពន្ធកំណត់ជាក់លា ក់ចំនួនពីរសម្រាប់ឯកសិទ្ធិនៃប្រតិបត្តិការនៅលើមហាវិថីសាធារណៈ។ ទាំងនេះគឺ (1) ថ្លៃឈ្នួលអាជ្ញាប័ណ្ណរថយន្ត និង (2) ថ្លៃឈ្នួលកែលម្អគមនា គមន៍ដែលទើបតែបានអនុម័តថ្មីៗនេះ ដែលថ្លៃឈ្នួលទាំងពីរនេះគឺផ្អែកទៅ លើតម្លៃរបស់រថយន្ត។ រដ្ឋធម្មនុញ្ញតម្រូវឲ្យចំណូលពីថ្លៃឈ្នួលគមនាគមន៍ ត្រូវចំណាយទៅលើមហាវិថី ផ្លូវថ្នល់ និងផ្លូវឆ្លងកាត់។

មូលនិធិគមនាគមន៍នៅរដ្ឋ CALIFORNIA

មូលនិធិគមនាគមន៍នៅរដ្ឋ California បច្ចុប្បន្ននេះ ត្រូវបានប៉ាន់ស្មាន ថាមានទឹកប្រាក់សរុប $35 ពាន់លានដុល្លារ។ ក្នុងចំនួនទឹកប្រាក់នេះ $16 ពាន់លានដុល្លារ បានមកពីធនធានក្នុងមូលដ្ឋាន $12 ពាន់លានដុល្លារ បានមកពីប្រភពនានារបស់រដ្ឋ និង $7 ពាន់លានដុល្លារ បានមកពីប្រភពនានារបស់សហព័ន្ធ។ មូលនិធិក្នុងមូលដ្ឋាន ភាគច្រើនបានមកពីពន្ធលើការលក់ ថ្លៃឈ្នួលផ្លូវឆ្លងកាត់ និងមូលនិធិទូទៅរបស់ទីក្រុង និងខោនធី ចំណែកមូលនិធិសហព័ន្ធភាគច្រើ នបានមកពីពន្ធលើប្រេងឥន្ធនៈរបស់សហព័ន្ធ។ មូលនិធិរដ្ឋភាគច្រើនបាន មកពីពន្ធលើប្រេងឥន្ធនៈ និងរថយន្តរបស់រដ្ឋ។ មូលនិធិរដ្ឋមានការកើនឡើ ងប្រហែលបីភាគបួនក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះភាគច្រើនគឺដោយសា រតែច្បាប់ថ្មីៗនេះ។

ច្បាប់មូលនិធិគមនាគមន៍រដ្ឋថ្មីៗនេះ។ នៅឆ្នាំ 2017 អង្គនីតិប ញ្ញត្តិបានអនុម័តសេចក្តីព្រាងច្បាប់ព្រឹទ្ធសភា (SB) 1 ដើម្បីបង្កើ នមូលនិធិរដ្ឋប្រចាំឆ្នាំសម្រាប់គមននាគមន៍តាមរយៈពន្ធលើប្រេង ឥន្ធនៈ និងរថយន្តផ្សេងៗជាច្រើន (បង្ហាញក្នុងរូបភាពលេខ 1)។ ជាពិសេស SB 1 បានបង្កើនអាករពិសេសលើសាំងធម្មតា (ត្រឹម 12 សេនក្នុងមួយហ្គាឡុង) និងពន្ធលក់ប្រេងម៉ាស៊ូត (ត្រឹម 4 ភាគរយ)។ វាក៏បានកំណត់នូវអត្រាថេរទៅលើអាករពិសេសលើសាំងទីពីរ (បន្ថែមពីលើ) និងអាករពិសេសលើប្រេងម៉ាស៊ូត ដែលអាករពិសេស ទាំងពីរនេះអាចមានការផ្លាស់ប្តូរជារៀងរាល់ឆ្នាំផ្អែកទៅលើតម្លៃប្រេងឥ ន្ធនៈ។ បន្ថែមពីលើនេះទៀត SB 1 បានបង្កើតនូវថ្លៃឈ្នួលកែលម្អគម នាគមន៍ (ដែលមានលំដាប់ចាប់ពី $25 ដល់ $175 ក្នុងមួយឆ្នាំ) និង

បំបាត់ចោលមូលនិធិការជួសជុលផ្លូវ និងគមនាគមន៍មួយចំនួន។ តម្រូវឲ្យមានពន្ធប្រេងឥន្ធនៈ និងថ្លៃរថយន្តមួយចំនួន ត្រូវបានអនុម័តដោយអង្គបោះឆ្នោត។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ។

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

ថ្លៃឈ្នួលសម្រាប់រថយន្តដែលគ្មានការបំភាយឧស្ម័ន (កំណត់នៅតម្លៃ $100 ក្នុងមួយឆ្នាំ សម្រាប់ឆ្នាំគំរូ 2020 និងឆ្នាំក្រោយៗទៀត)។ វាក៏ផ្តល់នូវការលៃតម្រូវអតិផរណានៅពេលអនាគតផងដែរ។ ឆ្នាំសារពើពន្ធនេះ រដ្ឋរំពឹងថាពន្ធនឹងកើនឡើង $4.4 ពាន់លានដុល្លារ។ ពីរឆ្នាំគិតចាប់ពីពេលនេះ នៅពេលពន្ធទាំងអស់មានប្រសិទ្ធភាព ហើយការលៃតម្រូវអតិផរណាបានចាប់ផ្តើម រដ្ឋរំពឹងថាពន្ធកើនឡើង $5.1 ពាន់លានដុល្លារ។ រដ្ឋធម្មនុញ្ញ តម្រូវឲ្យចំណូលថ្មីស្ទើរតែទាំងអស់នេះ ត្រូវចំណាយទៅលើគោលបំណងគមនាគមន៍។ សេចក្តីព្រាងច្បាប់ព្រឹទ្ធសភា 1 ប្រើប្រាស់ប្រហែលពីរភាគបីនៃចំណូលទៅលើការជួសជុលមហាវិថី និងផ្លូវថ្នល់ ចំណែកចំណូលដែលនៅសេសសល់ប្រើប្រាស់ទៅលើកម្មវិធីផ្សេងៗ (ដូចជា សម្រាប់ផ្លូវឆ្លងកាត់ទ្រង់ទ្រាយធំ)។

សេចក្តីស្នើច្បាប់

តម្រូវឲ្យអង្គនីតិបញ្ញត្តិទទួលបានការអនុម័តពីអ្នកបោះឆ្នោតសម្រាប់ពន្ធលើប្រេងឥន្ធនៈ និងរថយន្ត។ សំណើប្រជាមតិ 6 ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីតម្រូវឲ្យអង្គនីតិបញ្ញត្តិទទួលបានការអនុម័តពីអ្នកបោះឆ្នោតសម្រាប់ពន្ធថ្មី ឬពន្ធដែលបានបង្កើនលើការលក់ ការស្តុកទុក ឬការប្រើប្រាស់សាំង ឬប្រេងម៉ាស៊ូត ក៏ដូចជាសម្រាប់ពន្ធដែលបង់សម្រាប់ឯកសិទ្ធិនៃប្រតិបត្តិការរបស់រថយន្តនៅលើមហាវិថីសាធារណៈ។ ដូច្នេះ អង្គនីតិបញ្ញត្តិនឹងត្រូវការការអនុម័តពីអ្នកបោះឆ្នោតសម្រាប់ពន្ធដូចជា ពន្ធអាករពិសេស និងពន្ធលើការលក់សាំង និងម៉ាស៊ូត ថ្លៃឈ្នួលអាជ្ញាប័ណ្ណរថយន្ត និងថ្លៃឈ្នួលកែលម្អគមនាគមន៍។

លុបបំបាត់ពន្ធលើប្រេងឥន្ធនៈ និងរថយន្តដែលបានអនុម័តថ្មីៗនេះ។ សំណើប្រជាមតិ 6 ក៏លុបបំបាត់រាល់ពន្ធលើប្រេងឥន្ធនៈ និងរថយន្តដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិក្រោយ ថ្ងៃទី 1 ខែមករាឆ្នាំ 2017 និងរហូតដល់កាលបរិច្ឆេទដែល សំណើប្រជាមតិ 6 ចូលជាធរមាននៅខែធ្នូ។ ការនេះ នឹងលុបបំបាត់នូវពន្ធដែលបានបង្កើនលើប្រេងឥន្ធនៈ និងថ្លៃឈ្នួលកែលម្អគមនាគមន៍ដែលបានអនុម័តដោយ SB 1។

ផលប៉ះពាល់សារពើពន្ធ

លុបបំបាត់ចំណូលលើពន្ធពី SB 1។ នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន សំណើប្រជាមតិ 6 នឹងកាត់បន្ថយចំណូលលើពន្ធ SB 1 ពី $4.4 ពាន់លានដុល្លារមកនៅត្រឹម $2 ពាន់លានដុល្លារ—ថយចុះ$2.4 ពាន់លានដុល្លារ ។ ($2 ពាន់លានដុល្លារនៅក្នុងចំណូលដែលនៅសេសសល់ នឹងបានមកពីពន្ធដែលប្រមូលមុនពេលដែលសំណើប្រជាមតិ 6 ចូលជាធរមាននៅខែធ្នូ។) ពីរឆ្នាំ គិតចាប់ពីពេលនេះ ការកាត់បន្ថយចំណូលនឹងមានចំនួនសរុប $5.1 ពាន់លានដុល្លារ ប្រចាំឆ្នាំ។ ការកាត់បន្ថយមូលនិធិ នឹងប៉ះពាល់ភាគច្រើនទៅលើកម្មវិធីថែទាំ និងជួលជុលមហាវិថី និងផ្លូវថ្នល់ ក៏ដូចជាកម្មវិធីផ្លូវឆ្លងកាត់ផងដែរ។

ធ្វើឲ្យការអនុម័តពន្ធលើប្រេងឥន្ធនៈ និងរថយន្តកំណត់ជាក់លាក់កាន់តែពិបាក។ សំណើប្រជាមតិ 6 នឹងធ្វើឲ្យកាន់តែពិបាកក្នុងការអនុម័តពន្ធលើប្រេងឥន្ធនៈ និងរថយន្តកំណត់ជាក់លាក់ ពីព្រោះអ្នកបោះឆ្នោតក៏នឹងត្រូវអនុម័តលើពន្ធទាំងនោះដែរ។ ជាលទ្ធផល អាចមានចំណូលកាន់តែតិចពុំដូច្នោះទេនឹងជាករណីមួយ។ រាល់ការកាត់បន្ថយចំណូលពុំត្រូវបានដឹងឡើយ ពីព្រោះវានឹងអាស្រ័យទៅលើចំណាត់ការនាពេលអនាគតដោយអង្គនីតិបញ្ញត្តិ និងអ្នកបោះឆ្នោត។

រូបភាពលេខ 1

ចំណូលពីសេចក្តីព្រាងច្បាប់ព្រឹទ្ធសភា 1

	អត្រាពន្ធ		ចំណូលប្រចាំឆ្នាំ (គិតជាពាន់លាន)	
	អត្រាពីមុន	អត្រាថ្មី	ឆ្នាំ បច្ចុប្បន្ន	ក្នុងរយៈពេលពីរឆ្នាំ
ពន្ធលើសាំង				
អាករពិសេស (ធម្មតា)	18 សេន	30 សេន	$1.9	$2.1
អាករពិសេស (បន្ថែមពីលើ)	ប្រែប្រួល[a]	17.3 សេន	—[b]	0.2
ពន្ធលើម៉ាស៊ូត				
អាករពិសេស	ប្រែប្រួល[c]	36 សេន	0.7	0.7
ការលក់	1.75 សេន	5.75 សេន	0.3	0.4
ពន្ធលើរថយន្ត				
ថ្លៃកែលម្អគមនាគមន៍	—	$25 ដល់ $175	1.5	1.6
ថ្លៃឈ្នួលរថយន្តដែលគ្មានការបំភាយឧស្ម័ន	—	$100	—[b]	—[d]
សរុប			**$4.4**	**$5.1**

[a] កំណត់ប្រចាំឆ្នាំផ្អែកលើតម្លៃ។ អត្រាបច្ចុប្បន្នគឺ 11.7 សេន ប៉ុន្តែអត្រាមានលំដាប់ចាប់ពី 9.8 សេន ដល់ 21.5 សេន កាលពីមុន។
[b] អត្រាថ្មីពុំទាន់មានប្រសិទ្ធភាពទេ។
[c] កំណត់ប្រចាំឆ្នាំផ្អែកលើតម្លៃ។ អត្រាថ្មីបំផុតគឺ 16 សេន ប៉ុន្តែអត្រាមានលំដាប់ចាប់ពី 10 សេន ដល់ 18 សេន កាលពីមុន។
[d] $48 លាន។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជី នៃគណៈកម្មការដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីទទួលបានអ្នកចូលរួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានធ្វើទៅអ្នកដោយឥតគិតថ្លៃ។

បំបាត់ចោលមូលនិធិការជួសជុលផ្លូវ និងគមនាគមន៍មួយចំនួន។ តម្រូវឲ្យមានពន្ធប្រេងឥន្ធនៈ និងថ្លៃរថយន្តមួយចំនួន ត្រូវបានអនុម័តដោយអង្គបោះឆ្នោត។ ការផ្តើមប្រជាសិទ្ធិវិសោធនកម្មរដ្ឋធម្មនុញ្ញ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 6 ★

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 6 ដើម្បី *បន្ទាបតម្លៃដែលអ្នកបង់សម្រាប់សាំងភ្លាមៗ។*

សំណើប្រជាមតិ 6 ធ្វើកិច្ចការពីរយ៉ាង។ វាលុបចោលការបង្កើនទ្រង់ទ្រាយធំនូវពន្ធលើហ្គាស ម៉ាស៊ូត និងរថយន្ត ដែលតម្រូវឲ្យបង់ពន្ធដោយអង្គនីតិបញ្ញត្តិកាលពីឆ្នាំមុន។ ទីពីរ វាតម្រូវឲ្យមានការអនុម័តពីអ្នកបោះឆ្នោតសម្រាប់រាល់ការប៉ុនប៉ងនាពេលអនាគតដោយអង្គនីតិបញ្ញត្តិក្នុងការធ្វើវាម្តងទៀត។ តែប៉ុណ្ណឹងទេ។

នេះគឺជាមូលហេតុដែលសំណើប្រជាមតិ 6 សមនឹងទទួលបានការបោះឆ្នោតគាំទ្រ ពីអ្នក ៖

អង្គហេតុ៖ ចំណាយក្នុងការរស់នៅរដ្ឋ Californiaឡើងស្រឹតៗ ហើយគ្រួសារដែលជាកម្មករនិយោជិតកម្រនឹងដើរតាមទាន់ណាស់។ កំណើនពន្ធលើហ្គាស និងរថយន្ត អាចធ្វើឲ្យគ្រួសារដែលមានសមាជិកបួននាក់ត្រូវចំណាយលើសពី $500 ក្នុងមួយឆ្នាំ! នោះមិនមែនជាកាក់ឬសេនទេ នោះគឺជាលុយពិតៗ។

អង្គហេតុ៖ កំណើនពន្ធលើហ្គាសមិនយុត្តិធម៌ឡើយ។ វាគឺជាពន្ធត្រឡប់ក្រោយដែលបង្ករការលំបាកដល់គ្រួសារដែលជាកម្មករនិយោជិត និងគ្រួសារក្រីក្រច្រើនជាងគ្រួសារអ្នកមាន។

អង្គហេតុ៖ ពលរដ្ឋ California បង់ប្រាក់ប្រហែល 95.5 សេន ជូនរដ្ឋាភិបាលសម្រាប់រាល់ហ្គាឡុងនៃហ្គាស។ នោះគឺប្រហែល *$18 នៅក្នុងពន្ធ និងថ្លៃឈ្នួលលើការចាក់បំពេញជាទូទៅ*—**គឺច្រើនជាងការដែលអ្នកបើកបរបង់ប្រាក់នៅក្នុងរដ្ឋផ្សេងទៀត។**

អង្គហេតុ៖ រដ្ឋ California មានអតិរេកថវិកា $16 ពាន់លាន ប៉ុន្តែអ្នកនយោបាយនៅ Sacramento បានសម្រេចចំណាយប្រាក់រាប់ពាន់លាននៅឆ្នាំនេះទៅលើគម្រោងសំណព្វចិត្តរបស់ពួកគេ ជំនួសឲ្យការកែលម្អផ្លូវថ្នល់ ស្ពាន និងមហាវិថី។ តាមពិតទៅ អង្គនីតិបញ្ញត្តិបានកាត់បន្ថយមូលនិធី Caltrans ជាក់ស្តែងត្រឹម 18 ភាគរយក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ។

អង្គហេតុ៖ 72% នៃពន្ធ និងថ្លៃឈ្នួលទាក់ទងនឹងរថយន្តទាំងអស់របស់រដ្ឋ ដែលបានប្រមូលដោយរដ្ឋ ត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីផ្សេងៗក្រៅពីផ្លូវថ្នល់ និងមហាវិថី។ វាជាពេលដែលត្រូវបញ្ចប់ល្បែងនយោបាយមូលនិធិគមនាគមន៍ហើយ។

(ពិនិត្យមើលអង្គហេតុទាំងនេះ និងស្វែងយល់បន្ថែមនៅ GiveVotersAVoice.com)

កុំឆ្គួតនឹងអ្នកប្រឆាំងដែលអះអាងថាគ្មានលុយជួសជុលផ្លូវថ្នល់ ប្រសិនបើសំណើប្រជាមតិ 6 ត្រូវបានអនុម័ត។ ប្រសិនបើពន្ធ និងថ្លៃឈ្នួលទាក់ទងនឹងគមនាគមន៍ដែលយើងបានបង់រួច *មុនពេល* **កំណើនពន្ធថ្មីនេះចូលជាធរមានត្រូវបានចំណាយទៅលើគមនាគមន៍នោះ—រដ្ឋនឹងមាន $5.6 ពាន់លានដុល្លារ ប្រចាំឆ្នាំសម្រាប់តម្រូវការគមនាគមន៍** *ដោយពុំចាំបាច់* **ដំឡើងពន្ធ។**

ហេតុដូច្នេះហើយទើបអ្នកជំនាញផ្នែកគមនាគមន៍អញ្ញាក្រឹត្យយល់ស្របនឹងតម្រូវការរបស់អង្គនីតិបញ្ញត្តិក្នុងការផ្តល់អាទិភាពលើការចំណាយរបស់ខ្លួន ហើយកំណើនពន្ធលើហ្គាស និងរថយន្តមិនចាំបាច់ត្រូវជួសជុលផ្លូវថ្នល់ឡើយ។

"ការខ្ជះខ្ជាយលុយរបស់អ្នកជាប់ពន្ធដែលចំណាយទៅលើគមនាគមន៍គឺជារឿងល្អីល្ហាញ។ រដ្ឋ California អាចមានផ្លូវថ្នល់អស្ចារ្យ ប្រសិនបើរដ្ឋគ្រាន់តែអនុម័តកំណែទម្រង់មូលដ្ឋាន។"—**Robert K. Best, អតីតប្រធាន Caltrans**

មុនពេលដំឡើងពន្ធលើហ្គាស និងរថយន្តត្រឹម $52 ពាន់លានដុល្លារ ក្នុងរយៈពេល 10 ឆ្នាំអង្គនីតិបញ្ញត្តិគួរតែបោសសម្អាតអំពើពុករលួយ និងអប្រសិទ្ធភាពដែលបណ្តាលឲ្យរដ្ឋ California ត្រូវចំណាយ 62% លើសពីមធ្យមភាគជាតិក្នុងការកសាងចំណែកផ្លូវមហាវិថី។

ពលរដ្ឋ California ជិតមួយលាននាក់ រងការឈឺចាប់ពីតម្លៃហ្គាសខ្ពស់—ម្ចាស់អាជីវកម្មខ្នាតតូច គ្រូបង្រៀន និវត្តជន សមាជិកសហជីព—បានចុះហត្ថលេខាលើបណ្តឹងទាមទារដើម្បីដាក់សំណើប្រជាមតិ 6 នៅលើសន្លឹកឆ្នោត។

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីឲ្យគ្រួសារអ្នកសន្សំលុយរាប់រយដុល្លារក្នុងមួយឆ្នាំ ដោយលុបចោលនូវការដំឡើងពន្ធលើហ្គាស និងរថយន្តដែលមិនចាំបាច់—និងបញ្ចប់ល្បែងនយោបាយដែលអ្នកនយោបាយ Sacramento លេងជាមួយនឹងមូលនិធិគមនាគមន៍របស់យើង។

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីជួយឲ្យគ្រួសារជីវភាពមធ្យម និងគ្រួសារដែលជាកម្មករនិយោជិតរបស់រដ្ឋ California មានលុយចំណាយគ្រប់គ្រាន់។

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីទាមទារថា អ្នកនយោបាយត្រូវចំណាយលុយបង់ពន្ធគមនាគមន៍របស់យើងតាមបំណង និងតាមការសន្យា—ដើម្បីថែទាំផ្លូវថ្នល់ មហាវិថី និងស្ពានរបស់យើង។

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីបន្ទាបតម្លៃហ្គាសភ្លាមៗ!

JOHN COX, ប្រធានកិត្តិយស
ផ្តល់ជូនអ្នកបោះឆ្នោតនូវសំឡេង—គាំទ្រ លើសំណើប្រជាមតិ 6
DELORES CHAVEZ, ប្រធាន
សមាគមអ្នកនយោបាយអាមេរិកឡាទីន
PEGGI BUFF, ប្រធាន
សមាគមភាពជាអ្នកដឹកនាំស្ត្រីរដ្ឋ California

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 6 ★

កុំយល់ច្រឡំ។ អ្នកនយោបាយនៅក្រៅរដ្ឋ និងការប្រាក់ពិសេសបានចំណាយលុយរាប់លានដើម្បីដាក់បញ្ចូលសំណើប្រជាមតិ 6 នៅលើសន្លឹកឆ្នោត។ សំណើប្រជាមតិ 6 នឹងធ្វើឲ្យស្ពាន ផ្លូវថ្នល់ និងប្រព័ន្ធគមនាគមន៍របស់យើងកាន់តែគ្មានសុវត្ថិភាព ហើយយើងនឹងត្រូវបង់លុយកាន់តែច្រើនរយៈពេលយូរ ពីព្រោះផ្លូវថ្នល់បន្តទ្រុឌទ្រោមថែមទៀត។

អង្គហេតុ៖ សំណើប្រជាមតិ 6 ពុំមានបទបញ្ញត្តិណាមួយដែលធានាថា តម្លៃហ្គាសរបស់យើងនឹងត្រូវបានកាត់បន្ថយឡើយ។

អង្គហេតុ៖ អ្នកបោះឆ្នោតអនុម័តសំណើប្រជាមតិ 69 យ៉ាងច្រើនលើសលប់នៅខែមិថុនា ដែលបង្ការអ្នកនយោបាយនៅ Sacramento ពីការលួចឆ្នក់មូលនិធិគមនាគមន៍ និងធានាថាមូលនិធិទាំងនេះត្រូវបានប្រើប្រាស់សម្រាប់តែការកែលម្អគមនាគមន៍ប៉ុណ្ណោះ។

អង្គហេតុ៖ សំណើប្រជាមតិ 6 លុបបំបាត់ប្រាក់ $5 ពាន់លានប្រចាំឆ្នាំនៅក្នុង *មូលនិធិគមនាគមន៍ដែលមានស្រាប់* **ហើយនឹងប៉ះពាល់ដល់គម្រោងគមនាគមន៍ក្នុងមូលដ្ឋានជាង 6,500 គម្រោង** *ដែលកំពុងដំណើរការបច្ចុប្បន្ន* **ទូទាំងរដ្ឋ California។ ពេលនេះមិនមែនជាពេលដែលត្រូវបញ្ឈប់ដំណើរការឡើយ។**

អង្គហេតុ៖ សំណើប្រជាមតិ 6 គំរាមកំហែងដល់សុវត្ថិភាពសាធារណៈ។ រដ្ឋ California មានស្ពាន និងផ្លូវដែលឆ្លងកាត់ពីលើជាង 1,600 ដែលមានឱនភាព និងគ្មានសុវត្ថិភាពផ្នែករចនាសម្ព័ន្ធ ហើយ 89% នៃខោនធីមានផ្លូវថ្នល់ដែលមានចំណាត់ថ្នាក់ស្ថានភាព "អន់" ឬ "មានហានិភ័យ" ។ សំណើប្រជាមតិ 6 លុបបំបាត់គម្រោងដែលធ្វើការជួសជុលសុវត្ថិភាពស្ពាន និងផ្លូវដែលឆ្លងកាត់ពីលើ និងជួសជុលផ្លូវថ្នល់ដែលគ្រោះថ្នាក់។

អង្គហេតុ៖ សំណើប្រជាមតិ 6 នឹងធ្វើឲ្យអ្នកបើកបរត្រូវចំណាយច្រើនក្នុងរយៈពេលវែង។ អ្នកបើកបរជាមធ្យមត្រូវចំណាយ $739 ក្នុងមួយឆ្នាំទៅលើចំណាយលើរថយន្តដូចជា ការថ្លឹងលៃតម្រូវផ្នែកខាងមុខ និងផ្នែកខាងក្រោយរថយន្ត ការជួសជុលបូម និងសំបកកង់ ដែលបណ្តាលមកពីស្ថានភាពផ្លូវថ្នល់ដែលអន់។ វិធានការនេះនឹងធ្វើឲ្យស្ថានភាពផ្លូវថ្នល់កាន់តែអន់ថែមទៀត ហើយធ្វើឲ្យយើងត្រូវចំណាយកាន់តែច្រើនទៅលើការជួសជុលរថយន្តដោយគ្មានការរំពឹងទុក។

សំណើប្រជាមតិ 6 ត្រូវបានប្រឆាំងដោយអង្គការជាង 200 អង្គការ រួមមានជាអាទិ៍ ៖ • អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California • សង្គមវិស្វករស៊ីវិលអាមេរិក • សម្ព័ន្ធអ្នកបោះឆ្នោតស្ត្រីរដ្ឋ California • សភាពាណិជ្ជកម្មរដ្ឋ California • សមាគមត្រង់ស៊ីតរដ្ឋ California • សមាជមនុស្សចាស់រដ្ឋ California • សម្ព័ន្ធពលរដ្ឋអាមេរិកឡាទីនរដ្ឋ California (LULAC) • សមាគមអាជីវកម្មឡាទីន • សមាគមអ្នកល្បាតមហាវិថីរដ្ឋ California

ច្រានចោលសំណើប្រជាមតិn 6—បញ្ឈប់ការវាយលុកលើសុវត្ថិភាពស្ពាន & ផ្លូវថ្នល់។

www.NoProp6.com

BRIAN K. RICE, ប្រធាន
អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California
MARK GHILARDUCCI, នាយក
ការិយាល័យសេវាសង្គ្រោះបន្ទាន់រដ្ឋ California
YVONNE GONZALEZ DUNCAN, រដ្ឋនាយក
សម្ព័ន្ធពលរដ្ឋអាមេរិកឡាទីនរដ្ឋ California (LULAC)

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 6 ★

បោះឆ្នោតប្រឆាំង លើសំណើប្រជាមតិ 6៖ បញ្ឈប់ការវាយលុកលើសុវត្ថិភាពស្ពាន & ផ្លូវថ្នល់

អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California, សមាគមអ្នកល្បាតមហាវិថីរដ្ឋ California, សង្គមវិស្វករស៊ីវិលអាមេរិក និងអ្នកឆ្លើយតបដំបូងជំរុញ ទេ លើសំណើប្រជាមតិ 6 ពីព្រោះវានឹងបញ្ឈប់គម្រោងគមនាគមន៍សំខាន់ៗ និងបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពស្ពាន និងផ្លូវថ្នល់យើង។

សំណើប្រជាមតិ 6 លុបបំបាត់ $5 ពាន់លាន ប្រចាំឆ្នាំនៅក្នុង *មូលនិធិដែលមានស្រាប់* ដែលប្រើប្រាស់ក្នុងការជួសជុលផ្លូវថ្នល់ ស្ពាន និងហេដ្ឋារចនាសម្ព័ន្ធ។ សំណើប្រជាមតិ 6 នឹងបញ្ឈប់គម្រោង *ដែលកំពុងដំណើរការបច្ចុប្បន្ន* ទូទាំងរដ្ឋ California ដើម្បីធ្វើឲ្យប្រសើរឡើងនូវស្ពាន និងផ្លូវដែលឆ្លងកាត់ពីលើ ដើម្បីបំពេញតាមស្តង់ដារសុវត្ថិភាពរញ្ជួយដី និងដើម្បីកែលម្អសុវត្ថិភាពផ្លូវថ្នល់របស់យើង។

ទាំងនេះគឺជាអង្គហេតុ៖ • រដ្ឋ California មានស្ពាន និងផ្លូវដែលឆ្លងកាត់ពីលើជាង 1,600 ដែលមានឱនភាព និងគ្មានសុវត្ថិភាពផ្នែករចនាសម្ព័ន្ធ។ • ប៉ែតសិបប្រាំបួនភាគរយ (89%) នៃខោនធីមានផ្លូវថ្នល់ដែលមានស្ពានភាព 'អន់' ឬ 'មានហានិភ័យ' ។ • យោងតាមរដ្ឋបាលសុវត្ថិភាពចរាចរណ៍មហាវិថីជាតិ មានមនុស្សស្លាប់ជាង 3,600 នាក់នៅលើដងផ្លូវថ្នល់រដ្ឋ California ក្នុងឆ្នាំ 2016។

ការកែលម្អស្ពានភាពផ្លូវថ្នល់ និងលក្ខណៈពិសេសសុវត្ថិភាពផ្លូវថ្នល់ ត្រូវបានគេរកឃើញថាមានប្រសិទ្ធភាពយ៉ាងច្រើនក្នុងការកែលម្អសុវត្ថិភាពចរាចរណ៍។

សំណើប្រជាមតិ 6 លុបបំបាត់មូលនិធិសម្រាប់គម្រោងកែលម្អសុវត្ថិភាពផ្លូវថ្នល់ និងគមនាគមន៍ជាង 6,500 គម្រោង

យោងតាមទីភ្នាក់ងារគមនាគមន៍រដ្ឋ California មានគម្រោងកែលម្អគមនាគមន៍ក្នុងមូលដ្ឋានជាង 6,500 គម្រោងដែលកំពុងដំណើរការនៅ *គ្រប់* សហគមន៍រដ្ឋ California រួមមានជាអាទិ៍៖ • គម្រោងចំនួន 3,727 ដែលជួសជុលគ្រលុក និងក្រាលកៅស៊ូឡើងវិញលើផ្លូវថ្នល់ដែលខូច និងគ្មានសុវត្ថិភាព • ការជួសជុលឬផ្លាស់ប្តូរស្ពាន និងផ្លូវដែលឆ្លងកាត់ពីលើចំនួន 554 • ការកែលម្អចំនួន 453 ដងទៅលើប្រតិបត្តិការ និងសេវាគមនាគមន៍សាធារណៈ រួមមានជាអាទិ៍ រថយន្តក្រុង និងរថភ្លើង • គម្រោងចំនួន 337 ដែលជួយបន្ធូរបន្ថយការកកស្ទះចរាចរណ៍

ប្រសិនបើសំណើប្រជាមតិ 6 ត្រូវបានអនុម័ត ការសាងសង់នឹងផ្អាកភ្លាមៗនៅក្នុងទីក្រុង និងខោនធីនានាទូទាំងរដ្ឋ ដែលធ្វើឲ្យខ្ជះខ្ជាយលុយ និងធ្វើឲ្យស្ថានភាពផ្លូវថ្នល់កាន់តែយ៉ាប់យ៉ឺនថែមទៀត។

អ្នកបោះឆ្នោតនិយាយឮខ្លាំង និងច្បាស់ៗដើម្បីប្រើប្រាស់មូលនិធិផ្លូវថ្នល់

អ្នកបោះឆ្នោតអនុម័តសំណើប្រជាមតិ 69 យ៉ាងច្រើនលើសលប់នៅខែមិថុនា ដែលបង្ការអ្នកនយោបាយនៅ Sacramento ពីការលួចឆ្នក់មូលនិធិគមនាគមន៍ និងធានាថាមូលនិធិទាំងនេះត្រូវបានប្រើប្រាស់សម្រាប់តែការកែលម្អគមនាគមន៍ប៉ុណ្ណោះ។ យើងមិនគួរលុបបំបាត់ចំណូលគមនាគមន៍ដែលមានគណនេយ្យ ភាពចំពោះអ្នកជាប់ពន្ធ មិនអាចបង្ហែរបាន ហើយអ្នកបោះឆ្នោតប្តេជ្ញាចិត្តយ៉ាងលើសលប់ចំពោះការជួសជុលផ្លូវថ្នល់យើង។

សំណើប្រជាមតិ 6 លុបបំបាត់ការងាររាប់ពាន់ និងធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចយើង

សភាពាណិជ្ជកម្មរដ្ឋ California ប្រឆាំងនឹង សំណើប្រជាមតិ 6 ពីព្រោះវាអាចលុបបំបាត់ការងារ 68,000 ប្រចាំឆ្នាំ និងប្រាក់ $183 ពាន់លាន នៅក្នុងការវិនិយោគសេដ្ឋកិច្ច ពីព្រោះគម្រោងសាងសង់ផ្លូវថ្នល់រាប់ពាន់គម្រោងត្រូវបានផ្អាក។

សុវត្ថិភាពសាធារណៈ និងអ្នកដឹកនាំមូលដ្ឋានប្រឆាំងនឹងសំណើប្រជាមតិ 6

• អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California • សមាគមអ្នកល្បាតមហាវិថីរដ្ឋ California • សង្គមវិស្វករស៊ីវិលអាមេរិក • អ្នកឆ្លើយតប និងគ្រូពេទ្យអមវេជ្ជសាស្ត្រគ្រាមានអាសន្ន • សភាពាណិជ្ជកម្មរដ្ឋ California • សម្ព័ន្ធអ្នកបោះឆ្នោតអភិរក្សនិយម california • ក្រុមប្រឹក្សាពាណិជ្ជកម្មអគារ & សំណង់រដ្ឋ California • សមាគមន៍ខោនធីរដ្ឋ California • សម្ព័ន្ធទីក្រុងរដ្ឋ California • សម្ព័ន្ធភាពសម្រាប់ការងាររដ្ឋ California • សមាគមអាជីវកម្មឡាទីន • California សមាគមជាតិសម្រាប់ការរីកចម្រើនរបស់ប្រជាពលរដ្ឋភាគតិច (National Association for the Advancement of Colored People, NAACP) • សមាជនៃព្រឹទ្ធាចារ្យរដ្ឋ California • សម្ព័ន្ធពលរដ្ឋអាមេរិកឡាទីនរដ្ឋ California (LULAC)

"អ្នកឆ្លើយតបគ្រាមានអាសន្ន មើលឃើញមុនគេនូវហានិភ័យផ្នែកសុវត្ថិភាពចំពោះអ្នកបើកបរដែលបង្ករឡើងដោយផ្លូវថ្នល់ខូច ស្ពានដែលគ្មានសុវត្ថិភាពរចនាសម្ព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធដែលហួសសម័យ។ តាមរយៈការបញ្ឈប់គម្រោងកែលម្អគមនាគមន៍រាប់ពាន់គម្រោងសំណើប្រជាមតិ 6 នឹងធ្វើឲ្យផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធគមនាគមន៍របស់យើងកាន់តែគ្មានសុវត្ថិភាព ហើយបណ្តាលឲ្យមានគ្រោះថ្នាក់ និងមនុស្សស្លាប់ដោយចរាចរណ៍កាន់តែច្រើន។"—**Mark Ghilarducci,** ប្រធាន ការិយាល័យសេវាសង្គ្រោះបន្ទាន់រដ្ឋ California

បញ្ឈប់ការវាយលុកលើសុវត្ថិភាពស្ពាន & ផ្លូវថ្នល់។ បោះឆ្នោតប្រឆាំងលើសំណើប្រជាមតិ 6

NoProp6.com

BRIAN K. RICE, ប្រធាន
អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California
KWAME AGYARE, នាយកប្រចាំតំបន់
សង្គមវិស្វករស៊ីវិលអាមេរិក
DOUG VILLARS, ប្រធាន
សមាគមអ្នកល្បាតមហាវិថីរដ្ឋ California

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 6 ★

ចំណាយក្នុងការរស់នៅក្នុងរដ្ឋ California គឺវាខ្ពស់ពេករួចទៅហើយ។ បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីបន្ទាបតម្លៃដែលអ្នកបង់នៅស្ថានីយ៍ប្រេងឥន្ធនៈ។

កុំឆ្គួតនឹងអ្នកប្រឆាំងការប្រាក់ពិសេស ដែលអះអាងថាគ្មានលុយជួសជុលស្ពាន និងផ្លូវថ្នល់ លុះត្រាតែពន្ធត្រូវបានដំឡើងនោះ។ ទាំងនេះគឺជាអង្គហេតុ៖

- **រដ្ឋាភិបាលមានអតិរេកថវិកា $16 ពាន់លាន ប៉ុន្តែអង្គនីតិបញ្ញត្តិបានសម្រេចចំណាយប្រាក់រាប់ពាន់លានឆ្នាំនេះទៅលើគម្រោងសំណព្វចិត្តរបស់ពួកគេ ជំនួសឲ្យការកែលម្អផ្លូវថ្នល់ ស្ពាន និងមហាវិថី។**
- **អ្នកនយោបាយ Sacramento បានកាត់បន្ថយមូលនិធិ Caltrans ត្រឹម 18 ភាគរយក្នុងរយៈពេលដប់ឆ្នាំកន្លងមកនេះ។ 72% នៃពន្ធ និងថ្លៃឈ្នួលទាក់ទងនឹងរថយន្តទាំងអស់របស់រដ្ឋ ត្រូវបានប្រើប្រាស់សម្រាប់កម្មវិធីផ្សេងៗ ក្រៅពីផ្លូវថ្នល់ និងមហាវិថី។**
- **ពន្ធលើប្រេងឥន្ធនៈកាន់តែខ្ពស់បានធ្លាក់ទៅលើអ្នកប្រើប្រាស់ ដែលបង្កើនតម្លៃទំនិញគ្រប់យ៉ាងដែលយើងទិញ។ ចំណាយនៅរដ្ឋ California គឺវាខ្ពស់ពេករួចទៅហើយ។ ការបង្កើនពន្ធទ្រង់ទ្រាយធំនេះធ្វើឲ្យអ្វីៗកាន់តែយ៉ាប់យ៉ឺនថែមទៀត។**

ម្យ៉ាងវិញទៀត អ្នកនិយោបាយមិនប្រាប់ឲ្យអ្នកបានដឹងឡើយ៖

សេចក្តីព្រាងច្បាប់ពន្ធលើហ្គាសដែលលាក់ទុករបស់អង្គនីតិបញ្ញត្តិគឺជាមូលហេតុ ដែលអនុញ្ញាតឲ្យពន្ធកើនឡើងដោយស្វ័យប្រវត្តិរៀងរាល់ឆ្នាំដោយគ្មានការបោះឆ្នោតពីប្រជាជន។

ពលរដ្ឋ California ជាច្រើនបានរងទុក្ខដោយសារតែចំណាយខ្ពស់ក្នុងការរស់នៅរួចទៅហើយ។ សំណើប្រជាមតិ 6 ធ្វើតែកិច្ចការពីរយ៉ាងប៉ុណ្ណោះ ដើម្បីជួយឲ្យការរស់នៅរដ្ឋ California កាន់តែមានលទ្ធភាពចំណាយបាន៖

ទីមួយ វាលុបចោលការបង្កើនពន្ធលើហ្គាស និងរថយន្តដែលអយុត្តិធម៌ និងទ្រង់ទ្រាយធំ។

ទីពីរ វាតម្រូវឲ្យមានការបោះឆ្នោតពីប្រជាជនមុនពេលអ្នកនយោបាយអាចសាកល្បងបង្កើនពន្ធលើហ្គាស និងរថយន្តម្តងទៀត។

បោះឆ្នោតគាំទ្រ លើសំណើប្រជាមតិ 6 ដើម្បីតម្លៃហ្គាសទាបជាងមុន!
ចូលមើល *www.GiveVotersAVoice.com* **និង** *www.GasTaxRepeal.org* **ដើម្បីស្វែងយល់បន្ថែម។**

លោក JON COUPAL, ប្រធាន
សមាគមអ្នកបង់ពន្ធ Howard Jarvis
JOHN KABATECK, នាយកប្រចាំរដ្ឋ California
សហព័ន្ធអាជីវកម្មឯករាជ្យជាតិ
JESSE ROJAS, ប្រធាន
គណៈកម្មាធិការ PAC សម្រាប់កម្មករកសិដ្ឋាន និងគ្រួសាររដ្ឋ California

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

សំណើប្រជាមតិ 7 អនុលោមម៉ោងសន្សំពន្លឺថ្ងៃនៅរដ្ឋ CALIFORNIA ទៅនឹងច្បាប់សហព័ន្ធ។ អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិប្តូររយៈពេលម៉ោងសន្សំពន្លឺថ្ងៃ។ លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។

ចំណងជើង និងសេចក្តីសង្ខេបជាផ្លូវការ **រៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័រ របស់រដ្ឋលេខាធិការតាមអាសយដ្ឋាន *http://voterguide.sos.ca.gov*។

- **បង្កើតតំបន់ពេលវេលាកំណត់ដោយច្បាប់សហព័ន្ធជា "ម៉ោងស្តង់ដារប៉ាស៊ីហ្វិក" ជាពេលវេលាស្តង់ដារ នៅក្នុងរដ្ឋ California។**
- **ផ្តល់ជូនថាម៉ោងសន្សំពន្លឺថ្ងៃនៅរដ្ឋ California ចាប់ផ្តើមនៅម៉ោង 2 ព្រឹកនៅថ្ងៃអាទិត្យទីពីរនៃខែមីនាហើយបញ្ចប់នៅម៉ោង 2 ព្រឹកនៅថ្ងៃអាទិត្យដំបូងនៃខែវិច្ឆិកាស្របតាមច្បាប់សហព័ន្ធបច្ចុប្បន្ន។**
- **អនុញ្ញាតឱ្យអង្គនីតិបញ្ញត្តិដោយការបោះឆ្នោតពីរភាគបី ដើម្បីធ្វើការផ្លាស់ប្តូរនាពេលអនាគត លើរយៈពេលម៉ោងសន្សំពន្លឺថ្ងៃរបស់រដ្ឋ California រួមបញ្ចូលទាំងការអនុវត្តប្រចាំឆ្នាំរបស់ខ្លួន ប្រសិនបើការផ្លាស់ប្តូរគឺស្របតាមច្បាប់សហព័ន្ធ។**

សេចក្តីសង្ខេបការវាយតម្លៃនៃការវិភាគរបស់អង្គ នីតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋា ភិបាលមូលដ្ឋាន និងរដ្ឋ៖

- **វិធានការនេះមិនមានឥទ្ធិពលសារពើពន្ធដោយផ្ទាល់ទេដោយសារតែការប្តូរ ម៉ោងសន្សំពន្លឺថ្ងៃអាស្រ័យលើសកម្មភាពនាពេលអនាគតដោយ អង្គនីតិបញ្ញត្តិនិងរដ្ឋាភិបាលសហព័ន្ធ។**

ការបោះឆ្នោតសម្រេចដោយអង្គនីតិបញ្ញត្តិនៅលើ AB 807 (សំណើប្រជាមតិ 7)
(ជំពូក 60, លក្ខន្តិកៈឆ្នាំ 2018)

ព្រឹទ្ធសភា៖	ការគាំទ្រ 26	ការប្រឆាំង 9
រដ្ឋសភា៖	ការគាំទ្រ 68	ការប្រឆាំង 6

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

សាវតា

ច្បាប់សហព័ន្ធបង្កើតម៉ោងសន្សំពន្លឺថ្ងៃសម្រាប់ផ្នែកនៃឆ្នាំ។ ច្បាប់សហព័ន្ធបង្កើតតំបន់ម៉ោងស្តង់ដារសម្រាប់តំបន់នីមួយៗនៃសហរដ្ឋ។ ឧទាហរណ៍ រដ្ឋ California រដ្ឋផ្សេងទៀតនៅភាគខាងលិចស្ថិតក្នុងក្នុងតំបន់ម៉ោងស្តង់ដារប៉ាស៊ីហ្វិក។ ច្បាប់សហព័ន្ធតម្រូវឲ្យម៉ោងស្តង់ដារនៃរដ្ឋនីមួយៗដើរមុនគ្នាមួយម៉ោង ចាប់ពីដើមខែមីនាដល់ដើមខែវិច្ឆិកា—កំឡុងពេលដែលគេស្គាល់ថាជាម៉ោងសន្សំពន្លឺថ្ងៃ (DST)។ អំឡុងពេលនៃ DST ព្រះអាទិត្យរះ និងព្រះអាទិត្យលិចកើតឡើងយឺតជាងធម្មតាមួយម៉ោង។ បច្ចុប្បន្ននេះ ច្បាប់សហព័ន្ធ ពុំអនុញ្ញាតឲ្យរដ្ឋអនុម័ត DST ពេញមួយឆ្នាំឡើយ។ ទោះជាយ៉ាងណា ច្បាប់សហព័ន្ធអនុញ្ញាតឲ្យរដ្ឋជ្រើសរើស DST និងនៅតែស្ថិតលើម៉ោងស្តង់ដារពេញមួយឆ្នាំ ដូចគ្នានឹងបច្ចុប្បន្ននេះមានករណីនៅក្នុងរដ្ឋ Arizona និង Hawaii។

រដ្ឋ California បានបោះឆ្នោតលើ DST ប្រហែល 70 ឆ្នាំ កន្លងមកហើយ។ នៅឆ្នាំ 1949 អ្នកបោះឆ្នោតនៅរដ្ឋ California បានអនុម័តវិធានការផ្តួចផ្តើមមួយ

ដែលបានបង្កើត DST នៅរដ្ឋ California។ អង្គនីតិបញ្ញត្តិអាចធ្វើការផ្លាស់ប្តូរលើវិធានការផ្តួចផ្តើមនោះតែតាមរយៈការដាក់ស្នើការផ្លាស់ប្តូរទាំងនោះជូនអ្នកបោះឆ្នោតដើម្បីស្នើសុំការអនុម័តពីពួកគេប៉ុណ្ណោះ។

សេចក្តីស្នើច្បាប់

សំណើប្រជាមតិ 7 អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិដែលមានសំឡេងឆ្នោតពីរភាគបីធ្វើការផ្លាស់ប្តូរ DST (ដូចជា តាមរយៈការស្ថិតនៅលើ DST ពេញមួយឆ្នាំ) ឲ្យតែការផ្លាស់ប្តូរនោះត្រូវបានអនុញ្ញាតដោយច្បាប់សហព័ន្ធ។ នៅពេលមានការផ្លាស់ប្តូរនោះ រដ្ឋ California នឹងរក្សាកំឡុងពេល DST បច្ចុប្បន្ន។

ឥទ្ធិពលលើសារពើពន្ធ

ពុំមានឥទ្ធិពលនៃសារពើពន្ធផ្ទាល់ទៅលើរដ្ឋ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋានឡើយ។ វិធានការនេះ នឹងពុំមានឥទ្ធិពលផ្ទាល់ទៅលើចំណាយ ឬចំណូលរបស់រដ្ឋ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋានឡើយ។ នេះគឺដោយសារតែរាល់ការប៉ះពាល់ នឹងអាស្រ័យទៅលើចំណាត់ការនាពេលអនាគតដោយអង្គនីតិបញ្ញត្តិ—ហើយជាសក្តានុពលគឺរដ្ឋាភិបាលសហព័ន្ធ—ធ្វើការផ្លាស់ប្តូរ DST។

ផលប៉ះពាល់ដែលអាចកើតមានដោយសារការផ្លាស់ប្តូរ DST។ ប្រសិនបើអង្គនីតិបញ្ញត្តិផ្លាស់ប្តូរ DST អាចមានឥទ្ធិពលផ្សេងៗជាច្រើន។ ឧទាហរណ៍ ប្រសិនបើអង្គនីតិបញ្ញត្តិអនុម័ត DST ពេញមួយឆ្នាំនោះ ព្រះអាទិត្យរះ និងព្រះអាទិត្យលិចនឹងកើតឡើងមួយម៉ោងបន្ទាប់ ចន្លោះខែវិច្ឆិកា និងខែមីនា។ ការផ្លាស់ប្តូរនេះ អាចប៉ះពាល់ដល់បរិមាណថាមពលសុទ្ធដែលប្រើប្រាស់សម្រាប់បំភ្លឺ កម្តៅ និងធ្វើឲ្យត្រជាក់នៅអំឡុងខែទាំងនោះ។ បន្ថែមពីលើនេះទៀត ប្រព័ន្ធបច្ចុប្បន្ននៃ DST អំឡុងផ្នែកនៃឆ្នាំ ទំនងជាប៉ះពាល់ដល់បរិមាណនៃការទទួលទានដំណេករបស់ប្រជាជនមួយចំនួននៅពេលប្តូរពីម៉ោងស្តង់ដារ និង DST ពីរដងក្នុងមួយឆ្នាំ។ ការនេះប៉ះពាល់អាចកើតមានទៅលើអ្វីៗ ដូចជា ផលិតភាពរបស់កម្មករនិយោជិក និងចំនួនគ្រោះថ្នាក់។ DST ពេញមួយឆ្នាំ នឹងលុបបំបាត់ឥទ្ធិពលទាំងនេះ។ ឥទ្ធិពលសុទ្ធនៃការផ្លាស់ប្តូរទាំងនេះទៅលើហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋាភិបាលថ្នាក់មូលដ្ឋាន ពុំមានភាពច្បាស់លាស់ទេ ប៉ុន្តែទំនងជាមានតិចតួច។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីទទួលបានអ្នកចូលរួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មាធិការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

អនុលោមម៉ោងសន្សំពន្លឺថ្ងៃនៅរដ្ឋ CALIFORNIA ទៅនឹងច្បាប់សហព័ន្ធ។
អនុញ្ញាតឲ្យអង្គនីតិបញ្ញត្តិបួនរយៈពេលម៉ោងសន្សំពន្លឺថ្ងៃ។
លក្ខន្តិកៈអង្គនីតិបញ្ញត្តិ។

★ ទឡ្ឍីករណ៍គាំទ្រសំណើប្រជាមតិលេខ 7 ★

តើយើងខាតបង់អ្វីខ្លះក្នុងការផ្លាស់ប្តូរម៉ោងរបស់យើងពីរដងក្នុងមួយឆ្នាំ? នេះជាការពិតមួយចំនួនដើម្បីពិចារណា។

ការសិក្សាវេជ្ជសាស្ត្រនៅសាកលវិទ្យាល័យក្នុងឆ្នាំ 2012 បានរកឃើញថា ហានិភ័យនៃការគាំងបេះដូងកើនឡើង 10% ក្នុងរយៈពេល 2 ថ្ងៃបន្ទាប់ពីមានការប្តូរម៉ោង។

នៅឆ្នាំ 2016 ការស្រាវជ្រាវបន្ថែមបានបង្ហាញថាហានិភ័យនៃជំងឺដាច់សរសៃឈាមខួរក្បាលកើនឡើង 8% នៅពេលយើងប្តូរម៉ោងរបស់យើង។ សម្រាប់អ្នកជំងឺមហារីក ហានិភ័យនៃជំងឺដាច់សរសៃឈាមខួរក្បាលកើនឡើង 25% ហើយសម្រាប់អ្នកដែលមានអាយុលើសពី 65 ឆ្នាំ ហានិភ័យនៃជំងឺដាច់សរសៃឈាមខួរក្បាលកើនឡើង 20%។ ទាំងអស់នេះកើតឡើងព្រោះយើងរំខានទម្រង់នៃដំណេករបស់យើង។

ឪពុកម្តាយគ្រប់រូបច្បាស់ជាដឹងហើយថាមានរឿងអ្វីកើតឡើងនៅពេលដែលទម្រង់នៃដំណេកកូនរបស់យើងត្រូវបានរំខានពីរដងក្នុងមួយឆ្នាំ។

ឥឡូវ សូមពិចារណាអំពីលុយ។ ការប្តូរម៉ោងបស់យើងពីរដងក្នុងមួយឆ្នាំបង្កើនការប្រើប្រាស់អគ្គិសនីរបស់យើង 4% នៅតាមតំបន់ជាច្រើននៃពិភពលោក បង្កើនបរិមាណប្រេងឥន្ធនៈដែលយើងប្រើប្រាស់ក្នុងឡានរបស់យើង ហើយសរុបជាទឹកប្រាក់គឺមានតម្លៃ $434 លានដុល្លារ។ នោះជាលុយដែលយើងអាចសន្សំបាន។

ការប្តូរម៉ោងរបស់យើងមិនប្តូរម៉ោងដែលព្រះអាទិត្យរះ ឬលិចនោះទេ។ ព្រះអាទិត្យរះ ឬលិចនៅពេលណានោះគឺធម្មជាតិជាអ្នកកំណត់។ រយៈពេលភ្លឺនៅរដូវក្តៅនឹងតែងតែយូរ។ រយៈពេលភ្លឺនៅរដូវរងារនឹងតែងតែខ្លី។

ចាប់តាំងពីឆ្នាំ 2000 មក ប្រទេសចំនួន 14 បានបញ្ឈប់ការប្តូរម៉ោង។ ហើយបច្ចុប្បន្ន 68% នៃបណ្តាប្រទេសទាំងអស់មិនមានការប្តូរម៉ោងទេ។ ពួកគេអនុញ្ញាតឱ្យធម្មជាតិកំណត់ពេលវេលា មិនមែនរដ្ឋាភិបាលរបស់គេទេ។

ការកាត់បន្ថយហានិភ័យសុខភាព។

ការកាត់បន្ថយការប្រើប្រាស់ថាមពល។ ការសន្សំសំចៃ។

ការបោះឆ្នោតគាំទ្រ សំណើប្រជាមតិលេខ 7 អនុញ្ញាតឱ្យរដ្ឋ California ពិចារណាពីការប្តូរម៉ោងសន្សំពន្លឺថ្ងៃ ឬម៉ោងស្តង់ដារ ឱ្យទៅជាម៉ោងសម្រាប់ពេញមួយឆ្នាំ—ធ្វើការផ្លាស់ប្តូរអ្វីផ្សេងដែលសំខាន់ជាងការប្តូរម៉ោងរបស់យើង។ សំណើប្រជាមតិលេខ 7 នឹងតម្រូវឱ្យមានការបោះឆ្នោតពីរភាគបីនៃសភា មុនពេលការសម្រេចចុងក្រោយណាមួយត្រូវបានធ្វើឡើង។

សមាជិកសភា KANSEN CHU
មណ្ឌលទី 25 នៃសភារដ្ឋ California

សមាជិកសភា LORENA GONZALEZ
សភាតំណាងរាស្ត្រថ្នាក់រដ្ឋ មណ្ឌល 80

វេជ្ជបណ្ឌិត SION ROY **វេជ្ជបណ្ឌិត ឯកទេសជំងឺបេះដូង**

★ការឆ្លើយតបទៅនឹងទឡ្ឍីករណ៍ក្នុងការគាំទ្រសំណើប្រជាមតិលេខ 7★

អ្នកគាំទ្រម៉ោងសន្សំពន្លឺថ្ងៃ អចិន្ត្រៃ លើកហេតុផលថាវានឹងជួយសន្សំថាមពលរបស់យើង។ វាមិនពិតទេ។ ការសិក្សាជាច្រើនត្រូវបានធ្វើឡើងលើប្រធានបទនេះ ហើយគ្មានភស្តុតាងជាក់ស្តែងណាដែលបង្ហាញថាម៉ោងសន្សំពន្លឺថ្ងៃនឹងជួយសន្សំសំចៃយើងទេ។ ការបង្កើនសក្តានុពលណាមួយក្នុងស្ថានភាពវេជ្ជសាស្ត្រត្រូវយកមកពិចារណាធៀបនឹងគ្រោះថ្នាក់នៃភាពងងឹតនៅពេលព្រឹកក្នុងរដូវរងារ។

ការប្តូរម៉ោងរបស់យើងពីរដងក្នុងមួយឆ្នាំអាចមិនស្រួលទេ។ ប៉ុន្តែការតម្រូវឱ្យចាប់ផ្តើមថ្ងៃក្នុងភាពងងឹតនារដូវរងាគឺពិតជាមិនងាយស្រួលទេ - វាអាចបង្កគ្រោះថ្នាក់។ វា អាចបង្កគ្រោះថ្នាក់សម្រាប់កុមារដែលធ្វើដំណើរទៅសាលារៀន ឬរង់ចាំរថយន្តក្រុងនៅក្នុងភាពងងឹត ហើយក៏គ្រោះថ្នាក់សម្រាប់មនុស្សពេញវ័យដែលត្រូវចាប់ផ្តើមធ្វើដំណើរទៅធ្វើការនៅក្នុងភាពងងឹតដែរ។ ការពិសោធន៍ដែលបរាជ័យដូចគ្នានេះនៅក្នុងឆ្នាំ 1974 ក្នុងការប្រើម៉ោងសន្សំពន្លឺថ្ងៃ ពេញមួយឆ្នាំ បានបញ្ជាក់ពីការពិតដ៏គ្រោះថ្នាក់នេះ។

គុណសម្បត្តិដែលបង្ហាញយ៉ាងច្បាស់នៃការប្រើប្រព័ន្ធម៉ោងសន្សំពន្លឺថ្ងៃ បច្ចុប្បន្ននៅនិទាឃរដូវ រដូវក្តៅ និងរដូវស្លឹកឈើជ្រុះ ហើយប្រើម៉ោងស្តង់ដារនៅរដូវរងារ៖

- មានពន្លឺថ្ងៃនៅពេលល្ងាចនៅក្នុងរដូវក្តៅ
- មានពន្លឺថ្ងៃនៅពេលព្រឹកនៅក្នុងរដូវរងារ
- ជៀសវាងការកំណត់ឱ្យពួកយើងប្រើពេលវេលាដើរ 1 ម៉ោងលើសរដ្ឋជិតខាងនៅភាគខាងលិច និងប្រទេស Mexico ម៉ិកស៊ិក 4 ខែក្នុងមួយឆ្នាំ

មានគ្រោះថ្នាក់ច្រើនឡើងសម្រាប់កុមារ និងមនុស្សពេញវ័យនៅក្នុងរដូវរងារ និងពេលផ្សេងទៀតលើសរដ្ឋដែលនៅជុំវិញយើង។ វា មិនមានប្រយោជន៍ទេ។ បោះឆ្នោតប្រឆាំងសំណើប្រជាមតិលេខ 7។

សមាជិកព្រឹទ្ធសភា HANNAH-BETH JACKSON
ខមណ្ឌលព្រឹទ្ធសភាទី 19

ទឡ្ឍីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ឍីករណ៍ប្រឆាំងសំណើប្រជាមតិលេខ 7 ★

សូមបោះឆ្នោត "ប្រឆាំង" សំណើប្រជាមតិលេខ 7 ។

សំណើប្រជាមតិលេខ 7 នឹងធ្វើឱ្យរដ្ឋ California ប្តូរទៅប្រើម៉ោងសន្សំពន្លឺថ្ងៃ អចិន្ត្រៃយ៍។

យើងបានសាកល្បងវាម្តងហើយពីមុន ហើយវាគឺជាការខាតបង់មួយដ៏ធំ។ នៅឆ្នាំ 1974 វិបត្តិថាមពលមួយបាននាំឱ្យលោកប្រធានាធិបតី Nixon ប្រកាសភាពអាសន្ននៃម៉ោងសន្សំពន្លឺថ្ងៃ។ ភាពអាសន្ននោះត្រូវមានរយៈពេល 16 ខែ ប៉ុន្តែត្រូវបានបញ្ចប់ក្រោយរយៈពេល 10 ខែ ដោយសារតែប្រជាជនមិនសប្បាយចិត្តដែលព្រះអាទិត្យរះយឺតពេក នៅពេលព្រឹក។

ម៉ោងសន្សំពន្លឺថ្ងៃ មិនបង្កើតម៉ោងបន្ថែមទេ។ វាគ្រាន់តែប្តូរពេលដែលថ្ងៃមានពន្លឺប៉ុន្មានម៉ោងប៉ុណ្ណោះ។ ប្រសិនបើអ្នករស់នៅក្នុងក្រុង Anaheim ព្រះអាទិត្យនឹងរះនៅម៉ោង 6:55 នាទីព្រឹកនៅថ្ងៃបុណ្យណូអែលឆ្នាំនេះ។ ជាមួយនឹងម៉ោងសន្សំពន្លឺថ្ងៃ ព្រះអាទិត្យនឹងរះនៅម៉ោង 7:55 នាទីព្រឹក

យើងប្រើម៉ោងសន្សំពន្លឺថ្ងៃ នៅរដូវក្តៅ ដូច្នេះពេលយើងត្រឡប់ទៅដល់ផ្ទះពីកន្លែងធ្វើការ វានៅភ្លឺនៅឡើយ។ ហើយយើងប្តូរទៅម៉ោងស្តង់ដានៅក្នុងរដូវរងា ដូច្នេះថ្ងៃរះលឿនក្នុងពេលព្រឹក។

តើវាមានប្រយោជន៍អ្វីក្នុងការប្រើម៉ោងសន្សំពន្លឺថ្ងៃ អចិន្ត្រៃយ៍? ព្រះអាទិត្យនឹងរះយឺតមួយម៉ោង ប្រសិនបើយើងស្ថិតនៅលើស្តង់ដារ។ ប្រសិនបើអ្នករស់នៅក្នុងក្រុង Eureka ឬ Susanville នៅថ្ងៃចូលឆ្នាំថ្មី ម៉ោង 8 ព្រឹកក៏នៅងងឹតនៅឡើយទេ"។ ប្រសិនបើអ្នករស់នៅទីក្រុង Los Angeles ឬ Twentynine Palms ព្រះអាទិត្យនឹងមិនរះទេរហូតដល់ម៉ោង 7:30 ព្រឹក រះយឺងជាងនេះពីខែវិច្ឆិកាដល់ខែកុម្ភៈ។

អ្នកដែលចូលចិត្តភ្ញាក់ឡើងទន្ទឹមនឹងព្រះអាទិត្យរះ នឹងភ្ញាក់ឡើងក្នុងភាពងងឹត។ អ្នកនឹងត្រូវរៀបចំសម្រាប់ក្រុមគ្រួសាររបស់អ្នកនៅក្នុងភាពងងឹត។ កូនៗរបស់អ្នកនឹងត្រូវដើរទៅសាលារៀន ឬរង់ចាំរថយន្តសាលា មុនព្រះអាទិត្យរះ។

សម្រាប់អ្នកដែលហាត់ប្រាណ ឬចូលរួមកម្មវិធីសាសនាមុនទៅធ្វើការ អ្នកនឹងត្រូវបានធ្វើវានៅក្នុងភាពងងឹត។

អ្នកខ្លះនិយាយថាការប្រើម៉ោងសន្សំពន្លឺថ្ងៃ អាចជួយសន្សំសំចៃថាមពល ឬធ្វើឱ្យយើងមានសុវត្ថិភាពជាងមុន។ ប៉ុន្តែគ្មានភស្តុតាងវិទ្យាសាស្ត្រណាបញ្ជាក់ដូច្នេះទេ។ វាគ្រាន់តែជាហេតុផលនៃភាពងាយស្រួលមួយប៉ុណ្ណោះ។ ឥឡូវ យើងប្រើម៉ោងសន្សំពន្លឺថ្ងៃ នៅរដូវក្តៅដើម្បីយើងមានពន្លឺថ្ងៃវែងនៅពេលល្ងាច ដែលយើងអាចរីករាយជាមួយវាបានជាជាងការមានពន្លឺថ្ងៃចន្លោះពីម៉ោង 5 ទៅម៉ោង 6 ព្រឹក ជាពេលដែលយើងចង់ឱ្យវាងងឹតនោះ។ ហើយបន្ទាប់មកនៅក្នុងរដូវរងារ យើងប្តូរទៅម៉ោងស្តង់ដារវិញ ដូច្នេះវាមិនសូវងងឹតទេនៅពេលព្រឹក។

ការប្រើម៉ោងសន្សំពន្លឺថ្ងៃ អចិន្ត្រៃយ៍នឹងធ្វើឱ្យយើងមិនមានភាពស្របគ្នាជាមួយអ្នកជិតខាងរបស់យើង។ ខណៈពេលដែលយើងប្រើម៉ោងដូចរដ្ឋ Arizona តែពេលខ្លះនៅក្នុងឆ្នាំ យើងបែរជាប្រើម៉ោងដូចរដ្ឋតំបន់ភ្នំទៅវិញ ពេលផ្សេងទៀតក្នុងឆ្នាំ យើងប្រើម៉ោងដូចរដ្ឋ Nevada រដ្ឋ Oregon រដ្ឋ Washington និងប្រទេស Mexico ។

មែនហើយ វាជាបញ្ហាបន្តិចបន្តួចនៅពេលដែលយើង "ប្តូរម៉ោងទៅមុខ" ហើយយើងបាត់បង់រយៈពេលមួយម៉ោងនោះ (ទោះបីជាវាជា"រឿងល្អដែលយើងទទួលបានមួយម៉ោងបន្ថែមនៅពេលដែលយើង "ប្តូរម៉ោងទៅក្រោយ"វិញនោះ) ។ ប៉ុន្តែការផ្លាស់ប្តូរទាំងនេះគឺគ្មានប្រយោជន៍ទេ តែនាំឱ្យការយល់ច្រឡំជាមួយម៉ោងរបស់រដ្ឋផ្សេងទៀត ហើយខែដែលមានពេលព្រឹកងងឹតយើងនឹងត្រូវស៊ូទ្រាំ ប្រសិនបើយើងប្រើម៉ោងសន្សំពន្លឺថ្ងៃ អចិន្ត្រៃយ៍។

សមាជិកព្រឹទ្ធសភា HANNAH-BETH JACKSON
មណ្ឌលព្រឹទ្ធសភាទី 19
PHILLIP CHEN សមាជិកសភា
មណ្ឌលទី 55

★ ការឆ្លើយតបទៅនឹងទឡ្ឍីករណ៍ប្រឆាំងនឹងសំណើប្រជាមតិលេខ 7 ★

អ្នកប្រឆាំងសំណើប្រជាមតិលេខ 7 មិនអាច " ជំទាស់អង្គហេតុផ្នែកវិទ្យាសាស្ត្រ និងសេដ្ឋកិច្ចដែលបង្ហាញថាការផ្លាស់ប្តូរម៉ោងចំនួនពីរដងក្នុងមួយឆ្នាំបង្ករគ្រោះថ្នាក់ដល់សុខភាព និងសេដ្ឋកិច្ចរបស់យើងទេ។ សំណើប្រជាមតិលេខ 7 និយាយអំពីការរក្សាសហគមន៍ កន្លែងធ្វើការ សាលារៀន និងផ្លូវថ្នល់ឱ្យមានសុវត្ថិភាព និងផលិតភាព។

នៅពេលណាដែលមានការប្តូរម៉ោង ការសិក្សានានាបានបង្ហាញថាជំងឺបេះដូង និងជម្ងឺដាច់សរសៃឈាមក្នុងក្បាលកើតឡើងកាន់តែច្រើន។

កុមារត្រូវអនុវត្តខុសទម្លាប់ដំណេកធម្មតារបស់ពួកគេ ហើយធ្វើឱ្យពួកគេបាត់បង់ការផ្តោតអារម្មណ៍កាន់តែខ្លាំងនៅក្នុងថ្នាក់រៀន។

គ្រោះថ្នាក់ចរាចរណ៍ និងរបួសនៅកន្លែងធ្វើការបានកើនឡើងយ៉ាងខ្លាំង បន្ទាប់ពីយើងប្តូរម៉ោងរបស់យើង។

នេះមិនទាន់និយាយដល់ការខាតបង់ផ្នែកសេដ្ឋកិច្ចរបស់យើងផង ដែលត្រូវចំណាយ $434 លានដុល្លារ ក្នុងមួយឆ្នាំងពីការបាត់បង់ផលិតភាព នៅពេលមានការប្តូរម៉ោងមួយម៉ោងទៅមុខ និងមួយម៉ោងថយក្រោយនោះ។

រដ្ឋ California អាចដោះស្រាយបញ្ហាដ៏គ្រោះថ្នាក់នៃការប្តូរម៉ោងនេះ ដោយបោះឆ្នោតគាំទ្រសំណើប្រជាមតិលេខ 7 ។

សូមចូលរួមជាមួយឪពុកម្តាយ អ្នកជំនាញវេជ្ជសាស្ត្រ និងអ្នកតស៊ូមតិលើការការពារសុវត្ថិភាពនៅកន្លែងធ្វើការ ដោយបោះឆ្នោត "គាំទ្រ" សំណើប្រជាមតិលេខ 7 ។

www.YesProp7.info.

សមាជិកសភា KANSEN CHU
មណ្ឌលទី 25 នៃសភារដ្ឋ California
សមាជិកសភា LORENA GONZALEZ
សភាតំណាងរាស្ត្រថ្នាក់រដ្ឋ California មណ្ឌល 80

សំណើប្រជាមតិ 8 កំណត់តម្លៃដែលមន្ទីរព្យាបាលតម្រងនោមសម្រាប់អ្នកជំងឺមិនសម្រាកពេទ្យចំពោះការព្យាបាលដោយការលាងឈាម។ លក្ខន្តិកៈផ្តើមប្រជាសិទ្ធិ។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ — **បានរៀបចំដោយអគ្គមេធាវី**

អត្ថបទនៃវិធានការនេះអាចរកបាននៅលើគេហទំព័ររដ្ឋលេខាធិការ *http://voterguide.sos.ca.gov* ។

- កំណត់ការគិតថ្លៃនេះគឺត្រឹម 115 ភាគរយនៃចំណាយសម្រាប់ការថែទាំអ្នកជំងឺដោយផ្ទាល់ និងការចំណាយលើការលើកកម្ពស់គុណភាព រួមមានការបណ្តុះបណ្តាល ការអប់រំអ្នកជំងឺ និងការគាំទ្រផ្នែកបច្ចេកវិទ្យាជាដើម។
- តម្រូវឱ្យមានការបង្វិលប្រាក់សងវិញ និងការពិន័យ ប្រសិនបើការគិតថ្លៃលើសពីការកំណត់។
- តម្រូវឱ្យមានរបាយការណ៍ប្រចាំឆ្នាំជូនរដ្ឋអំពីការចំណាយរបស់គ្លីនិក ការគិតថ្លៃពីអ្នកជំងឺ និងប្រាក់ចំណូល។
- ហាមឃាត់គ្លីនិកពីការបដិសេធមិនព្យាបាលអ្នកជំងឺដោយសារប្រភពនៃការបង់ប្រាក់សម្រាប់ការថែទាំ។

សេចក្តីសង្ខេបការវាយតម្លៃនៃការវិភាគរបស់អង្គ នីតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ផលប៉ះពាល់ប្រចាំឆ្នាំរួមរបស់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានគិតចាប់ពីផលវិជ្ជមានក្នុងកម្រិតទឹកប្រាក់រាប់លានដុល្លារ រហូតដល់ផលអវិជ្ជមានក្នុងទឹកកម្រិតទឹកប្រាក់រាប់សិបលានដុល្លារ។

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

សាវតា

ការព្យាបាលដោយលាងឈាម

ខូចតម្រងនោម។ តម្រងនោមដែលមានសុខភាពល្អ ច្រោះ ឈាមរបស់មនុស្សដើម្បីយកចេញនូវកាកសំណល់ និងសារធាតុរាវដែលមិនចាំបាច់។ ជំងឺតម្រងនោមសំដៅលើពេលដែលតម្រងនោមរបស់មនុស្សដំណើរការមិនល្អ។ យូរៗទៅ មនុស្សម្នាក់អាចវិវត្តទៅជាជំងឺខូចតម្រងនោម ដែលត្រូវបានគេស្គាល់ថាជាជំងឺតម្រងនោមដំណាក់កាលចុងក្រោយ។ វាមានន័យថា មុខងារតម្រងនោមលែងដំណើរការល្អគ្រប់គ្រាន់ ដើម្បីឱ្យមនុស្សរស់បានដោយគ្មានការវះកាត់ប្តូរតម្រងនោម ឬការព្យាបាលជាបន្តបន្ទាប់ដែលគេហៅថាការលាងឈាម។

ការលាងឈាមធ្វើតាមមុខងារតម្រងនោមធម្មតា។ ការលាងឈាមធ្វើតាមបែបសិប្បនិមិត្តតាមមុខងារធម្មតារបស់មម្រងនោមដែលមានសុខភាពល្អ។ មនុស្សភាគច្រើនដែលមានជំងឺតម្រងនោមត្រូវឆ្លងកាត់ការលាងឈាមបែបវិធីច្រោះឈាមដោយឡែក ដែលជាទម្រង់មួយនៃការលាងឈាម ដែលឈាមនោះត្រូវបានយកចេញពីរាងកាយ ចម្រោះតាមរយៈម៉ាស៊ីន ដើម្បីយកចេញនូវកាកសំណល់ និងសារធាតុរាវមិនចាំបាច់ ហើយបន្ទាប់មកបញ្ជូលវាទៅក្នុងរាងកាយវិញ។ ការព្យាបាលដោយវិធីច្រោះឈាមដោយឡែកនេះមានរយៈពេលប្រហែល 4 ម៉ោង និងជាធម្មតាត្រូវធ្វើបីដងក្នុងមួយសប្តាហ៍។

អ្នកជំងឺដែលត្រូវលាងឈាមភាគច្រើនទទួលការព្យាបាលនៅគ្លីនិក។ អ្នកដែលមានជំងឺខូចតម្រងនោមអាចទទួលការព្យាបាលដោយការលាងឈាមនៅមន្ទីរពេទ្យនានា ឬនៅផ្ទះរបស់ពួកគេផ្ទាល់ ប៉ុន្តែភាគច្រើនទទួលការព្យាបាលនៅគ្លីនិកព្យាបាលជំងឺលាងឈាមរ៉ាំរ៉ៃ (CDCs)។ គិតត្រឹមខែឧសភាឆ្នាំ 2018 CDC ដែលទទួលបានអាជ្ញាប័ណ្ណចំនួន 588 នៅរដ្ឋ California បានផ្តល់ការព្យាបាលដល់អ្នកជំងឺប្រហែល 80,000 នាក់ក្នុងមួយខែៗ។ CDC នីមួយៗធ្វើប្រតិបត្តិការលាងឈាមជាមធ្យម 22 កន្លែង ដោយកន្លែងនីមួយៗផ្តល់ការព្យាបាលដល់អ្នកជំងឺម្តងម្នាក់ៗ។ ក្រសួងសុខាភិបាលសាធារណៈរដ្ឋ California (CDPH) ទទួលខុសត្រូវលើការផ្តល់អាជ្ញាប័ណ្ណ និងត្រួតពិនិត្យ CDCs ។ អង្គភាពនានាកាន់កាន់ និងដំណើរការ CDC ។ ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី 1 អង្គភាព ឯកជនដែលរកប្រាក់ចំណេញពីរ ដំណើរការ ហើយយ៉ាងហោចណាស់មានភាពជាម្ចាស់មួយផ្នែក ក្នុងចំណោម CDC ភាគច្រើននៅក្នុងរដ្ឋ California។

ការបង់ថ្លៃសម្រាប់ការព្យាបាលការលាងឈាម

ការបង់ថ្លៃសម្រាប់ការព្យាបាលការលាងឈាមកើតចេញពីប្រភពសំខាន់ៗមួយចំនួន។ យើងប៉ាន់ប្រមាណថា CDC មានប្រាក់ចំណូលសរុបប្រហែល $3 ពាន់លានដុល្លារជារៀងរាល់ឆ្នាំ ពីប្រតិបត្តិការរបស់ពួកគេនៅក្នុងរដ្ឋ California។ ប្រាក់ចំណូលទាំងនេះរួមមានការបង់ថ្លៃសម្រាប់ការព្យាបាលដោយការលាងឈាមពីប្រភពសំខាន់មួយចំនួន ឬពី "អ្នកបង់ប្រាក់"

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

រូបភាពលេខ 1

គ្លីនិកដែលមានអាជ្ញាប័ណ្ណសម្រាប់ជំងឺលាងឈាមរ៉ាំរ៉ៃនៅក្នុងរដ្ឋ California

ខែឧសភា ឆ្នាំ 2018

អង្គភាពប្រតិបត្តិការ	ចំនួនគ្លីនិក	ភាគរយនៃគ្លីនិក
DaVita, Inc. (រកប្រាក់ចំណេញ)	292	50%
Fresenius Medical Care (រកប្រាក់ចំណេញ)	129	22
Satellite Healthcare (មិនរកប្រាក់ចំណេញ)	46	8
U.S. Renal Care (រកប្រាក់ចំណេញ)	38	6
ផ្សេងទៀត	83	14
សរុប	588	100%

- ***Medicare។*** កម្មវិធីដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលសហព័ន្ធនេះផ្តល់ការធានារ៉ាប់រងសុខភាពដល់មនុស្សភាគច្រើនដែលមានអាយុចាប់ពី 65 ឆ្នាំឡើងទៅ និងមនុស្សវ័យក្មេងដែលមានពិការភាព។ ច្បាប់សហព័ន្ធជាទូទៅអនុញ្ញាតិឱ្យមនុស្សដែលមានជំងឺខូចតម្រងនោមមានសិទ្ធិទទួលបានការធានារ៉ាប់រងពី Medicare ដោយមិនគិតពីអាយុ ឬស្ថានភាពពិការភាពឡើយ។ Medicare បង់ថ្លៃព្យាបាលដោយការលាងឈាមសម្រាប់មនុស្សភាគច្រើនដែលមានជំងឺត្រូវលាងឈាមនៅរដ្ឋ California។
- ***Medi-Cal។*** កម្មវិធី Medicaid របស់សហព័ន្ធ-រដ្ឋដែលគេស្គាល់ថាជា Medi-Cal នៅរដ្ឋ California ផ្តល់ការធានារ៉ាប់រងសុខភាពដល់ពលរដ្ឋដែលមានប្រាក់ចំណូលទាប។ រដ្ឋ និងរដ្ឋាភិបាលសហព័ន្ធរួមចំណែកក្នុងការចំណាយរបស់ Medi-Cal ។ ពលរដ្ឋមួយចំនួនមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ទាំង Medicare និង Medi-Cal ។ សម្រាប់ពលរដ្ឋទាំងនេះ Medicare ធានារ៉ាប់រងភាគច្រើននៃការបង់ថ្លៃសម្រាប់ការព្យាបាលដោយការលាងឈាមដែលជាការចំណាយចម្បង ហើយ Medi-Cal រ៉ាបរងអ្វីដែលនៅសេសសល់។ សម្រាប់ពលរដ្ឋដែលបានចុះឈ្មោះតែនៅក្នុង Medi-Cal នោះ កម្មវិធី Medi-Cal ទទួលខុសត្រូវតែមួយគត់ក្នុងការបង់ថ្លៃព្យាបាលដោយការលាងឈាម។
- ***ការធានារ៉ាប់រងសុខភាពជាក្រុម និងបុគ្គល។*** ពលរដ្ឋជាច្រើននៅក្នុងរដ្ឋមានការធានារ៉ាប់រងសុខភាពជាក្រុមតាមរយ:និយោជក ឬអង្គការផ្សេងទៀត (ដូចជាសហជីពជាដើម) ។ រដ្ឋាភិបាលរដ្ឋ California ប្រព័ន្ធសាកលវិទ្យាល័យរដ្ឋពីររបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានជាច្រើននៅក្នុងរដ្ឋ California បានផ្តល់ការធានារ៉ាប់រងសុខភាពជាក្រុមសម្រាប់បុគ្គលិករបស់ពួកគេ បុគ្គលិកដែលជិតចូលនិវត្តន៍ និងក្រុមគ្រួសាររបស់ពួកគេ។ ពលរដ្ឋមួយចំនួនដែលមិនមានការធានារ៉ាប់រងសុខភាពជាក្រុមត្រូវទិញធានារ៉ាប់រងសុខភាពជាលក្ខណ:បុគ្គល។ ការធានារ៉ាប់រងសុខភាពជាក្រុម និងជាលក្ខណ:បុគ្គលត្រូវបានផ្តល់ជូនជាញឹកញាប់ដោយក្រុមហ៊ុនធានារ៉ាប់រងឯកជន ដែលទទួលបានការទូទាត់បុព្វលាភធានារ៉ាប់រង ដើម្បីជាថ្នូរនឹងការចំណាយលើសេវាថែទាំសុខភាពដែលបានឯកភាព។ នៅពេលបុគ្គលដែលត្រូវបានធានារ៉ាប់រងមានជំងឺខូចតម្រងនោម បុគ្គលនោះអាចប្តូរទៅទទួលការធានារ៉ាប់រងលើ Medicare វិញបាន។ ច្បាប់របស់សហព័ន្ធតម្រូវឱ្យក្រុមហ៊ុនធានារ៉ាប់រងជាក្រុមនៅតែជាអ្នកបង់ប្រាក់ដ៏ចម្បងសម្រាប់ការព្យាបាលដោយការលាងឈាមសម្រាប់ "រយ:ពេលសម្របសម្រួល" ដែលមានរយ:ពេល 30 ខែ។

ជាធម្មតាក្រុមហ៊ុនធានារ៉ាប់រងសុខភាពជាក្រុម និងបុគ្គលតែងតែបង់ថ្លៃក្នុងអាត្រាខ្ពស់ សម្រាប់ការលាងឈាមជាងកម្មវិធីរបស់រដ្ឋាភិបាល។ អត្រាដែល Medicare និង Medi-Cal បង់ថ្លៃសម្រាប់ការព្យាបាលដោយការលាងឈាមគឺទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងតម្លៃជាមធ្យមសម្រាប់គ្លីនិកព្យាបាលជំងឺលាងឈាមរ៉ាំរ៉ៃ ដើម្បីផ្តល់ការព្យាបាលដោយការលាងឈាម និងត្រូវបានកំណត់យ៉ាងទូលំទូលាយតាមបទប្បញ្ញត្តិនេះ។ ផ្ទុយទៅវិញ ក្រុមហ៊ុនធានារ៉ាប់រងសុខភាពជាក្រុម និងជាលក្ខណ:បុគ្គល បង្កើតអត្រាតម្លៃរបស់ពួកគេដោយធ្វើការចរចាជាមួយគ្លីនិកព្យាបាលជំងឺលាងឈាមរ៉ាំរ៉ៃ ។ អត្រាដែលបានបង់ដោយក្រុមហ៊ុនធានារ៉ាប់រងទាំងនេះអាស្រ័យលើអំណាចចរចារបស់ក្រុមហ៊ុនធានារ៉ាប់រង និងគ្លីនិកព្យាបាលជំងឺលាងឈាមរ៉ាំរ៉ៃ ។ ជាមធ្យម ក្រុមហ៊ុនធានារ៉ាប់រងសុខភាពជាក្រុម និងជាលក្ខណ:បុគ្គល ចំណាយច្រើនដងជាងអ្វីដែលកម្មវិធីរបស់រដ្ឋាភិបាលបង់ថ្លៃសម្រាប់ការព្យាបាលដោយការលាងឈាម។

សេចក្តីស្នើច្បាប់

តម្រូវឱ្យគ្លីនិកទាំងអស់បង់ប្រាក់បង្វិលសងវិញនៅពេលដែលប្រាក់ចំណូលសរុបលើសពីចំនួនកំណត់ដែលបានបញ្ជាក់។ ចាប់ផ្តើមពីឆ្នាំ 2019 វិធានការនេះតម្រូវឱ្យ CDC ជារៀងរាល់ឆ្នាំ ដើម្បីគណនាចំនួនដែលប្រាក់ចំណូលរបស់ពួកគេលើសពីចំនួនកំណត់ដែលបានបញ្ជាក់។ វិធានការនេះតម្រូវឱ្យ CDCs ង់ប្រាក់បង្វិលសងវិញ (ដែលផ្តល់ត្រឡប់មកវិញ) ដល់អ្នកបង់ប្រាក់ ដោយមិនរាប់បញ្ចូល Medicare និងអ្នកបង់ប្រាក់រដ្ឋាភិបាលផ្សេងទៀតឡើយ ក្នុងចំនួនដែលប្រាក់ចំណូលលើសពីចំនួនដែលបានកំណត់។ អ្នកបង់ប្រាក់សម្រាប់ការព្យាបាលកាន់តែច្រើន អ្នកបង់ប្រាក់នោះក៏នឹងទទួលប្រាក់បង្វិលសងវិញកាន់តែច្រើនដែរ។

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

បន្ត

ការកំណត់ប្រាក់ចំណូលដែលមានមូលដ្ឋានលើការចំណាយរបស់ CDC លបានបញ្ជាក់។ ការកំណត់ប្រាក់ចំណូលដែលត្រូវបានបង្កើតឡើងដោយវិធានការនេះស្មើនឹង 115 ភាគរយនៃ "ការចំណាយលើសេវាថែទាំអ្នកជំងឺដោយផ្ទាល់" ដែលបានបញ្ជាក់ និង "ការចំណាយលើការកែលម្អគុណភាពនៃការថែទាំសុខភាព"។ ទាំងនេះរួមបញ្ចូលទាំងការចំណាយលើបញ្ហាផ្សេងៗ ដូចជាប្រាក់ឈ្នួល និងអត្ថប្រយោជន៍បុគ្គលិក ការបណ្តុះបណ្តាល និងការអភិវឌ្ឍបុគ្គលិក ការផ្គត់ផ្គង់ថ្នាំសង្កូវ និងថ្នាំពេទ្យ គ្រឿងបរិក្ខារប្រើប្រាស់ និងប្រព័ន្ធព័ត៌មានសុខាភិបាលអេឡិចត្រូនិកជាដើម។ ខាងក្រោមនេះយើងសំដៅទៅលើការចំណាយទាំងនេះថា ជា "ការអនុញ្ញាត" មានន័យថាពួកគេអាចរាប់បញ្ចូលធៀបនឹងការកំណត់ប្រាក់ចំណូល។ ការចំណាយផ្សេងៗ ទៀតដូចជាចំណាយផ្នែករដ្ឋបាលនឹងមិនត្រូវបានរាប់បញ្ចូលក្នុងការកំណត់ជាប្រាក់ចំណូលដែលបានកំណត់ទេ។

ការប្រាក់ និងការពិន័យលើចំនួនទឹកប្រាក់ដែលត្រូវបង្វិលសងវិញ។ បន្ថែមពីលើការបង្វិលសងវិញ CDC ត្រូវបង់ការប្រាក់លើចំនួនទឹកប្រាក់បង្វិលសងនោះទៀតដែលបានគណនាចាប់ពីថ្ងៃបង់ប្រាក់សម្រាប់ការព្យាបាល។ CDCs ក៏នឹងត្រូវបង់ពិន័យទៅ CDPH ចំនួន 5 ភាគរយនៃចំនួនទឹកប្រាក់នៃការបង្វិលសងដែលត្រូវបានតម្រូវរហូតដល់ប្រាក់ពិន័យអតិបរមា $100,000 ដុល្លារ។

ប្រាក់បង្វិលសងគណនាតាមកម្រិតម្ចាស់/ប្រតិបត្តិករ វិធានការនេះបញ្ជាក់ថា ការបង្វិលសងវិញនឹងត្រូវបានគណនាតាមកម្រិតនៃ "អង្គភាពគ្រប់គ្រង" របស់ CDC ដែលសំដៅទៅលើអង្គភាពដែលជាម្ចាស់ ឬបើកដំណើរការ CDC ("ម្ចាស់/ប្រតិបត្តិករ")។ ម្ចាស់/ប្រតិបត្តិករមួយចំនួនមាន CDC ច្រើននៅរដ្ឋ California ខណៈពេលដែលអ្នកផ្សេងទៀតអាចជាម្ចាស់ ឬដំណើរការ CDC តែមួយ។ សម្រាប់ម្ចាស់/ប្រតិបត្តិករដែលមាន CDCs ច្រើន វិធានការនេះតម្រូវឱ្យពួកគេបន្ថែមប្រាក់ចំណូល និងការចំណាយដែលគេអនុញ្ញាតនៅគ្រប់ CDC របស់ពួកគេនៅក្នុងរដ្ឋ California។ ប្រសិនបើប្រាក់ចំណូលសរុបលើសពី 115% នៃការចំណាយសរុបដែលអនុញ្ញាតឱ្យនៅទូទាំងគ្លីនិករបស់ម្ចាស់/ ប្រតិបត្តិករទាំងអស់ ពួកគេត្រូវបង្វិលប្រាក់សងវិញស្មើនឹងទឹកប្រាក់ល្អៀង។

ដំណើរការច្បាប់ក្នុងការបង្កើនការកំណត់ប្រាក់ចំណូលនៅក្នុងស្ថានភាពជាក់ស្តែង។ ទាំងរដ្ឋធម្មនុញ្ញក្នុងរដ្ឋ California និងរដ្ឋធម្មនុញ្ញសហរដ្ឋអាមេរិកហាមឃាត់រដ្ឋាភិបាលមិនឱ្យយកទ្រព្យសម្បត្តិឯកជន (ដែលរួមបញ្ចូលតម្លៃនៃអាជីវកម្ម) ដោយគ្មាននីតិវិធីផ្លូវច្បាប់ត្រឹមត្រូវ ឬសំណងសមស្របនោះឡើយ។ ម្ចាស់ ឬប្រតិបត្តិកររបស់ CDC អាចព្យាយាមបង្ហាញនៅតុលាការថានៅក្នុងស្ថានភាពពិសេសរបស់ពួកគេ ការបង្វិលប្រាក់សងវិញតាមការតម្រូវនេះ វាស្មើចំនួននៃការយកទៅធ្វើអាជីវកម្ម ដូច្នេះវារំលោភលើរដ្ឋធម្មនុញ្ញរដ្ឋ ឬសហព័ន្ធ។ ប្រសិនបើម្ចាស់/ប្រតិបត្តិកររបស់ CDC អាចបង្ហាញភ័ស្តុតាងបញ្ជាក់ពីរឿងនេះ វិធានការនេះបង្ហាញពីដំណើរការដែលតុលាការកាត់បន្ថយការបង្វិលសងប្រាក់តាមការតម្រូវដោយគ្រាន់តែលែងរំលោភរដ្ឋធម្មនុញ្ញតែប៉ុណ្ណោះ។ វិធានការនេះដាក់បន្ទុកទៅលើម្ចាស់/ប្រតិបត្តិកររបស់ CDC ក្នុងការកំណត់ចំនួនទឹកប្រាក់បង្វិលសងច្រើនបំផុតដែលនឹងជាការស្របច្បាប់។ វិធានការនេះបញ្ជាក់ថាការកែតម្រូវនៅក្នុងចំនួនទឹកប្រាក់បង្វិលសងវិញនេះនឹងត្រូវអនុវត្តក្នុងរយៈពេលតែមួយឆ្នាំប៉ុណ្ណោះ។

លក្ខខណ្ឌតម្រូវផ្សេងទៀត។ វិធានការនេះតម្រូវឱ្យម្ចាស់/ប្រតិបត្តិកររបស់ CDC បញ្ជូនរបាយការណ៍ប្រចាំឆ្នាំទៅ CDPH របាយការណ៍ទាំងនេះនឹងរាយនូវចំនួននៃការព្យាបាលដោយការលាងឈាមដែលបានផ្តល់ជូន ចំនួនទឹកប្រាក់នៃការចំណាយដែលគេអនុញ្ញាត ចំនួននៃប្រាក់ចំណូលដែលបានកំណត់របស់ម្ចាស់/ប្រតិបត្តិករ ដែលជាចំនួនប្រាក់ចំណូលដែលលើសចំនួនកំណត់ និងចំនួនទឹកប្រាក់នៃការបង្វិលសង។ វិធានការនេះក៏ហាមឃាត់ផងដែរដល់ CDC ពីការបដិសេធមិនផ្តល់ការព្យាបាលដល់មនុស្សម្នាក់ដោយផ្អែកទៅលើអ្នកដែលត្រូវចំណាយសម្រាប់ការព្យាបាលនោះ។

CDPH នឹងចេញបទប្បញ្ញត្តិ។ វិធានការនេះតម្រូវឱ្យក្រ CDPH បង្កើត និងចេញបទប្បញ្ញត្តិដើម្បីអនុវត្តបទប្បញ្ញត្តិរបស់វិធានការនេះ ក្នុងរយៈពេល 180 ថ្ងៃ ក្រោយកាលបរិច្ឆេទមានប្រសិទ្ធភាពរបស់វិធានការនេះ។ ជាពិសេស វិធានការនេះអនុញ្ញាតឱ្យ CDPH កំណត់តាមរយៈការកំណត់តម្លៃ CDC បន្ថែមទៀតដែលនឹងរាប់ជាការចំណាយដែលមានការអនុញ្ញាត ដែលអាចកាត់បន្ថយទឹកប្រាក់បង្វិលសងដែលជំពាក់ដោយ CDC ។

ផលប៉ះពាល់សារពើពន្ធ

វិធានការនឹងកាត់បន្ថយផលចំណេញរបស់ CDC

បច្ចុប្បន្ន វាបង្ហាញថា CDC ដែលប្រតិបត្តិការនៅរដ្ឋ California មានប្រាក់ចំណូលលើសចំនួនដែលបានកំណត់នៅក្នុងវិធានការនេះ។ ការទូទាត់ប្រាក់បង្វិលសំណងក្នុងចំនួនទឹកប្រាក់លើសនេះនឹងកាត់បន្ថយយ៉ាងខ្លាំងនូវចំណូលម្ចាស់/ប្រតិបត្តិកររបស់ CDC ។ ក្នុងករណីដែល CDCs ត្រូវបានដំណើរការដោយអង្គភាពរកប្រាក់ចំណេញ (ភាគច្រើននៃ CDCs) នេះមានន័យថា CDC នឹងទទួលបានប្រាក់ចំណេញតិចតួច ឬអាចមិនមានប្រាក់ចំណេញក៏ថាបាន។ នេះអាចនាំឱ្យមានការផ្លាស់ប្តូររបៀបនៃការព្យាបាលដោយការលាងឈាមនៅក្នុងរដ្ឋនេះ។ ការផ្លាស់ប្តូរទាំងនេះអាចមានផលប៉ះពាល់ផ្សេងៗទៅលើហិរញ្ញវត្ថុរដ្ឋ និងរដ្ឋអំណាចមូលដ្ឋាន។ ដូចដែលបានរៀបរាប់ខាងក្រោម ផលប៉ះពាល់នៃវិធានការទៅលើ CDC និងលើហិរញ្ញវត្ថុរដ្ឋ និងរដ្ឋអំណាចមូលដ្ឋាន គឺមិនច្បាស់លាស់ទេ។ នេះដោយសារ

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

បន្ត

តែផលប៉ះពាល់នេះនឹងអាស្រ័យលើសកម្មភាពនាពេលអនាគតរបស់និយតករ និងតុលាការរដ្ឋ ក្នុងការបកស្រាយវិធានការនេះ និង (2) CDCs ក្នុងការឆ្លើយតបទៅនឹងវិធានការនេះ។ សកម្មភាពនាពេលអនាគតទាំងនេះពិបាកនឹងទស្សន៍ទាយណាស់។

ប្រភពធំៗនៃភាពមិនប្រាកដប្រជា

មិនប្រាកដថាតើការចំណាយណាខ្លះដែលគេអនុញ្ញាតទេ។ ផលប៉ះពាល់នៃវិធានការនេះនឹងអាស្រ័យរបៀបកំណត់ការចំណាយដែលគេអនុញ្ញាត។ រួមទាំងការចំណាយបន្ថែមទៀតតាមដែលគេអនុញ្ញាតនឹងធ្វើឱ្យប្រាក់ចំណូលដែលបានកំណត់ខ្ពស់ជាងមុន និងអនុញ្ញាតឱ្យ CDCs រក្សាប្រាក់ចំណូលបន្ថែមរបស់ពួកគេ (ដោយការតម្រូវឱ្យមានការបង្វិលសងតិចជាងមុន) ។ រួមបញ្ចូលទាំងការចំណាយតិចជាងតាមដែលគេអនុញ្ញាតនឹងធ្វើឱ្យប្រាក់ចំណូលដែលបានកំណត់ថយចុះ និងអនុញ្ញាតឱ្យគ្លីនិកនានារក្សាប្រាក់ចំណូលរបស់ពួកគេតិច (ដោយការតម្រូវឱ្យមានការបង្វិលសងធំជាងមុន) ។ វាមិនច្បាស់លាស់ថាតើ CDPH (ក្នុងនាមជានិយតកររបស់រដ្ឋពាក់ព័ន្ធនឹងការអនុវត្ត និងការអនុវត្តវិធានការនេះ) ហើយតុលាការនឹងបកស្រាយបទប្បញ្ញត្តិរបស់វិធានការនេះដោយកំណត់នូវការចំណាយដែលគេអនុញ្ញាត។ ឧទាហរណ៍ វិធានការនេះបញ្ជាក់ថា ការចំណាយលើប្រាក់ឈ្នួល និងអត្ថប្រយោជន៍របស់បុគ្គលិកគឺអនុញ្ញាតសម្រាប់តែបុគ្គលិក "មិនមែនជាអ្នកគ្រប់គ្រង" ដែលផ្តល់ការថែទាំដោយផ្ទាល់ដល់អ្នកជំងឺលាងឈាមទេ។ ច្បាប់សហព័ន្ធតម្រូវឱ្យ CDCs រក្សាមុខតំណែងបុគ្គលិកមួយចំនួនជាលក្ខខណ្ឌនៃការទទួលបានសំណងពីការថែទាំវេជ្ជសាស្ត្រ។ មុខតំណែងមួយចំនួនក្នុងចំណោមមុខតំណែងដែលតម្រូវទាំងនេះ រួមទាំងនាយកវេជ្ជសាស្ត្រ និងគិលានុបដ្ឋាក — អនុវត្តមុខងារគ្រប់គ្រង ក៏ប៉ុន្តែក៏ចូលរួមក្នុងការថែទាំអ្នកជំងឺដោយផ្ទាល់ផងដែរ។ ការចំណាយលើមុខតំណែងទាំងនេះអាចមិនត្រូវបានគេចាត់ទុកថាអាចអនុញ្ញាតនោះទេ ពីព្រោះមុខតំណែងទាំងនេះមានមុខងារគ្រប់គ្រង។ ម្យ៉ាងវិញទៀត ការចំណាយលើមុខតំណែងទាំងនេះអាចត្រូវបានគេចាត់ទុកថាអាចអនុញ្ញាតបាន ពីព្រោះមុខតំណែងទាំងនេះទាក់ទងនឹងការថែទាំអ្នកជំងឺដោយផ្ទាល់។

មិនប្រាកដអំពីរបៀបដែល CDC នឹងឆ្លើយតបទៅនឹងវិធានការនេះទេ។ ម្ចាស់/ប្រតិបត្តិកររបស់ CDC ទំនងជានឹងឆ្លើយតបទៅនឹងវិធានការនេះដោយកែតម្រូវប្រតិបត្តិការរបស់ពួកគេតាមវិធីដែលកំណត់ លទ្ធភាពដែលអាចធ្វើទៅបានផលប៉ះពាល់នៃការតម្រូវឱ្យបង្វិលសងប្រាក់។ ពួកគេអាចធ្វើដូចខាងក្រោម៖

- ***បង្កើនការចំណាយដែលគេអនុញ្ញាត។*** ម្ចាស់ ឬប្រតិបត្តិកររបស់ CDC អាចបង្កើនការចំណាយដែលគេអនុញ្ញាត ដូចជាប្រាក់ឈ្នួល និងអត្ថប្រយោជន៍សម្រាប់បុគ្គលិកដែលមិនមែនជាអ្នកគ្រប់គ្រងដែលផ្តល់ការថែទាំអ្នកជំងឺដោយផ្ទាល់។ ការបង្កើនចំណាយដែលគេអនុញ្ញាតនឹងបង្កើនប្រាក់ចំណូលដែលបានកំណត់ កាត់បន្ថយចំនួនទឹកប្រាក់នៃការបង្វិលសងដែលនៅជំពាក់ និងអាចទុកម្ចាស់/ប្រតិបត្តិកររបស់ CDC ដែលគ្រាន់បើ ប្រសិនបើពួកគេត្រូវទុកការចំណាយដែលគេអនុញ្ញាតនៅកម្រិតបច្ចុប្បន្ននោះ។ នេះដោយសារតែចំនួនប្រាក់ចំណូលដែលម្ចាស់ ឬប្រតិបត្តិកររបស់ CDC អាចរក្សាបានគឺច្រើនជាងការចំណាយបន្ថែម (ប្រាក់ចំណូលដែលបានកំណត់នឹងកើនឡើង 115 ភាគរយនៃការចំណាយដែលគេអនុញ្ញាតបន្ថែម)។
- ***កាត់បន្ថយការចំណាយផ្សេងទៀត*** ។ ម្ចាស់/ប្រតិបត្តិកររបស់ CDC ក៏អាចកាត់បន្ថយការចំណាយផ្សេងទៀតបើអាចធ្វើទៅបាន ដែលមិនរាប់បញ្ចូលការកំណត់ប្រាក់ចំណូលដែលបានកំណត់ (ដូចជាការចំណាយផ្នែករដ្ឋបាលជាដើម) ។ ការនេះនឹងមិនផ្លាស់ប្តូរចំនួនទឹកប្រាក់នៃការបង្វិលសងដែលនៅជំពាក់នោះទេ ប៉ុន្តែវានឹងធ្វើឱ្យប្រសើរឡើងនូវភាពដែលអាចចណេញរបស់ម្ចាស់ CDC
- ***ស្វែងរកការកែតម្រូវចំពោះប្រាក់ចំណូលដែលបានកំណត់។*** ប្រសិនបើម្ចាស់ ឬប្រតិបត្តិកររបស់ CDC ជឿជាក់ថាពួកគេមិនអាចទទួលបានចំណូលសមរម្យចំពោះប្រតិបត្តិការរបស់ពួកគេ សូម្បីបន្ទាប់ពីធ្វើការកែតម្រូវដូចដែលបានរៀបរាប់ខាងលើ ពួកគេអាចព្យាយាមជំទាស់នឹងការផ្តល់ប្រាក់បង្វិលសងនេះនៅតុលាការដើម្បីទទួលបានប្រាក់ចំណូលដើមទុនខ្ពស់ដូចដែលបានកំណត់ នៅក្នុងវិធានការនេះ។ ប្រសិនបើបញ្ហាប្រឈមបែបនេះទទួលបានជោគជ័យ នោះម្ចាស់/ប្រតិបត្តិកររបស់ CDC មួយចំនួនអាចមានប្រាក់ចំណូលដែលបានកំណត់ខ្ពស់ និងជំពាក់តិចតួចក្នុងការបង្វិលសងក្នុងឆ្នាំខ្លះ។
- ***ប្រតិបត្តិការកាត់បន្ថយ។*** ក្នុងករណីមួយចំនួន ម្ចាស់/ប្រតិបត្តិករ អាចសម្រេចចិត្តបើក CDC ថ្មីតិចជាងមុន ឬបិទ CDC មួយចំនួន ប្រសិនបើចំនួននៃទឹកប្រាក់បង្វិលសងគឺធំ ហើយប្រាក់ចំណូលដែលបានកាត់បន្ថយនោះមិនបានផ្តល់ចំណូលគ្រប់គ្រាន់លើការវិនិយោគដើម្បីពង្រីក ឬស្ថិតនៅក្នុងទីផ្សារនេះដដែល។ ប្រសិនបើបញ្ហានេះកើតឡើង អ្នកផ្តល់សេវាដទៃទៀតនៅទីបំផុតនឹងត្រូវអន្តរាគមន៍ដើម្បីបំពេញតម្រូវការសម្រាប់ការលាងឈាមនេះ។ អ្នកផ្តល់សេវាផ្សេងទៀតទាំងនេះអាចនឹងដំណើរការមិនសូវមានប្រសិទ្ធភាព (មានការចំណាយខ្ពស់ជាងមុន) ។ អ្នកផ្តល់សេវាផ្សេងទៀតមួយចំនួនអាចមានការលើកលែងពីបទប្បញ្ញត្តិនៃវិធានការនេះ ប្រសិនបើពួកគេមិនប្រតិបត្តិតាមអាជ្ញាប័ណ្ណ CDC (ឧទាហរណ៍ មន្ទីរពេទ្យ) ជាដើម ។ ការផ្លាស់ប្តូរទូលំទូលាយបែបនេះនៅក្នុងឧស្សាហកម្មលាងឈាមគឺជាការពិបាកក្នុងការទស្សន៍ទាយណាស់។

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

បន្ត

ផលប៉ះពាល់នៃបទប្បញ្ញត្តិបង្វិលសងប្រាក់លើហិរញ្ញវត្ថុរដ្ឋនិង មូលដ្ឋាន

យើងប៉ាន់ប្រមាណថា បើគ្មានការចាត់វិធានការដោយ CDC ដើម្បីឆ្លើយតបទៅនឹងវិធានការនេះទេនោះ ការបង្វិលសងប្រាក់ដែលមានសក្តានុពលដែលនៅជំពាក់ អាចមានចំនួនដល់រាប់រយលានដុល្លារឯណោះ។ ដោយអាស្រ័យលើកត្តាផ្សេងៗដែលបានពិភាក្សាខាងលើ បទប្បញ្ញត្តិបង្វិលសងប្រាក់របស់វិធានការនេះ អាចមានប្រភេទនៃផលប៉ះពាល់ច្រើនទៅលើហិរញ្ញវត្ថុរដ្ឋ និងហិរញ្ញវត្ថុមូលដ្ឋាន។

វិធានការអាចបង្កើតការ ថែទាំសុខភាព. . . របស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋន ការសន្សំសំចៃក្នុងករណីដែល CDC បង់ប្រាក់បង្វិលសងការចំណាយរបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានសម្រាប់ការថែទាំសុខភាពរបស់បុគ្គលិកអាចត្រូវបានកាត់បន្ថយ។ ដូចដែលបានកត់សម្គាល់ពីមុន វិធានការនេះមិនរាប់បញ្ចូលអ្នកបង់ប្រាក់របស់រដ្ឋាភិបាលដែលទទួលបានប្រាក់បង្វិលសងទេ។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋ និងរដ្ឋអំណាចមូលដ្ឋាន ជាញឹកញាប់ធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជនដើម្បីផ្តល់ការធានារ៉ាប់រងដល់បុគ្គលិករបស់ពួកគេ។ ក្នុងនាមជាអង្គភាពឯកជន ក្រុមហ៊ុនធានារ៉ាប់រងទាំងនេះអាចមានសិទ្ធិទទួលបានប្រាក់បង្វិលសងមកវិញក្រោមវិធានការនេះ។ បើទោះជាពួកគេមិនមានសិទ្ធិទទួលបានប្រាក់បង្វិលសងវិញក៏ដោយ ក៏ពួកគេនៅតែមានតួនាទីក្នុងការចរចាក្នុងអត្រាទាបជាមួយម្ចាស់ និងប្រតិបត្តិករបស់ CDC ដែរ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងនេះអាចផ្ញើប្រាក់សន្សំមួយចំនួនឬទាំងអស់ទៅឱ្យនិយោជករដ្ឋាភិបាលក្នុងទម្រង់ជាបុព្វលាភធានារ៉ាប់រងសុខភាពដែលត្រូវបានកាត់បន្ថយ។

. . . ឬការចំណាយ។ ម្យ៉ាងទៀត ដូចដែលបានរៀបរាប់ខាងលើ CDC អាចឆ្លើយតបទៅនឹងវិធានការនេះ ដោយបង្កើនចំណាយដែលគេអនុញ្ញាត។ ប្រសិនបើ CDCs បង្កើនការចំណាយដែលគេអនុញ្ញាតឱ្យបានគ្រប់គ្រាន់ អត្រាដែលក្រុមហ៊ុនធានារ៉ាប់រងសុខភាពបង់ប្រាក់សម្រាប់ការព្យាបាលការលាងឈាមអាចកើនឡើងលើសពីអ្វីដែលពួកគេនឹងមានក្នុងពេលគ្មានវិធានការនេះ។ ប្រសិនបើបញ្ហានេះកើតឡើង ក្រុមហ៊ុនធានារ៉ាប់រងទាំងនេះអាចផ្ញើប្រាក់សន្សំមួយចំនួនឬទាំងអស់ទៅឱ្យនិយោជករដ្ឋាភិបាលក្នុងទម្រង់ជាបុព្វលាភធានារ៉ាប់រងសុខភាពដែលត្រូវបានបង្កើន។

សម្ពាធតម្លៃវេជ្ជសាស្ត្ររបស់រដ្ឋ ។ កម្មវិធី Medi-Cal ក៏បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធានារ៉ាប់រងឯកជនផងដែរដើម្បីផ្តល់ការការធានារ៉ាប់រងការលាងឈាមសម្រាប់អ្នកចុះឈ្មោះរបស់ខ្លួនមួយចំនួន។ ស្រដៀងគ្នាទៅនឹងក្រុមហ៊ុនធានារ៉ាប់រងសុខភាពមួយចំនួនដែលផ្តល់ការធានារ៉ាប់រងដល់និយោជិតរដ្ឋាភិបាល ក្រុមហ៊ុនធានារ៉ាប់រងឯកជនដែលបានចុះកិច្ចសន្យាជាមួយ Medi-Cal ក៏អាចទទួលបានប្រាក់បង្វិលសងមកវិញដែរ (ប្រសិនបើពួកគេត្រូវបានកំណត់ថាមានសិទ្ធិទទួល) ឬអាចចរចាអត្រាទាបជាមួយម្ចាស់ និងប្រតិបត្តិករបស់ CDC ។ ប្រាក់សន្សំមួយចំនួន ឬទាំងអស់អាចត្រូវបានបញ្ជូនទៅរដ្ឋ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារអត្រាដែលបង់ជូន CDC ដោយក្រុមហ៊ុនធានារ៉ាប់រងទាំងនេះមានកម្រិតទាប ប្រាក់សន្សំប្រាក់បែបនេះទំនងជានៅមានកម្រិត។ ម្យ៉ាងទៀត ប្រសិនបើ CDC ឆ្លើយតបទៅនឹងវិធានការនេះដោយបង្កើនចំណាយអនុញ្ញាតនោះការចំណាយជាមធ្យមនៃការព្យាបាលដោយការលាងឈាមនឹងកើនឡើង។ ការធ្វើបែបនេះនឹងដាក់សម្ពាធទៅលើអត្រា Medi-Cal និងអាចបង្កើនចំណាយរដ្ឋ។

ការផ្លាស់ប្តូរចំណូលពន្ធរដ្ឋ។ ចំពោះវិសាលភាព នៃបទប្បញ្ញត្តិបង្វិលប្រាក់សងវិញរបស់វិធានការនេះ ប្រតិបត្តិការដើម្បីកាត់បន្ថយប្រាក់ចំណូលសុទ្ធរបស់ម្ចាស់/ប្រតិបត្តិកររបស់ CDC វិធានការនេះទំនង ជានឹងកាត់បន្ថយចំនួននៃពន្ធលើប្រាក់ចំណូលដែលរកប្រាក់ ចំណេញម្ចាស់/ប្រតិបត្តិករត្រូវបាន តម្រូវឱ្យបង់ប្រាក់ទៅឱ្យរដ្ឋ។ ប្រាក់ចំណូលដែលត្រូវបានកាត់បន្ថយនេះ អាចត្រូវបានទូទាត់ក្នុងចំនួនមិនដឹងច្បាស់តាមរយៈការផ្លាស់ប្តូរផ្សេងៗទៀតចំពោះចំណូលរបស់រដ្ឋ។ ឧទាហរណ៍ ចំណូលពន្ធបន្ថែមអាចនឹងត្រូវបានបង្កើតឡើង ប្រសិនបើ CDCs ឆ្លើយតបទៅនឹងវិធានការនេះដោយការបង្កើនការ ចំណាយទៅលើប្រាក់ឈ្នួលបុគ្គលិកដែលគេអនុញ្ញាតនោះ។

ទាក់ទងនឹងភាពមិនប្រាកដប្រជាដ៏សំខាន់ ផលប៉ះពាល់ជាទូទៅលើហិរញ្ញវត្ថុរដ្ឋ និងមូលដ្ឋានគឺមិនច្បាស់លាស់។ ការបកស្រាយខុសគ្នាអំពីបទប្បញ្ញត្តិរបស់វិធានការ

នេះ និងការឆ្លើយតបរបស់ CDC ដែលផ្សេងគ្នា ចំពោះវិធានការនេះនឹងនាំឱ្យមានផលប៉ះពាល់ផ្សេងគ្នា សម្រាប់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋាន។ ទាក់ទងនឹងភាពមិនច្បាស់លាស់ដ៏សំខាន់អំពីវិធីរបៀបបក ស្រាយវិធានការនេះ និងរបៀបដែល CDC អាចឆ្លើយតបទៅនឹងផលប៉ះពាល់សុទ្ធដែលអាចកើតមាន ជាច្រើនលើហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានគឺអាចកើតមាន។

ផលប៉ះពាល់ទូទៅអាចមានចាប់ពីផលប៉ះពាល់វិជ្ជមានសុទ្ធក្នុងទឹកប្រាក់រាប់លាន ដុល្លារកម្រិតទាប។ ប្រសិនបើទីបំផុតវិធានការនេះត្រូវបាន បកស្រាយដើម្បីកំណត់ន័យឱ្យបានទូលំទូលាយអំពីការចំណាយដែលគេអនុញ្ញាតដូចជាការរួមបញ្ចូលការចំណាយសម្រាប់ អ្នកគ្រប់គ្រងគិលានុបដ្ឋាក និងនាយកវេជ្ជសាស្ត្រ ចំនួនទឹកប្រាក់នៃការបង្វិលសងម្ចាស់/ប្រតិបត្តិកររបស់ CDC ត្រូវបានតម្រូវឱ្យចំណាយនឹងកាន់តែតិច។ នៅក្រោមការបកស្រាយនេះ វាទំនងជាម្ចាស់/ប្រតិបត្តិករបស់ CDC នឹងឆ្លើយតបជាមួយនឹងការប្រែប្រួលតិចតួចនេះចំពោះ រចនាសម្ព័ន្ធនៃការចំណាយរបស់

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

ពួកគេ។ នៅក្នុងសេណារីយ៉ូនេះ ការចំណាយរបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានសម្រាប់អត្ថប្រយោជន៍សុខភាពនិយោជិតអាចត្រូវបានកាត់បន្ថយ។ ប្រាក់សន្សំទាំងនេះទំនងជាត្រូវបានទូទាត់ដោយផ្នែកដោយការកាត់បន្ថយសុទ្ធនៅក្នុងចំណូលពន្ធរដ្ឋ។ ជារួម យើងប៉ាន់ប្រមាណថា វិធានការនេះអាចមានផល ប៉ះពាល់ជាវិជ្ជមានដល់ហិរញ្ញវត្ថុរបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានដែលឈានដល់រាប់សិបលាន ដុល្លារជារៀងរាល់ឆ្នាំកម្រិតទាបនៅក្នុងសេណារីយ៉ូនេះ។

. . . ចំពោះផលប៉ះពាល់អវិជ្ជមានសុទ្ធក្នុងទឹកប្រាក់រាប់សិបលានដុល្លារ។ ប្រសិនបើ ទីបំផុតវិធានការនេះត្រូវបានបកស្រាយដើម្បីឱ្យមាននិយមន័យកាន់តែចង្អៀត និងតឹងរ៉ឹងអំពីការចំណាយដែលគេអនុញ្ញាតនោះ ចំនួនទឹកប្រាក់នៃការបង្ហិលសងម្ចាស់/ប្រតិបត្តិកររបស់ CDC ដែលត្រូវតម្រូវឱ្យបង់នោះកាន់តែច្រើនឡើង។ ក្រោមការបកស្រាយនេះ ម្ចាស់ និងប្រតិបត្តិកររបស់ CDC ប្រហែលជានឹងឆ្លើយតបជាមួយនឹងការផ្លាស់ប្តូរដ៏សំខាន់ៗនៃរចនាសម្ព័ន្ធចំណាយរបស់ពួកគេ ជាពិសេសតាមរយៈការបង្កើនការចំណាយដែលគេអនុញ្ញាត។ ម្ចាស់/ប្រតិបត្តិកររបស់ CDC ក៏ទំនងជានឹងស្វែងរកការកែតម្រូវចំពោះប្រាក់ចំណូលដែលបានកំណត់ ឬប្រតិបត្តិការកាត់បន្ថយនៅក្នុងស្ថាប័នរដ្ឋផងដែរ។ នៅក្នុងសេណារីយ៉ូនេះ ការចំណាយរបស់រដ្ឋ និងរដ្ឋអំណាចមូលដ្ឋានសម្រាប់អត្ថប្រយោជន៍សុខភាពនិយោជិត និងការចំណាយ Medi-Cal អាចកើនឡើង។ ចំណូលពន្ធរដ្ឋក៏អាចត្រូវបានកាត់បន្ថយផងដែរ។ ជារួម យើងប៉ាន់ប្រមាណថាវិធានការនេះអាចមានផលប៉ះពាល់អវិជ្ជមានសុទ្ធដែលឈានទៅដល់ទឹកប្រាក់រាប់សិបលានដុល្លារជារៀងរាល់ឆ្នាំនៅក្នុងសេណារីយ៉ូនេះ។

ផលប៉ះពាល់សារពើពន្ធផ្សេងទៀតដែលអាចកើតមាន។ សេណារីយ៉ូដែលបានរៀបរាប់ខាងលើនេះតំណាងឱ្យការប៉ាន់ប្រមាណដ៏ល្អបំផុតរបស់យើង អំពីផលប៉ះពាល់សារពើពន្ធជាច្រើនដែលទំនងជាកើតមានរបស់វិធានការនេះ។ ទោះជាយ៉ាងណាក៏ដោយ ផលប៉ះពាល់សារពើពន្ធដទៃទៀតអាចកើតមាន។ ជាឧទាហរណ៍ ប្រសិនបើ CDCs ឆ្លើយតបទៅនឹងប្រតិបត្តិការនេះដោយការកាត់បន្ថយប្រតិបត្តិការនៅក្នុងស្ថាប័នរដ្ឋ នោះ អ្នកជំងឺលាងឈាមមួយចំនួនដែលទទួលបានការព្យាបាលជំងឺលាងឈាម អាចត្រូវបានអាក់ខានក្នុងរយៈពេលខ្លី។ នេះអាចនាំឱ្យមានផលវិបាកសុខភាពដែលនាំឱ្យមានការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ ចំពោះវិសាលភាពដែលថា អ្នកជំងឺលាងឈាមត្រូវបានគេបញ្ជូនទៅកាន់មន្ទីរពេទ្យកាន់តែញឹកញាប់ដោយសារតែវិធានការចំណាយនេះ នោះការចំណាយរបស់រដ្ឋ — ជាពិសេសខាង Medi-Cal — អាចកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលខ្លី។

ផលប៉ះពាល់ផ្នែករដ្ឋបាល

វិធានការនេះដាក់ការទទួលខុសត្រូវថ្មីៗលើ CDPH យើងប៉ាន់ប្រមាណថាការចំណាយប្រចាំឆ្នាំដើម្បីអនុវត្តទំនួលខុសត្រូវថ្មីទាំងនេះ ទំនងជាមិនលើប៉ុន្មានលានដុល្លារទេក្នុងមួយឆ្នាំ។ វិធានការនេះតម្រូវឱ្យ CDPH ដើម្បីកែតម្រូវថ្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំដែលបង់ដោយ CDC (បច្ចុប្បន្នមានតម្លៃប្រហែល $3,400 ដុល្លារក្នុងមួយកន្លែង) ដើម្បីគ្របដណ្តប់លើការចំណាយទាំងនេះ។ មួយចំនួននៃការចំណាយរដ្ឋបាលទាំងនេះអាចត្រូវបានទូទាត់ដោយការពិន័យបង់ដោយ CDCs ទាក់ទងទៅនឹងការបង្ខិលប្រាក់ឬបរាជ័យក្នុងការអនុវត្តតាមវិធានការនេះតម្រូវការរាយការណ៍នេះ។ គេមិនដឹងចំនួនទឹកប្រាក់សម្រាប់ការផាត់ទាត់ណាមួយទេ។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណ:កម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ សូមចូលទៅ *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីមើលអ្នកផ្តល់វិភាគទានកំពូលចំនួន 10 របស់គណកម្មាធិការនេះ។

ប្រសិនបើអ្នកចង់បានអត្ថបទទាំងមូលនៃវិធានការរដ្ឋនេះ សូមទូរស័ព្ទមកលេខាធិការរបស់រដ្ឋ តាមរយៈលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែលទៅ *vigfeedback@sos.ca.gov* ដើម្បីទទួលបានអត្ថបទនេះមួយដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 8 ★

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 8—តម្លៃយុត្តិធម៌សម្រាប់ច្បាប់ស្តីពីការលាងឈាម

ការលាងឈាម គឺជាការព្យាបាលសង្គ្រោះជីវិតសម្រាប់អ្នកជំងឺដែលខូចតម្រងនោម ដែលក្នុងនោះឈាមពួកគេត្រូវបូមចេញ សម្អាត រួចដាក់ចូលទៅក្នុងរាងកាយពួកគេវិញ។ អ្នកជំងឺលាងឈាម ត្រូវមានបរិស្ថានស្អាត គ្មានមេរោគនៅអំឡុងពេលព្យាបាលពួកគេ ប៉ុន្តែអ្នកផ្តល់សេវាលាងឈាមខ្នាតធំជាសាជីវកម្ម ដែលរកលុយបានរាប់ពាន់លាន ដោយគិតថ្លៃឈ្នួលពីអ្នកជំងឺឈឺធ្ងន់ទាំងនេះរហូតដល់ $150,000 ក្នុងមួយឆ្នាំ នឹងមិនវិនិយោគគ្រប់គ្រាន់នៅក្នុងអនាម័យមូលដ្ឋានឡើយ។ ស្នាមប្រឡាក់ឈាម កន្លាត និងបន្ទប់ទឹកកខ្វក់ត្រូវបានគេរាយការណ៍នៅគ្លីនិកលាងឈាម ហើយអាយុជីវិតរបស់អ្នកជំងឺ មានហានិភ័យដោយសារតែប្រឈមនឹងការចម្លងមេរោគគ្រោះថ្នាក់ និងជំងឺផ្សេងៗ។ តម្លៃខ្ពស់ទាំងនេះ ធ្វើឲ្យមានចំណាយក្នុងការថែទាំសុខភាពកាន់តែខ្ពស់ឡើងសម្រាប់ពលរដ្ឋ California។ សំណើប្រ.មតិ 8 នឹងតម្រូវឲ្យសាជីវកម្មទាំងឡាយសងមកវិញនូវប្រាក់ចំណូលលើសលប់ ដែលមិនត្រូវបានចំណាយទៅលើការកែលម្អការថែទាំអ្នកជំងឺលាងឈាម។

បញ្ឈប់ការគិតថ្លៃហួសហេតុពីអ្នកជំងឺ

ក្រុមហ៊ុនលាងឈាមធំជាងគេនៅរដ្ឋ Californiaបង្កើនថ្លៃឈ្នួលរបស់ខ្លួនរហូតដល់ 350% ខ្ពស់ជាងតម្លៃជាក់ស្តែងសម្រាប់ការផ្តល់ការថែទាំ ឬរហូតដល់ $150,000 ក្នុងមួយឆ្នាំ។ សំណើប្រ.មតិ 8 នឹងផ្តល់គ្រឿងលើកទឹកចិត្តមុតមាំសម្រាប់ក្រុមហ៊ុនលាងឈាមឲ្យបន្ទាបតម្លៃ និងកែលម្អគុណភាពនៃការថែទាំរបស់ពួកគេ ធ្វើឲ្យអ្នកជំងឺជាអាទិភាពគ្រប់ទីកន្លែង ដែលមានសារសំខាន់ជាពិសេសសម្រាប់សហគមន៍ដែលមានប្រាក់ចំណូលទាប និងសហគមន៍ជនជាតិភាគតិច។

បន្ទាបតម្លៃថែទាំសុខភាពសម្រាប់គ្រប់គ្នា

ដោយសារតែអ្នកជំងឺលាងឈាម តែងតែត្រូវបានគិតថ្លៃឈ្នួលក្នុងចំនួនទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ សម្រាប់ការព្យាបាលសង្គ្រោះជីវិតរបស់ពួកគេ ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានបង្ខំឲ្យរុញចំណាយទាំងនោះទៅអ្នកមានប័ណ្ណសន្សារ៉ាប់រង ដែលធ្វើឲ្យចំណាយលើការថែទាំសុខភាពមានការកើនឡើងសម្រាប់ពលរដ្ឋ California ទាំងអស់។ ក្រុមហ៊ុនផ្តល់សេវាធានារ៉ាប់រងមួយគឺ Blue Shield of California បានរាយការណ៍ថា ខ្លួនយកអ្នកមានប័ណ្ណសន្សារ៉ាប់រង 3,800 នាក់ផ្សេងទៀត ដើម្បីមកទូទាត់តម្លៃលើអ្នកជំងឺលាងឈាមម្នាក់។ សំណើប្រ.មតិ 8 នឹងជួយបន្ទាបតម្លៃក្នុងការថែទាំសុខភាពសម្រាប់ពលរដ្ឋ California ទាំងអស់។

គាំទ្រដោយសម្ព័ន្ធភាពដ៏ទូលំទូលាយ

អ្នកតស៊ូមតិអ្នកជំងឺលាងឈាម LLC • ពលរដ្ឋ California ដើម្បីសិទ្ធិពិការភាព • CalPERS • សមាជនៃព្រឹទ្ធាចារ្យរដ្ឋ California • សហជីពកម្មករនិយោជិកផ្តល់សេវាអន្តរជាតិរដ្ឋ California • សម្ព័ន្ធភាពអតីតយុទ្ធជនជនជាតិភាគតិចរដ្ឋ California • និងជាច្រើនទៀត . . .

ធ្វើឲ្យអ្នកជំងឺជាអាទិភាពខ្ពស់បំផុត

យើងគួរតែបោះឆ្នោត "គាំទ្រ" លើសំណើប្រជាមតិ 8 និងប្រាប់ក្រុមហ៊ុនលាងឈាមឲ្យផ្តល់អាទិភាពលើការព្យាបាលសង្គ្រោះជីវិតសម្រាប់អ្នកជំងឺ លើប្រាក់ចំណូលរបស់សាជីវកម្ម។

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 8

ស្វែងយល់បន្ថែមអំពីរបៀបដែលសំណើប្រជាមតិ 8 នឹងជួយកែលម្អការថែទាំសុខភាពសម្រាប់ពលរដ្ឋ California តាមរយៈ *www.YESonProp8.com*

TANGI FOSTER, អ្នកជំងឺលាងឈាម

GARY PASSMORE, ប្រធាន
សមាជនៃព្រឹទ្ធាចារ្យរដ្ឋ California

NANCY BRASMER, ប្រធាន
សម្ព័ន្ធដើម្បីនិវត្តជនអាមេរិកនៅរដ្ឋ California

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 8 ★

អ្នកគាំទ្រកំពុងធ្វើឲ្យអ្នកបោះឆ្នោតយល់ច្រឡំ។ វិធានការនេះមានគុណវិបត្តិ និងគ្រោះថ្នាក់។ នេះគឺជាការពិត។

សំណើប្រជាមតិ 8 is ត្រូវបានប្រឆាំងដោយអ្នកមានអាជីពថែទាំសុខភាព និងអ្នកជំងឺលាងឈាមរាប់ពាន់នាក់ទូទាំងរដ្ឋ California រួមមានជាអាទិ៍ សមាគមគិលានុប្បដ្ឋាកអាមេរិក\California, សមាគមវេជ្ជសាស្ត្ររដ្ឋ, និងមហាវិទ្យាល័យគ្រូពេទ្យសង្គ្រោះបន្ទាន់អាមេរិក, California Chapter ពីព្រោះ វាប៉ះពាល់ដល់លទ្ធភាពទទួលបានការថែទាំសម្រាប់អ្នកជំងឺនៅរដ្ឋ California ចំនួន 66,000 ដែលត្រូវការការលាងឈាមដើម្បីបន្តជីវិតរស់នៅ។

"ការខកខានណាត់ជួបសូម្បីតែម្តង ក៏អាចបង្ករគ្រោះថ្នាក់ដល់អាយុជីវិតអ្នកជំងឺលាងឈាមបានដែរ។ តាមរយៈការដាក់កម្រិតលើលទ្ធភាពទទួលបានការថែទាំលាងឈាម សំណើប្រជាមតិ 8 ធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតអ្នកជំងឺ។"

—Dr. Theodore M. Mazer, ប្រធាន, សមាគមវេជ្ជសាស្ត្ររដ្ឋ California, តំណាងឲ្យវេជ្ជបណ្ឌិត 43,000 នាក់

គ្លីនិកលាងឈាមនៅរដ្ឋ CALIFORNIA មានចំណាត់ថ្នាក់ក្នុងចំណោម ខ្ពស់បំផុតនៅក្នុងប្រទេសសម្រាប់ការថែទាំប្រកបដោយគុណភាព

គ្លីនិកលាងឈាមនៅរដ្ឋ California ត្រូវបានដាក់បញ្ញត្តិខ្ពង់ខ្ពស់បំផុតនៅថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធ។ យោងតាមនិយ័តករសហព័ន្ធ គ្លីនិកនៅរដ្ឋ California អនុវត្តការងារបានល្អនៅរដ្ឋផ្សេងទៀតតាមគុណភាពគ្លីនិក និងមានការពេញចិត្តពីអ្នកជំងឺ។

សំណើប្រ.មតិ 8 នឹងបង្ខំឲ្យគ្លីនិកលាងឈាមក្នុងសហគមន៍ កាត់បន្ថយសេវា និងបិទទ្វារ—ដែលបង្ករគ្រោះថ្នាក់ដល់អ្នកជំងឺ

ការវិភាគឯកភាជ្យមួយដែលបានធ្វើឡើងដោយអតីតអ្នកវិភាគច្បាប់របស់រដ្ឋ Californiaបានរកឃើញថា ក្រោមសំណើប្រជាមតិ 8 នឹងបណ្តាលឲ្យ 83% នៃគ្លីនិកលាងឈាមត្រូវប្រតិបត្តិការទាំងខាត។ តថភាពនោះ នឹងបង្ខំឲ្យគ្លីនិករាប់រយត្រូវកាត់បន្ថយប្រតិបត្តិការ ឬបិទទ្វារ។

សំណើប្រជាមតិ 8 នឹងធ្វើឲ្យអ្នកប្រើប្រាស់ និងអ្នកបង់ពន្ធទាំងអស់ត្រូវមានតម្លៃក្នុងចំនួនទឹកប្រាក់រាប់រយលានប្រចាំឆ្នាំ

សំណើប្រ.មតិ 8 ដាក់កម្រិតទៅលើអ្វីដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវបង់ប្រាក់សម្រាប់ការថែទាំលាងឈាម។ ប៉ុន្តែគ្មានអ្វីមួយនៅក្នុងសំណើប្រ.មតិ 8 ដែលតម្រូវឲ្យក្រុមហ៊ុនធានារ៉ាប់រងផ្តល់ប្រាក់សន្សំណាមួយជូនអ្នកប្រើប្រាស់ឡើយ។ តាមពិតទៅ សំណើប្រ.មតិ 8 នឹងបង្កើនចំណាយសម្រាប់អ្នកបង់ពន្ធនូវចំនួនទឹកប្រាក់រាប់រយលានប្រចាំឆ្នាំ ដោយបង្ខំអ្នកជំងឺលាងឈាមឲ្យចូលទៅក្នុងមន្ទីរពេទ្យ និងបន្ទប់សង្គ្រោះបន្ទាន់ ដែលមានចំណាយកាន់តែថ្លៃ ដែលបង្កឲ្យមានភាពតានតឹងថែមទៀតនៅក្នុងបន្ទប់សង្គ្រោះបន្ទាន់ ដែលមានមនុស្សច្រើនរួចទៅហើយ។

សូមចូលរួមជាមួយវេជ្ជបណ្ឌិត គិលានុប្បដ្ឋាក និងអ្នកជំងឺ។

បោះឆ្នោត ប្រឆាំង លើសំណើប្រជាមតិ 8។ វាមានគ្រោះថ្នាក់។

www.NoProp8.com

PHILLIP BAUTISTA, RN, ប្រធាន
សមាគមគិលានុប្បដ្ឋាកអាមេរិក\California

TERRY RICO, អ្នកជំងឺលាងឈាម

THEODORE M. MAZER, MD, ប្រធាន
សមាគមវេជ្ជសាស្ត្ររដ្ឋ California

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយទីភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 8 ★

សំណើប្រ.មតិ 8 ធ្វើឲ្យអាយុជីវិតរបស់អ្នកជំងឺលាងឈាមដែលងាយរងគ្រោះមានហានិភ័យ

សមាគមគិលានុប្បដ្ឋាកអាមេរិក\California, សមាគមវេជ្ជសាស្ត្ររដ្ឋ California, មហាវិទ្យាល័យគ្រូពេទ្យសង្គ្រោះបន្ទាន់អាមេរិក, California Chapter និងអ្នកតស៊ូមតិអ្នកជំងឺទាំងអស់សុទ្ធតែ ប្រឆាំងនឹង សំណើប្រ.មតិ 8 ពីព្រោះវាប៉ះពាល់ដល់លទ្ធភាពទទួលបានការថែទាំសម្រាប់អ្នកជំងឺនៅរដ្ឋ California ចំនួន 66,000 ដែលត្រូវការការព្យាបាលលាងឈាមញឹកញាប់ដើម្បីបន្តជីវិតរស់នៅ។

"អ្នកជំងឺលាងឈាមខូចតម្រងនោម ហើយឈឺខ្លាំង។ ពួកគេត្រូវការការលាងឈាមបីថ្ងៃក្នុងមួយសប្តាហ៍ រយៈពេលបួនម៉ោងក្នុងមួយលើក ក្នុងការធ្វើការងារនៃតម្រងនោមរបស់ពួកគេ ដើម្បីយកជាតិពុលចេញពីរាងកាយ។ អ្នកជំងឺទាំងនេះមិនអាចរស់បានដោយគ្មានការព្យាបាលជាប្រចាំបានឡើយ។ សំណើប្រ.មតិ 8 មានគ្រោះថ្នាក់ក្នុងការកាត់បន្ថយលទ្ធភាពទទួលបានការថែទាំ និងធ្វើឲ្យអ្នកជំងឺងាយរងគ្រោះមានហានិភ័យ។"—**Phillip Bautista, BSN, RN, PHN,** ប្រធាន, **សមាគមគិលានុប្បដ្ឋាកអាមេរិក\California**

សំណើប្រ.មតិ 8 នឹងបង្ខំឲ្យគ្លីនិកលាងឈាមក្នុងសហគមន៍ កាត់បន្ថយសេវា និងបិទទ្វារ

សំណើប្រជាមតិ 8 ដាក់កម្រិតយ៉ាងធ្ងន់ធ្ងរទៅលើអ្វីដែលក្រុមហ៊ុនធានារ៉ាប់រងត្រូវបានតម្រូវឲ្យបង់ប្រាក់សម្រាប់ការថែទាំលាងឈាម។ ការដាក់កម្រិតមជ្ឈត្តកម្មនេះ នឹងមិនរ៉ាប់រងទៅលើតម្លៃជាក់ស្តែងនៃការផ្តល់ការថែទាំឡើយ។

តាមពិតទៅ ការវិភាគឯករាជ្យមួយដែលបានធ្វើឡើងដោយអតីតអ្នកវិភាគច្បាប់របស់រដ្ឋ Californiaបានសន្និដ្ឋានថា សំណើប្រជាមតិ 8 នឹងបណ្តាលឲ្យ 83% នៃគ្លីនិកលាងឈាមត្រូវប្រតិបត្តិការទាំងខាត។ ការនោះនឹងបង្ខំឲ្យគ្លីនិករាប់រយត្រូវកាត់បន្ថយប្រតិបត្តិការ ឬបិទទ្វារ ដែលបង្ករគ្រោះថ្នាក់ដល់អ្នកជំងឺ។

បើគ្មានលទ្ធភាពទទួលបានគ្លីនិកក្នុងសហគមន៍ទេនោះ អ្នកជំងឺនឹងត្រូវធ្វើដំណើរទៅឆ្ងាយ ខកខានការព្យាបាល ឬត្រូវចូលក្នុងបន្ទប់សង្គ្រោះបន្ទាន់។

វេជ្ជបណ្ឌិត គិលានុប្បដ្ឋាក និងអ្នកតស៊ូមតិអ្នកជំងឺទាំងអស់ សុទ្ធតែប្រឆាំងនឹង សំណើប្រ.មតិ 8

"ការខកខានណាត់ជួបសូម្បីតែម្តង ក៏អាចបង្ករគ្រោះថ្នាក់ដល់អាយុជីវិតអ្នកជំងឺលាងឈាមបានដែរ។ តាមរយៈការដាក់កម្រិតលើលទ្ធភាពទទួលបានការថែទាំលាងឈាម សំណើប្រជាមតិនេះធ្វើឲ្យប៉ះពាល់ដល់អាយុជីវិតអ្នកជំងឺ។"—**Dr. Theodore M. Mazer,** ប្រធាន, **សមាគមវេជ្ជសាស្ត្ររដ្ឋ California, តំណាងឲ្យវេជ្ជបណ្ឌិត 43,000 នាក់**

"ក្នុងនាមជាគ្រូពេទ្យសង្គ្រោះបន្ទាន់ម្នាក់ យើងតែងតែព្យាបាលអ្នកជំងឺលាងឈាមជាប្រចាំ ដែលចុងក្រោយស្ថិតក្នុងបន្ទប់សង្គ្រោះបន្ទាន់ ដោយសារតែខកខានការណាត់ជួប ឬមានភាពស្មុគស្មាញដោយសារខូចតម្រងនោម។ សំណើប្រជាមតិនេះ នឹងបង្កើនហានិភ័យស្មុគស្មាញដែលគំរាមកំហែងដល់អាយុជីវិតសម្រាប់អ្នកជំងឺដែលងាយរងគ្រោះបំផុតទាំងនេះ។" —**Dr. Aimee Moulin,** ប្រធាន, **មហាវិទ្យាល័យគ្រូពេទ្យសង្គ្រោះបន្ទាន់អាមេរិក, California Chapter**

សំណើប្រ.មតិ 8 បង្ករការប៉ះពាល់ដោយវិសមាមាត្រទៅលើសហគមន៍ដែលជួបប្រទះការលំបាក

សំណើប្រ.មតិ 8 ត្រូវបានប្រឆាំងដោយ California NAACP និងសមាគមជាតិវេជ្ជសាស្ត្រអេស្ប៉ាញ ពីព្រោះវានឹងប៉ះពាល់ដោយវិសមាមាត្រទៅលើអ្នកជំងឺនៅតាមសហគមន៍ដែលជួបប្រទះការលំបាក ដែលមានហានិភ័យខូចតម្រងនោមខ្លាំង។

សំណើប្រ.មតិ 8 បង្កើនចំណាយសម្រាប់ពលរដ្ឋ CALIFORNIA ទាំងអស់ក្នុងចំនួនទឹកប្រាក់រាប់រយលានប្រចាំឆ្នាំ

នៅពេលគ្លីនិកបិទទ្វារ អ្នកជំងឺលាងឈាមត្រូវចូលក្នុងបន្ទប់សង្គ្រោះបន្ទាន់ ដែលការថែទាំរឹតតែថ្លៃថែមទៀត។ យោងតាមអតីតអ្នកវិភាគច្បាប់ វិធានការនេះនឹងបង្កើនចំណាយរបស់អ្នកបង់ពន្ធជិត $300 លានដុល្លារ ប្រចាំឆ្នាំ។

គុណភាពនៃការលាងឈាមនៅរដ្ឋ CALIFORNIA មានចំណាត់ថ្នាក់ក្នុងចំណោមគុណភាពខ្ពស់បំផុតនៅក្នុងប្រទេស

គ្លីនិកលាងឈាមនៅរដ្ឋ California មានការដាក់បញ្ញត្តិយ៉ាងខ្ពង់ខ្ពស់ពីនិយ័តករសហព័ន្ធ និងរដ្ឋ ដែលផ្តល់របាយការណ៍ប្រកបដោយគុណភាពស្តីពីគ្លីនិកនីមួយៗ។ យោងតាមមជ្ឈមណ្ឌលសេវា Medicare និង Medicaid របស់សហព័ន្ធ គ្លីនិកនៅរដ្ឋ California អនុវត្តការងារបានល្អនៅរដ្ឋផ្សេងទៀតតាមគុណភាពគ្លីនិក និងមានការពេញចិត្តពីអ្នកជំងឺ។ វិធានការនេះគ្មានន័យអ្វីសោះ នៅពេលការថែទាំលាងឈាមនៅរដ្ឋ California មានការដាក់បញ្ញត្តិយ៉ាងខ្ពង់ខ្ពស់ និងសង្គ្រោះជីវិត។

សំណើប្រ.មតិ 8 ស្ថិតនៅចន្លោះវេជ្ជបណ្ឌិត និងអ្នកជំងឺ

បោះឆ្នោត ប្រឆាំង លើសំណើប្រ.មតិ 8 និងទុកឲ្យការសម្រេចចិត្តអំពីវេជ្ជសាស្ត្រស្មុគស្មាញអំពីការលាងឈាមនៅក្នុងដៃរបស់វេជ្ជបណ្ឌិត និងអ្នកជំងឺ។

សំណើប្រ.មតិ 8 មានគ្រោះថ្នាក់។ បោះឆ្នោត ប្រឆាំង។

សូមចូលរួមជាមួយវេជ្ជបណ្ឌិត គិលានុប្បដ្ឋាក និងអ្នកតស៊ូមតិអ្នកជំងឺ និងច្រានចោលសំណើប្រជាមតិដែលមានគ្រោះថ្នាក់នេះ ដែលធ្វើឲ្យអ្នកជំងឺលាងឈាមដែលងាយរងគ្រោះមានហានិភ័យ។ *www.NoProp8.com*

PHILLIP BAUTISTA, RN, ប្រធាន
សមាគមគិលានុប្បដ្ឋាកអាមេរិក\California
THEODORE M. MAZER, MD, ប្រធាន
សមាគមវេជ្ជសាស្ត្ររដ្ឋ California
AIMEE MOULIN, MD, ប្រធាន
មហាវិទ្យាល័យគ្រូពេទ្យសង្គ្រោះបន្ទាន់អាមេរិក, California Chapter

★ ការឆ្លើយតបទៅនឹងទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 8 ★

បោះឆ្នោត គាំទ្រ លើសំណើប្រជាមតិ 8 ដើម្បីកែលម្អការថែទាំសុខភាពនៅរដ្ឋ CALIFORNIA។

សាជីវកម្មលាងឈាមកាត់បន្ថយសេវា និងបង្ករគ្រោះថ្នាក់ដល់អ្នកជំងឺ

អ្នកជំងឺដែលខូចតម្រងនោម ជាទូទៅត្រូវទទួលការលាងឈាមបីដងក្នុងមួយសប្តាហ៍ ដែលឈាមរបស់ពួកគេត្រូវបូមយកចេញ សម្អាត និងដាក់បញ្ចូលក្នុងរាងកាយពួកគេវិញ។ អ្នកជំងឺ និងអ្នកផ្តល់ការថែទាំ រាយការណ៍អំពីលក្ខខណ្ឌគ្មានសុវត្ថិភាពនៅគ្លីនិកលាងឈាម រួមមានជាអាទិ៍ មានបុគ្គលិកបម្រើក្នុងពេលខ្លី ហើយអនាម័យ និងបង្ករន់អនាម័យនៅខ្សោយ ដែលធ្វើឲ្យពួកគេមានហានិភ័យគំរាមកំហែងដល់អាយុជីវិតដោយសារតែការឆ្លងមេរោគ។

"នៅពេលខ្ញុំចាប់ផ្តើមលាងឈាម ខ្ញុំមិនរំពឹងថា ខ្ញុំនឹង ត្រូវបារម្ភអំពីគ្លីនិកដែលគួរតែការារក្សាឲ្យខ្ញុំមានសុខភាពល្អឡើយ។ ខ្ញុំបានឃើញសត្វល្អិតវារនៅចន្លោះផ្ទាស្ទិកដែលគ្របពីលើគ្រឿងបំពាក់ភ្លើងនៅលើពិដាន។ ខ្ញុំត្រូវទូរស័ព្ទទៅកាន់នាយកដ្ឋានសុខាភិបាលជាច្រើនលើកច្រើនសារ ដើម្បីរាយការណ៍អំពីសត្វកន្លាត ស្នាមឈាមប្រឡាក់ និងកង្វះការសម្អាតឲ្យបានគ្រប់គ្រាន់។"— *Tangi Foster, អ្នកជំងឺលាងឈាម*

ចូលមើល *www.Yes0n8.com* **ដើម្បីអានជាមុនអំពីការវាយតម្លៃពីអ្នកជំងឺលាងឈាម។**

សាជីវកម្មលាងឈាម រកប្រាក់ចំណេញយ៉ាងច្រើនសន្ធឹកសន្ធាប់ពីការចំណាយរបស់ អ្នកជំងឺ

សាជីវកម្មលាងឈាមរកប្រាក់ចំណេញ រកបានប្រាក់ចំណេញរាប់ពាន់លាន ខណៈដែលគ្លីនិកនៅតាមសហគមន៍គ្លីនិកមានការអន់ថយ ដោយគ្មានវេជ្ជបណ្ឌិតប្រចាំការនៅពេលខ្លះ។

សំណើប្រ.មតិ 8 ជំរុញឲ្យសាជីវកម្មលាងឈាមត្រូវវិនិយោគប្រាក់ចំណេញទាំងនោះ ដើម្បីកែលម្អការថែទាំអ្នកជំងឺ ដែលត្រូវការជាពិសេសនៅក្នុងសហគមន៍មានប្រាក់ចំណូលទាប។

ការគិតថ្លៃហួសហេតុធ្វើឲ្យតម្លៃសម្រាប់ពួកយើងទាំងអស់គ្នាមានការកើនឡើង

សាជីវកម្មលាងឈាមបង្កើនតម្លៃលើការថែទាំសម្រាប់អ្នកជំងឺមួយចំនួននៅអត្រា 350% ដែលជាចំណាយមួយដែលស្រូបយកដោយក្រុមហ៊ុនធានារ៉ាប់រង ហើយរុញទៅលើអ្នកមានប័ណ្ណសន្សារ៉ាប់រងទូទាំងរដ្ឋ California។

តម្លៃខ្ពស់របស់ពួកគេធ្វើឲ្យការថែទាំសុខភាពកាន់តែថ្លៃសម្រាប់យើងទាំងអស់គ្នា។

គណបក្សប្រជាធិបតេយ្យរដ្ឋ California, អតីតយុទ្ធជន, អ្នកតស៊ូមតិការថែទាំសុខភាព និងមេដឹកនាំសាសនា សុទ្ធតែគាំទ្រ គាំទ្រ លើសំណើប្រ.មតិ 8។

វាគឺជាពេលដែលសាជីវកម្មលាងឈាមត្រូវផ្តល់អាទិភាពលើការថែទាំអ្នកជំងឺ មិនមែនប្រាក់ចំណេញរបស់ពួកគេឡើយ។

GUADALUPE TELLEZ, គិលានុប្បដ្ឋាកលាងឈាមមានបញ្ជីកា
PASTOR WILLIAM D. SMART, JR.
សន្និសីទថ្នាក់ដឹកនាំគ្រីស្ទានភាគខាងត្បូងនៃ California
TANGI FOSTER, អ្នកជំងឺលាងឈាម

នៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2018, សំណើប្រជាមតិ 9 ត្រូវបានដកចេញពីសន្លឹកឆ្នោតតាមដីកានៃតុលការជាន់ខ្ពស់រដ្ឋ California។

នៅថ្ងៃទី 18 ខែកក្កដា ឆ្នាំ 2018, សំណើប្រជាមតិ 9 ត្រូវបានដកចេញពីសន្លឹកឆ្នោតតាមដីកានៃតុលការជាន់ខ្ពស់រដ្ឋ California។

10 សំណើប្រជាមតិ ពង្រីកអំណាចរដ្ឋាភិបាលមូលដ្ឋាន ដើម្បីអនុម័តការគ្រប់គ្រងការជួលលអចលនទ្រព្យលំនៅដ្ឋាន។ លក្ខន្តិកៈផ្ដួចផ្ដើម។

ចំណងជើង និងសេចក្ដីសង្ខេបជាផ្លូវការ — រៀបចំដោយអគ្គមេធាវី

អត្ថបទនៃវិធានការនេះអាចរកនៅលើគេហទំព័ររដ្ឋលេខាធិការនៅ *http://voterguide.sos.ca.gov*។

- លុបចោលច្បាប់របស់រដ្ឋដែលបច្ចុប្បន្ននេះដាក់ កម្រិតវិសាលភាពនៃគោលនយោបាយគ្រប់គ្រងការជួលដែលទីក្រុង និងយុត្តាធិការក្នុងមូលដ្ឋានផ្សេងទៀតអាចដាក់លើអចលនទ្រព្យជាលំនៅដ្ឋាន
- អនុញ្ញាតគោលនយោបាយដែលនឹងកំណត់អត្រាការជួលដែលថាម្ចាស់អចលនទ្រព្យជាលំនៅដ្ឋាន អាចនឹងគិតប្រាក់សម្រាប់អ្នកជួលថ្មី សំណង់ថ្មី និងផ្ទះគ្រួសារតូច។
- ស្របតាមច្បាប់រដ្ឋ California ផ្ដល់នូវគោលនយោបាយគ្រប់គ្រងការជួលមិនអាចបំពានសិទ្ធម្ចាស់ផ្ទះ ក្នុងការទទួលបានផលចំណេញផ្នែកហិរញ្ញវត្ថុត្រឹមត្រូវលើអចលនទ្រព្យជួលរបស់ពួកគាត់នោះទេ។

វិភាគដោយអ្នកវិភាគច្បាប់ការប៉ាន់ប្រមាណរបស់រដ្ឋ សុទ្ធ និងផលប៉ះពាល់សារពើពន្ធរបស់រដ្ឋាភិបាលក្នុងតំបន់ៈ

- សក្តានុពលនៃការកាត់ បន្ថយសុទ្ធនៅក្នុងប្រាក់ចំណូល រដ្ឋនិងមូលដ្ឋាន រាប់សិបលានដុល្លារក្នុងមួយឆ្នាំៗក្នុងរយៈពេលវែង។ អាស្រ័យលើសកម្មភាពរបស់សហគមន៍មូលដ្ឋាន ការបាត់បង់ប្រាក់ចំណូលអាចមានចំនួនតិចជាង ឬទ៖នងជាច្រើនជាងនេះ។

ការវិភាគដោយអ្នកវិភាគច្បាប់

ជីវប្រវត្តិ

នៅ California ការជួលផ្ទះមានតម្លៃថ្លៃ។ អ្នកជួលនៅ California ជាធម្មតាបង់ 50% លើសអ្នកជួលផ្ទះនៅក្នុងរដ្ឋផ្សេងទៀត។ ក្នុងតំបន់ខ្លះនៃរដ្ឋ តម្លៃជួលគឺច្រើនជាងពីរដងនៃតម្លៃមធ្យមថ្នាក់ជាតិ។ ការជួលខ្ពស់ក្នុង California ពីព្រោះរដ្ឋមិនមានលំនៅដ្ឋានគ្រប់គ្រាន់សម្រាប់អ្នកទាំងអស់គ្នាដែលចង់រស់នៅទីនេះ។ ប្រជាជនដែលចង់រស់នៅទីនេះត្រូវតែប្រកួតប្រជែងដើម្បីទិញផ្ទះដែលនាំឲ្យការជួលកើនឡើង។

ទីក្រុងជាច្រើនមានច្បាប់ត្រួតត្រាជួល។ ទីក្រុង California ជាច្រើន—រួមទាំង Los Angeles, San Francisco និង San Jose—មានច្បាប់ដែលកំណត់ថាតើម្ចាស់ដីអាចបង្កើនប្រាក់ឈ្នួលសម្រាប់ជួលពីមួយឆ្នាំទៅមួយឆ្នាំដែរឬទេ។ ច្បាប់ទាំងនេះជាញឹកញាប់ត្រូវបានគេហៅថាការគ្រប់គ្រងការជួល។ ប្រហែល 1 ភាគ 5 នៃប្រជាជន California រស់នៅក្នុងទីក្រុងដែលមានការគ្រប់គ្រងការជួល។ ក្រុមប្រឹក្សាភិបាលក្នុងស្រុកគ្រប់គ្រងការត្រួតពិនិត្យការជួល។ ក្រុមប្រឹក្សាភិបាលទាំងនេះត្រូវបានផ្ដល់មូលនិធិតាមរយៈថ្លៃលើម្ចាស់ផ្ទះ។

សេចក្ដីសម្រេចរបស់តុលាការកំណត់ការត្រួតពិនិត្យការជួលតាមមូលដ្ឋាន។ តុលាការបានសម្រេចថាច្បាប់គ្រប់គ្រងការជួលត្រូវអនុញ្ញាតឱ្យម្ចាស់ផ្ទះទទួលបាន "អត្រាប្រាក់ត្រឡប់មកវិញដោយត្រឹមត្រូវ។" នេះមានន័យថាម្ចាស់ដីត្រូវបានអនុញ្ញាតឱ្យបង្កើនប្រាក់ឈ្នួលឱ្យបានគ្រប់គ្រាន់ដើម្បីទទួលប្រាក់ចំណេញខ្លះៗរៀងរាល់ឆ្នាំ។

ច្បាប់រដ្ឋកំណត់ការត្រួតពិនិត្យការជួលតាមមូលដ្ឋាន។ ថ្លៃ តំលៃ ត្រូវបានគេស្គាល់ថាជាច្បាប់លំនៅដ្ឋាន Costa-Hawkins (Costa-Hawkins), កំណត់ព្រំដែនច្បាប់គ្រប់គ្រងការជួលក្នុងតំបន់។ Costa-Hawkins បង្កើតដែនកំណត់សំខាន់បី។ ទី 1 ការត្រួតពិនិត្យការជួលមិនអាចអនុវត្តចំពោះផ្ទះគ្រួសារ។តូចបានទេ។ ទី 2 គ្រប់គ្រងការជួលមិនអាចអនុវត្តចំពោះលំនៅដ្ឋានថ្មីដែលបានសាងសង់រួចរាល់នៅថ្ងៃទី 1 ខែកុម្ភៈ ឆ្នាំ 1995 ឬក្រោយថ្ងៃនេះនោះទេ ទី 3 ច្បាប់គ្រប់គ្រងការជួលមិនអាចកំណត់តម្លៃដល់ម្ចាស់ផ្ទះក្នុងការគិតថ្លៃឈ្នួលដល់គ្រួសារថ្មី នៅពេលដែលពួកគេទើបរើចូលនៅដំបូងនោះទេ

ប្រាក់ចំណូលពន្ធរដ្ឋ និងរដ្ឋាភិបាលមូលដ្ឋាន។ ពន្ធបីគឺជាធនធានធំនៃចំណូលពន្ធសម្រាប់រដ្ឋ និងរដ្ឋាភិបាលមូលដ្ឋានក្នុង California ។ រដ្ឋប្រមូលពន្ធចំណូលផ្ទាល់ខ្លួនលើចំណូល—រួមទាំងការជួលដែលម្ចាស់ផ្ទះ—ទទួលបានពីការជួលនៅក្នុងរដ្ឋនេះផងដែរ រដ្ឋាភិបាលប្រមូលពន្ធអចលនទ្រព្យពីម្ចាស់អចលនទ្រព្យដោយផ្អែកលើតម្លៃនៃអចលនទ្រព្យរបស់ពួកគាត់ រដ្ឋាភិបាលមូលដ្ឋានប្រមូលពន្ធការលក់លើការលក់រាយទំនិញ។

សេចក្ដីស្នើច្បាប់

ការបដិសេធ Costa-Hawkins។ វិធានការបដិសេធលើការកំណត់ច្បាប់គ្រប់គ្រងការជួលក្នុងតំបន់ នៅ Costa-Hawkins។ ក្រោមវិធានការនេះ ក្រុង និងខោនធីអាចគ្រប់គ្រងថ្លៃជួល *លំនៅដ្ឋាន* ណាមួយ។ ពួកគេក៏អាចកំណត់ថាតើម្ចាស់ផ្ទះអាចបង្កើនប្រាក់ឈ្នួលនៅពេលអ្នកផ្លាស់ប្តូរទីលំនៅថ្មីចូល។ វិធានការនេះមិនធ្វើការផ្លាស់ប្តូរណាមួយដល់ច្បាប់គ្រប់គ្រងការជួលក្នុងតំបន់នោះទេ។ ជាមួយករណីលើកលែងមួយចំនួន ក្រុង ខោនធីនឹងត្រូវចាត់វិធានការដាច់ដោយឡែកដើម្បីផ្លាស់ប្តូរច្បាប់ក្នុងមូលដ្ឋាន

ការវិភាគដោយអ្នកវិភាគច្បាប់ បន្ត

តម្រូវឱ្យមានអត្រាប្រាក់ត្រឡប់ស្មើរ។ វិធានការនេះតម្រូវឱ្យច្បាប់គ្រប់គ្រងការជួលអនុញ្ញាតឱ្យម្ចាស់ដីទទួលបានអត្រាប្រាក់ត្រឡប់មកវិញដោយត្រឹមត្រូវ នេះធ្វើឱ្យលទ្ធផលនៃសេចក្ដីសម្រេចរបស់តុលាការកន្លងមកក្លាយជាច្បាប់របស់រដ្ឋ។

ផលប៉ះពាល់សារពើពន្ធ

ផលប៉ះពាល់សេដ្ឋកិច្ច ប្រសិនបើសហគមន៍ឆ្លើយតបចំពោះវិធានការនេះដោយការពង្រីកច្បាប់គ្រប់គ្រងការជួលរបស់ពួកគេវាអាចនាំទៅរកផលប៉ះពាល់សេដ្ឋកិច្ចជាច្រើន។ ផលប៉ះពាល់ភាគច្រើនគឺ៖

- ដើម្បីចៀសវាងបទបញ្ញត្តិ ម្ចាស់ផ្ទះមួយចំនួន នឹងលក់ផ្ទះជួលរបស់ពួកគេទៅឲ្យម្ចាស់ថ្មីដែលនឹងរស់នៅទីនោះ។
- តម្លៃផ្ទះជួលនឹងធ្លាក់ចុះព្រោះម្ចាស់ផ្ទះសក្តានុពលមិនចង់ចំណាយប្រាក់ច្រើនសម្រាប់អចលនទ្រព្យទាំងនេះ។
- អ្នកជួលមួយចំនួននឹងចំណាយតិចលើការជួល ហើយម្ចាស់ផ្ទះមួយចំនួននឹងទទួលបានចំណូលតិច។
- អ្នកជួលមួយចំនួននឹងមិនសូវរើផ្ទះ

ផលប៉ះពាល់ទាំងនេះ ផ្អែកលើថាតើមានសហគមន៍ចំនួនប៉ុន្មានអនុម័តតាមច្បាប់ថ្មីនេះ មានអចលនទ្រព្យចំនួនប៉ុន្មាននិងកំណត់តម្លៃជួលប៉ុន្មាន អ្នកបោះឆ្នោតក្នុងសហគមន៍មួយចំនួនបានស្នើឱ្យពង្រីកការត្រួតពិនិត្យការជួលប្រសិនបើវិធានការនេះត្រូវបានអនុវត្តន៍។ ប្រសិនបើមានតំបន់ជាច្រើនបានអនុម័តឱ្យមានបទបញ្ញត្តិថ្លៃជួលផ្ទះ ផលប៉ះពាល់សេដ្ឋកិច្ចផ្សេងទៀត (ដូចជាផលប៉ះពាល់លើការសាងសង់លំនៅដ្ឋាន) អាចកើតមានឡើង។

ការផ្លាស់ប្តូរប្រាក់ចំណូលរដ្ឋ និងក្នុងតំបន់។ វិធានការផលប៉ះពាល់សេដ្ឋកិច្ចនឹងប៉ះពាល់ដល់ពន្ធអចលនទ្រព្យ ពន្ធការលក់ និងពន្ធលើប្រាក់ចំណូល ផលប៉ះពាល់ធំបំផុត និងអាចកើតឡើងបំផុតគឺ៖

- ***ពន្ធអចលនទ្រព្យដែលត្រូវបានបង់ដោយម្ចាស់ផ្ទះមានចំនួនតិចជាងមុន*** ការធ្លាក់ចុះតម្លៃអចលនទ្រព្យជួលក្នុងរយៈពេលជាច្រើនឆ្នាំ នឹងនាំឱ្យមានការថយចុះការបង់ពន្ធអចលនទ្រព្យដោយម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យទាំងនោះ។
- ***ពន្ធលើការលក់ច្រើនជាងមុនដែលបង់ដោយអ្នកជួល*** អ្នកជួលដែលចំណាយលើថ្លៃជួលតិចនឹងប្រើប្រាស់ប្រាក់សន្សំមួយចំនួនរបស់ពួកគេដើម្បីទិញទំនិញជាប់ពន្ធ។
- ***ផ្លាស់ប្តូរពន្ធលើប្រាក់ចំណូលដែលបង់ដោយម្ចាស់ផ្ទះ។*** ការទូទាត់ពន្ធលើប្រាក់ចំណូលរបស់ ម្ចាស់ផ្ទះនឹងត្រូវបានផ្លាស់ប្តូរក្នុងទំរង់ជាច្រើន ម្ចាស់ផ្ទះមួយចំនួននឹងទទួលចំណូលថ្លៃជួលតិច។ នេះនឹងកាត់បន្ថយការបង់ពន្ធលើប្រាក់ចំណូលរបស់ពួកគេ ម្យ៉ាងវិញទៀតយូរទៅម្ចាស់ផ្ទះនឹងចំណាយតិចក្នុងការទិញអចលនទ្រព្យជួល។ ការធ្វើបែបនេះនឹងកាត់បន្ថយការចំណាយដែលពួកគេអាចទាមទារឱ្យបន្ថយការបង់ពន្ធលើប្រាក់ចំណូល (ដូចជាការប្រាក់កម្ចីទិញផ្ទះ ពន្ធអចលនទ្រព្យ និងការរំលោះ)។ នេះនឹងបង្កើនការបង់ពន្ធលើប្រាក់ចំណូលរបស់ពួកគេ វិធានការផលប៉ះពាល់សុទ្ធលើពន្ធលើប្រាក់ចំណូលដែលបង់ដោយម្ចាស់ផ្ទះក្នុងរយៈពេលវែងគឺមានភាពមិនច្បាស់លាស់នោះទេ

ជាទូទៅ វិធានការនេះទំនងជានឹងកាត់បន្ថយប្រាក់ចំណូលរដ្ឋ និងប្រាក់ចំណូលមូលដ្ឋានក្នុងរយៈពេលវែង ជាមួយផលប៉ះពាល់ធំបំផុតទៅលើពន្ធអចលនទ្រព្យ។ ចំនួននៃការបាត់បង់ប្រាក់ចំណូលគឺអាស្រ័យលើកត្តាជាច្រើនដែលសំខាន់បំផុតថាតើមានសហគមន៍ចំនួនប៉ុន្មាននឹងឆ្លើយតបចំពោះវិធានការនេះ។ ប្រសិនបើសហគមន៍មួយចំនួនពង្រីកការគ្រប់គ្រងការជួលដើម្បីគ្របដណ្ដប់លើលំនៅដ្ឋានជួលរបស់ពួកគេការខាតបង់ប្រាក់ចំណូលអាចនឹងមានចំនួនរាប់ម៉ឺនលានដុល្លារក្នុងមួយឆ្នាំៗ។ ប្រសិនបើសហគមន៍មួយចំនួនធ្វើការផ្លាស់ប្តូរ ការបាត់បង់ប្រាក់ចំណូលនឹងមានតិចតួច។ ប្រសិនបើសហគមន៍ជាច្រើនអនុវត្តន៍ការត្រួតពិនិត្យការជួលនេះ ការខាតបង់ប្រាក់ចំណូលអាចមានចំនួនរាប់រយលានដុល្លារក្នុងមួយឆ្នាំៗ។

តម្លៃរដ្ឋាភិបាលក្នុងតំបន់បានកើនឡើង។ ប្រសិនបើក្រុង ឬខោនធីបង្កើតច្បាប់គ្រប់គ្រងការជួលថ្មី ឬពង្រីកកន្លែងដែលមានស្រាប់ក្រុមប្រឹក្សាភិបាលជួលក្នុងមូលដ្ឋាននឹងត្រូវប្រឈមនឹងការកើនឡើងនៃចំណាយរដ្ឋបាល និងនិយតកម្ម។ អាស្រ័យលើជម្រើសរដ្ឋាភិបាលមូលដ្ឋាន ការចំណាយទាំងនេះអាចមានចាប់ពី **តិចតួចទៅរាប់សិបលានដុល្លារ** ក្នុងមួយឆ្នាំៗ។ ការចំណាយទាំងនេះទំនងជានឹងត្រូវបានបង់ដោយថ្លៃលើម្ចាស់ផ្ទះជួល។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីចូលទៅកាន់អ្នកបរិច្ចាគកំពូលៗទាំង 10 របស់គណៈកម្មាធិការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានធ្វើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 10 ★

ថ្លៃជួលគឺខ្ពស់ខ្លាំងមែនទែន! ការបោះឆ្នោតបាទ/ចាស សំណើប្រជាមតិ 10 នឹងធ្វើឱ្យមានសេរីភាពដល់បណ្តាសហគមន៍ក្នុងតំបន់របស់យើងក្នុងការសម្រេចចិត្តលើការការពារការគ្រប់គ្រងថ្លៃជួលដែលចាំបាច់ បើមានដើម្បីដោះស្រាយវិបត្តិលំនៅដ្ឋាន។ សំណើប្រ.មតិ ដប់ការពារអ្នកជួល។

គ្រួសារជាច្រើនចំណាយជាងពាក់កណ្តាលប្រាក់ចំណូលរបស់ពួកគាត់លើលំនៅដ្ឋាន។ នេះគឺមិនអាចទទួលយកបានឡើយ ការរស់នៅយកប្រាក់ខែបង់ថ្លៃសែកមានន័យថា វាពិបាកសម្រាប់ក្រុមគ្រួសារទាំងនេះដើម្បីបំពេញសេចក្តីត្រូវការប្រាក់សន្សំសម្រាប់ប្រើក្នុងគ្រាអាសន្នមានតិចតួច។ មនុស្សចាស់ដែលមានប្រាក់ចំណូលថេរមានប្រាក់តិចតួចសម្រាប់ចំណាយលើមួយអាហារ និងថ្នាំពេទ្យ។ មនុស្សជាច្រើនដែលជាគ្រឹះនៃបណ្តាសហគមន៍ក្នុងស្រុករបស់យើង—គ្រូបង្រៀន គិលានុបដ្ឋាយិកា និងអ្នកពន្លត់អគ្គីភ័យ—ត្រូវបានបង្ខំឱ្យផ្លាស់ទីចេញទៅឆ្ងាយពីបណ្តាសហគមន៍ដែលពួកគេបម្រើការងារ ពីព្រោះតែម្ចាស់ផ្ទះសាជីវកម្មនឹងដំឡើងថ្លៃជួលពីរដង ឬបីដង។ ជាមួយការលំបាករបស់ក្រុមគ្រួសារជាច្រើនបែបនេះ មនុស្សជាច្រើនត្រូវបានជម្រុញឱ្យផ្លាស់ទីចេញពី California ដោយចាកចេញពីការងារ សាច់ញាติ និងសាលារៀនរបស់ពួកគេ។ កាន់តែអាក្រក់ជាងនេះទៅទៀតក្រុមគ្រួសារជាច្រើនត្រូវបានបង្ខំឲ្យគ្មានផ្ទះសម្បែងនិងរស់នៅលើដងផ្លូវ។ ជាមួយការកើនឡើងថ្លៃជួល 5% មនុស្សជាង 2,000 នាក់ត្រូវបានបង្ខំឱ្យចេញពីផ្ទះរបស់ពួកគេ—ពួកគេត្រូវបានបំផ្លិចបំផ្លាញ និងកាន់តែអាក្រក់ជាងនេះទៅទៀត California ត្រូវដោះស្រាយបញ្ហាគ្មានផ្ទះសម្បែង

ការបោះឆ្នោ: បាទ/ចាសលើ សំណើប្រ.មតិ 10 នឹងអនុញ្ញាតឱ្យបណ្តាក្រុងនានាដែលត្រូវការអនុម័តច្បាប់កំណត់ការឡើងថ្លៃឈ្នួល សំណើប្រ.មតិ 10 មិនកំណត់អាណាត្តិការគ្រប់គ្រងថ្លៃជួលឡើយ។ វាមិនបង្ខំឲ្យសហគមន៍ណាមួយទទួលយកវិធានការគ្រប់គ្រងថ្លៃជួលណាមួយដែលមិនល្អសម្រាប់ស្ថានភាពលំនៅដ្ឋានរបស់ពួកគេនោះទេ។ វាមិនបង្ខំឲ្យប្រើវិធីសាស្ត្រមួយដើម្បីដោះស្រាយបញ្ហាទាំងអស់នៅក្នុងក្រុងនោះទេ ជំនួសមកវិញ សំណើប្រ.មតិ 10 ជាសាមញ្ញអនុញ្ញាតឱ្យបណ្តាសហគមន៍ដែលកំពុងជម្នះជាមួយថ្លៃចំណាយលើលំនៅដ្ឋានដែលកើនឡើងកប់ពពក ដាក់ដែនកំណត់ប្រចាំឆ្នាំលើការកើនឡើងថ្លៃជួល បណ្តាសហគមន៍គឺមានសេរីភាពក្នុងការនាំមកនូវភាពស្មើគ្នាចំពោះលំនៅដ្ឋាន ដោយធានាថា អ្នកជួលមានការការពារប្រឆាំងនឹងការកើនឡើងថ្លៃជួលដ៏ខ្ពស់ ស្របពេលដែលម្ចាស់ផ្ទះទទួលបានអត្រាប្រាក់ត្រឡប់មកវិញដោយត្រឹមត្រូវជាមួយនិងកំណើនប្រចាំឆ្នាំសមស្រប

អ្នកបោះឆ្នោតបានលឹមទឡ្ហីករណ៍ភ័ន្តច្រឡំជាច្រើនអំពីសំណើប្រជាមតិ 10។ កុំជឿការវាយប្រហារនានា។ សាជីវកម្ម Wall Street ដូចជា Blackstone ដែលជាប់ពាក់ព័ន្ធនិង Donald Trump បានចំណាយរាប់លានដុល្លារដើម្បីប្រយុទ្ធប្រឆាំងនឹងវិធានការនេះ ពីព្រោះពួកគេភ័យខ្លាចថា វានឹងកាត់ផលចំណេញជាច្រើនដែលពួកគេរកបានពីការលក់ផ្ទះរាប់ពាន់ដែលពួកគេរឹងអូសបានពួកគេមិនខ្វាយខ្វល់ថា គ្រួសារ California កំពុងត្រូវបានប៉ះទង្គិចដោយថ្លៃជួលខ្ពស់ឡើយ។ វាគឺដល់ពេលដែលត្រូវក្រោកឈរសម្រាប់លំនៅដ្ឋានដែលអាចទិញបាន និងប្រឆាំងនឹងពួកមហាសេដ្ឋី Wall Street និងម្ចាស់ផ្ទះសាជីវកម្មដែលលោភលន់ហើយដោយការបោះឆ្នោតបាទ/ចាសសំណើប្រ.មតិ 10។

សំណើប្រ.មតិ 10 គឺជាវិធានការមានកម្រិតមួយដែលឆ្លើយតបទៅនិងសំណួរមួយ៖ នរណាសម្រេចចិត្តលើគោលនយោបាយលំនៅដ្ឋាន—បណ្តាសហគមន៍ក្នុងតំបន់ ឬផលប្រយោជន៍ពិសេសរបស់ Sacramento និងអ្នកវិនិយោគលើអចលនទ្រព្យដ៏មានអនុភាព? វាមិនបង្កើតគោលនយោបាយលំនៅដ្ឋានថ្មី វាគ្រាន់តែអនុញ្ញាតឱ្យបណ្តាសហគមន៍ក្នុងតំបន់—ដែលនៅកៀកនឹងប្រជាជនជាង—សម្រេចចិត្តលើអ្វីដែលបានផលល្អបំផុតសម្រាប់ពួកគេប៉ុណ្ណោះ។ វាគឺដល់ពេលដែលយើងមានអំណាចក្នុងការដោះស្រាយបញ្ហានានានៃភាពគ្មានផ្ទះសម្បែង និងថ្លៃជួលកប់ពពកនៅក្នុងសហគមន៍ផ្ទាល់ខ្លួនរបស់យើងហើយ។

គិលានុបដ្ឋាយិកា California, គ្រូបង្រៀន, មនុស្សចាស់ជរា, ពលករមានការគ្រប់គ្រង ដែលរួមមានក្រុមប្រឹក្សារដ្ឋ សហភាពអន្តរជាតិនិយោជិកខាងបម្រើសេវា (Employees International Union (SEIU) អ្នកគាំពារលំនៅដ្ឋាន ក្រុមសិទ្ធិស៊ីវិល ក្រុមបព្វជិត និងអ្នកដែលផ្នែកលើជំនឿ និងអង្គការដទៃទៀតដែលអ្នកទុកចិត្តស្នើសុំការគាំទ្រលើ សំណើប្រជាមតិ 10។ ចូរចងចាំថា សំណើប្រ.មតិ ដប់ការពារអ្នកជួល។

ទទួលអង្គហេតុអំពី សំណើប្រជាមតិ 10 ៖
www.VoteYesOnProp10.org

ZENEI CORTEZ, សហប្រធាន
សមាគមគិលានុបដ្ឋាយិកា California
NAN BRASMER, ប្រធាន
សម្ព័ន្ធ California សម្រាប់ពលរដ្ឋអាមេរិកដែលចូលនិវត្តន៍
ELENA POPP, នាយកប្រតិបត្តិ
បណ្តាញការពារការបណ្តេញចេញ

★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 10 ★

សំណើប្រ.មតិ 10 នឹងធ្វើឱ្យវិបត្តិលំនៅដ្ឋានកាន់តែអាក្រក់ទៅៗ
គ្មានភាពប្រសើរឡើយ

អ្នកឧបត្ថម្ភនៃសំណើប្រ.មតិ 10 ចង់ឱ្យអ្នកជឿថា វានឹងដោះស្រាយ "វិបត្តិលំនៅដ្ឋានរបស់យើង" ដោយវេទមន្ត ប៉ុន្តែវានាំមកនូវការខូចខាត ហើយនឹងធ្វើឲ្យវិបត្តិផ្ទះសម្បែងកាន់តែអាក្រក់ឡើងៗ។ សំណើប្រ.មតិ 10 ៖

- អនុញ្ញាតឱ្យមានបទបញ្ញត្តិនៃផ្ទះលរបស់គ្រួសារតូច
- ឲ្យអ្នកធ្វើការក្នុងការិយល័យទទួលបន្ទុកការសម្រេចចិត្តទៅលើផ្ទះ
- ផ្តល់អំណាចដល់ក្រុមប្រឹក្សាភិបាលជួល 539 នាក់ ឱ្យបន្ថែមថ្លៃឈ្នួល
- ធ្វើឲ្យអ្នកបង់ពន្ធប្រឈមនិងហានិភ័យរាប់លានចំពោះតម្លៃផ្ទះច្បាប់
- បន្ថែមរាប់សិនលានលើថ្លៃចំណាយថ្មីៗទៅកាន់រដ្ឋាភិបាលមូលដ្ឋាន

ថ្នាក់ដឹកនាំលំនៅដ្ឋានដែលមានតម្លៃសមរម្យ យល់ព្រម៖ ប្រឆាំងលើសំណើប្រ.មតិ 10

"សំណើប្រ. មតិ 10 បង្ការដំណោះស្រាយលំនៅដ្ឋានទូទាំងរដ្ឋនាពេលអនាគត និងចាត់ការលើរដ្ឋសភា និងអភិបាលខេត្តពីការទទួលយកការការពារអ្នកជួលផ្ទះ។" **—Alice Huffman,** ប្រធាន, សន្និសីទរដ្ឋ California NAACP

"សំណើប្រ.មតិ. 10 មិនបានធ្វើអ្វីដើម្បីសាងសង់លំនៅដ្ឋានថ្មីដែលមានតម្លៃសមរម្យ ដែលក្រុមគ្រួសារត្រូវការនោះទេ។" **—John Gamboa,** សហស្ថាបនិក, The Two Hundred—សម្ព័ន្ធភាពនៃថ្នាក់ដឹកនាំយុត្តិធម៌សង្គម លើសពី 200

"ក្រោមសំណើប្រ.មតិ 10, គ្រួសារដែលស្វែងរកលំនៅដ្ឋានដែលមានតម្លៃសមរម្យនឹងរកឃើញជម្រើសផ្ទះតិចជាងមុនជាមួយនិងតម្លៃថ្លៃជាងមុន" **—Robert Apodaca,** នាយកប្រតិបត្តិ, ការបោះឆ្នោត United Latinos

"សម្រាប់មនុស្សចាស់លើសន្តិសុខសង្គម និងប្រាក់ចំណូលថេរ សំណើប្រ.មតិ 10 អាចកំពុងបំផ្លិចបំផ្លាញពួកគាត់" **—Marilyn H. Markham,** សមាជិកក្រុមប្រឹក្សាភិបាល, សម្ព័ន្ធអ្នកគាំពារមនុស្សចាស់ California

"សំណើប្រ.មតិ 10 អនុញ្ញាតឱ្យអ្នកធ្វើការការិយាល័យប្រាប់ម្ចាស់ផ្ទះពីអ្វីដែលពួកគាត់អាចឬមិនអាចធ្វើបានចំពោះផ្ទះរបស់ពួកគាត់។" **—Stephen White,** ប្រធាន, សមាគមភ្នាក់ងារអចលនទ្រព្យ California

"សំណើប្រ.មតិ 10 នឹងអនុញ្ញាតឱ្យអ្នកការិយាល័យដែលមិនបានជាប់ឆ្នោតដាក់ចេញនូវថ្លៃផ្សេងៗលើលំនៅដ្ឋានទាំងអស់ រួមមានផ្ទះសម្រាប់គ្រួសារតូចដែលមិនមានការបោះឆ្នោតពីមនុស្ស ឬអង្គភាពដែលបានជាប់ឆ្នោតក្នុងតំបន់" **—Jon Coupal,** ប្រធាន, សមាគមអ្នកបង់ពន្ធ Howard Jarvis

ចូលរួមជាមួយអ្នកឯករាជ្យ អ្នកប្រជាធិបតេយ្យ អ្នកសាធារណរដ្ឋ អ្នកជួល និងម្ចាស់ផ្ទះ ជនចាស់ជរា អ្នកបង់ពន្ធ និងក្រុមអនីតិជនក្នុងការបោះឆ្នោតប្រឆាំងនឹង សំណើប្រ.មតិ 10!

ALICE A. HUFFMAN, ប្រធាន
សន្និសីទរដ្ឋ California នៃសមាគមជាតិសម្រាប់ការរីកចម្រើនរបស់ប្រជាជនដែលមានពណ៌សម្បុរ (NAACP)
BETTY JO TOCCOLI, ប្រធាន
សមាគមអាជីវកម្មខ្នាតតូច California
MARILYN H. MARKHAM, សមាជិកក្រុមប្រឹក្សាភិបាល
សម្ព័ន្ធអ្នកគាំពារមនុស្សចាស់ California

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 10 ★

សំណើប្រ.មតិ 10 គឺបានធ្វើឲ្យខូចខាតហើយនឹងធ្វើឱ្យវិបត្តិលំនៅដ្ឋានរបស់យើងកាន់តែអាក្រក់ឡើងថែមទៀត។ បោះឆ្នោតប្រឆាំង

- សំណើប្រ.មតិ 10 ៖ អាក្រក់សម្រាប់ម្ចាស់ផ្ទះបច្ចុប្បន្ន និងអនាគត

"សំណើប្រជាមតិ 10 អាចធ្វើឱ្យប៉ះពាល់ដល់ម្ចាស់ផ្ទះដោយផ្តល់អំនាចដល់ការិយាធិបតេយ្យរបស់រដ្ឋាភិបាលថ្មីដែលអាចបញ្ជាម្ចាស់ផ្ទះពីអ្វីដែលពួកគាត់អាចធ្វើ ឬមិនអាចធ្វើចំពោះលំនៅដ្ឋានឯកជនរបស់ពួកគេ។ វាអាចធ្វើឱ្យផ្ទះកាន់តែឡើងថ្លៃសម្រាប់អ្នកទិញក្នុងពេលអនាគត ហើយប៉ះពាល់ដល់ក្រុមគ្រួសារដែលកំពុងព្យាយាមទិញផ្ទះជាលើកដំបូងរបស់ពួកគេ។"—**Stephen White**, ប្រធាន, សមាគមភ្នាក់ងារអចលនទ្រព្យ **California**។

- សំណើប្រ.មតិ. 10 ៖ អាក្រក់សម្រាប់អ្នកជួល

"អ្នកជួលរាប់ម៉ឺននាក់ រួមទាំងមនុស្សចាស់ និងអ្នកផ្សេងទៀត ដែលមានប្រាក់ចំណូលថេរ អាចត្រូវបានបង្ខំឱ្យចេញពីអាផាត់មិន និងបណ្តាសហគមន៍របស់ពួកគេ ក្រោមសំណើប្រ.មតិ. 10, ដែលអនុញ្ញាតឱ្យ ម្ចាស់ផ្ទះសាជីវកម្មដែលមានទ្រព្យស្តុកស្តម្ភប្រែក្លាយអាផាត់មិនទៅជាខុនដូ និងជួលសម្រាប់ការវិស្សមកាលរយៈពេលខ្លី។ វានឹងបង្កើនថ្លៃជួល និងធ្វើឱ្យកាន់តែពិបាកស្វែងរកលំនៅដ្ឋានតម្លៃសមរម្យ។"
—**Alice Huffman**, ប្រធាន, សន្និសីទរដ្ឋ **California NAACP**

ទេចំពោះ 10—គុណវិបត្តិច្រើនពេកហើយ៖

- អនុញ្ញាតឱ្យមានបទបញ្ញត្តិនៃផ្ទះរបស់គ្រួសារតូច

សំណើប្រ.មតិ 10 ទុកជានិរាករណ៍នូវការការពារដែលម្ចាស់ផ្ទះបានរីករាយរយៈពេលជាង 20 ឆ្នាំ និងអនុញ្ញាតឱ្យរដ្ឋាភិបាលកំណត់តម្លៃសម្រាប់ផ្ទះគ្រួសារតូចដែលជាកម្មសិទ្ធិឯកជន ដោយគ្រប់គ្រងតម្លៃដែលម្ចាស់ផ្ទះអាចជួលបាន—ឬសូម្បីតែតម្លៃជួលបន្ទប់។ សំណើប្រ.មតិ 10 អាចនាំឲ្យអ្នកធ្វើការក្នុងការិយាល័យគិតថ្លៃពីម្ចាស់ផ្ទះសម្រាប់ការមិនដាក់ផ្ទះរបស់ពួកគេជួល

- ធ្វើឲ្យអ្នកធ្វើការក្នុងការិយាល័យទទួលបន្ទុកផ្ទះ

សំណើប្រ.មតិ 10 ដាក់ក្រុមប្រឹក្សាភិបាលការជួលចំនួន 539 នាក់ឱ្យទទួលបន្ទុកលំនៅដ្ឋាន ដោយផ្តល់អំនាចគ្មានដែនកំណត់ដល់ទីភ្នាក់ងាររដ្ឋាភិបាលក្នុងការបន្ថែមថ្លៃលើលំនៅដ្ឋាន ជាចុងក្រោយដោយបង្កើនថ្លៃជួល និងធ្វើឱ្យផ្ទះ និងអាផាត់មិនកាន់តែថ្លៃ។ ក្រុមប្រឹក្សាភិបាលទាំងនេះអាចមានអំណាចគ្មានដែនកំណត់ក្នុងការកំណត់ប្រាក់ខែ និងអត្ថប្រយោជន៍របស់ពួកគេ ខណៈពេលដែលបន្ថែមថ្លៃផ្ទះកាន់តែខ្ពស់ទៅដល់អ្នកជួលផ្ទះ

- ធ្វើឲ្យអ្នកបង់ពន្ធប្រឈមនិងហានិភ័យរាប់លានចំពោះតម្លៃផ្លូវច្បាប់

ប្រសិនបើម្ចាស់ផ្ទះ អ្នកជួល ឬអ្នកបោះឆ្នោតប្រឆាំងនឹងច្បាប់នៅក្នុងតុលាការ សំណើប្រ.មតិ 10 តម្រូវឱ្យអ្នកបង់ពន្ធ **California** បង់ថ្លៃវិក្កយបត្រស្របច្បាប់របស់ អ្នកឧបត្ថម្ភ។ អ្នកបង់ពន្ធអាចនឹងជាប់គាំងក្នុងការបង់ប្រាក់រាប់សិនលានដុល្លារសម្រាប់វិធានការព្រាងដ៏អន់ និងមានកំហុសដ៏ច្រើននេះ

- បន្ថែមរាប់សិនលានលើថ្លៃចំណាយថ្មីៗទៅកាន់រដ្ឋាភិបាលមូលដ្ឋាន

អ្នកវិភាគច្បាប់គ្មានបក្សពន្ធរបស់រដ្ឋនិយាយថា សំណើប្រ.មតិ 10 អាចបង្កើនថ្លៃចំណាយសម្រាប់រដ្ឋាភិបាលមូលដ្ឋានរាប់សិបលានដុល្លារក្នុងមួយឆ្នាំ ហើយនាំឱ្យរដ្ឋខាតបង់ប្រាក់ចំណូលកាន់តែច្រើនលានថែមទៀត។ នេះអាចនាំឱ្យមានប្រាក់តិចសម្រាប់សាលារៀន និងសេវាសង្គ្រោះបន្ទាន់ កាត់បន្ថយការសាងសង់ផ្ទះថ្មី និងការបាត់បង់ការងារសាងសង់ដែលមានប្រាក់រាប់ពាន់។

- បង្កើនថ្លៃផ្ទះដែលមានស្រាប់

ថ្លៃសេវារដ្ឋាភិបាល និងបទបញ្ញត្តិថ្មីនឹងផ្តល់ឱ្យម្ចាស់ផ្ទះនូវការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដ៏ធំមួយដើម្បីបម្លែងអចលនទ្រព្យជួលទៅជាអចលនទ្រព្យដែលទទួលបានប្រាក់ចំណេញកាន់តែច្រើនដូចជាការជួលសម្រាប់វិស្សមកាលរយៈពេលខ្លី ដោយបង្កើនថ្លៃចំណាយលំនៅដ្ឋានដែលមានស្រាប់ និងធ្វើឱ្យប់អ្នកជួលកាន់តែពិបាកក្នុងការស្វែងរកលំនៅដ្ឋានដែលពួកគេអាចមានលទ្ធភាពជួលបាននាពេលអនាគត

បន្ទាត់ក្រោម៖ សំណើប្រ.មតិ 10 មានគុណវិបត្តិច្រើនពេក ហើយនឹងធ្វើឱ្យវិបត្តិលំនៅដ្ឋានកាន់តែអាក្រក់។

ស្វែងយល់ពីមូលហេតុដែលអ្នកបោះឆ្នោតទទួលបានការបញ្ចុះបញ្ចូលពីគណបក្សនយោបាយនៃ **California** នឹងបោះឆ្នោតប្រឆាំងលើសំណើប្រ.មតិ 10 នៅ *www.ReadItForYourself.com*

G.I. អាមេរិក វេទិកា **California**, សម្ព័ន្ធអ្នកគាំពារមនុស្សចាស់ **California**, សន្និសីទរដ្ឋ **California NAACP**, សមាគមភ្នាក់ងារអចលនទ្រព្យ **California**, សមាគមអាជីវកម្មបែបគ្រួសារ **California**, សមាគមអ្នកបង់ពន្ធ **Howard Jarvis**, សភាពាណិជ្ជកម្ម **California**, កិច្ចប្រជុំតុមូលអាជីវកម្ម **California**, ការបោះឆ្នោត**United Latinos**

ALICE A. HUFFMAN, ប្រធាន
សន្និសីទរដ្ឋ **California** នៃសមាគមជាតិសម្រាប់ការរីកចម្រើនរបស់ប្រជាជនដែលមានពណ៌សម្បុរ (**NAACP**)
FREDERICK A. ROMERO, មេបញ្ជាការរដ្ឋ
G.I. អាមេរិក វេទិកា **California**
STEPHEN WHITE, ប្រធាន
សមាគមភ្នាក់ងារអចលនទ្រព្យ **California**

★ ការឆ្លើយបដិសេធទៅលើទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 10 ★

កុំឱ្យគេបំភាន់ដោយផលប្រយោជន៍ពិសេសសាជីវកម្មប្រឆាំងនឹងសំណើប្រជាមតិ 10។ បើពួកគេចង់ជួយអ្នកជួលឲ្យមានលទ្ធភាពក្នុងការជួលផ្ទះដែលជាសេចក្តីត្រូវការមូលដ្ឋានរបស់មនុស្ស**California** នឹងមិនស្ថិតក្នុងវិបត្តិលំនៅដ្ឋានបែបនេះឡើយ។ ផ្ទើតាមប្រាក់៖ ផលប្រយោជន៍អចលនទ្រព្យដែលមានស្តុកស្តម្ភម្ចាស់សាជីវកម្ម និងអ្នកវិនិយោគ **Wall Street** បានទទួលផលចំណេញពីប្រព័ន្ធបច្ចុប្បន្នជាច្រើនទស្សវត្សរ៍មកហើយ។ សាជីវកម្មធំៗទាំងនេះតម្លើងថ្លៃជួលពីរដង ឬបីដងដោយឥតអៀនខ្មាស ពីព្រោះពួកគេអាចធ្វើបែបនេះដោយរួចខ្លួនបាន ពួកគេរកបានផលចំណេញដ៏ច្រើនពីវិបត្តិលំនៅដ្ឋានដែលពួកគេបានជួយបង្កើន។ គ្មានចម្ងល់ទេដែលថា ពួកគេមិនចង់ដោះស្រាយវា!

តើនរណាគាំទ្រសំណើប្រ.មតិ 10? អង្គការមិនស្វែងរកប្រាក់ចំណេញ គ្រូបង្រៀន គិលានុបដ្ឋាយិកា អ្នកចូលនិវត្តន៍ ពលករ ក្រុមផ្នែកលើជំនឿ អ្នកគាំពារលំនៅដ្ឋាន និងគណបក្សប្រជាធិបតេយ្យ **California** ទាំងអស់គ្នាស្នើសុំឱ្យ **បាទ/ចាស** ពីព្រោះតែសំណើប្រ.មតិ ដប់នេះការពារអ្នកជួល។

អ្នកជួល និងម្ចាស់ផ្ទះគួរតែបោះឆ្នោតបាទ/ចាស ដើម្បីរក្សាបណ្តាសហគមន៍ឱ្យរឹងមាំ។ វាអាចឱ្យប្រជានជនដែលកំពុងធ្វើការ—គ្រូបង្រៀន អ្នកពន្លត់អគ្គីភ័យ បុគ្គលិកថែទំារយៈពេលយូរអង្វែង បុគ្គលិកហាងលក់គ្រឿងទេស—បន្តរស់នៅក្នុងបណ្តាសហគមន៍ដែលពួកគេបម្រើការ ស្របពេលដែលពួកគេអាចមានលទ្ធភាពក្នុងការបំពេញតម្រូវការមូលដ្ឋានដូចជាអាហារនិងការថែទំាកូនជាដើម ម្ចាស់ផ្ទះសាជីវកម្មដែលលោភលន់កំពុងបង្ខំជនមានពិការភាព និងមនុស្សចាស់ជាច្រើនដែលមានប្រាក់ចំណូលថេរឱ្យជ្រើសរើស រវាងថ្លៃជួល ឬថ្នាំពេទ្យ ហើយពួកគេកំពុងបង្ខំក្រុមគ្រួសារដែលមានប្រាក់ចំណូលទាបជាច្រើនទៀតធ្លាក់ចូលទៅក្នុងភាពគ្មានផ្ទះសម្បែង—ដែលជាវិបត្តិនៃថ្លៃចំណាយកើនឡើង។

សំណើប្រ.មតិ 10 មិនផ្តល់អាណត្តិដល់ច្បាប់ថ្មី ឬការិយាធិបតេយ្យសម្រាប់សហគមន៍ទាំងឡាយឡើយ—វាគ្រាន់តែផ្តល់ឱ្យអ្នក ក្នុងនាមជាប្រជាជន នូវអំណាចក្នុងការអភិវឌ្ឍគោលនយោបាយគ្រប់គ្រងថ្លៃជួលសម្រាប់សហគមន៍របស់អ្នកប៉ុណ្ណោះ។ ប្រជាជនឈ្នះ មិនមែនជាផលប្រយោជន៍ពិសេសដែលលោភលន់នោះទេ។ ថ្លៃជួលគឺខ្ពស់ខ្លាំងមែនទែន! **បាទ/ចាស** លើសំណើប្រជាមតិលេខដប់ដើម្បីការពារអ្នកជួល។

ទទួលបានការគាំទ្រពីគណបក្សប្រជាធិបតេយ្យ **California**;
សមាគមគិលានុបដ្ឋាយិកា **California**; លំនៅដ្ឋាន **California**;
សមព័ន្ធនគរូបនីយកម្មជាតិ; **ACLU** នៃ **California**; មូលនិធិចែទំាសុខភាព **AIDS**;
ម្ចាស់អចលនទ្រព្យសម្រាប់លំនៅដ្ឋានមានតម្លាភាព និងលួមអាចចំណាយបាន;
អ្នកគូររូប និងជំនួញរួមសម្ព័ន្ធ 36; សហភាពបុគ្គលិកសេវាកម្មអន្តរជាតិ (**SEIU**);
សហព័ន្ធរដ្ឋអាមេរិក, បុគ្គលិកខោនធី និងបុគ្គលិកក្រុង (**AFSCME**); ក្រុមប្រឹក្សាភិបាលពលករកណ្តាលនៃខោនធី **Humboldt** និង **Del Norte AFL-CIO**; មូលនិធិជំនួយផ្នែកច្បាប់តំបន់ជនបទ **California**; មជ្ឈមណ្ឌលភាគខាងលិចស្តីពីច្បាប់និងភាពក្រីក្រ; បណ្តាញសកម្មភាពជាតិ-ឡូសអេនដែលេស; សម្ព័ន្ធឆ្នេរសមុទ្រកណ្តាលរួបរួមសម្រាប់សេដ្ឋកិច្ចអាចទ្រទ្រង់បាន; និងអង្គភាពអ្នកជួលទូទាត់រដ្ឋ។
www.VoteYesOnProp10.org

ERIC C. HEINS, ប្រធាន
សមាគមគ្រូបង្រៀនរដ្ឋ **California**
REV. WILLIAM D. SMART, JR., ប្រធាន, សន្និសីទភាពជាអ្នកដឹកនាំគ្រីស្ទៀនភាគខាងត្បូងនៃ **California** ភាគខាងត្បូង
ROXANNE SANCHEZ, ប្រធាន
SEIU California

11 សំណើប្រជាមតិ តម្រូវឲ្យបុគ្គលិករថយន្តពេទ្យបន្ទាន់អាសន្នផ្នែកវិស័យឯកជនអោយនៅប្រចាំការទទួលទូរស័ព្ទក្នុងកំឡុងពេលសម្រាកធ្វើការ។ លុបបំបាត់ទំនួលខុសត្រូវនិយោជកមួយចំនួន។ លក្ខន្តិកៈផ្ទួចផ្ដើម។

ចំណងជើង និងសេចក្ដីសង្ខេបផ្លូវការ

បានរៀបចំដោយអគ្គមេធាវី

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័រ របស់រដ្ឋលេខាធិការ *http://voterguide.sos.ca.gov* ។

- ធ្វើច្បាប់ការងារផ្ដល់សិទ្ធិដល់និយោជិតធ្វើការម៉ោងសម្រាកពីការងារសម្រាប់បរិភោគ និងសម្រាក ដោយមិននៅប្រចាំការទទួលទូរស័ព្ទដែលមិនទាក់ទងនឹង និយោជិតខាងឡានពេទ្យសង្គ្រោះបន្ទាន់ ក្នុងវិស័យឯកជន។ ធ្វើនិយ័តកម្មពេលវេលានៃការសម្រាកបរិភោគ សម្រាប់បុគ្គលិកទាំងនេះ។
- លុបបំបាត់ ការទទួលខុសត្រូវរបស់ និយោជក-ក្នុងសកម្មភាពដែលនៅមិនទាន់សម្រេចនៅថ្ងៃ ឬបន្ទាប់ពីថ្ងៃទី 25 ខែតុលា ឆ្នាំ 2017-ចំពោះការរំលោភច្បាប់ដែលមានស្រាប់ទាក់ទងនឹងការសម្រាកនៅកន្លែងការងារ។ តម្រូវអោយនិយោជកផ្ដល់ការបណ្ដុះបណ្ដាលទាក់ទងនឹងព្រឹត្តិការអាសន្នមួយចំនួន ការបង្ការអំពើហិង្សា និងសុខភាពផ្លូវចិត្ត និងសុខុមាលភាព។
- តម្រូវឱ្យនិយោជកផ្ដល់ដល់បុគ្គលិកនូវសេវាសុខភាពផ្លូវចិត្ត មួយចំនួន។

សេចក្ដីសង្ខេបការវាយតម្លៃនៃការវិភាគរបស់អង្គ នីតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ទំនងជាផលប្រយោជន៍សារពើពន្ធទៅរដ្ឋាភិបាលក្នុងមូលដ្ឋាន (នៅក្នុងទម្រង់មានតម្លៃ ទាបនិងទទួលប្រាក់ចំណូលខ្ពស់) អាចមានចំនួន រាប់សិបលានដុល្លារជារៀងរាល់ឆ្នាំ។

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

ការដឹកជញ្ជូនខាងវេជ្ជសាស្ត្រគ្រាអាសន្ន 911

រថយន្តសង្គ្រោះបន្ទាន់ផ្ដល់ការថែទាំ និងការដឹកជញ្ជូនផ្នែកវេជ្ជសាស្ត្រក្នុងគ្រាអាសន្ន ។ នៅពេលទូរស័ព្ទទៅ 911 សម្រាប់ជំនួយវេជ្ជសាស្ត្ររថយន្តសង្គ្រោះបន្ទាន់មួយនឹងត្រូវបានបញ្ជូនទៅទីតាំងនោះ។ (ជាទូទៅ រថយន្តពន្លត់អគ្គិភ័យមូលដ្ឋានមួយក៏ត្រូវបានបញ្ជូនទៅជាមួយដែរ)។ នៅកន្លែងកើតហេតុ ក្រុមការងារផ្ដល់ការព្យាបាលដល់អ្នកជំងឺ។ ប្រសិនបើចាំបាច់ ក្រុមការងារដឹកអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត។ (រថយន្តសង្គ្រោះបន្ទាន់ក៏ផ្ដល់ការដឹកជញ្ជូនករណីមិនបន្ទាន់ដល់មន្ទីរពេទ្យ ឬការិយាល័យគ្រូពេទ្យដែរ នៅពេលដែលអ្នកជំងឺត្រូវការការព្យាបាល ឬការធ្វើតេស្ត។)

រថយន្តសង្គ្រោះបន្ទាប់ភាពច្រើនត្រូវបានប្រតិបត្តិការដោយក្រុមហ៊ុនឯកជន។ ក្រុមហ៊ុនឯកជនកាន់កាប់ និងប្រតិបត្តិការរថយន្តសង្គ្រោះបន្ទាន់ភាគច្រើននៅរដ្ឋ California។ ពួកគេផ្ដល់ប្រហែល 75% នៃការដឹកជញ្ជូនតាមរថយន្តសង្គ្រោះបន្ទាន់ទាំងអស់។ ក្នុងករណី 25 ភាគរយ ផ្សេងទៀត នាយកដ្ឋានពន្លត់អគ្គិភ័យមូលដ្ឋានមានរថយន្តសង្គ្រោះបន្ទាន់ផ្ទាល់ខ្លួន និងដឹកជញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យដោយខ្លួនឯង។

ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់ភាគច្រើនត្រូវបង់ថ្លៃដោយក្រុមហ៊ុនធានារ៉ាប់រងសុខភាព។ ច្បាប់រដ្ឋតម្រូវឱ្យរថយន្តសង្គ្រោះបន្ទាន់ដឹកអ្នកជំងឺទាំងអស់ សូម្បីតែអ្នកជំងឺដែលមិនមានការធានារ៉ាប់រងសុខភាព និងមិនអាចបង់ថ្លៃបានក៏ដោយ។ ទោះជាយ៉ាងណា ក្នុងករណីភាគច្រើន ការធានារ៉ាប់រងចេញថ្លៃសម្រាប់ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់។ លើសពីរភាគបីនៃការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់គឺសម្រាប់អ្នកជំងឺដែលមានការធានារ៉ាប់រងរបស់រដ្ឋាភិបាល ដូចជា Medicare និង Medicaid (ដែលគេស្គាល់ថាជា Medi-Cal នៅក្នុងរដ្ឋ California) ។ ប្រហែល 20 ភាគរយនៃការធ្វើដំណើរគឺសម្រាប់អ្នកជំងឺដែលមានធានារ៉ាប់រងសុខភាពពាណិជ្ជកម្ម ជាទូទៅជាធានារ៉ាប់រងដែលគេទទួលបានតាមរយៈការងាររបស់ពួកគេ។ ការធ្វើដំណើរផ្សេងទៀតគឺសម្រាប់អ្នកជំងឺដែលគ្មានធានារ៉ាប់រង។

ធានារ៉ាប់រងពាណិជ្ជកម្មបង់ថ្លៃសម្រាប់ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់ច្រើនជាងធានារ៉ាប់រងរបស់រដ្ឋាភិបាល។ ការចំណាយជាមធ្យមសម្រាប់ការធ្វើដំណើររថយន្តសង្គ្រោះបន្ទាន់នៅរដ្ឋ California គឺប្រហែល $750 ដុល្លារ។ Medicare និង Medi-Cal បង់ប្រាក់ឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់សំរាប់ការធ្វើដំណើរនីមួយៗ។ Medicare បង់ប្រាក់ប្រហែល $450 ដុល្លារក្នុងមួយជើងហើយ Medi-Cal ចំណាយប្រហែល $100 ដុល្លារក្នុងមួយជើង។ ជាលទ្ធផល ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ខាតបង់ប្រាក់ក្នុងការដឹកជញ្ជូនអ្នកជំងឺ Medicare និង Medi-Cal ។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ក៏ខាតបង់ប្រាក់ នៅពេលដែលពួកគេដឹកអ្នកជំងឺដែលគ្មានធានារ៉ាប់រង។ នេះដោយសារតែអ្នកជំងឺទាំងនេះជាទូទៅមិនមានលទ្ធភាពបង់ប្រាក់សម្រាប់ការធ្វើដំណើរទាំងនេះបានទេ។ ដើម្បីប៉ះប៉ូវចំពោះការបាត់បង់ទាំងនេះ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់គិតប្រាក់អ្នកជំងឺដោយប្រើធានារ៉ាប់រងពាណិជ្ជកម្ម ដែលមានតម្លៃខ្ពស់ជាងការចំណាយជាមធ្យមសម្រាប់ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់។ ជាមធ្យម ក្រុមហ៊ុនធានារ៉ាប់រងពាណិជ្ជកម្មបង់ប្រាក់ចំនួន $1,800 ដុល្លារក្នុងមួយជើង គឺច្រើនជាងទ្វេដងនៃការចំណាយសម្រាប់ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់។

ឧស្សាហកម្មរថយន្តសង្គ្រោះបន្ទាន់

ខោនធីជ្រើសអ្នកផ្ដល់សេវារថយន្តសង្គ្រោះបន្ទាន់។ ទីភ្នាក់ងារខោនធីបែងចែកខោនធីទៅជាតំបន់មួយចំនួន។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដែលត្រូវបានជ្រើសរើសឱ្យបម្រើតំបន់នីមួយៗមានសិទ្ធិផ្ដាច់មុខក្នុងការឆ្លើយតបទៅនឹងការទូរស័ព្ទហៅគ្រាអាសន្នទាំងអស់នៅក្នុងតំបន់នោះ។ ក្រុមហ៊ុននោះរកប្រាក់ចំណូលដោយការប្រមូលប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នកជំងឺ ។ ជាផលត្រឡប់ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់បង់ប្រាក់ទៅឱ្យខោនធីដើម្បីផ្ដល់សេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់នោះ។ ខោនធី ជាទូទៅ ជ្រើសរើសក្រុមហ៊ុនសង្គ្រោះបន្ទាន់តាមរយៈដំណើរការដេញថ្លៃដែលមានលក្ខណៈប្រកួតប្រជែងមួយ។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដេញថ្លៃ ដោយផ្ដល់សេវាដែលមានលក្ខណៈប្រកួតប្រជែង—ឧទាហរណ៍ ឆ្លើយតបឱ្យបានច្រើនបំផុតទៅនឹងការហៅទូរស័ព្ទគ្រាអាសន្ន 911 ក្នុងរយៈពេលកំណត់ណាមួយ—និងការបង់ប្រាក់ដែលមានលក្ខណៈប្រកួតប្រជែងសម្រាប់ខោនធីនោះ។ ខោនធីជ្រើសរើសយកការផ្ដល់ជូនល្អបំផុត និងចុះហត្ថលេខាលើកិច្ចសន្យារយៈពេលជាច្រើនឆ្នាំជាមួយក្រុមហ៊ុននោះ។

កិច្ចសន្យារថយន្តសង្គ្រោះបន្ទាន់មូលដ្ឋានឆ្លុះបញ្ចាំងពីការចំណាយក្នុងឧស្សាហកម្មនៅតំបន់នោះ។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ស្នើឱ្យមាន

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

កិច្ចព្រមព្រៀងស្តីពីពេលវេលាឆ្លើយតប និងកម្រិតនៃការបង់ប្រាក់ឱ្យខោនធីដែលដែលនឹងទទួលបានផលចំណេញសម្រាប់អាជីវកម្មរបស់ខ្លួន។ ក្នុងការធ្វើការដេញថ្លៃ ពួកគេគណនាថាតើវានឹងត្រូវចំណាយប៉ុន្មានក្នុងការផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់នោះ និងតើពួកគេនឹងរកប្រាក់ប្រាក់ចំណូលបានប៉ុន្មាន។ ជាលទ្ធផល វាអាស្រ័យលើភាពចម្រុះនៃប្រភេទធានារ៉ាប់រងនៅក្នុងតំបន់នោះ។ ការចូលរួមចេញថ្លៃខ្ពស់របស់អ្នកជំងឺជាមួយក្រុមហ៊ុនធានារ៉ាប់រងឯកជនមានន័យថាពួកគេនឹងរកប្រាក់ចំណូលបានច្រើន។ ការចូលរួមចេញថ្លៃខ្ពស់របស់អ្នកជំងឺដែលមានធានារ៉ាប់រងរដ្ឋាភិបាល ឬគ្មានធានារ៉ាបរង មានន័យថាពួកគេនឹងរកប្រាក់ចំណូលបានតិច។

ដើម្បីឆ្លើយតបបានឆាប់រហ័ស រថយន្តសង្គ្រោះបន្ទាន់ភាគច្រើនមិនត្រូវបានទុកនៅទីតាំងអចិន្ត្រៃយ៍ទេ។ ខុសពីក្រុមពន្លត់អគ្គីភ័យដែលរង់ចាំទូរស័ព្ទសុំជំនួយសង្គ្រោះបន្ទាន់នៅទីតាំងអចិន្ត្រៃយ៍ ក្រុមបុគ្គលិកសង្គ្រោះបន្ទាន់ភាគច្រើនត្រូវប្រចាំការនៅទូទាំងទីក្រុង ឬតំបន់ដើម្បីរងចាំការហៅទូរស័ព្ទគ្រាអាសន្ន 911 ។ បន្ទាប់ពីទទួលបានការហៅទូរស័ព្ទ 911 ហើយរថយន្តសង្គ្រោះបន្ទាន់ដែលនៅជិតបំផុតត្រូវផ្តល់ការឆ្លើយតប រីឯក្រុមការងារសង្គ្រោះបន្ទាន់ផ្សេងទៀតនៅក្នុងទីតាំងនោះ ត្រូវរៀបចំសម្រួលទីតាំងឈរជើងឡើងវិញដើម្បីត្រៀមឆ្លើយតបទៅនឹងការហៅ 911 បន្ទាប់។ ការអនុវត្តនេះ—ដែលគេហៅថា "ការចែកប៉ុស្តិ៍"អនុញ្ញាតឱ្យក្រុមហ៊ុនផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់បំពេញតាមតម្រូវការស្តីពីពេលវេលាឆ្លើយតប ដែលចែងនៅក្នុងកិច្ចសន្យារបស់ខ្លួន ខណៈពេលដែលពួកគេប្រើក្រុមការងាររថយន្តសង្គ្រោះបន្ទាន់តិចជាង់ការប្រចាំការនៅទីតាំងអចិន្ត្រៃយ៍ដែលនាំឱ្យមានការចំណាយរួមទាប។

អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ

Californiaអ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ ។ មានអ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ (EMT) ចំនួន 17000 នាក់ និងនិងភ្នាក់ងារគិលានសង្គ្រោះ នៅរដ្ឋ California និងរថយន្តសង្គ្រោះបន្ទាន់ប្រហែល 3600 គ្រឿង។ អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ផ្តល់នូវជំនួយបឋម និងការថែទាំវេជ្ជសាស្ត្រមូលដ្ឋាន។ ភ្នាក់ងារគិលានសង្គ្រោះផ្តល់ការថែទាំសុខភាពកម្រិតខ្ពស់។ រថយន្តសង្គ្រោះបន្ទាន់មានបុគ្គលិកពីរនាក់-អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ពីរនាក់ អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ម្នាក់ និងភ្នាក់ងារគិលានសង្គ្រោះម្នាក់ ឬពីរនាក់។ ក្រុមការងាររថយន្តសង្គ្រោះបន្ទាន់ ជាធម្មតាធ្វើកាបូរវេនក្នុងរយៈពេល 12 ម៉ោង។

អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះមួយចំនួនទទួលបានសេវាសុខភាពផ្លូវចិត្ត។ បុគ្គលិកឆ្លើយតបគ្រោះអាសន្ន-ដូចជាមន្ត្រីប៉ូលីស ក្រុមពន្លត់អគ្គិភ័យ អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ-ជាញឹកញាប់ជួបប្រទះព្រឹត្តិការណ៍ប៉ះទង្គិចផ្លូវចិត្តក្នុងពេលធ្វើការងារ។ ទាំងនេះរួមមានការរងរបួសទាក់ទងនឹងការងារ គ្រោះមហន្តរាយធម្មជាតិ ភេរវកម្ម ឬគ្រោះថ្នាក់ពាក់ព័ន្ធនឹងកុមារ។ ជាលទ្ធផល មនុស្សដែលធ្វើការងារទាំងនេះមានអត្រាខ្ពស់នៃជំងឺបាក់ស្បាត (PTSD) បាក់ទឹកចិត្ត និងការធ្វើអត្តឃាតច្រើនជាងមនុស្សទូទៅ។ និយោជកក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ជាច្រើនផ្តល់ការប្រឹក្សាដល់បុគ្គលិកដែលបានជួបប្រទះនឹងព្រឹត្តិការណ៍រន្ធត់។ និយោជកខ្លះក៏ផ្តល់នូវការអប់រំសុខភាព និងផែនការសុខភាពផ្លូវចិត្តផងដែរ។

អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះមួយចំនួនទទួលបានការបណ្តុះបណ្តាលបន្ថែម។ មន្ត្រីរដ្ឋ ដោយសហការជាមួយក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជន ត្រួតពិនិត្យការបណ្តុះបណ្តាលដើម្បីជួយដល់ អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិ ស្ថានភាពពាក់ព័ន្ធនឹងការបាញ់កាំភ្លើងសកម្ម និងអំពើភេរវកម្ម។ កាលៈទេសៈទាំងនេះតម្រូវឱ្យមានការឆ្លើយតបជាពិសេស-ដូចជាការយកអ្នកជំងឺដែលរងរបួសចេញពីតំបន់ដែលមានគ្រោះថ្នាក-មិនបានរួមបញ្ចូលជាផ្នែកមួយនៃការបណ្តុះបណ្តាអ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ ឬការបណ្តុះបណ្តាភ្នាក់ងារគិលានសង្គ្រោះទេ។

ការឈប់សម្រាកញ៉ាំអាហារ និងសម្រាកការងារ សម្រាប់អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ

និយោជកត្រូវធ្វើតាមច្បាប់ការងាររបស់រដ្ឋស្តីពីការឈប់សម្រាកញ៉ាំអាហារ និងសម្រាកការងារ។ និយោជករដ្ឋ California ត្រូវតែអនុវត្តតាមច្បាប់ការងារផ្សេងៗ រួមទាំងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមារបស់រដ្ឋ ម៉ោងអាចដែលអាចធ្វើការបាន សុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ ការសម្រាកញ៉ាំអាហារ និងសម្រាកការងារ។ និយោជកភាគច្រើនត្រូវផ្តល់ការសម្រាកញ៉ាំអាហារដែលមិនទទួលបានប្រាក់ក ម្រៃរយៈពេល 30 នាទីក្នុងកំឡុងពេលនៃវេនធ្វើការនីមួយៗ និងការឈប់សម្រាកការងារ 10 នាទីក្នុងរយៈពេល 4 ម៉ោងម្តង។

ការឈប់សម្រាក់ញ៉ាំអាហារ និងសម្រាកការងារ របស់ អ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ។ នៅក្នុងការអនុវត្តជាក់ស្តែង EMTs និងភ្នាក់ងារគិលានសង្គ្រោះ ត្រូវស្ថិតក្នុងភារកិច្ច សម្រាប់រយៈពេលទាំងមួលនៃវេនរបស់ខ្លួន ក្នុងករណីដែលពួកគេទទួលបានការហៅទូរស័ព្ទគ្រោះអាសន្ន។ នេះមានន័យថាការសម្រាករបស់ពួកគេជួនកាលត្រូវបានរំខានដោយការហៅទូរស័ព្ទ 911 ។ ពួកគេក៏អាចត្រូវបានរំខានដោយសំណើឱ្យទៅប្តូរទីតាំងឈរថ្មីដែរ។ ជាលទ្ធផល EMT និងភ្នាក់ងារគិលានសង្គ្រោះ ជារឿយៗមិនអាចរៀបចំផែនការញ៉ាំអាហារ និងសម្រាកបានត្រឹមត្រូវទេ។ ទន្ទឹមនឹងនេះដែរ រថយន្តសង្គ្រោះបន្ទាន់ភាគច្រើនមានវេននៅចន្លោះពេលនៃការហៅទូរស័ព្ទគ្រោះអាសន្ន។ (តំបន់ក្រុងទំនងជាមានពេលវេលាតិចជាងតំបន់ជនបទ)។ ជាលទ្ធផល ក្រុមការងារតែងតែមានពេលគ្រប់គ្រាន់ក្នុងវេនរបស់ពួកគេដើម្បីទទួលទានអាហារ និងសម្រាក បើទោះបីជាពួកគេកំពុងទទួលការហៅទូរស័ព្ទក៏ដោយ។

សេចក្តីសម្រេចរបស់តុលាការនាពេលថ្មីៗនេះតម្រូវឱ្យមាន "ពេលសម្រាកសម្រាប់ ***EMT*** និង ***ភ្នាក់ងារគិលានសង្គ្រោះ។*** នៅឆ្នាំ 2016 តុលាការកំពូលរដ្ឋ California បានសម្រេចថា ការទទួលទូរស័ព្ទនៅពេលសម្រាកនេះរំលោភបំពានច្បាប់ស្តីពីការងាររបស់រដ្ឋ។ ផ្ទុយទៅវិញ និយោជកត្រូវផ្តល់ការសម្រាក ហើយមិនមានការរំខាន បើទោះបីជាមានករណីអាសន្នកើតឡើងក៏ដោយ។ សេចក្តីសម្រេចនេះគឺសេវាកម្មសុវត្ថិភាព *Augustus v ABM*។ ករណីនេះពាក់ព័ន្ធនឹងសន្តិសុខឯកជនដែលនិយោជករបស់ពួកគេបានតម្រូវឱ្យពួកគេបើកវិទ្យុទាក់ទងរបស់ពួកគេអំឡុងពេលសម្រាក។ តុលាការនេះបានឱ្យក្រុមហ៊ុនទូទាត់ប្រាក់ដល់សន្តិសុខដោយសារតែការរំលោភបំពាននេះ។ មុនពេលសេចក្តីសម្រេច *Augustus* ត្រូវបានធ្វើឡើងនោះ EMT និងភ្នាក់ងារគិលានសង្គ្រោះបានដាក់ពាក្យបណ្តឹងស្រដៀងគ្នាជាច្រើនប្តឹងក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជនទាំងនេះ។ បណ្តឹងទាំងនេះនៅស្ថិតក្រោមចំណាត់ការដដែល។ ច្បាប់ការងារនិងការអនុវត្តឧស្សាហកម្មសម្រាប់សន្តិសុខឯកជនមានលក្ខណៈស្រដៀងគ្នានឹងច្បាប់និងការអនុវត្តឧស្សាហកម្មសម្រាប់ EMT និងភ្នាក់ងារគិលានសង្គ្រោះ។ ដោយសារភាពស្រដៀងគ្នានេះ វាហាក់ដូចជា សេចក្តីសម្រេច *Augustus* នឹងអនុវត្តផងដែរចំពោះអ្នកបច្ចេកទេសវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ និងភ្នាក់ងារគិលានសង្គ្រោះ ក្នុងពេលអនាគតដ៏ខ្លីខាងមុខ។

11 សំណើប្រជាមតិ

តម្រូវឲ្យបុគ្គលិករថយន្តពេទ្យបន្ទាន់អាសន្នផ្នែកវិស័យឯកជនអោយនៅប្រចាំការទទួលទូរស័ព្ទក្នុងកំឡុងពេលសម្រាកធ្វើការ។ លុបបំបាត់ទំនួលខុសត្រូវនិយោជកមួយចំនួន។ លក្ខន្តិក:ផ្ទួចផ្ដើម។

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ការអនុវត្តពេញលេញតាម **សេចក្ដីសម្រេចរបស់** ***Augustus*** **នឹងបង្កើ**នការចំណាយសម្រាប់ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់។ ដើម្បីអនុវត្តតាមច្បាប់របស់រដ្ឋនៅក្រោម *Augustus* ក្រុមការងាររថយន្តសង្គ្រោះបន្ទាន់នឹងត្រូវសម្រាកក្នុងអំឡុងពេលញ៉ាំអាហារ និងពេលសម្រាក។ ជាលទ្ធផលដើម្បីបំពេញតាមលក្ខខណ្ឌនៃកិច្ចសន្យាដែលមានស្រាប់របស់ពួកគេ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ នឹងទំនងជាធ្វើប្រតិបត្តិការរថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់នីមួយៗឱ្យបានច្រើនជាងពួកគេធ្វើនាពេលបច្ចុប្បន្ននេះ។ នេះនឹងបង្កើនការចំណាយទៅលើក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់-ទំនងជាច្រើនជាង $100 លានដុល្លារជារៀងរាល់ឆ្នាំនៅទូទាំងរដ្ឋ។

ការឆ្លើយតបរបស់ឧស្សាហកម្មរថយន្តសង្គ្រោះបន្ទាន់ទៅនឹងសេចក្ដីសម្រេច **Augustus** ។ ដើម្បីដោះស្រាយការចំណាយខ្ពស់ និងនៅតែមានប្រាក់ចំណេញនោះ ក្រុមហ៊ុននឹងត្រូវបង្កើនចំណូល និង / ឬកាត់បន្ថយចំណាយ។ ដើម្បីឆ្លើយតបទៅនឹង ការសម្រេច *Augustus* ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាច៖

- ***ចរចាអំពីកិច្ចព្រមព្រៀងស្របច្បាប់ដែលអនុញ្ញាតឱ្យមានការអនុវត្តតាមផ្នែក។*** ក្នុងករណីមួយចំនួន ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ និង EMT និងភ្នាក់ងារគិលានសង្គ្រោះ អាចយល់ស្របចំពោះការសម្របសម្រួលស្ដីពីពេលញ៉ាំអាហារ និងពេលសម្រាក ដែលចំណាយតិចសម្រាប់ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ជាងការផ្ដល់ការឈប់សម្រាកក្រៅភារកិច្ច។ កិច្ចព្រមព្រៀងសក្តានុពលដូចជាកិច្ចព្រមព្រៀងទាំងនេះគឺជាការសម្របសម្រួលមួយរវាងការអនុវត្តបច្ចុប្បន្ន និងការអនុលោមទាំងស្រុងតាមសេចក្ដីសម្រេច *Augustus* ធៀបនឹងការចំណាយទាបក្នុងការអនុលោមទាំងស្រុងតាមសេចក្ដីសម្រេច *Augustus*។
- ***បង្កើនការគិតប្រាក់ធានារ៉ាប់រង។*** ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាចគិតប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រងពាណិជ្ជកម្មបន្ថែមសម្រាប់ការធ្វើដំណើររបស់អ្នកជំងឺរបស់ពួកគេ ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងពាណិជ្ជកម្មយល់ព្រមបង់ក្នុងអាត្រាខ្ពស់ទាំងនេះ វានឹងបង្កើនបុព្វលាភធានារ៉ាប់រងសុខភាពសម្រាប់ពលរដ្ឋដែលមានការធានារ៉ាប់រងសុខភាពផ្នែកពាណិជ្ជកម្ម។ ដូចដែលបានកត់សម្គាល់ខាងដើម ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់បានគិតប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រងរួចហើយច្រើនជាងការចំណាយជាមធ្យមសម្រាប់ការធ្វើដំណើរតាមរថយន្តសង្គ្រោះបន្ទាន់ទៅទៀត។ ក្រុមហ៊ុនរថយន្តសង្គ្រោះអាចនឹងបង្កើតប្រាក់ចំណូលបន្ថែមពីក្រុមហ៊ុនធានារ៉ាប់រង ប៉ុន្តែវាទំនងជាមិនអាចទេដែលថាការចំណាយពេញលេញនេះអនុវត្តតាម សេចក្ដីសម្រេចរបស់ *Augustus* អាចត្រូវបានរ៉ាប់រងក្នុងវិធីនេះ។
- ***កាត់បន្ថយចំណាយអាជីវកម្ម។*** ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាចផ្លាស់ប្ដូររបៀបដែលពួកគេធ្វើអាជីវកម្មដើម្បីកាត់បន្ថយការចំណាយ។ ឧទាហរណ៍ពួកគេអាចពន្យារពេលឆ្លើយតបរបស់ពួកគេសម្រាប់ការហៅពេលមានអាសន្ន ឬជំនួសដោយការផ្ដល់ប្រាក់ឈ្នួលខ្ពស់ដល់ភ្នាក់ងារគិលានសង្គ្រោះជាមួយ EMT (ដែលជាទូទៅត្រូវបានផ្ដល់ប្រាក់ឈ្នួលទាប) ។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ត្រូវតែចរចារអំពីការផ្លាស់ប្ដូរទាំងនេះជាមួយខោនធីនានា។ ប្រភេទនៃការផ្លាស់ប្ដូរទាំងនេះទំនងជាមានលក្ខណៈតិតតួច ហេតុដូច្នេះហើយមិនចាំបាច់ផ្ដល់ការសន្សំសំចៃចំណាយធំៗទេ។
- ***ការទូទាត់កិច្ចសន្យាតូចៗផ្ដល់ទៅឱ្យរដ្ឋអំណាចមូលដ្ឋាន។*** ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាចបង់ប្រាក់ដល់ខោនធីនានាតិចសម្រាប់សិទ្ធិផ្ដល់សេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់នីមួយៗ។ នៅក្នុងតំបន់ដែលមានប្រាក់ចំណេញតិចតួច ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាចនឹងលែងបង់ប្រាក់សម្រាប់សិទ្ធិផ្ដល់សេវារថយន្តសង្គ្រោះបន្ទាន់នៅក្នុងតំបន់នោះ។ ក្នុងករណីទាំងនេះ ខោនធីជាច្រើនប្រហែលជាចាំបាច់ត្រូវបង់ប្រាក់ទៅឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដើម្បីធានាថាសេវារថយន្តសង្គ្រោះបន្ទាន់នៅតែមាននៅក្នុងតំបន់នោះ។

ភាគច្រើននៃការចំណាយថ្មីទាំងនេះនឹងត្រូវបានបង់ដោយខោនធីនានា។ ថ្មីបើការបង្កើនចំណាយកើនឡើងទាក់ទងនឹងការអនុលោមតាមសេចក្ដីសម្រេច *Augustus* នឹងត្រូវបានទូទាត់ដោយក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់តាមវិធីជាច្រើនដូចដែលបានរៀបរាប់ខាងលើក៏ដោយ ក៏វាទំនងជាថា ភាគច្រើននៃការចំណាយខ្ពស់ទាំងនេះនឹងជាបន្ទុករបស់ខោនធីទាំងនោះដែរ។

សេចក្ដីស្នើច្បាប់

វិធានការនេះធ្វើឱ្យមានការផ្លាស់ប្ដូរច្បាប់របស់រដ្ឋដែលជះឥទ្ធិពលលើ EMT និងភ្នាក់ងារគិលានសង្គ្រោះឯកជន។ វិធានការនេះនឹងមិនត្រូវបានអនុវត្តចំពោះ EMT និងភ្នាក់ងារគិលានសង្គ្រោះដែលធ្វើការសម្រាប់ទីភ្នាក់ងារសាធារណៈ ដូចជានាយកដ្ឋានពន្លត់អគ្គីភ័យទេ។ វិធានការនេះត្រូវបានរៀបរាប់លម្អិតបន្ថែមដូចខាងក្រោម។

តម្រូវឱ្យ EMT និងភ្នាក់ងារគិលានសង្គ្រោះនៅចំាទទួលការហៅទូរស័ព្ទគ្រោះអាន្ន ទោះបីពួកគេញ៉ាំអាហារ ឬសម្រាកក៏ដោយ។ **វិធានការនេះតម្រូវឱ្យ EMT និងភ្នាក់ងារគិលានសង្គ្រោះនៅចំាទទួលទូរស័ព្ទគ្រប់ពេលពេញមួយវេនរបស់ពួកគេ។ ជាទូទៅវ៉ិ ធានការនេះបន្ថែការអនុវត្តបច្ចុប្បន្នដែលតម្រូវឱ្យ EMT និងភ្នាក់ងារគិលានសង្គ្រោះនៅចំាទទួលការហៅទូរស័ព្ទក្នុងកំឡុងពេលសម្រាក។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលទន្ទឹមគ្នានេះ វិធានការនេះតម្រូវថាការសម្រាកញ៉ាំអាហារ (1) មិនត្រូវស្ថិតក្នុងកំឡុងពេលដំបូង ឬម៉ោងចុងក្រោយនៃវេនទេ ហើយ (2) ត្រូវមានចន្លោះដាច់ពីគ្នាយ៉ាងហោចណាស់ពីរម៉ោង។ វិធានការនេះតម្រូវឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដំណើរការរថយន្តសង្គ្រោះបន្ទាន់ក្នុងចំនួនគ្រប់គ្រាន់ ដើម្បីបំពេញតាមកាលវិភាគអាហារទាំងនេះ។**

ព្យាយាមកំណត់ថ្លៃចំណាយសម្រាប់ការអនុវត្តកន្លងមកស្ដីពីការស្ថិតក្នុងភារកិច្ចនៅពេលញ៉ាំអាហារ និងសម្រាក ។ **សេចក្ដីសម្រេច *Augustus* គ្រឹះស្ថានបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវ: និងភ្នាក់ងារគិលានសង្គ្រោះនៅរង់ចាំការហៅទូរស័ព្ទគ្រោះអាសន្ន ក្នុងអំឡុងពេលសម្រាក ជាការខុសច្បាប់។ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ឯកជនឥឡូវអាចជំពាក់ប្រាក់ពិន័យចំពោះការរំលោភបំពាននាពេលកន្លងមក។ ក្រុម EMTs និងភ្នាក់ងារគិលានសង្គ្រោះមួយចំនួនបានប្ដឹងក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដោយចោទប្រកាន់ពីបទរំលោភទាំងនេះ។ បណ្ដឹងទាំងនេះនៅស្ថិតក្រោមចំណាត់ការដដែល។ ក្រៅពីតម្រូវឱ្យនៅរង់ចាំទទួលទូរស័ព្ទក្នុងពេលញ៉ាំអាហារ និងពេលសម្រាកសម្រាប់ទៅថ្ងៃមុខហើយ វិធានការនេះអះអាងថាការអនុវត្តបច្ចុប្បន្ននៃការរងចាំទទួលទូរស័ព្ទក្នុងពេលញ៉ាំអាហារ និងពេលសម្រាកត្រូវបានអនុញ្ញាតដោយច្បាប់ទៅវិញ។ វាអាចលុបបំបាត់ការចំណាយដែលក្រុមហ៊ុនរថយន្តសង្គ្រោះអាចត្រូវបង់ចំពោះបណ្ដឹងទាំងនេះ។**

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

តម្រូវឱ្យមានការបណ្តុះបណ្តាលដែលផ្តល់ដោយនិយោជក និងសេវាសុខភាពផ្លូវចិត្ត។ វិធានការនេះតម្រូវឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ផ្តល់ឱ្យ EMT និងភ្នាក់ងារគិលានសង្គ្រោះ (1) ការបណ្តុះបណ្តាលស្តីពីគ្រោះមហន្តរាយធម្មជាតិប្រចាំឆ្នាំ ការបាញ់រះលើមហាជន និងអំពើហឹង្សា (2) ការអប់រំផ្នែកសុខភាពផ្លូវចិត្ត និងសុខមាលភាព (3) វគ្គផ្តល់ប្រឹក្សាអំពីសុខភាពផ្លូវចិត្ត និង (4) ការទទួលបានសេវាសុខភាពផ្លូវចិត្តរយៈពេលវែង។

ផលប៉ះពាល់សារពើពន្ធ

ដូចដែលបានរៀបរាប់ខាងលើ ស្ថានភាពច្បាប់នៃតម្រូវការច្បាប់ការងារចំពោះឧស្សាហកម្មដូចជាសេវារថយន្តសង្គ្រោះបន្ទាន់មានការផ្លាស់ប្តូរជាបន្តបន្ទាប់។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ទំនងជានឹងត្រូវបានតម្រូវឱ្យផ្តល់ពេលញ៉ាំអាហារ និងសម្រាក នៅក្រៅការងារ។ ប្រសិនបើដូច្នេះ វានឹងមានឥទ្ធិពលដែលបង្កើនចំណាយនៃការផ្តល់សេវារថយន្តសង្គ្រោះបន្ទាន់។ ការចំណាយខ្ពស់ទាំងនេះនឹងប៉ះពាល់ដល់ខោនធី ដោយកាត់បន្ថយការបង់ប្រាក់របស់ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ទៅពួកគេ និង/ឬដោយការតម្រូវឱ្យបង់ប្រាក់របស់ខោនធីទៅឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ ដើម្បីធានាបាននូវសេវាកម្មគ្រប់គ្រាន់។

ទោះជាយ៉ាងណាក៏ដោយ នៅក្រោមសំណើប្រជាមតិលេខ 11 ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់នឹងជៀសវាងការចំណាយថ្មីទាំងអស់នេះ ព្រោះថាជាទូទៅវិធានការនេះនឹងអនុញ្ញាតឱ្យពួកគេបន្តប្រតិបត្តិការដូចដែលពួកគេធ្លាប់មានពីមុន។ មានន័យថាពួកគេអាចបន្តប្រើពេលញ៉ាំអាហារពេល និងសម្រាកទន្ទឹមនឹងការរង់ចាំទទួលការហៅចូល។ ជាលទ្ធផល សំណើប្រជាមតិលេខ 11 នឹងមានផលប៉ះពាល់ដូចខាងក្រោមលើការចំណាយលើរថយន្តសង្គ្រោះបន្ទាន់៖

- ***បន្ថយចំណាយប្រតិបត្តិការសុទ្ធ។*** វិធានការនេះតម្រូវឱ្យ EMTs និងភ្នាក់ងារគិលានសង្គ្រោះបន្តរង់ចាំការហៅចូលក្នុងអំឡុងពេលសម្រាក។ ដូច្នេះ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់នឹងមិនប្រឈមនឹងការចំណាយថ្មីៗដែលកំពុងបន្តទេ-ដែលអាចច្រើនជាង $100 លានដុល្លារក្នុងមួយឆ្នាំ-ទាក់ទងជាមួយនឹងការផ្តល់នូវការសម្រាកនៅក្រៅភារកិច្ច។ ទន្ទឹមគ្នានេះ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់នឹងត្រូវប្រតិបត្តិការរថយន្តសង្គ្រោះបន្ទាន់ច្រើនជាងការដែលពួកគេអនុវត្តនាពេលបច្ចុប្បន្ន ដើម្បីគោរពតាមតម្រូវការផ្សេងទៀតនៃវិធានការនេះ ដែលទាក់ទងទៅនឹងកាលវិភាគញ៉ាំអាហារ និងការសម្រាក។ នេះនឹងនាំឱ្យមានការចំណាយថ្មីមួយចំនួន។ ជាសរុប ច្បាប់ស្តីពីការរង់ចាំទទួលការហៅចូលនៅពេលញ៉ាំអាហារ និងពេលសម្រាកនេះនឹងនាំឱ្យមានការចំណាយទាបក្នុងតម្លៃរាប់សិបលានដុល្លារជារៀងរាល់ឆ្នាំសម្រាប់ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ បើប្រៀបធៀបទៅនឹងការចំណាយនៃការគោរពតាម *សេចក្តីសម្រេច Augustus*។
- ***ការចំណាយថ្មីមួយចំនួនដើម្បីផ្តល់ការបណ្តុះបណ្តាល និងសេវាសុខភាពផ្លូវចិត្ត។*** ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ដែលបច្ចុប្បន្នមិនផ្តល់ការបណ្តុះបណ្តាល និងសេវាសុខភាពផ្លូវចិត្តដែលតម្រូវដោយវិធានការនេះ នឹងត្រូវបង់ចំណាយថ្មីទៅឱ្យពួកគេ។ អត្ថប្រយោជន៍ទាំងនេះទំនងជាធ្វើឱ្យក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ចំណាយប្រាក់រាប់លានដុល្លារជារៀងរាល់ឆ្នាំ។
- ***ការជៀសវាងសក្តានុពលនៃការចំណាយតែម្តង។*** សំណើប្រជាមតិលេខ 11 សំដៅកាត់បន្ថយការចំណាយដែលក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់អាចបង់ ដែលជាលទ្ធផលនៃបណ្តឹងសកម្មប្រឆាំងនឹងការរំលោភបំពាននានា។ (ក្រុមហ៊ុនអាចជំពាក់បុគ្គលិកដោយសារតែការរំលោភបំពានទាំងនេះ។) តុលាការនឹងសម្រេចថាតើវិធាននេះនឹងកំហិតចំណាយទាំងនេះដែរ ឬទេ។ ប្រសិនបើវិធានការនេះលុបបំបាត់ការចំណាយទាំងនេះ ក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់នឹងជៀសវាងការចំណាយដែលមិនដឹងច្បាស់ ប៉ុន្តែអាចមានតម្លៃធំធេង។

អត្ថប្រយោជន៍សារពើពន្ធចំពោះរដ្ឋាភិបាលមូលដ្ឋានដោយសារតែការចំណាយលើសេវាសង្គ្រោះបន្ទាន់ទាប។ ដោយសារតែការចំណាយសុទ្ធលើក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់ទាប វិធានការនេះនឹងផ្តល់អត្ថប្រយោជន៍សារពើពន្ធដល់រដ្ឋាភិបាលមូលដ្ឋាន (ក្នុងទម្រង់ជាការចំណាយទាប និងប្រាក់ចំណូលខ្ពស់) អាចរាប់ពាន់លានដុល្លារក្នុងមួយឆ្នាំៗ ។ នេះគឺដោយសារតែក្រុមហ៊ុនរថយន្តសង្គ្រោះបន្ទាន់នឹងជៀសវាងការកើនឡើងចំណាយដែលទាក់ទងទៅនឹងការផ្តល់ម៉ោងញ៉ាំអាហារ និងការឈប់សម្រាកក្រៅភារកិច្ច។ ក្រុមហ៊ុនធានារ៉ាប់រងនឹងទទួលបានអត្ថប្រយោជន៍ទាំងនេះមួយផ្នែក ប៉ុន្តែអត្ថប្រយោជន៍ភាគច្រើននឹងបានទៅរដ្ឋាភិបាលមូលដ្ឋាន។

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជីនៃគណៈកម្មាធិការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ សូមចូលទៅ *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីមើលអ្នកផ្តល់វិភាគទានកំពូលចំនួន 10 របស់គណកម្មាធិការនេះ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិ 11 ★

សំណើប្រ.មតិ 11 ធានាថា ការថែទាំសង្គ្រោះបន្ទាន់ 911 របស់អ្នកនឹងមិនត្រូវបានពន្យារពេល

សំណើប្រ.មតិ 11 បង្កើតទៅជាច្បាប់នូវការអនុវត្តឧស្សាហកម្មរយៈពេលវែងនៃការទូទាប្រាក់ឲ្យអ្នកបច្ចេកទេសវេជ្ជសាស្ត្រខាងសង្គ្រោះបន្ទាន់ (EMTs) និងអ្នកជំនួយវេជ្ជបណ្ឌិតដើម្បីអាចរកពួកគាត់ឃើញពេលសម្រាកក្នុងករណីមានការសង្គ្រោះបន្ទាន់—គឺឱ្យដូចទៅនឹងអ្នកពន្លត់អគ្គីភ័យ និងមន្ត្រីប៉ូលីសដែរ។

សំណើប្រ.មតិ 11 គឺត្រូវការជាចាំបាច់ដោយសារតែច្បាប់តុលាការ California កាលពីពេលថ្មីៗអាចបញ្ឈប់ការអនុវត្តរយៈពេលយូរអង្វែងនេះ **និងតម្រូវឱ្យ EMTs** និងអ្នកជំនួយវេជ្ជបណ្ឌិតមិនឆ្លើយតបការងារក្នុងកំឡុងពេលសម្រាក។ ឱ្យ នេះមានន័យថា បើឡានពេទ្យដែលនៅជិតបំផុតចំពោះគ្រោះអាសន្នរបស់អ្នកឋិតក្នុងការសម្រាក នៅពេលអ្នកហៅទៅសុំជំនួយពី 911 អ្នកទទួលទូរសព្ទមិនអាចទាក់ទងទៅកាន់បុគ្គលិកឡានពេទ្យបាននោះទេ ព្រោះតែឧបករណ៍ទំនាក់ទំនងទាំងអស់ត្រូវបានបិទ។ **សំណើប្រ.មតិ 11 ធានាថា ការថែទាំសង្គ្រោះបន្ទាន់ 911 របស់អ្នកគឺមិនត្រូវបានពន្យារពេល។**

"សំណើប្រ.មតិ 11 ធានាថា EMTs និងអ្នកជំនួយវេជ្ជបណ្ឌិតអាចឆ្លើយតបយ៉ាងរហ័សដើម្បីផ្តល់ការថែទាំចាំបាច់បំផុតដែលអ្នកត្រូវការ។ វាគ្រាន់តែធ្វើឱ្យមានន័យប៉ុណ្ណោះ។ បោះឆ្នោត បាទ/ចាស លើ 11."—**Adam Dougherty, MD, MPH,** គ្រូពេទ្យខាងសង្គ្រោះបន្ទាន់

នៅពេលអ្នកហៅទូរស័ព្ទទៅ 911 វិនាទីអាចជាភាពខុសគ្នា រវាងជីវិត និងការបាត់បង់ជីវិត

វាជាការចាំបាច់ដែល EMTs និងអ្នកជំនួយវេជ្ជបណ្ឌិត អាចឆ្លើយតបយ៉ាងរហ័ស និងផ្តល់ជូនការថែទាំវេជ្ជសាស្ត្រសង្គ្រោះអាយុជីវិត អំឡុងពេលមានព្រឹត្តិការណ៍ចៃដន្យធំៗ ដូចជាគ្រោះឧបទ្ទវហេតុពីអ្នកបាញ់សកម្ម និងគ្រោះមហន្តរាយធម្មជាតិ។ **សំណើប្រ.មតិ 11 ទាមទារឲ្យបុគ្គលិកវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់គឺត្រូវបានទូទាត់ប្រាក់ដោយនិយោជនរបស់ពួកគេ ដើ**ម្បីទទួលបានការបណ្តុះបណ្តាលបន្ថែមដែលបំពេញបានតាមស្តង់ដារ **FEMA** សម្រាប់ការការពារអំពើហិង្សា អ្នកបាញ់សកម្ម ភាពចៃដន្យជាច្រើន និងឧបទ្ទវហេតុពីគ្រោះមហន្តរាយធម្មជាតិជាដើម។ **បាទ/ចាស់ លើ 11។**

"ក្នុងនាមជាអ្នកជំនួយវេជ្ជបណ្ឌិតម្នាក់ ខ្ញុំចង់ទៅដល់ទីនោះ នៅពេលមនុស្សត្រូវការជំនួយ។ សំណើប្រ.មតិ 11 ធ្វើឱ្យប្រាកដថា នៅពេលអាយុជីវិតប្រឈមនិងហានិភ័យ ការថែទាំសង្គ្រោះបន្ទាន់នឹងមិនត្រូវបានពន្យារពេល ហើយយើងគឺត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបទៅសឹងតែគ្រប់គ្រោះមហន្តរាយទាំងឡាយ។"—**Daniel Iniguez,** អ្នកជំនួយបណ្ឌិតដែលមានអាជ្ញាប័ណ្ណ

សំណើប្រ.មតិ 11 ធានាថា EMTs និងអ្នកជំនួយវេជ្ជបណ្ឌិតមានការការពារនៅកន្លែងធ្វើការ

EMTs និងអ្នកជំនួយវេជ្ជបណ្ឌិតគួរតែមានការការពារនៅកន្លែងធ្វើការដើម្បីធានាថា ពួកគេគឺអាចសម្រាកបានស្រួល។ **សំណើប្រ.មតិ 11 តម្រូវឲ្យប្រតិ**បត្តិការឡានពេទ្យ911 **រក្សាកម្រិតបុគ្គលិកឲ្យបានច្រើនគ្រប់គ្រាន់ដើម្បីមា**នអ្នកទទួលខុសត្រូវនៅពេលសម្រាក។ **សំណើប្រ.មតិ 11 បានចែងថាបុ**គ្គលិកវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់**នឹងបន្តទទួលបានប្រាក់**បន្ថែមគិតជាម៉ោងបើពួកគេខកខានមិនបានសម្រាក ហើយពួកគេមិនទទួលបានការសម្រាកសងមកវិញនៅម៉ោងធ្វើការ **បាទ/ចាស់ លើ 11។**

សំណើប្រ.មតិ 11 ផ្តល់អត្ថប្រយោជន៍សុខភាពផ្លូវចិត្តសម្រាប់ EMTs និងអ្នកជំនួយវេជ្ជបណ្ឌិត

នេះត្រូវការឲ្យមានមនុស្សប្រភេទពិសេសដើម្បីក្លាយជា EMT ឬអ្នកជំនួយវេជ្ជបណ្ឌិត ហើយពេលខ្លះវាអាចជាការងារដែលពោពេញដោយភាពតានតឹង។ **សំណើប្រ.មតិ 11 តម្រូវឱ្យនិយោជកផ្តល់ឱ្យបុគ្គ**លិកវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់**នូវការគ្របដណ្តប់សុខភាពផ្លូវចិត្ត**ចាំបាច់ ក៏ដូចជាការបណ្តុះបណ្តាលសុខភាព **និងសុខុមាលភាពផ្លូវចិត្ត**ប្រចាំឆ្នាំផងដែរ។ **បាទ/ចាស់ លើ 11។**

បោះឆ្នោតបាទ/ចាស់លើសំណើ 11 ដើម្បីការពារសុវត្ថិភាពសាធារណៈ និងដើម្បីធានាថា EMTs និងអ្នកជំនួយវេជ្ជបណ្ឌិតអាចឆ្លើយតបយ៉ាងរហ័ស នៅពេលអ្នកមានការបន្ទាន់។

ស្វែងយល់បន្ថែមនៅ *www.YESon11.org*

ADAM DOUGHERTY, MD, MPH, គ្រូពេទ្យសង្គ្រោះបន្ទាន់
CAROL MEYER, RN, អតីតនាយក
ទីភ្នាក់ងារសេវាកម្មវេជ្ជសាស្ត្រខាងសង្គ្រោះបន្ទាន់ខោនធី **Los Angeles**
JAISON CHAND, អ្នកជំនួយវេជ្ជបណ្ឌិតដែលមានអាជ្ញាប័ណ្ណ

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 11 ★

គ្មានទឡ្ហីករណ៍ប្រឆាំងនឹងសំណើប្រជាមតិ 11 ត្រូវបានដាក់ស្នើឡើយ

សំណើប្រជាមតិ 12 បង្កើតស្តង់ដារថ្មីសម្រាប់ការដាក់ឃាំងសត្វកសិដ្ឋានជាក់លាក់ ហាមឃាត់ការលក់ផលិតផលមិនអនុវត្តតាមច្បាប់។ លក្ខន្តិកៈផ្តួចផ្តើម។

ចំណងជើង និងសេចក្តីសង្ខេបផ្លូវការ

រៀបចំដោយអគ្គមេធាវី

អត្ថបទនៃវិធានការនេះអាចរកឃើញនៅលើគេហទំព័រ របស់រដ្ឋលេខាធិការតាមអាសយដ្ឋាន *http://voterguide.sos.ca.gov*។

- បង្កើតកិច្ចតម្រូវទំហំកន្លែងអប្បបរមាថ្មីសម្រាប់ការឃុំ ឃាំងកូនគោ ជ្រូកបង្កាត់ និងមាន់ញីអាច មានពង។
- តំរូវឱ្យចិញ្ចឹមមាន់ញីដែលអាចមានពងដោយមិន បាច់ដាក់ក្នុងទ្រុងក្រោយថ្ងៃទី 31 ខែធ្នូឆ្នាំ 2021។
- ហាមឃាត់ការលក់ពាណិជ្ជកម្មមួយប្រភេទនៃសាច់ និងផលិតផលស៊ុតមួយចំនួន មកពីសត្វដែលត្រូវ បានបង្ខាំងដោយមិនអនុវត្តតាមច្បាប់។
- ដាក់កំណត់ក្រមចំពោះការរំលោភបំពានលើការលក់ជាការប្រកួតប្រជែងមិនយុត្តិធម៌។
- បង្កើតការការពារដ៏ល្អសម្រាប់អ្នកលក់ដែលពឹងផ្អែកលើការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអ្នកផ្គត់ផ្គង់ថាផលិតផលសាច់និងស៊ុតអនុលោមតាមស្តង់ដា បង្ខាំងថ្មីៗ។
- តម្រូវអោយរដ្ឋ California ឱ្យចេញបទបញ្ជាអនុវត្ត។

សេចក្តីសង្ខេបការវាយតម្លៃនៃការវិភាគរបស់អង្គ នីតិបញ្ញត្តិនៃផលប៉ះពាល់សារពើពន្ធសុទ្ធនៃរដ្ឋាភិបាលមូលដ្ឋាន និងរដ្ឋ៖

- ការថយចុះប្រាក់ចំណូលពន្ធដែលអាចមានលើចំណូលរដ្ឋពីអាជីវកម្ម កសិដ្ឋានទំនងជាមិនមាន ច្រើនជាងចំនួនច្រើនលានដុល្លារក្នុងមួយ ឆ្នាំឡើយ។
- រដ្ឋចំណាយប្រាក់រហូតដល់ $10 លានដុល្លារ ក្នុង មួយឆ្នាំដើម្បីអនុវត្ត វិធានការនេះ។

ការវិភាគដោយអ្នកវិភាគអង្គនីតិបញ្ញត្តិ

ជីវប្រវត្តិ

កសិកម្មគឺជាឧស្សាហកម្មចម្បងមួយនៅរដ្ឋ California។ កសិដ្ឋាននៅរដ្ឋ California ផលិតចំណីអាហារបានច្រើន—ដូចជា ផ្លែឈើ បន្លែ គ្រាប់ធញ្ញជាតិ សាច់ និងស៊ុត—ជាងនៅក្នុងរដ្ឋផ្សេងទៀត។ ពលរដ្ឋ California ក៏ទិញចំណីអាហារដែលបានផលិតនៅក្នុងរដ្ឋផ្សេងទៀតផងដែរ រួមមានជាអាទិ៍ ភាគច្រើននៃស៊ុត និងសាច់ជ្រូកដែលពួកគេបរិភោគ។ ក្រសួងចំណីអាហារ និងកសិកម្មរដ្ឋ California (CDFA) ទទួលបន្ទុកក្នុងការផ្សព្វផ្សាយកសិកម្មរដ្ឋ California និងមើលការខុសត្រូវសុខភាពសត្ត និងសុវត្ថិភាពចំណីអាហារផងដែរ។

ច្បាប់រដ្ឋហាមឃាត់អំពើយោរយៅចំពោះសត្ត។
រយៈកាលមួយសតវត្ស៍កន្លងមកហើយ រដ្ឋមានច្បាប់ដែលហាមឃាត់ការធ្វើបាបសត្ត រួមទាំងសត្វកសិដ្ឋាន។ ឧទាហរណ៍ ជនណាម្នាក់ដែលរក្សាទុកសត្ត នៅកន្លែងបិទជិត ត្រូវផ្តល់ទីធ្លាហាត់ប្រាណដល់សត្ត នោះ ព្រមទាំងផ្តល់លទ្ធភាពទទួលបានទីជម្រក ចំណីអាហារ និងទឹកផងដែរ។ ជនណាម្នាក់អាចនឹងត្រូវបានរកឃើញថាមានទោសបទល្មើសមជ្ឈឹម ឬបទឧក្រិដ្ឋ អាស្រ័យលើការបំពានលើលក្ខខណ្ឌតម្រូវទាំងនេះ ដែលបទល្មើសមួយណាក៏អាចត្រូវបានដាក់ទោសដោយការផាកពិន័យ ដាក់ពន្ធនាគារ ឬទាំងពីរផងដែរ។

ការអនុវត្តសត្វកសិដ្ឋានកំពុងមានការផ្លាស់ប្តូរ។ មានកំណើនចំណាប់អារម្មណ៍ពីសាធារណជនលើការប្រព្រឹត្តចំពោះសត្វកសិដ្ឋាន។ ដោយឡែក មានការសម្តែងនូវក្តីកង្វល់អំពីការរក្សាទុកសត្វកសិដ្ឋាន នៅក្នុងទ្រុង និងឡាំង។ ជាការឆ្លើយតបមួយផ្នែកទៅនឹងក្តីកង្វល់ទាំងនេះ សមាគមកសិដ្ឋានចិញ្ចឹមសត្ត ជាច្រើនបានបង្កើតនូវគោលការណ៍ណែនាំ និងការអនុវត្តន៍ល្អទាំងឡាយ ដើម្បីកែលម្អការថែទាំ និងការចាប់កាន់សត្ត ក្នុងកសិដ្ឋាន។ ជាការឆ្លើយតបទៅនឹងក្តីកង្វល់ទាំងនេះផងដែរ ហាងលក់ឥវ៉ាន់ចាប់ហួយធំៗ ភោជនីយដ្ឋាន និងក្រុមហ៊ុនផ្សេងទៀត បានប្រកាសថា ពួកគេកំពុងឈានឆ្ពោះទៅរកការតម្រូវឲ្យអ្នកផ្គត់ផ្គង់ចំណីអាហាររបស់ពួកគេត្រូវផ្តល់ទីធ្លាបន្ថែមដល់សត្វកសិដ្ឋាន ដើម្បីឲ្យវាផ្លាស់ទីទៅមក (ឧទាហរណ៍ ដោយការទិញស៊ុតតែពីកសិករណាដែលប្រើរោង “គ្មានទ្រុង” សម្រាប់មាន់មេប៉ុណ្ណោះ)។

សំណើប្រជាមតិ 2 (2008) បានបង្កើតស្តង់ដារសម្រាប់ការធ្វើរោងសត្វកសិដ្ឋានមួយចំនួន។ សំណើប្រជាមតិ 2 ជាទូទៅ ហាមឃាត់កសិករនៅរដ្ឋ California ពីការធ្វើរោងជ្រូកធើម កូនគោចិញ្ចឹមយកសាច់ និងមាន់មេចិញ្ចឹមយកពងនៅក្នុងទ្រុង ឬឡាំង ដែលមិនអនុញ្ញាតឲ្យវាផ្លាស់ទីទៅមកដោយសេរី ដេក ឈរ និងត្រដាងអវៈយវៈវាបានពេញលេញ។ ក្រោមសំណើប្រជាមតិ 2 អ្នកដែលបំពានច្បាប់នេះ មានទោសពីបទល្មើសមជ្ឈឹម។

ច្បាប់រដ្ឋបានហាមប្រាមការលក់ស៊ុតដែលមិនបំពេញតាមស្តង់ដារ។ ច្បាប់រដ្ឋដែលបានអនុម័តក្រោយសំណើប្រជាមតិ 2 ចាត់ទុកជាការខុសច្បាប់ចំពោះអាជីវកម្ម នៅក្នុងរដ្ឋ California ដែលលក់ស៊ុតដែលពួកគេបានដឹងថាមកពីមាន់មេក្នុងរោងដែលមិនបំពេញតាមស្តង់ដារសម្រាប់មាន់មេចិញ្ចឹមយកពងរបស់ សំណើប្រជាមតិ 2 ។ ច្បាប់នេះអនុវត្តចំពោះស៊ុតដែលមកពីរដ្ឋ California ឬរដ្ឋផ្សេងទៀត។ ជនណាដែលបំពានច្បាប់នេះ មានទោសបទល្មើសមជ្ឈឹម។ (ច្បាប់នេះមិនគ្រប់ដណ្ដប់ទៅលើស៊ុត *រាវ* ដែលជាស៊ុតលឿង និងស៊ុតស ដែលបានយកចេញពីសំបកវា និងកែច្នៃសម្រាប់ដាក់លក់ឡើយ។)

សេចក្តីស្នើច្បាប់

បង្កើតស្តង់ដារថ្មីសម្រាប់ការធ្វើរោងសត្វកសិដ្ឋានមួយចំនួន។ វិធានការនេះ (សំណើប្រជាមតិ 12) បង្កើតលក្ខខណ្ឌតម្រូវអប្បបរមាថ្មីទៅលើកសិករ ដើម្បីផ្តល់នូវទីធ្លាបន្ថែមសម្រាប់មាន់មេចិញ្ចឹមយកពង ជ្រូកមេចិញ្ចឹមយកកូន និងកូនគោចិញ្ចឹមយកសាច់។ លក្ខខណ្ឌតម្រូវទាំងនេះ ដែលអនុវត្តចំពោះសត្វកសិដ្ឋាន ចិញ្ចឹមនៅក្នុងរដ្ឋ California នឹងចាប់ផ្តើមប្រើប្រាស់នៅក្នុងឆ្នាំក្រោយៗជាច្រើនឆ្នាំ។ រូបភាពលេខ 1 បង្ហាញពីលក្ខខណ្ឌតម្រូវជាក់លាក់សម្រាប់សត្ត ពេលដែលវាត្រូវបានចាប់ផ្តើមប្រើប្រាស់ និងរបៀបដែលវាប្រៀបធៀបជាមួយនឹងច្បាប់បច្ចុប្បន្ន។

ហាមឃាត់ការលក់ផលិតផលទាំងឡាយណាដែលមិនបំពេញតាមស្តង់ដារ។ វិធានការនេះ ក៏ចាត់ទុកជាអំពើខុសច្បាប់ផងដែរ

វិភាគដោយអ្នកវិភាគអង្គនិតិបញ្ញត្តិ

រូបភាពលេខ 1

តម្រូវការទីធ្លាអប្បបរមាក្រោម ច្បាប់បច្ចុប្បន្ន និងសំណើប្រជាមតិ 12

ហ្វុតការ៉េក្នុងសត្វមួយក្បាល

		សំណើប្រជាមតិ 12[a]	
សត្វក្នុងកសិដ្ឋាន	**ច្បាប់បច្ចុប្បន្ន[a]**	**ចាប់ផ្តើមនៅឆ្នាំ 2020**	**ចាប់ផ្តើមនៅឆ្នាំ 2022**
មាន់មេចិញ្ចឹមយកពង	ត្រូវតែអាចបង្វិលខ្លួនដោយសេរី ដេក ឈរ និងត្រដាងអវៈយវៈវាបានពេញលេញ។[b]	1 ហ្វុតការ៉េនៃទីធ្លាកម្រាល	រោងគ្មានទ្រុង[c]
ជ្រូកមេចិញ្ចឹមយកកូន		—	24 ហ្វុតការ៉េនៃទីធ្លាកម្រាល
កូនគោចិញ្ចឹមយកសាច់		43 ហ្វុតការ៉េនៃទីធ្លាកម្រាល	មិនប្រែប្រួល (43 ហ្វុតការ៉េ)

[a] ច្បាប់បច្ចុប្បន្ន និងសំណើប្រជាមតិ 12 សុទ្ធតែដាក់បញ្ចូលការលើកលែងមួយចំនួនចំពោះតម្រូវការទីធ្លាអប្បបរមា។
[b] ជាទូទៅ បទបញ្ជារដ្ឋតម្រូវឲ្យមាន 0.8 ហ្វុតការ៉េនៃទីធ្លាកម្រាលសម្រាប់មេមាន់ចិញ្ចឹមយកពងមួយក្បាល។ ពុំមានបទបញ្ជាស្រដៀងគ្នានេះសម្រាប់ជ្រូកមេចិញ្ចឹមយកកូន ឬកូនគោចិញ្ចឹមយកសាច់ឡើយ។
[c] គ្មានទ្រុង រួមមានជាអាទិ៍ ប្រព័ន្ធរោងនៅក្នុងអគារ ដែលផ្តល់ 1 ទៅ 1.5 ហ្វុតការ៉េនៃទីធ្លាកម្រាលសម្រាប់មាន់មេមួយក្បាល ហើយអនុញ្ញាតឲ្យមាន់មេផ្លាស់ទីទៅមកនៅក្នុងអគារ។

សម្រាប់អាជីវកម្មទាំងឡាយនៅរដ្ឋ California ដែលមានចេតនាលក់ស៊ុត (រួមទាំងស៊ុតរាវ) ឬសាច់ជ្រូក ឬសាច់គោមិនទាន់ចម្អិន ដែលមកពីសត្វក្នុងរោងដែលមិនបំពេញតាមលក្ខខណ្ឌតម្រូវរបស់វិធានការនេះ។ ការហាមឃាត់ចំពោះការលក់នេះ ត្រូវបានអនុវត្តចំពោះផលិតផលមកពីសត្វដែលចិញ្ចឹមនៅក្នុងរដ្ឋ California ឬក្រៅរដ្ឋនេះ។ ការហាមឃាត់ចំពោះការលក់នេះជាទូទៅពុំត្រូវបានអនុវត្តចំពោះចំណីអាហារទាំងឡាយណាដែលមានស៊ុត សាច់ជ្រូក ឬសាច់គោជាគ្រឿងផ្សំ ឬដាក់ពីលើឡើយ (ដូចជា នំ cookie dough និងភីហ្សា)។ ការបំពានលក្ខខណ្ឌតម្រូវសម្រាប់ការធ្វើរោង ឬការហាមឃាត់ចំពោះការលក់នេះ នឹងជាបទល្មើសមជ្ឈឹមមួយ ហើយការបំពានលើការហាមឃាត់ចំពោះការលក់នេះ ក៏អាចត្រូវស្ថិតក្រោមការផាកពិន័យនៅក្នុងតុលាការខាងរដ្ឋឬវេណីផងដែរ។ វិធានការនេះ ក៏តម្រូវឲ្យ CDFA និងក្រសួងសុខាភិបាលសាធារណៈក្នុងរដ្ឋ California ត្រូវចែងពីបទបញ្ជាទាំងឡាយដើម្បីអនុវត្តលក្ខខណ្ឌតម្រូវទាំងនេះផងដែរ។

ផលប៉ះពាល់សារពើពន្ធ

តម្លៃសម្រាប់អ្នកប្រើប្រាស់ទំនងជានឹងកើនឡើង។ វិធានការនេះទំនងជានឹងបណ្តាលឲ្យមានកំណើនតម្លៃសម្រាប់ស៊ុត សាច់ជ្រូក និងសាច់គោដោយសារហេតុផលពីរយ៉ាង។ ទីមួយ វិធានការនេះនឹងបណ្តាលឲ្យកសិករជាច្រើនត្រូវតែរចនាម៉ូដថ្មីឡើងវិញ ឬសង់រោងថ្មីមួយទៀតសម្រាប់សត្ว—ដូចជា ដំឡើងរោងគ្មានទ្រុងសម្រាប់មាន់មេជាដើម។ នៅក្នុងករណីខ្លះ រោងនេះក៏អាចមានចំណាយកាន់តែថ្លៃក្នុងការដំណើរការជាបន្តបន្ទាប់ផងដែរ។ ភាគច្រើននៃចំណាយដែលមានការកើនឡើងនេះ ទំនងជាត្រូវបានរុញទៅឲ្យអ្នកប្រើប្រាស់ ដែលទិញផលិតផល។

ទីពីរ វាអាចចំណាយពេលជាច្រើនឆ្នាំដើម្បីឲ្យមានកសិករគ្រប់គ្រាន់នៅរដ្ឋ California និងរដ្ឋផ្សេងទៀត ក្នុងការផ្លាស់ប្តូរប្រព័ន្ធរោង ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់វិធានការនេះ។ ប្រសិនបើនៅពេលអនាគត

កសិករមិនអាចផលិតស៊ុត សាច់ជ្រូក និងសាច់គោ បានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការនៅរដ្ឋ California បានទេនោះ ការធ្លាក់ចុះទាំងនេះនឹងបណ្តាលឲ្យមានកំណើនតម្លៃរហូតដល់កសិករអាចបំពេញតាមតម្រូវការបាន។

ដូចដែលមានពិភាក្សាពីខាងលើ ក្រុមហ៊ុនជាច្រើនបានប្រកាសថា ពួកគេកំពុងឈានឆ្ពោះទៅរកការតម្រូវឲ្យអ្នកផ្គត់ផ្គង់ចំណីអាហាររបស់ពួកគេត្រូវផ្តល់ទីធ្លាបន្ថែមដល់សត្វកសិដ្ឋាន ដើម្បីឲ្យវាផ្លាស់ទីទៅមក (ឧទាហរណ៍ ដោយការទិញតែស៊ុតណាដែលប្រើរោង "គ្មានទ្រុង" ប៉ុណ្ណោះ)។ ចំពោះវិសាលភាពដែលការណ៍នេះកើតឡើងបាន កំណើនតម្លៃមួយចំនួនដែលមានពណ៌នាខាងលើ នឹងកើតឡើងនៅឆ្នាំអនាគតទៀតជាពុំខាន។

ការកាត់បន្ថយចំណូលរដ្ឋាភិបាលតិចតួច។ ដោយសារតែវិធានការនេះ នឹងបង្កើនចំណាយសម្រាប់កសិករមួយចំនួននៅរដ្ឋ California ដែលផលិតស៊ុត សាច់ជ្រូក និងសាច់គោនោះ ពួកគេមួយចំនួនអាចនឹងជ្រើសរើសការឈប់ផលិត ឬកាត់បន្ថយផលិតកម្មរបស់ពួកគេ។ ចំពោះវិសាលភាពដែលការណ៍នេះកើតឡើងបាន អាចមានប្រាក់ចំណូលពីពន្ធចំណូលរដ្ឋពីអាជីវកម្មកសិដ្ឋានទាំងនេះកាន់តែតិចនាពេលអនាគត។ ការកាត់បន្ថយទូទាំងរដ្ឋ ទំនងជានឹងមិនមានចំនួនច្រើនជាងរាប់លានដុល្លារជារៀងរាល់ឆ្នាំទេ។

ចំណាយលើការមើលការខុសត្រូវរបស់រដ្ឋ។ CDFA នឹងបង្កើនបន្ទុកការងារក្នុងការប្រតិបត្តិវិធានការនេះ។ ឧទាហរណ៍ ក្រសួងនឹងត្រូវពិនិត្យឲ្យដឹងថាតើកសិករនៅរដ្ឋ California និងរដ្ឋផ្សេងទៀត ដែលលក់មកកាន់រដ្ឋ California បានប្រើប្រាស់រោងសត្វដែលបំពេញតាមលក្ខខណ្ឌតម្រូវរបស់វិធានការនេះដែរឬទេ។ CDFA ក៏នឹងត្រូវធ្វើឲ្យប្រាកដផងដែរថាផលិតផលដែលលក់នៅរដ្ឋ California អនុលោមតាមលក្ខខណ្ឌតម្រូវរបស់វិធានការនេះ។ តម្លៃ **នៃបន្ទុកការងារបន្ថែមនេះ អាចមានចំនួនរហូតដល់ $10 លានដុល្លារក្នុងមួយឆ្នាំ។**

ចូលមើល *http://www.sos.ca.gov/campaign-lobbying/cal-access-resources/measure-contributions/2018-ballot-measure-contribution-totals/* សម្រាប់បញ្ជី នៃគណៈកម្មការ ដែលបង្កើតឡើងជាចម្បងដើម្បីគាំទ្រ ឬជំទាស់វិធានការនេះ។ ចូលមើល *http://www.fppc.ca.gov/transparency/top-contributors/nov-18-gen.html* ដើម្បីទទួលបានអ្នកចូលរួមវិភាគទានកំពូលៗទាំង 10 របស់គណៈកម្មការ។

ប្រសិនបើអ្នកចង់បានច្បាប់ចម្លងនៃអត្ថបទពេញលេញនៃវិធានការរដ្ឋ សូមទូរស័ព្ទមករដ្ឋលេខាធិការ តាមលេខ (888) 345-4917 ឬអ្នកអាចអ៊ីម៉ែល *vigfeedback@sos.ca.gov* ហើយច្បាប់ចម្លងមួយនឹងត្រូវបានផ្ញើទៅអ្នកដោយឥតគិតថ្លៃ។

★ ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិលេខ 12 ★

គាំទ្រសំណើប្រជាមតិលេខ 12—បញ្ឈប់ភាពយោរយៅលើសត្ត

អង្គការសង្គមមនុស្សធ៌មសហរដ្ឋអាមេរិក អង្គការ សមាគមអាមេរិចសម្រាប់ការការពារភាពសាហាវយោរយៅចំពោះសត្ត (American Society for the Prevention of Cruelty to Animals, ASPCA) និងពេទ្យសត្តជតិ *500* នាក់នៅរដ្ឋ *California* គាំទ្រសំណើប្រជាមតិលេខ 12។

ការបោះឆ្នោតគាំទ្រ គឺការពារកុំឱ្យគេញាត់កូនគោចិញ្ចឹមយកសាច់ មេជ្រូក និងមេមាន់ចិញ្ចឹមយកពងចូលទៅក្នុងទ្រុងដ៏តូចចង្អៀតអស់មួយជីវិត។ វានឹងលុបបំបាត់ផលិតផលអមនុស្សធ៌ម និងគ្មានសុវត្ថិភាពពីសត្តដែលត្រូវបានរំលោភបំពានទាំងនេះពីទីផ្សាររដ្ឋ California ។ ការបោះឆ្នោតគាំទ្រកាត់បន្ថយហានិភ័យរបស់ប្រជាជនដែលឈឺដោយការពុលអាហារ និងការបំពុលនៅកសិដ្ឋានរោងចក្រ និងជួយក្រុមគ្រួសារកសិករ។

បោះឆ្នោតគាំទ្រ សំណើប្រជាមតិលេខ 12 ដើម្បី៖

បង្ការភាពយោរយៅលើសត្ត។ វាយោរយៅណាស់ក្នុងការបង្ខាំងកូនគោលនៅក្នុងទ្រុងតូចចង្អៀត។ យកវាចេញឆ្ងាយពីមេក្រោយវាកើតភ្លាមបង្ខាំងវាប្រកប់ដោយភាពបំពានរហូតទាល់វាត្រូវបានបញ្ជូនទៅសត្តឃាតដ្ឋាន—អាយុត្រឹមតែបួនខែប៉ុណ្ណោះ។

មេជ្រូកមិនគួរត្រូវបានចាក់សោក្នុងទ្រុងដែកតូចចង្អៀត កន្លែងដែលនាងពិបាកផ្លាស់ទីនោះទេ។ នាងត្រូវបានជាប់អន្ទាក់ ត្រូវបានបង្ខំឱ្យរស់នៅក្នុងកន្លែងមានទំហំតូចសម្រាប់ពេល *ជិតបួនឆ្នាំ*។

វាគឺខុសឆ្គងក្នុងការញាត់មាន់យ៉ាងតឹងក្នុងទ្រុងខ្សែចង្អៀតសម្រាប់ពេញអាយុកាលរបស់នាង។ នាងត្រូវបានបង្ខំឱ្យញ៉ាំ ដេក និងជុំ និងនោម និងក្រាបពងក្នុងទីតាំងតូចដូចគ្នារៀបរាល់ថ្ងៃតែម្តង។

ការពារគ្រួសាររបស់យើងពីការបំពុលម្ហូបអាហារ និងការបំពុលកសិដ្ឋានរោងចក្រ។ ។ក្បាលពីសត្តមាន់ដែលមាន់ដោយសារតែពួកគេបានស្លាប់ *Salmonella*, ការសិក្សាវិទ្យាសាស្ត្រជាច្រើនបានរកឃើញថាការវេចខ្ជប់សត្តនៅក្នុងទ្រុងតូចៗធ្វើអោយមានហានិភ័យនៃការពុលអាហារ។ សូម្បី *ពិភពសត្តបក្សី*, ការបោះពុម្ពផ្សាយឧស្សាហកម្មស៊ីតឈានមុខគេបានទទួលស្គាល់, *"Salmonella ប្រឹងប្រែងនៅក្នុងលំនៅដ្ឋានដែលដាក់ក្នុងទ្រុង។"*

ហេតុនេះហើយ បានជាទាំង *មជ្ឈមណ្ឌលសម្រាប់សុវត្ថិភាពម្ហូបអាហារ* និងសម្ព័ន្ធអ្នកប្រើប្រាស់ជាតិ គាំទ្រសំណើប្រជាមតិលេខ 12។

សមាគមសុខាភិបាលសាធារណៈអាមេរិក បានអំពាវនាវឱ្យផ្អាកការវះកាត់សត្តស្លាងថ្មី ដោយសារតែពួកគេបំពុលខ្យល់និងដីទឹក និងបន្ថយគុណភាពជីវិតសម្រាប់ម្ចាស់ផ្ទះជិតៗនោះ។

ជួយកសិករគ្រួសារ និងបង្កើនសេដ្ឋកិច្ចកាលីហ្វ័រញ៉ា។ កសិដ្ឋានគ្រួសារមេហ្គាដែលសត្តទ្រុងបានកាត់បន្ថយជ្រុងនិងជំរុញកសិករគ្រួសារចេញពីអាជីវកម្ម។ ដោយការបោះឆ្នោតបាទ / ចាសនៅលើលេស 12 យើងអាចបង្កើតស្តុង់ដារសមរម្យដែលរក្សាកសិករក្នុងអាជីវកម្ម—និងអនុញ្ញាតឱ្យពយកគេធ៌ធាត់។ ដោយសារតែកសិដ្ឋានឥតគិតថ្លៃប្រើប្រាស់កម្មករកាន់តែច្រើន វិធានការនឹងបង្កើត *ការងារកាន់តែច្រើន* សម្រាប់ក្រុមគ្រួសារកសិដ្ឋានខ្ចីតខំធ្វើការ។

អាស្រ័យហេតុនេះ *កសិករគ្រួសារ California* និង *កម្មករកសិកររួបរួម* គាំទ្រសំណើប្រជាមតិ 12 នេះ។

កំណែទម្រង់ទូទៅ

- **សេចក្តីប្រកាសលេខ 12 បានពង្រឹងច្បាប់យោរយៅសត្តព្រៃអាយុមួយទសវត្សរ៍ហើយផ្តល់នូវពេលវេលាល្អសម្រាប់អ្នកផលិតដើម្បីប្តូរទៅអនុវត្តមិនមានទ្រុង។**
- **ក្រុមហ៊ុនអាហារធំ ៗ ជាង 200 ផ្សេងទៀតដូចជា** *ក្រុមហ៊ុន Walmart, McDonald's, Taco Bell, Burger King, Safeway,* **និង** *Dollar Tree* **បានប្តេជ្ញាប្រើប្រាស់ផលិតផលដែលមិនមានទ្រុង។**
- **រដ្ឋចំនួន 12 បានអនុម័តច្បាប់ទាក់ទងនឹងការបង្ខាំងសត្តកសិកម្ម។**
- **ការបោះឆ្នោតដែលត្រូវបានអនុម័តដោយ** *ពួកមេដឹកនាំកាតូលិកកាតូលិក, បព្វជិតសាស្តា, គ្រឹស្តសាសនា, មេតូឌីស, ជ្វីហ្ស, បព្វជិតភាព, គ្រឹស្តសាសនា, មេតូឌីស,* **និង** *ជ្វីហ្ស, អ្នកផ្សាយដំណឹងល្អ, និង* **ជម្រកសត្តព្រៃ** *នៅទូទាំងរដ្ឋកាលីហ្វ័រញ៉ា*។

យើងនឹងមិនបង្ខំឆ្កែ ឬឆ្មារបស់យើងឱ្យរស់នៅក្នុងទ្រុងតូចមួយដ៏កខ្វក់អស់មួយជីវិតរបស់នាង។ យើងមិនគួរអនុញ្ញាតឱ្យសត្តណាមួយស៊ូទ្រាំការរងទុក្ខបែបនេះឡើយ។ **សត្តទាំងអស់រួមទាំងសត្តកសិកម្មសមនឹងទទួលបានការការពារពីភាពសាហាវយោរយៅ និងការរំលោភបំពាន។**

www.YesOn12CA.com

CRYSTAL MORELAND, **នាយករដ្ឋ California Humane Society of the United States**

បណ្ឌិត JAMES REYNOLDS DVM, MPVM, DACAW, **សាស្ត្រាចារ្យផ្នែកឱសថធ៌ ៗ និងសុខុមាលភាពមហាវិទ្យាល័យវេណាវ៉ាសនានៃសាកលវិទ្យាល័យវេស្ទើន**

ANDREW DECORIOLIS **នាយក** **នៃកម្មវិធី** **កម្មវិធីយុទ្ធសាស្ត្រនិងការចូលរួមការធ្វើកសិកម្មទៅមុខ**

★ ការឆ្លើយចំពោះទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិលេខ 12 ★

សំណើប្រជាមតិលេខ12 គឺជាអំពើក្បត់សត្ត និងអ្នកបោះឆ្នោតដ៏យោរយៅ

ទឡ្ហីករណ៍គាំទ្រសំណើប្រជាមតិលេខ 12 **គឺពោពេញដោយភាពមិនច្បាស់លាស់ ហើយព្យាយាមមិននិយាយអំពីសហគមន៍អ្នកផលិតស៊ុត (United Egg Producers) ការទទួលយកការបន្តប្រើទ្រុងយ៉ាងហោចណាស់រហូតដល់ឆ្នាំ *2022* ដោយអនុញ្ញាតឱ្យប្រើទ្រុងដែលមានទំហំតែ*មួយហ្វុតការ៉ែ*សម្រាប់មេមាន់នីមួយៗ ឬព្យាយាមមិននិយាយចំណុចជាក់លាក់ដែលគ៌ិនិតផ្តួចផ្តើមនេះនឹងធ្វើ។**

អាចនិយាយម៉្យាងទៀតបានថា អង្គការសង្គមមនុស្សធ៌មសហរដ្ឋអាមេរិកដែលពោរពេញដោយរឿងអាស្រូវត្រលប់ទៅប្រើល្បិចចាស់របស់គេវិញហើយ។

ក្រុមដដែលដែលពីមុននិយាយថាមាន់នៅរដ្ឋ California នឹងមិនត្រូវបានដាក់ទ្រុងទេនៅដំណាច់ឆ្នាំ *2015* ដែល Michael Vick គឺជាអ្នកចិញ្ចឹមសត្តដ៏ល្អដែលគាំទ្រក្រុមហ៊ុន SeaWorld និងបានខាតបង់ប្រាក់រាប់លានដុល្លារនៅក្នុងបណ្តឹងច្បាប់ Racketeer Influenced and Corrupt Organizations **ឥឡូវនេះបានត្រឡប់មកវិញហើយ។**

ជាថ្មីម្តងទៀត សង្គមមនុស្សនៅសហរដ្ឋអាមេរិក (Humane Society of the United States, HSUS) កំពុងសន្យាថានឹងហាមឃាត់ការប្រើទ្រុងឧស្សាហកម្មស៊ីត ទោះបីជាវាបានចំណាយពេលពេញមួយទសវត្សអ៊ុនអាងថាពួកគេបានធ្វើ*រារួចហើយក៏ដោយ*!

ទន្ទឹមនឹងនេះដែរពួកគេកំពុងវាយប្រហារអ្នកដែលរាយការណ៍ព័ត៌មានអំពីពួកគេ។ **យើងដឹងនៅពេលដែលអង្គការសប្បុរសធ៌មមួយបរាជ័យក្នុងការបំពេញកាតព្វកិច្ចមូលដ្ឋានបំផុតនៃទំនុកចិត្តរបស់ខនោះ។** *ជាជាងការវាយប្រហារទៅលើស្ត្រីដែលទទួលរងការរំលោភបំពាន HSUS គួរតែផ្លាស់ប្តូរវប្បធ៌មរបស់ខ្លួន។ - អង្គការជាតិស្ត្រី*

នៅពេលស្ត្រីបានប្រមូលផ្តុំគ្នាប្រឆាំងនឹងវប្បធ៌មពីសពុលរបស់ HSUS **វាកើតចេញពីការចោទប្រកាន់ជាច្រើនអំពីការបៀតបៀនផ្លូវភេទ និងការប្រព្រឹត្តិខុសប្រឆាំងនឹងស្ថាបនិករបស់សំណើប្រជាមតិលេខ 12 ដែលជាអតីតនាយកប្រតិបត្តិ** **គឺលោក Wayne Pacelle ។ ការឆ្លើយតបដំបូងរបស់ HSUS** **គឺចោទសួរសុច្ចរិតភាពរបស់*ស្ត្រី*។**

យុទ្ធសាស្ត្រនេះត្រូវបានប្រើប្រាស់ប្រឆាំងនឹងអ្នកតស៊ូមតិសម្រាប់សត្តដែលប្រឆាំងនឹងសំណើប្រជាមតិលេខ 12 ។

ការពិតដែលមិនអាចប្រកែកបាននោះគឺ៖ ប្រសិនបើមិនមែនដោយសារតែភាពខ្ជីខ្ជារបស់ HSUS ទេនោះ មាន់នៅរដ្ឋ California នឹងមិនត្រូវបានបង្ខាំងក្នុងទ្រុងនេះ*នៅវិនាទីនេះ*។ យើងមិនធ្លាក់ក្នុងល្បិចកលដដែលនេះជាលើកទីពីរទេ។

www.StopTheRottenEggInitiative.org

MARK EMERSON **សមាជិកក្រុមប្រឹក្សាភិបាលពលរដ្ឋ California ប្រឆាំងនឹងភាពយោរយៅ ការដាក់ទ្រុង និងការក្លែងបន្លំ**

ERIC MILLS **អ្នកសំរបសំរួលសកម្មភាពសម្រាប់សត្ត**

PETER T. BROWN **សមាជិកក្រុមប្រឹក្សាភិបាលមិត្តសត្ត**

ទឡ្ហីករណ៍ដែលបានបោះពុម្ពនៅលើទំព័រនេះគឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យរកភាពត្រឹមត្រូវដោយភ្នាក់ងារផ្លូវការណាមួយទេ។

★ ទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិ 12 ★

ការបោះឆ្នោតលេខ: ទប់ស្កាត់ការយោរយៅ, ទ្រុងនិងការបន្ទំ។

អង្គការសង្គមមនុស្សធ៌មសហរដ្ឋអាមេរិក (HSUS) ដែលមានមូលដ្ឋាននៅទីក្រុងវ៉ាស៊ីនតោន DC បានស្វែងរកវិធីជាថ្មីម្តងទៀតដើម្បីយកបញ្ហានេះដាក់លើសន្លឹកឆ្នោតរបស់រដ្ឋ California ដោយបោកបញ្ឆោតអ្នកបោះឆ្នោត និយាយត្រឡប់ត្រឡិនអំពីទ្រុង ហើយបន្តលើកឡើងពីការរងទុក្ខវេទនារបស់មេមាន់ *រាប់លានៗនាក់ក្បាល* ។

សោយផ្សព្វផ្សាយខុសពីការពិតថាជាវិធានការ "មិនដាក់ទ្រុង" សំណើប្រជាមតិលេខ 12ការពិត យ៉ាងណាស់នឹងធ្វើឱ្យស្របច្បាប់ដល់ការបន្តប្រើទ្រុងរោងចក្រផលិតស៊ុតសម្រាប់រយៈពេលច្រើនឆ្នាំទៅមុខទៀត។

សំណើលេខ 12 គឺជាលទ្ធផលនៃសម្ព័ន្ធភាពសាធារណៈរវាង HSUS និងសហគមន៍ពាណិជ្ជកម្មជាតិសហគមន៍នៃសមាគមផលិតស៊ុត។

នៅឯការចំណាយរបស់អ្នកជាប់ពន្ធពួកគេកំពុងតែប្រើប្រាស់គំនិតផ្តួចផ្តើមរបស់រដ្ឋកាលីហ្វ័រនីញ៉ាជំនួសឱ្យការជំនួសច្បាប់លំនៅឋានរបស់ពួកគេដោយមានការណែនាំពីអ្នកផលិតស៊ុតយូ។

សំណើប្រជាមតិលេខ 12 ធ្វើឱ្យស្របច្បាប់នូវការប្រើទ្រុងដ៏ឃោរឃៅ ដែលពលរដ្ឋ California ភាគច្រើនបោះឆ្នោតហាមឃាត់កាលពីដប់ឆ្នាំមុន។

ច្បាប់បច្ចុប្បន្នរបស់រដ្ឋ California (សំណើប្រជាមតិលេខ 2) ចែងថាត្រូវផ្តល់លំហរគ្រប់គ្រាន់សម្រាប់មាន់ចិញ្ចឹមយកពងដើម្បី៖

". . . វាអាចលាស្លាបទាំងសងខាងបានពេញលេញដោយមិនប៉ះជញ្ជាំងទ្រុង ឬប៉ះមេមាន់ផ្សេងទៀតទេ។"

សំណើប្រជាមតិលេខ 12 នឹង *និវាករណ៍* ច្បាប់ដែលបានអនុម័តដោយអ្នកបោះឆ្នោត ដើម្បីអនុញ្ញាតឱ្យរោងចក្រផលិតស៊ុប្រើទ្រុង ឬលំហត្រឹមតែ *1 ហ្វុតការ៉ែ* ប៉ុណ្ណោះ សម្រាប់មេមាន់នីមួយៗ។

សំណើប្រជាមតិលេខ 12 គឺជាការបោកបញ្ឆោតដ៏ឃោរឃៅលើសត្វកសិកម្ម និងលើអ្នកបោះឆ្នោតនៅរដ្ឋ California ។

ដោយសារតែការធ្វើពង្រាង សំណើប្រជាមតិលេខ 2 ដ៏ខ្ជីខ្ជានៅឆ្នាំ 2008មេមាន់ចិញ្ចឹមយកពងរាប់លានក្បាលនៅបន្តរងគ្រោះក្នុងទ្រុងរោងចក្រផលិតស៊ុតនៅទូទាំងរដ្ឋ California ។

ទោះជាយ៉ាងណាក៏ដោយ សាធារណៈជនដែលទិញស៊ុតត្រូវបានគេប្រាប់ជាច្រើនលើកច្រើនសារថា សំណើប្រជាមតិលេខ 2 បានហាមឃាត់ការប្រើប្រាស់ទ្រុងទាំងនោះដោយជោគជ័យ ។ សម្រាប់រយៈពេលមួយទសវត្សរ៍ នោះគឺជាពាក្យអះអាងក្នុងការផ្សព្វផ្សាយធំបំផុតរបស់ HSUS ។

ឥលូវនេះ មិនសូវមានការអះអាងអ្វីច្រើនទេ *តែអ្នកគាំទ្រការអះអាងដែលថារដ្ឋ California គួរធ្វើជារដ្ឋដែលមិនប្រើទ្រុងមុនដំណាច់ឆ្នាំ 2015*បានត្រឡប់មកវិញជាមួយការសន្យាបោកប្រាស់មួយផ្សេងទៀតហើយ។

គ្រាន់តែពេលនេះ ពួកគេនិយាយថាប្រជាជន California នឹងត្រូវរង់ចាំដល់ឆ្នាំ *2022!* ហើយសូម្បីតែកាលបរិច្ឆេទនោះគឺមិនច្បាស់ដែរ។ សំណើប្រជាមតិលេខ 12 ត្រូវបានសរសេរច្បាស់ថាអនុញ្ញាតឱ្យសភាធ្វើការកែប្រែនៅពេលណាក៏បាន ដោយគ្មានការយល់ព្រមពីអ្នកបោះឆ្នោត ។

សំណើប្រជាមតិលេខ 12 មិនជួយអ្វីទេដល់ជ្រូក ឬកូនគោ។

ចំពោះការកុហកទាំងនេះ ក្រុមមនុស្សដដែលដែលបង្កើតសំណើប្រជាមតិលេខ 2 នេះ ហើយដែលសន្យាថារដ្ឋ California នឹងជារដ្ឋមិនប្រើទ្រុងនៅដំណាច់ឆ្នាំ 2015 ឥឡូវនេះកំពុងអះអាងថា សំណើប្រជាមតិលេខ 12 នឹងកំណត់ការអនុវត្តន៍របស់អ្នកផលិតសាច់ជ្រូក និងសាច់គោ *ក្រៅរដ្ឋ* ។ មិនគួរមានអ្នកណាចាញ់បោកឧបាយកលនោះទេ។

វាទំនងជាមិនអាចទៅរួចទេដែលបញ្ញត្តិដែលប្រាកចាកពីរដ្ឋធម្មនុញ្ញរបស់សំណើប្រជាមតិលេខ ១២ អាចជៀសផុតពីបញ្ហាប្រឈមផ្នែកច្បាប់ដែលជៀសមិនផុត (ការការពារសំណើប្រជាមតិនេះនឹងដាក់សម្ពាធលើការចំណាយរបស់អ្នកបង់ពន្ធ) តែទោះជាក្នុងករណីដែរវាអាចទៅរួចក៏ដោយ សភាកំពុងតែដំណើរការច្បាប់ដើម្បីធ្វើមោយភាពបញ្ញត្តិដែលមាននៅច្រើនរដ្ឋទាំងនេះ។

ហើយទន្ទឹមនឹងការអះអាងថានឹងកំណត់បញ្ញត្តិសម្រាប់ *រដ្ឋ* ផ្សេងទៀត សំណើប្រជាមតិលេខ 12 *អនុញ្ញាត*ឱ្យមានការបង្ខាំងគោចិញ្ចឹមយកទឹកដោះដ៏ឃោរឃៅ នៅរដ្ឋ California នេះ!

សំណើប្រជាមតិលេខ 12 គឺជាការកេងប្រវ័ញ្ចដែលគ្មានកោតក្រែងលើដំណើរការផ្តួចផ្តើមរបស់រដ្ឋ California ដែលមិនត្រឹមតែធ្វើឱ្យប៉ះពាល់ដល់សត្វកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏បង្កគ្រោះថ្នាក់ដ៏ធំធេងផងដែរដល់អ្នកប្រើប្រាស់ សត្ត និងច្បាប់ការពារបរិស្ថាន។

គំនិតផ្តួចផ្តើមដ៏ពឹសពុលនេះគួរតែត្រូវបានបដិសេធចោលជាដាច់ខាត។

ស្វែងយល់ថាហេតុអ្វីបានជាអង្គការប្រជាជនដើម្បីការព្យាបាលសត្ត អង្គការមិត្តសត្ត សមាគមកសិកម្មមនុស្សធ៌ម អង្គការពលរដ្ឋ California ប្រឆាំងនឹងភាពឃោរឃៅ ការដាក់ទ្រុង និងការក្លែងបន្លំ និងក្រុមផ្សេងទៀតជាច្រើនទៀតប្រឆាំងនឹងសំណើប្រជាមតិលេខ 12 ។

សូមចូលមើល៖ *www.NoOnProposition12.org*

BRADLEY MILLER ប្រធាន
សមាគមកសិដ្ឋានមនុស្សធ៌ម (HFA)

PETER T. BROWN សមាជិកក្រុមប្រឹក្សាភិបាល
អង្គការមិត្តសត្ត (FoA)

LOWELL FINLEY ហិរញ្ញិក
ពលរដ្ឋ California ប្រឆាំងនឹងភាពឃោរឃៅ ការដាក់ទ្រុង និងការក្លែងបន្លំ

★ ការឆ្លើយចំពោះទឡ្ហីករណ៍ប្រឆាំងសំណើប្រជាមតិលេខ 12 ★

គាំទ្រសំណើប្រជាមតិលេខ 12 ដើម្បីបញ្ឈប់អំពើឃោរឃៅ និងអមនុស្សធ៌លើសត្វកសិកម្ម។ ដូច្នេះ ស្ថាប័ននានាដែលគេជឿទុកចិត្តបំផុតទាក់ទងនឹងភាពសាហាវឃោរឃៅលើសត្ត ការធ្វើកសិកម្មការប្រកបដោយនិរន្តភាព និងសុវត្ថិភាពអាហារ គាំទ្រសំណើប្រជាមតិលេខ 12៖ ពេទ្យសត្ត ជិត 500 នាក់ កសិករលក្ខណៈគ្រួសារនៅរដ្ឋ California កន្លែងផ្តល់ជម្រកសត្តរដ្ឋ California អង្គការ ASPCA អង្គការសង្គមមនុស្សធ៌មសហរដ្ឋអាមេរិក មជ្ឈមណ្ឌលសម្រាប់សុវត្ថិភាពអាហារ សហជីពអ្នកធ្វើការងារកសិកម្ម និងសម្ព័ន្ធអ្នកប្រើប្រាស់ជាតិ។

ក្រុមមួយក្តាប់តូចដែលប្រឆាំងនឹងសំណើប្រជាមតិលេខ 12 ដែលគេស្គាល់ថាជាសមាគមកសិកម្មមនុស្សធ៌—មានប្រវត្តិអាក្រក់ចូលរួមជាមួយកសិដ្ឋានចិញ្ចឹមសត្ត៍ដ៏ប់ពុល ក្នុងការប្រឆាំងនឹងច្បាប់ស្តីពីភាពឃោរឃៅលើសត្ត និងត្រូវបានគាំទ្រដោយអ្នកបញ្ជល់សត្ត ដែលមានការបោះពុម្ពផ្សាយសម្ងាត់មួយអួតអាងថាការវាយប្រហាររបស់ HFA ទៅលើអង្គការសប្បុរសធ៌សត្ត បានជួយដល់អ្នកជល់មាន់!"

ការពិត: កាលពី 10 ឆ្នាំមុនប្រជាជនកាលីហ្វ័រនីញ៉ាបានអនុម័តច្បាប់មួយដែលផ្តល់ឱ្យសត្វកសិកម្មច្រើនកន្លែង។ វាបាននាំអ្នកផលិតស៊ុត និងសាច់ជ្រូកជាច្រើនឱ្យចាកចេញពីការប្រើទ្រុង ហើយក្រុមហ៊ុន McDonald ក្រុមហ៊ុន Safeway ក្រុមហ៊ុន Burger King និងក្រុមហ៊ុនដទៃទៀតរាប់រយក្រុមហ៊ុន បានចាប់ផ្តើមប្រើផលិតផលសត្ដដែលមិនដាក់ទ្រុង។

ប៉ុន្តែកសិដ្ឋានរបស់រោងចក្រមួយចំនួន—គ្មានអ្នកដែលប្រឆាំងសំណើប្រជាមតិលេខ 12—បានរកឃើញវិធីនៅជុំវិញច្បាប់ហើយនៅតែកំណត់សត្ដនៅក្នុងទ្រុង។ *នោះគឺពិតប្រាកដណាស់ហេតុអ្វីបានជាសំណើប្រជាមតិលេខ 12 ត្រូវបានគេត្រូវការ។*

សំណើប្រជាមតិលេខ 12 *ពង្រឹង* ច្បាប់ស្តីពីភាពឃោរឃៅដោយផ្តល់ការការពារកាន់តែប្រសើរ រួមទាំងលក្ខខណ្ឌការរស់នៅល្អ លក្ខខណ្ឌអប្បបរមាលំហរ និងកន្លែងរស់នៅដោយគ្មានទ្រុងដោយមានកាលវិភាគចាប់ផ្តើមអនុវត្តដែលការពារកសិករលក្ខណៈគ្រួសារ។

ដូចដែលភាសាក្នុងសន្លឹកឆ្នោតបានបង្ហាញច្បាស់ សំណើប្រជាមតិលេខ 12 បង្ការការបង្ខាំងឃោរឃៅលើមាន់ចិញ្ចឹមយកស៊ុត ព្រមទាំងកូនគោ និងជ្រូក។ *សត្ដទាំងនេះសមនឹងទទួលបានការការពារពីការរំលោភបំពាន*។

គាំទ្រការអនុវត្តមនុស្សធ៌លើសត្ដកសិកម្ម។ គាំទ្រសម្រាប់សុវត្ថិភាពអាហារ។ គាំទ្រសម្រាប់កសិករលក្ខណៈគ្រួសារ។ គ្រាំទ្រសម្រាប់ក្តីមេត្តា និងសុភវិនិច្ឆ័យ។

www.YesOn12CA.com

DR. BARBARA HODGES, DVM, MBA, អ្នកផ្តល់ប្រឹក្សាខាងពេទ្យសត្ដ
សមាគមវេជ្ជសាស្ត្រពេទ្យសត្ដនៃសង្គមមនុស្សធ៌

JEFF PETERSON អ្នកគ្រប់គ្រងទូទៅ
Central Valley Eggs

BROOKE HAGGERTY នាយកប្រតិបត្ដិ
សម្ព័ន្ធការការពារ និងសង្គ្រោះសត្ដ

ទិដ្ឋភាពទូទៅនៃបំណុលប័ណ្ណកម្ចីរដ្ឋ

រៀបចំដោយអ្នកវិភាគនិតិបញ្ញត្តិ

ទិដ្ឋភាពទូទៅនៃបំណុលប័ណ្ណកម្ចីរបស់រដ្ឋ។ វាក៏ពិភាក្សាផងដែរអំពីរបៀបដែលវិធានការប័ណ្ណកម្ចីនៅលើសន្លឹកឆ្នោត ប្រសិនបើត្រូវបានអនុម័តដោយអ្នកបោះឆ្នោត នឹងប៉ះពាល់យ៉ាងណាដល់ការចំណាយរបស់រដ្ឋដើម្បីសងបំណុលប័ណ្ណកម្ចី។

ប័ណ្ណកម្ចីរដ្ឋ និងការចំណាយលើប័ណ្ណកម្ចី

តើអ្វីជាប័ណ្ណកម្ចី? ប័ណ្ណកម្ចីគឺជាវិធីមួយដែលរដ្ឋាភិបាល និងក្រុមហ៊ុនខ្ចីប្រាក់។ រដ្ឋាភិបាលថ្នាក់រដ្ឋប្រើប័ណ្ណកម្ចីជាចម្បងដើម្បីចំណាយសម្រាប់ការធ្វើផែនការ ការសាងសង់ និងជួសជុលគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្ពាន ទំនប់ ពន្ធនាគារ ឧទ្យាន សាលារៀន និងអគារការិយាល័យ។ រដ្ឋលក់ប័ណ្ណកម្ចីដល់វិនិយោគិនដើម្បីទទួលបានមូលនិធិ "ជាមុន" សម្រាប់គម្រោងទាំងនេះ ហើយបន្ទាប់មកសងវិនិយោគិនដោយមានការប្រាក់ក្នុងរយៈពេលមួយ។

ហេតុអ្វីបានជាប័ណ្ណកម្ចីត្រូវបានប្រើ? មូលហេតុចម្បងសម្រាប់ការចេញប័ណ្ណកម្ចីគឺថាហេដ្ឋារចនាសម្ព័ន្ធ ជាធម្មតា ផ្តល់សេវាក្នុងរយៈពេលច្រើនឆ្នាំ។ ដូច្នេះ វាសមហេតុសមផលសម្រាប់មនុស្ស ទាំងក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគតដើម្បីជួយបង់ថ្លៃគម្រោង។ ដូចគ្នានេះផងដែរ វាអាចជាការលំបាកក្នុងការបង់ប្រាក់ទាំងអស់ក្នុងពេលតែមួយសម្រាប់ការចំណាយដ៏ធំនៃគម្រោងទាំងនេះ។

តើប្រភេទសំខាន់ៗនៃប័ណ្ណកម្ចីអ្វីខ្លះ? ប័ណ្ណកម្ចីដែលរដ្ឋប្រើមានពីរប្រភេទធំៗគឺប័ណ្ណកម្ចីកាតព្វកិច្ចទូទៅ និងប័ណ្ណកម្ចីប្រាក់ចំណូល។ ភាពខុសគ្នាមួយរវាងប័ណ្ណកម្ចីកាតព្វកិច្ចទូទៅ និងប័ណ្ណកម្ចីចំណូលគឺរបៀបសងបណ្ណកម្ចីទាំងពីរ។ រដ្ឋជាធម្មតាសងប័ណ្ណកម្ចីកាតព្វកិច្ចទូទៅដោយប្រើមូលនិធិទូទៅរបស់រដ្ឋ (គណនីប្រតិបត្តិការចម្បងរបស់រដ្ឋដែលរដ្ឋប្រើដើម្បីបង់ថ្លៃការអប់រំ ពន្ធនាគារ ការថែទាំសុខភាព និងសេវាផ្សេងទៀត) ។ មូលនិធិទូទៅត្រូវបានគាំទ្រជាចម្បងដោយប្រាក់ចំណូល និងចំណូលពន្ធលើការលក់។ រដ្ឋតែងតែសងប័ណ្ណកម្ចីចំណូលពីប្រភពផ្សេងទៀត ដូចជា កម្រៃដែលបង់ដោយអ្នកប្រើប្រាស់គម្រោងដែលទទួលបានមូលនិធិ (ដូចជាកម្រៃសេវាប្រើប្រាស់ស្ពាន) ។ ភាពខុសគ្នាមួយទៀតរវាងប័ណ្ណកម្ចីកាតព្វកិច្ចទូទៅ និងប័ណ្ណកម្ចីចំណូលរបស់រដ្ឋ គឺជារបៀបដែលប័ណ្ណទាំងនេះត្រូវបានអនុម័ត។ ប័ណ្ណកម្ចីកាតព្វកិច្ចទូទៅដែលចេញដោយរដ្ឋត្រូវតែអនុម័តដោយអ្នកបោះឆ្នោត ខណៈដែលប័ណ្ណកម្ចីចំណូលមិនតម្រូវដូច្នោះទេ។

តើអ្វីហិរញ្ញបទានប័ណ្ណកម្ចីមានចំណាយអ្វីខ្លះ? បន្ទាប់ពីលក់ប័ណ្ណកម្ចី រដ្ឋធ្វើការបង់ប្រាក់ប្រចាំឆ្នាំក្នុងរយៈពេលពីរបីទសវត្សរ៍ខាងមុខរហូតដល់អស់បំណុល។ (វាគឺស្រដៀងគ្នាទៅនឹងរបៀបដែលក្រុមគ្រួសារបង់សងប្រាក់កម្ចីទិញផ្ទះដូច្នោះដែរ)។ រដ្ឋបង់សងគម្រោងដែលទទួលបានមូលនិធិពីប័ណ្ណកម្ចីច្រើនជាងការបង់សងរបស់រដ្ឋសម្រាប់គម្រោងដែលរដ្ឋមិនខ្ចីប្រាក់ដោយសារតែការចំណាយលើការប្រាក់។ ការចំណាយបន្ថែមអាស្រ័យទៅលើអត្រាការប្រាក់ និងរយៈពេលដែលប័ណ្ណកម្ចីត្រូវបានសង ។

ប័ណ្ណកម្ចី និងថវិការដ្ឋ

ចំនួនបំណុលមូលនិធិទូទៅ។ រដ្ឋមានប័ណ្ណកម្ចីដែលគាំទ្រដោយមូលនិធិទូទៅប្រមាណ $83 ពាន់លាន ដែលរដ្ឋកំពុងបង់សងប្រាក់ដើម និងការប្រាក់ជារៀងរាល់ឆ្នាំ។ លើសពីនេះទៅទៀត អ្នកបោះឆ្នោត និងសភាបានយល់ព្រមអនុម័តលើប័ណ្ណកម្ចីដែលគាំទ្រដោយមូលនិធិទូទៅចំនួន $39 ពាន់លាន ដែលមិនទាន់ត្រូវបានលក់នៅឡើយ។ ភាគច្រើននៃប័ណ្ណកម្ចីទាំងនេះត្រូវបានគេរំពឹងថានឹងត្រូវបានលក់នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ព្រោះគម្រោងបន្ថែមទៀតត្រូវការថវិកា។ បច្ចុប្បន្ននេះ យើងប៉ាន់ស្មានថារដ្ឋនឹងចំណាយប្រាក់ប្រមាណ $6 ពាន់លានជារៀងរាល់ឆ្នាំពីមូលនិធិទូទៅ ដើម្បីសងប័ណ្ណកម្ចី ។

សំណើប្រជាមតិនានាលើសន្លឹកឆ្នោតនេះ ។ មានវិធានការប័ណ្ណកម្ចីកាតព្វកិច្ចទូទៅចំនួនបីនៅលើសន្លឹកឆ្នោតនេះ។ រួមគ្នា វិធានការទាំងនេះនឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់បន្ថែមចំនួន $14.4 ពាន់លាន៖

- សំណើប្រជាមតិទី1 នឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់ចំនួន $4 ពាន់លានសម្រាប់កម្មវិធីលំនៅដ្ឋានដែលមានតម្លៃសមរម្យ និងកម្មវិធីទាក់ទងនឹងអតីតយុទ្ធជន។ (ក្នុងចំណោមទឹកប្រាក់សរុបនេះ នឹងមានទឹកប្រាក់ $1 ពាន់លានសម្រាប់កម្មវិធីប្រាក់កម្ចីទិញផ្ទះ ដែលត្រូវបានរំពឹងថានឹងត្រូវសងដោយអតីតយុទ្ធជន ដែលចូលរួមក្នុងកម្មវិធីនេះជាជាងសងដោយមូលនិធិទូទៅ) ។
- សំណើប្រជាមតិទី 3 នឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់ចំនួន $8.9 ពាន់លានសម្រាប់គម្រោងទឹក និងគម្រោងបរិស្ថានដទៃទៀត។

- សំណើប្រជាមតិទី 4 នឹងអនុញ្ញាតឱ្យរដ្ឋខ្ចីប្រាក់ $1.5 ពាន់លានសម្រាប់មន្ទីរពេទ្យមួយចំនួនដែលព្យាបាលកុមារ។

លើសពីនេះ វិធានការមួយលើសន្លឹកឆ្នោត គឺសំណើប្រជាមតិទី 2 នឹងអនុញ្ញាតឱ្យរដ្ឋប្រើប្រាស់មូលនិធិប័ណ្ណកម្ចីចំណូលរហូតដល់ $2 ពាន់លាន ដើម្បីផ្តល់លំនៅដ្ឋានសម្រាប់អ្នកជំងឺផ្លូវសតិដែលគ្មានផ្ទះរស់នៅ។ ប័ណ្ណកម្ចីទាំងនេះនឹងត្រូវបានសងដោយប្រាក់ចំណូលដែលត្រូវបានគេទុកដោយឡែកសម្រាប់កម្មវិធីសុខភាពផ្លូវសតិ មិនមែនមូលនិធិទូទៅទេ។

ផលប៉ះពាល់នៃការបោះឆ្នោតនេះលើការសងប្រាក់បំណុល ។ យើងប៉ាន់ស្មានថាការចំណាយសរុប (រាប់បញ្ចូលទាំងការប្រាក់) ដើម្បីសងវិធានការប័ណ្ណកម្ចីកាតព្វកិច្ចទាំងបី នៅលើសន្លឹកឆ្នោតនេះ នឹងមានទំហំទឹកប្រាក់ប្រហែលជា $26 ពាន់លាន។ ការចំណាយទាំងនេះនឹងត្រូវបានបង់សងក្នុងរយៈពេលប្រហែល 40 ឆ្នាំ ដែលការបង់សងជាមធ្យមមានទឹកប្រាក់ $650ក្នុងមួយឆ្នាំ។ ការចំណាយនេះគឺច្រើនជាង 11 ភាគរយនៃការចំណាយពីមូលនិធិទូទៅលើបំណុលប័ណ្ណកម្ចីបច្ចុប្បន្នរបស់រដ្ឋ។ ការចំណាយជាក់លាក់នឹងអាស្រ័យលើព័ត៌មានលំអិតនៃការលក់ប័ណ្ណកម្ចី។

ផលប៉ះពាល់នៃការបោះឆ្នោតនេះលើប្រាក់ចំណូលរបស់រដ្ឋដែលត្រូវបានប្រើប្រាស់ដើម្បីសងបំណុល។ សូចនាករមួយនៃស្ថានភាពបំណុលរបស់រដ្ឋគឺចំណែកមួយនៃប្រាក់ចំណូលមូលនិធិទូទៅប្រចាំឆ្នាំរបស់រដ្ឋដែលត្រូវបានគេទុកដោយឡែកដើម្បីសងបំណុលប័ណ្ណកម្ចី។ នេះត្រូវបានគេស្គាល់ថាអនុបាតសេវាកម្ម-បំណុលរបស់រដ្ឋ (DSR)។ ដោយសារតែរដ្ឋត្រូវតែប្រើប្រាក់ចំណូលទាំងនេះដើម្បីសងបំណុល គេមិនអាចយកទៅចំណាយលើកម្មវិធីរដ្ឋផ្សេងទៀតបានទេ។ ដូចបង្ហាញក្នុងរូបភាពទី 1 DSR ឥឡូវនេះមានចំនួនលើសពី 4 ភាគរយ។ ប្រសិនបើអ្នកបោះឆ្នោតមិនអនុម័តប័ណ្ណកម្ចីណាមួយដែលបានស្នើនៅក្នុងសន្លឹកឆ្នោតនេះទេ យើងព្យាករណ៍ថា DSR របស់រដ្ឋលើប័ណ្ណកម្ចីដែលបានអនុម័តហើយនឹងកើនឡើងក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ—ខ្ពស់បំផុតត្រឹម 4.5 ភាគរយក្នុងឆ្នាំ 2021–22—ហើយបន្ទាប់មកចាប់ផ្តើមថយចុះ។ ប្រសិនបើ អ្នកបោះឆ្នោតអនុម័តសំណើប័ណ្ណកម្ចីកាតព្វកិច្ចទូទៅទាំងអស់លើសន្លឹកឆ្នោតនេះ យើងព្យាករណ៍ថាវានឹងបង្កើន DSR តិចជាង 0.5 ភាគរយ បើធៀបទៅនឹងការមិនអនុម័ត។ អនាគត DSR របស់រដ្ឋនឹងខ្ពស់ជាងការបង្ហាញនៅក្នុងតារាង ប្រសិនបើរដ្ឋ និងអ្នកបោះឆ្នោតអនុម័តប័ណ្ណកម្ចីបន្ថែម នាពេលអនាគត។

រូបភាពលេខ 1

សមាមាត្រសេវាបំណុលនៃមូលនិធិទូទៅ

ភាគរយនៃប្រាក់ចំណូលរបស់មូលនិធិទូទៅបានប្រើប្រាស់លើសេវាបំណុល



ព័ត៌មានអំពីការថ្លែងរបស់បេក្ខជន
នៅក្នុងសៀវភៅមគ្គទ្វេសក៏នេះ

សៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះរួមមានព័ត៌មានអំពីព្រឹទ្ធសភាសហរដ្ឋអាមេរិក និងបេក្ខជនការិយាល័យធម្មនុញ្ញភាពដែលចាប់ផ្តើមនៅទំព័រ 75 នៃសៀវភៅមគ្គទេសក៏នេះ។

បេក្ខជនព្រឹទ្ធសភាសហរដ្ឋអាមេរិកអាចទិញកន្លែងសម្រាប់ចុះផ្សាយសេចក្តីថ្លែងការណ៍បេក្ខជនរបស់ពួកគេនៅក្នុងសៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះ។ តែទោះជាយ៉ាងណា បេក្ខជនខ្លះជ្រើសរើសមិនទិញកន្លែងសម្រាប់ចុះផ្សាយសេចក្តីថ្លែងការណ៍ទេ។

បេក្ខជនសម្រាប់ព្រឹទ្ធសភាសហរដ្ឋអាមេរិកគឺ៖

Kevin de León	ប្រជាធិបតេយ្យ
Dianne Feinstein	ប្រជាធិបតេយ្យ

ច្បាប់រដ្ឋ California រួមបញ្ចូលទាំងដែនកំណត់នៃការចំណាយស្ម័គ្រចិត្តសម្រាប់បេក្ខជនដែលឈរឈ្មោះសម្រាប់ការិយាល័យរដ្ឋ (មិនមែនការិយាល័យសហព័ន្ធ)។ បេក្ខជនឈរឈ្មោះសម្រាប់ការិយាល័យធម្មនុញ្ញភាពទូទាំងរដ្ឋសម្រាប់តំណែងអភិបាលរដ្ឋ អភិបាលរដ្ឋរង រដ្ឋលេខាធិការ ស្នងការហិរញ្ញវត្ថុ ហិរញ្ញិក អគ្គរដ្ឋអាជ្ញា ស្នងការធានារ៉ាប់រង អ្នកមើលការខុសត្រូវលើការណែនាំសាធារណៈ និងក្រុមប្រឹក្សាភិបាលសមភាព ដែលកំណត់ការចំណាយរបស់យុទ្ធនាការពួកគេក្នុងដែនកំណត់ដែលបានបញ្ជាក់ អាចទិញទីតាំងទំនេរសម្រាប់ចុះផ្សាយសេចក្តីថ្លែងការណ៍របស់បេក្ខជនបាន (រហូតដល់ 250 ពាក្យ) ក្នុងសៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះ។

ដែនកំណត់នៃការចំណាយស្ម័គ្រចិត្តរបស់បេក្ខជនសម្រាប់តំណែងអភិបាលរដ្ឋនៅក្នុងការបោះឆ្នោតទូទៅ ថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 គឺ $14,588,000។

ដែនកំណត់ការចំណាយស្ម័គ្រចិត្តសម្រាប់បេក្ខជនសម្រាប់តំណែងអភិបាលរដ្ឋរង រដ្ឋលេខាធិការ ស្នងការហិរញ្ញវត្ថុ ហិរញ្ញិក អគ្គរដ្ឋអាជ្ញា ស្នងការធានារ៉ាប់រង អ្នកមើលការខុសត្រូវនៃការណែនាំសាធារណៈនៅក្នុងការបោះឆ្នោតទូទៅ ថ្ងៃទី 6 ខែវិច្ឆិកាឆ្នាំ 2018 គឺ $8,753,000។

ដែនកំណត់ការចំណាយស្ម័គ្រចិត្តរបស់បេក្ខជនសម្រាប់ក្រុមប្រឹក្សាភិបាលសមភាពនៅក្នុងក្នុងការបោះ ឆ្នោតទូទៅ ថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 គឺ $2,188,000។

ក្នុងបញ្ជីបេក្ខជនខាងក្រោម សញ្ញាផ្កាយ (*) ជ្រើសតំាងបេក្ខជនការិយាល័យធម្មនុញ្ញភាពទូទាំងរដ្ឋ ដែលបានទទួលដែនកំណត់ការចំណាយលើយុទ្ធនាការស្ម័គ្រចិត្ត ហើយដូច្នេះមានជម្រើសក្នុងការទិញទីតាំងទំនេរសម្រាប់ចុះផ្សាយសេចក្តីថ្លែងការណ៍របស់បេក្ខជន នៅក្នុងសៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះ។ (បេក្ខជនដែលមានលក្ខណសម្បត្តិខ្លះ ជ្រើសរើសមិនទិញទីតាំងទំនេរដើម្បីចុះផ្សាយសេចក្តីថ្លែងការណ៍ទេ។)

សេចក្តីថ្លែងការណ៍របស់បេក្ខជនសម្រាប់ការិយាល័យធម្មនុញ្ញភាពទូទាំងរដ្ឋគឺនៅទំព័រ 75–88 នៃសៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះ។

បញ្ជីឈ្មោះបេក្ខជនសម្រាប់ការិយាល័យធម្មនុញ្ញភាពទូទាំងរដ្ឋខាងក្រោមគឺជាបញ្ជីបច្ចុប្បន្ន រហូតដល់ថ្ងៃទី 13 ខែសីហា ឆ្នាំ 2018 ដែលជាថ្ងៃចុងបញ្ចប់នៃរយៈពេលបង្ហាញសាធារណៈដែលតម្រូវសម្រាប់សៀវភៅមគ្គទេសក៏អ្នកបោះឆ្នោតនេះ។ សម្រាប់បញ្ជីបេក្ខជនដែលបានបញ្ជាក់ចុងក្រោយ ដែលគឺដល់កំណត់ បន្ទាប់ពីសៀវភៅមគ្គទេសក៏នេះត្រូវបានបោះពុម្ពផ្សាយ សូមចូលទៅកាន់ *www.sos.ca.gov/elections/candidate-statements/*។

អភិបាលរដ្ឋ

John H. Cox*	សាធារណរដ្ឋ
Gavin Newsom	ប្រជាធិបតេយ្យ

អភិបាលរដ្ឋរង

Eleni Kounalakis*	ប្រជាធិបតេយ្យ
Ed Hernandez*	សាធារណរដ្ឋ

រដ្ឋលេខាធិការ

Alex Padilla*	ប្រជាធិបតេយ្យ
Mark P. Meuser*	សាធារណរដ្ឋ

ស្នងការហិរញ្ញវត្ថុ

Betty T. Yee*	ប្រជាធិបតេយ្យ
Konstantinos Roditis*	សាធារណរដ្ឋ

ហេរញ្ញិក

Greg Conlon*	សាធារណរដ្ឋ
Fiona Ma*	ប្រជាធិបតេយ្យ

អគ្គរដ្ឋអាជ្ញា

Steven C. Bailey*	សាធារណរដ្ឋ
Xavier Becerra*	ប្រជាធិបតេយ្យ

ស្នងការធានារ៉ាប់រង

Ricardo Lara*	ប្រជាធិបតេយ្យ
Steve Poizner*	គ្មានចំណូលចិត្តគណបក្ស

សមាជិកក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 1

Ted Gaines*	សាធារណរដ្ឋ
Tom Hallinan*	ប្រជាធិបតេយ្យ

សមាជិកក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 2

Malia Cohen*	ប្រជាធិបតេយ្យ
Mark Burns*	សាធារណរដ្ឋ

សមាជិកក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 3

Tony Vazquez*	ប្រជាធិបតេយ្យ
G. Rick Marshall*	សាធារណរដ្ឋ

សមាជិកក្រុមប្រឹក្សាភិបាលសមភាព មណ្ឌល 4

Mike Schaefer*	ប្រជាធិបតេយ្យ
Joel Anderson*	សាធារណរដ្ឋ

ស្នងការការអប់រំសាធារណ:

Tony K. Thurmond*	គ្មានចំណូលចិត្តគណបក្ស
Marshall Tuck*	គ្មានចំណូលចិត្តគណបក្ស

សេចក្តីថ្លែងការណ៍របស់បេក្ខជន
ព្រឹទ្ធបុរសសហរដ្ឋអាមេរិក

- បម្រើជាសមាជិកព្រឹទ្ធសភាមួយរូបក្នុងចំណោមពីររូប ដែលតំណាងឱ្យផលប្រយោជន៍របស់រដ្ឋ California នៅក្នុងសភារបស់សហរដ្ឋអាមេរិក។
- ដាក់ស្នើ និងបោះឆ្នោតលើច្បាប់ជាតិថ្មី។
- ការបោះឆ្នោតលើការបញ្ជាក់ទទួលយកចៅក្រមសហព័ន្ធ ចៅក្រមតុលាការជាន់ខ្ពស់របស់សហរដ្ឋអាមេរិក និងការតែងតាំងកម្រិតខ្ពស់ររបស់ប្រធានាធិបតីជាច្រើនចំពោះមុខតំណែងស៊ីវិលនិងយោធា។

Kevin de León | ប្រជាធិបតេយ្យ

ខ្ញុំមានកិត្តិយសជាបេក្ខជនដែលបានគាំទ្រដោយគណបក្សប្រជាធិបតេយ្យរដ្ឋ California សម្រាប់ ព្រឹទ្ធសភាសហរដ្ឋអាមេរិក។ លោកប្រធានាធិបតេយ្យមានទំនោរជ្រុលទៅរកការបំបែកបំបាក់ប្រជាជនរបស់យើង និងបន្ទាបបន្ថោកភាពប្រពៃនៃរដ្ឋ California របស់យើង។ ការអនុវត្តដដែលៗរបស់ Washington គឺដោយសារមានឆន្ទៈ ឬអសមត្ថភាពក្នុងការប្រឆាំងតប។ ពលរដ្ឋកាលីហ្វូញ៉ាសមទទួលបានសមាជិកព្រឹទ្ធសភាពមួយរូបដែលមានមហិច្ឆតា និងឯករាជ្យភាព ហ៊ានប្រឆាំងដើម្បីអនាគតរបស់ពួកគេ។ ដូចមនុស្សជាច្រើនដែលកំពុងព្យាយាមសម្រេចក្តីសុបិន្តអាមេរិករបស់ពួកគេ ខ្ញុំយល់ថាគ្មានអ្វីដែលគេប្រគល់ឱ្យអ្នកដោយឯកឯងនោះទេ។ មានតែនៅក្នុងប្រទេសអាមេរិកប៉ុណ្ណោះដែលកូនប្រុសអ្នកសម្អាតផ្ទះអន្តោប្រវេសន៍ម្នាក់ដូចរូបខ្ញុំអាចធំឡើងដឹកនាំព្រឹទ្ធសភារដ្ឋ California បាន។ ខ្ញុំមានបទពិសោធន៍ជីវិតដូចអ្នកដែរ—ដោយតស៊ូបង់ថ្លៃផ្ទះ បារម្ភអំពីថ្លៃសិក្សាមហាវិទ្យាល័យ និងបង់ថ្លៃលើការថែទាំសុខភាព។ វាជាការតស៊ូដែលអ្នកនយោបាយក្រុង Washington DC តិចតួចណាស់យល់។ ដោយមានសេដ្ឋីពីភាគបីកាន់កាប់ព្រឹទ្ធសភា វាងាយយល់ទេថាហេតុអ្វីបានជាពួកគេមិនយល់ពីការលំបាកប្រចាំថ្ងៃរបស់ពលរដ្ឋអាមេរិកនោះ។ ទោះបីជាវោហារសាស្ត្ររបស់ពួកគេយ៉ាងណាក៏ដោយ ពួកប្រជាធិបតេយ្យក្រុង Washington DC មិនមានឆន្ទៈអនុវត្ត *Medicare-for-all* និងការប្រែប្រួលអាកាសធាតុទេ ដោយសារពួកគេក្រឹងរអាន៖ក្រុមអ្នកបញ្ចុះបញ្ចូលមកពីក្រុមហ៊ុនប្រេង និងក្រុមហ៊ុនថ្នាំ។ ក្នុងនាមជាប្រធានព្រឹទ្ធសភារដ្ឋ California ខ្ញុំមិនដែលគិតពីបញ្ហាតូចតាចឡើយ។ ខ្ញុំប្រឆាំងតបនឹងក្រុមហ៊ុនធានារ៉ាប់រងធំៗ ដោយតស៊ូដើម្បីផ្តល់ការថែទាំសុខភាពសម្រាប់អ្នករាល់គ្នា។ ខ្ញុំបានប្រយុទ្ធប្រឆាំងនឹង *ការដំឡើងពន្ធរបស់លោក Trump* ដើម្បីការពារពលរដ្ឋដែលមានចំណូលមធ្យម ជម្រុញគោលនយោបាយសិក្សានៅមហាវិទ្យាលើតតបង់ថ្លៃ *សមភាពប្រាក់ឈ្នួល សិទ្ធិជនអន្តោប្រវេសន៍ និងសិទ្ធិស៊ីវិល*ព្រមទាំងបានធ្វើឱ្យរដ្ឋ California ជាអ្នកដឹកនាំពិភពលោកមួយក្នុង ការ *ប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ*។ យើងត្រូវការភាពជាអ្នកដឹកនាំក្លាហាននៅក្នុងព្រឹទ្ធសភា ដើម្បីដឹកនាំប្រទេសនេះលើវិថីដ៏ត្រឹមត្រូវ ដោយមានសេដ្ឋកិច្ចមួយដែលដំណើរការសម្រាប់ពួកយើងទាំងអស់គ្នា មិនមែនសម្រាប់តែអ្នកមានឡើយ។ ខ្ញុំនឹងនាំយកភាពជាអ្នកដឹកនាំរបស់រដ្ឋ California ដែលមានការបញ្ជាក់ទៅកាន់ ព្រឹទ្ធសភាសហរដ្ឋអាមេរិក។

3605 Long Beach Blvd.
Ste. 426
Long Beach, CA 90807

ទូរស័ព្ទ៖ (818) 850-6462
អ៊ីម៉ែល៖ Kevin@KevindeLeon.com
www.KevindeLeon.com
https://twitter.com/Kdeleon

Dianne Feinstein | ប្រជាធិបតេយ្យ

ក្នុងនាមជាសមាជិកព្រឹទ្ធរដ្ឋ California ខ្ញុំប្រឹងប្រែងធ្វើការជារៀងរាល់ថ្ងៃដើម្បីធ្វើជាសំឡេងដ៏រឹងមាំ និងមានប្រសិទ្ធភាពសម្រាប់គុណតម្លៃវឌ្ឍនភាពនៃរដ្ឋរបស់យើង ហើយខ្ញុំមានមោទនភាពដែលបានឈ្នះ ការបោះឆ្នោតបឋមក្នុង California ដោយទទួលបានសម្លេង 70% នៃសន្លឹកឆ្នោតប្រជាធិបតេយ្យ។ ខ្ញុំជាអ្នកគាំទ្រឥតងាករេចំពោះគោលនយោបាយថែទាំសុខភាពជាសាកល សិទ្ធិស្ត្រី សិទ្ធិបុគ្គលភេទទីបី និងអ្នកប្តូរភេទ (lesbian, gay, bisexual, transgender, and queer LGBTQ) និងសិទ្ធិរបស់ជនអន្តោប្រវេសន៍។ ខ្ញុំបានប្រឆាំងសមាគមកាំភ្លើងជាតិ (NRA) ដើម្បីបំបាត់អាវុធចេញពីដងផ្លូវរបស់យើង តស៊ូប្រឆាំងដើម្បីសមភាពប្រាក់ឈ្នួលវត្សសម្រាប់ស្ត្រី និងគាំទ្រច្បាប់ការពារ Dreamers និងបញ្ចប់គោលនយោបាយសាហាវយង់ឃ្នងនៃការបំបែកកូនៗចេញពីឪពុកម្តាយរបស់ពួកគេនៅព្រំដែន។ ខ្ញុំបានការពារឱកាសសេដ្ឋកិច្ចដែលលើកកម្ពស់ពលរដ្ឋ California ទាំងអស់ ជាពិសេសគ្រួសារធ្វើការដែលតស៊ូក្នុងសេដ្ឋកិច្ចសព្វថ្ងៃនេះ។ ខ្ញុំប្រឆាំងយ៉ាងខ្លាំងជំទាស់នឹងលោក Donald Trump និងរបៀបវារៈរបស់គាត់ដែលបំបែកប្រជាជាតិរបស់យើង និងបន្ថយសម្ព័ន្ធមិត្តរបស់យើងនៅជុំវិញពិភពលោក។ ខ្ញុំបានជួយយកជ័យជម្នះលើការខិតខំរបស់ក្រុមសាធារណរដ្ឋ ក្នុងការធ្វើនិរាករណ៍ និងធ្វើឱ្យខូចដល់ច្បាប់ Affordable Care ។ ក្នុងនាមជាសមាជិកគណបក្សប្រជាធិបតេយ្យដែលមានដំណែងនៅក្នុងគណៈកម្មការយុត្តិធម៌របស់ព្រឹទ្ធសភា ខ្ញុំបានជំទាស់យ៉ាងខ្លាំងក្លានឹងការតែងតាំងចៅក្រមដែលមានទំនោរជ្រុលនិយមរបស់លោក Trump។ ខ្ញុំកំពុងប្រយុទ្ធប្រឆាំងដើម្បីការពារស្ត្រីនៅកន្លែងធ្វើការ និងបានអនុម័តច្បាប់មួយក្នុងឆ្នាំនេះដែលការពារអត្តពលិកស្ត្រីវ័យក្មេង និងអត្តពលិកមិនមែនអាជីពដទៃទៀត ពីអ្នករំលោភបំពានផ្លូវភេទ។ ហើយខ្ញុំនឹងបន្តប្រឆាំង និងបញ្ឈប់ររបៀបវារៈប្រឆាំងនឹងបរិស្ថានដ៏ងងើលកំព្រើសរបស់លោក Trump ដែលរួមមានការបដិសេធការប្រែប្រួលអាកាសធាតុ ការវាយប្រហាររបស់គាត់លើតំបន់ការពាររបស់រដ្ឋ California និងការគម្រាមកំហែងរបស់គាត់ក្នុងការផ្តល់ការអនុញ្ញាតឱ្យខួងយកប្រេងក្នុងតំបន់ឆ្នេរ រដ្ឋ California។ ដោយបានការគាំទ្រពីលោកប្រធានាធិបតី Barack Obama និងព្រឹទ្ធសមាជិក Kamala Harris ខ្ញុំស្នើសុំការបោះឆ្នោតគាំទ្ររបស់អ្នក ដើម្បីឱ្យខ្ញុំអាចបន្តក្រោកឈរតស៊ូសម្រាប់ រដ្ឋ California ក្នុងពេលដ៏មានឧបសគ្គនេះ។

P.O. Box 1270
Los Angeles, CA 90078

ទូរស័ព្ទ៖ (866) 747-2981
អ៊ីមែល៖ contact@feinsteinforca.com
www.feinsteinforca.com
Facebook.com/DianneFeinstein

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ថ្លៃដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញឈ្មោះនៅលើសន្លឹកឆ្នោតដែរ។

សេចក្តីថ្លែងការណ៍របស់បេក្ខជន
អភិបាលរដ្ឋ

- ក្នុងនាមជានាយកប្រតិបត្តិរបស់រដ្ឋ ដែលត្រួតពិនិត្យលើក្រសួង និងភ្នាក់ងាររដ្ឋភាគច្រើន និងតែងតាំងចៅក្រម។
- ស្នើច្បាប់ថ្មី អនុម័តច្បាប់ និងធ្វើមោឃភាពច្បាប់ ដាក់ស្នើថវិកាប្រចាំឆ្នាំរបស់រដ្ឋទៅសភា។
- ប្រមូលផ្តុំ និងគ្រប់គ្រងធនធានរបស់រដ្ឋក្នុងគ្រាអាសន្ន។

John H. Cox | សាធារណរដ្ឋ

ខ្ញុំមិននឹកស្មានថាធ្វើខ្ញុំឈានចូលដល់ការប្រកួតចុងក្រោយសម្រាប់តំណែងអភិបាលរដ្ឋនេះទេ។ ខ្ញុំគ្មានចំណែករួមក្នុងថ្នាក់អ្នកនយោបាយ មិនបានកើតក្នុងគ្រួសារអ្នកមាន គ្មានគ្រួសារដែលមានទំនាក់ទំនងនយោបាយឡើយ។ ខ្ញុំឈ្មោះ John Cox ហើយខ្ញុំគិតពីអ្វីដែលថ្នាក់អ្នកនយោបាយបានធ្វើចំពោះពលរដ្ឋដែលធ្វើការនៅក្នុងរដ្ឋ California គឺជាបទល្មើសមួយ។ ពួកគេបានរៀបចំល្បែង ផ្តោះប្តូរអត្ថប្រយោជន៍ និងបង្កើនធនធានរបស់ពួកគេ ខណៈពេលដែលពលរដ្ឋ កាលីហ្វូញ៉ារាប់លាននាក់ត្រូវបានបំភ្លេចចោល និងមិនត្រូវបានគេខ្វល់ខ្វាយ។ យើងត្រូវបង់តម្លៃប្រេង និងថ្លៃយានយន្តខ្ពស់កប់ពពក ជាមួយអត្រាភាពក្រីក្រខ្ពស់បំផុតក្នុងប្រទេសនេះ។ មនុស្សរាប់លាននាក់ធ្វើដំណើរទៅមកដើម្បីធ្វើការក្នុងទីក្រុងដែលគេស្រលាញ់ ប៉ុន្តែគេមិនមានលទ្ធភាពរស់នៅក្នុងទីក្រុងនេះបាន។ ដូច្នេះ ពួកគេត្រូវធ្វើដំណើរទៅមកលើផ្លូវដែលមានចរាចរជាប់គាំង។ ពួកគេបញ្ជូនកូនៗរបស់ពួកគេទៅរៀននៅសាលាដែលកំពុងត្រដាបត្រដួស។ អ្នកនយោបាយទីក្រុង Sacramento បែងចែកទឹកតាមផ្ទះរបស់យើង ប៉ុន្តែកំពុងធ្វើឱ្យខ្សោះប្រភពផ្ត់ផ្គង់ទឹកដ៏សំបូររបស់យើងទៅក្នុងមហាសមុទ្រ។ មិត្តភក្តិ និងគ្រួសាររបស់យើងកំពុងផ្លាស់ទីចេញពីរដ្ឋ California មិនមែនដោយសារតែពួកគេចង់ទេ ប៉ុន្តែដោយសារតែពួកគេត្រូវតែចាកចេញ។ សម្រាប់ពលរដ្ឋ California ជាច្រើនលើសលប់ វាគឺជាជម្រើស រវាងការចាក់សាំងដើម្បីទៅជិះធ្វើការ និងការទិញម្ហូបសម្រាប់គ្រួសារ។ នោះគឺជាជម្រើសមួយដែលគ្មាននរណាម្នាក់ក្នុងចំណោមពួកគេគួរតែត្រូវធ្វើឡើយ។ ដំណឹងល្អគឺថា យើងមិនចាំបាច់ទទួលយកស្ថានភាពនេះទេ *ព្រោះយើងនឹងមានជំនួយក្នុងពេលឆាប់ៗនេះ*។ យើងអាចបញ្ឈប់ការបែងចែកទឹក លប់ចោលពន្ធប្រេង ជួសជុលសាលារៀនរបស់យើង និងធ្វើឱ្យលំនៅដ្ឋានមានតម្លៃសមរម្យឡើងវិញ ប៉ុន្តែទាល់តែយើងមានឆន្ទៈធ្វើឱ្យអ្នកដឹកនាំនយោបាយរបស់យើងមានគណនីយភាព។ ខ្ញុំឈ្មោះ John Cox ហើយខ្ញុំចង់ក្លាយជាអភិបាលរដ្ឋ *របស់អ្នក* ។

អ៊ីមែល៖ info@JohnCoxforGovernor.com
JohnCoxforGovernor.com
Twitter: @TheRealJohnHCox

Gavin Newsom | ប្រជាធិបតេយ្យ

គ្មានសេចក្តីថ្លែងការណ៍របស់បេក្ខជន

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ថ្លៃដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញឈ្មោះនៅលើសន្លឹកឆ្នោតដែរ។

សេចក្តីថ្លែងការណ៍របស់បេក្ខជន
អភិបាលរដ្ឋរង

- ចូលកាន់ដំណែង និងទទួលភារកិច្ចជាអភិបាលរដ្ឋ ក្នុងករណីមានការស្នើដកហូតដំណែង ការស្លាប់ ការលាចាកពីតំណែង ការដកចេញពីដំណែង ឬអវត្តមានពីរដ្ឋ។
- បម្រើជាប្រធានព្រឹទ្ធសភារបស់រដ្ឋ និងមានសម្លេងឆ្នោតសម្រេច សម្រាប់បំបែកសំលេងឆ្នោតស្មើគ្នា។
- ជាប្រធានគណៈកម្មការអភិវឌ្ឍន៍សេដ្ឋកិច្ច ជាសមាជិកនៃគណៈកម្មាធិការដីធ្លីរបស់រដ្ឋនិងក្រុមប្រឹក្សាការពារមហាសមុទ្រ និងជាសមាជិកគណៈកម្មការនាយកនៃប្រព័ន្ធសាកលវិទ្យាល័យរដ្ឋ California។

Eleni Kounalakis | ប្រជាធិបតេយ្យ

ខ្ញុំជាស្ត្រីអ្នកជំនួញ ជាម្តាយ និងជាអតីតឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ក្រោមប្រធានាធិបតី Obama។ ខ្ញុំកំពុងឈរឈ្មោះសម្រាប់ដំណែងអភិបាលរដ្ឋរងដើម្បីការពារតម្លៃនៃភាពសម្រុះ និងឱកាសរបស់រដ្ឋ California ពីព្រោះវាជាអ្វីដែលដំណើរការសេដ្ឋកិច្ចរបស់យើង។ ខ្ញុំមានមោទភាពដែលបានទទួលការគាំទ្រដោយ *ព្រឹទ្ធសមាជិក Kamala Harris ព្រឹទ្ធសមាជិក Dianne Feinstein សម្ព័ន្ធអ្នកបោះឆ្នោតអភិរក្សនិយមរដ្ឋ California អង្គការជាតិសម្រាប់ស្ត្រី និងសហព័ន្ធគ្រូបង្រៀនរដ្ឋ California*។ ក្នុងនាមជាកូនស្រីជនអន្តោប្រវេសន៍ និងជានិស្សិតបញ្ចប់ការសិក្សាពីមហាវិទ្យាល័យដំបូងគេក្នុងគ្រួសាររបស់ខ្ញុំ ខ្ញុំនឹងប្រយុទ្ធប្រឆាំងសម្រាប់ការអប់រំដែលមានតម្លៃទាប ដោយ *ជំទាស់នឹងការដំឡើងថ្លៃសិក្សា* នៅសាកលវិទ្យាល័យ UCs សាកលវិទ្យាល័យ CSUs និងមហាវិទ្យាល័យសហគមន៍របស់យើង។ ខ្ញុំនឹងធ្វើការដើម្បីផ្លាស់ប្តូរវប្បធម៌នយោបាយក្រុង Sacramento ដើម្បី *បញ្ឈប់ការវាយរំលោភផ្លូវភេទ* នៅកន្លែងធ្វើការគ្រប់ទីកន្លែង ធ្វើឱ្យជនដែលប្រព្រឹត្តិបទល្មើសទទួលខុសត្រូវចំពោះទង្វើរបស់ពួកគេ និងធានាថា *ស្ត្រីទទួលបានសមភាពប្រាក់ឈៀវត្ស* សម្រាប់សមភាពការងារ។ ក្នុងនាមជាឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ខ្ញុំបានធ្វើដំណើរ ជាមួយយោធារបស់យើង និងដឹងថាការលើកកម្ពស់ប្រជាធិបតេយ្យនៅក្រៅប្រទេសមានន័យថាជា *ការគាំទ្រអតីតយុទ្ធជនរបស់យើង* នៅពេលពួកគេត្រឡប់មកប្រទេសកំណើតវិញ។ ខ្ញុំមានជំនឿលើគុណភាព *ការថែទាំកុមារដែលមានតម្លៃទាប* និង *ការថែទាំសុខភាពសាកល*។ ខ្ញុំនឹងធ្វើជាប្រធានគណៈកម្មការដីធ្លីរដ្ឋ និងតស៊ូប្រឆាំងនឹងផែនការរបស់លោក Donald Trump ដែលបើក សមុទ្រ California សម្រាប់ការខួងប្រេងបន្ថែមក្នុងដែនឆ្នេរសមុទ្ររបស់យើង។ ក្នុងនាមជាស្ត្រីអ្នកជំនួញ ខ្ញុំបានកសាងគម្រោងហេដ្ឋារចនាសម្ព័ន្ធធំៗ បានបង្កើតការងារនានាសម្រាប់ពលរដ្ឋកាលីហ្វូញ៉ា និងបានផ្តល់ជូនលំនៅដ្ឋានដែលមានតម្លៃសមរម្យសម្រាប់គ្រួសារដែលធ្វើការ។ ខ្ញុំយល់ថាយើងត្រូវតែកសាងសេដ្ឋកិច្ចមួយដែលលើកកម្ពស់ពលរដ្ឋកាលីហ្វូញ៉ា ទាំងអស់ និងការពារក្តីសុបិន្តថ្មអាមេរិករបស់ពួកគេ។ *ខ្ញុំបានធ្វើដំណើរការទៅគ្រប់ទាំង 58 ខោនធី* និងបានឮរឿងរ៉ាវរបស់អ្នក។ ខ្ញុំនឹងនៅ ស្តាប់ សំឡេងរបស់ពលរដ្ឋកាលីហ្វូញ៉ាទាំងអស់ជានិច្ច។ សូមអរគុណអ្នកសម្រាប់ការពិចារណា និងការបោះឆ្នោតគាំទ្ររបស់អ្នក។

916 Kearny St. #605
San Francisco, CA 94104

ទូរស័ព្ទ៖ (415) 857-0921
អ៊ីមែល៖ info@eleniforca.com
www.EleniforCA.com
@eleniforca

Ed Hernandez | ប្រជាធិបតេយ្យ

Dr. Ed Hernandez ជាព្រឹទ្ធសមាជិករបស់រដ្ឋ និងជាអ្នកជំនួញថ្នាក់តូច កំពុងឈរឈ្មោះសម្រាប់តំណែងអភិបាលរដ្ឋរងក្នុងការពង្រីកការទទួលសេវាថែទាំសុខភាព កាត់បន្ថយតម្លៃថ្នាំពេទ្យ ការពារគ្រួសារដែលធ្វើការ ការពារបរិស្ថានរបស់យើង និងធ្វើឱ្យការអប់រំឧត្តមសិក្សាកាន់តែទូលំទូលាយ និងកាន់តែមានតម្លៃសមរម្យ ។ ជាឪពុក និងជាជីតាម្នាក់ លោក Hernandez បានចំណាយពេលវេលាក្នុងជីវិតរបស់គាត់ដើម្បីបំពេញតម្រូវការថែរក្សាសុខភាពសហគមន៍របស់គាត់ ដោយនាំយកសេវាថែទាំភ្នែកប្រកបដោយសាគុណភាពជូនដល់គ្រួសារដែលធ្វើការនៅតំបន់ San Gabriel Valley។ ជាចៅប្រុសរបស់ជនអន្តោប្រវេសន៍ លោក Hernandez បានធំធាត់នៅក្នុងសហគមន៍អ្នកធ្វើការក្នុងខោនធី L.A. ដែលបានខិតខំបញ្ចប់ការសិក្សាមហាវិទ្យាល័យ និងបានកសាងអាជីវកម្មបែបគ្រួសារថ្នាក់តូចដ៏ជោគជ័យមួយជាមួយប្រពន្ធរបស់គាត់។ ក្នុងនាមជាអ្នកផ្តល់សេវាថែទាំសុខភាព ព្រឹទ្ធសមាជិក Hernandez បានដឹកនាំការតស៊ូដើម្បីធ្វើឱ្យការថែទាំសុខភាពកាន់តែមានតម្លៃសមរម្យ និងកាន់តែទូលំទូលាយ ដោយអនុម័តច្បាប់សំខាន់ៗ ដែលបង្ក្រាបក្រុមហ៊ុនឱសថធំៗ ដែលបានដំឡើងថ្លៃថ្នាំពេទ្យ តាមរយៈការបង្កើតច្បាប់តម្លាភាពថ្មីដើម្បីកាត់បន្ថយតម្លៃឱសថ។ ក្នុងនាមជា អ្នកដឹកនាំព្រឹទ្ធសភារបស់រដ្ឋ លោក Hernandez បានជួយអនុម័តច្បាប់ផ្សេងៗដើម្បីការពារការទទួលបានខ្យល់ស្អាត និងទឹកស្អាត បង្កើនមូលនិធិសម្រាប់សាលារៀន និងកម្មវិធីអប់រំអាជីព និងផ្តល់នូវការសិក្សាក្នុងមហាវិទ្យាល័យសហគមន៍រយៈពេលមួយឆ្នាំដោយឥតគិតថ្លៃ។ ជាសមាជិកព្រឹទ្ធសភារបស់រដ្ឋ លោក Ed Hernandez ក៏ជួយដឹកនាំកិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ចប់វប្បធម៌ស្ងប់ស្ងាត់របស់ Sacramento ដើម្បីការពារមនុស្សពីការរំលោភបំពានផ្លូវភេទ ចាប់ខ្លួនអ្នករំលោភបំពាន និងដកជនល្មើសពីមុខតំណែង។ លោក Hernandez ត្រូវបានគាំទ្រដោយ គ្រូបង្រៀន អ្នកពន្លត់អគ្គីភ័យប៉ូលីស គិលានុបដ្ឋាយិកា អង្គការភាពជាឪពុកម្តាយដែលបានគ្រោងទុក (Planned Parenthood) ស្នងការហិរញ្ញវត្ថុរបស់រដ្ឋ Betty Yee និងអគ្គរដ្ឋអាជ្ញា Xavier Becerra របស់រដ្ឋ California ដោយសារតែពួកដឹងថា គាត់នឹងតស៊ូដើម្បីក្រុមគ្រួសារ ប្រឆាំងនឹងក្រុមសាជីវកម្មដែលមានផលប្រយោជន៍ពិសេស។ បោះឆ្នោតជូនព្រឹទ្ធសមាជិក Ed Hernandez ឱ្យធ្វើអភិបាលរដ្ឋរងរបស់រដ្ឋ California។

អ៊ីមែល៖ info@edhernandez4ca.com
www.edhernandez4ca.com

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឈ្មោះព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ថ្លៃដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញឈ្មោះនៅលើសន្លឹកឆ្នោតដែរ។

សេចក្តីថ្លែងការណ៍របស់បេក្ខជន
រដ្ឋលេខាធិការ

- ក្នុងនាមជាមន្ត្រីរៀបចំការបោះឆ្នោតប្រមុខរបស់រដ្ឋ ត្រួតពិនិត្យការបោះឆ្នោតទូទាំងរដ្ឋ និងផ្តល់លទ្ធភាពដល់សាធារណៈជនឱ្យទទួលបានព័ត៌មានស្តីពីយុទ្ធនាការ និងព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមអ្នកបញ្ចុះបញ្ចូល។
- ថែរក្សាឯកសារអាជីវកម្ម បញ្ជាក់ភាពត្រឹមត្រូវនៃនិមិត្តសញ្ញាកំណត់បញ្ញត្តិសារការនិងអនុញ្ញាតឱ្យម្ចាស់បំណុលដែលមានការធានាការពារផលប្រយោជន៍ហិរញ្ញវត្ថុរបស់ពួកគេ។
- ការពារប្រវត្តិសាស្ត្ររបស់រដ្ឋ California តាមរយៈការទិញ ការការពារ និងការចែករំលែករតនសម្បត្តិប្រវត្តិសាស្ត្ររបស់រដ្ឋ។

Alex Padilla | ប្រជាធិបតេយ្យ

ខ្ញុំកំពុងឈរឈ្មោះដើម្បីបន្តបម្រើការជារដ្ឋលេខាធិការបស់អ្នក។ នេះគឺជាពេលវេលាដ៏សំខាន់ខ្លាំងណាស់សម្រាប់សិទ្ធិបោះឆ្នោត ហើយខ្ញុំមានប្រវត្តិច្បាស់លាស់ដែលបង្ហាញអំពីការសម្រេចបានលទ្ធផល។ ក្នុងអាណត្តិដំបូងរបស់ខ្ញុំ ខ្ញុំបានធ្វើការដើម្បីពង្រីកសិទ្ធិចូលទៅកាន់ប្រអប់ឆ្នោត ការពារសន្តិសុខការបោះឆ្នោតរបស់យើង ហើយ *ដោយសារតែការងាររបស់ខ្ញុំ រដ្ឋ California ឥឡូវនេះគឺកំពុងបន្ថែមអ្នកបោះឆ្នោតរាប់លានអ្នកដែលមានសិទ្ធិទៅក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតរបស់ខ្លួន*។ រដ្ឋលេខាធិការរបស់យើងត្រូវតែផ្តល់ជូនសម្រាប់ពលរដ្ឋកាលីហ្វូញ៉ា។ *ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលក្រុង Los Angeles ជាព្រឹទ្ធសមាជិករបស់រដ្ឋ និងជារដ្ឋលេខាធិការរបស់អ្នក ខ្ញុំបានធ្វើកិច្ចការទាំងអស់*នោះ។ ខ្ញុំសុំសន្លឹកឆ្នោតដោយអ្នកដោយសេចក្តីគោរព។ ចូលមើល
Alex-Padilla.com ដើម្បីស្វែងរយល់បន្ថែម។

777 South Figueroa Street,
Suite 4050
Los Angeles, CA 90017

ទូរស័ព្ទ៖ (213) 452-6565
អ៊ីម៉ែល៖ alex@alex-padilla.com
www.alex-padilla.com
@alexpadilla4ca

Mark P. Meuser | សាធារណរដ្ឋ

ការបោះឆ្នោតសំខាន់។ ថ្មីៗនេះ គម្រោងសុចរិតភាពការបោះឆ្នោតរដ្ឋ California បានដាក់បណ្តឹងមួយ ដែលពួកគេបានអះអាងថារដ្ឋ California មានអ្នកបោះឆ្នោតដែលបានចុះបញ្ជីច្រើនជាងអ្នកបោះឆ្នោតដែលមានសិទ្ធិ បើនិយាយឱ្យជាក់លាក់គឺ 101%។ *ខោនធី Los Angeles មានការចុះបញ្ជីអ្នកបោះឆ្នោតដល់ទៅ 144%*។ ការបំប៉ោងបញ្ជីឈ្មោះអ្នកបោះឆ្នោតបានចំណាយប្រាក់អ្នកបង់ពន្ធលើការបញ្ជូនសំភារៈបោះឆ្នោតដែលមិនចាំបាច់។ ពួកគេក៏បង្កើនឱកាសសម្រាប់ការលួចបន្លំផងដែរ។ យើងត្រូវដកឈ្មោះចេញពីអ្នកដែលបានស្លាប់ អ្នកផ្លាស់ទីលំនៅ អ្នកដែលមិនមែនជាពលរដ្ឋ ឈ្មោះជាន់គ្នា និងការចុះឈ្មោះក្លែងក្លាយចេញពីបញ្ជី។ ការបោះឆ្នោតគឺសំខាន់ណាស់ដើម្បីឱ្យពលរដ្ឋកាលីហ្វូញ៉ា អាចប្រាប់ដល់រដ្ឋាភិបាលរបស់យើងអំពីរបៀបគ្រប់គ្រងដែលយើងចង់បាន។ ការបោះឆ្នោតដោយយុត្តិធម៌ចាប់ផ្តើមជាមួយនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតត្រឹមត្រូវ ដែលមានតែអ្នកដែលមានសិទ្ធិបោះឆ្នោតប៉ុណ្ណោះត្រូវបានចុះឈ្មោះ។ *លេខាធិការរបស់រដ្ឋទទួលខុសត្រូវក្នុងការរក្សាបញ្ជីឈ្មោះបោះឆ្នោតទាំងនេះ*។ ប្រសិនបើបញ្ជីឈ្មោះនៅតែមានចំនួនលើសលប់ ក្រុមមានផលប្រយោជន៍ពិសេសអាចប្រើលុយ និងឥទ្ធិពលជ្រើសរើស ទិញ និងបង់លុយឱ្យអ្នកនយោបាយ។ ជារៀងរាល់ថ្ងៃ ខ្ញុំឮរឿងរ៉ាវផ្ទាល់របស់ពលរដ្ឋ California ដែលឃើញអ្នកបោះឆ្នោតមិនមែនជាពលរដ្ឋបានបោះឆ្នោត ឬបានដឹងថាសាច់ញាតិដែលបានស្លាប់ហើយបានបោះឆ្នោត។ ខ្ញុំជាពលរដ្ឋដើមរដ្ឋ California ដែលប្រកាន់ខ្ជាប់ការអនុវត្តច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់បោះឆ្នោត។ ពេលខ្ញុំឃើញភាពអយុត្តិធម៌ ខ្ញុំក្រោកឈរគាំទ្រហើយជួយអ្នកដែលត្រូវការជំនួយ។ ខ្ញុំបានប្រយុទ្ធដើម្បីសិទ្ធិជនពិការ និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់និស្សិតមហាវិទ្យាល័យ ហើយខ្ញុំបានឈ្នះ។ ឥឡូវនេះខ្ញុំសុំឱ្យអ្នកបោះឆ្នោតឱ្យខ្ញុំដើម្បីសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលត្រូវបានគេបំប៉ោង របស់រដ្ឋ California។ ខ្ញុំនឹងប្រើបច្ចេកវិទ្យា និងសំណុំទិន្នន័យដើម្បីសម្អាតបញ្ជីឈ្មោះអ្នកបោះឆ្នោត ដើម្បីទប់ស្កាត់សម្លេងឆ្នោតខុសច្បាប់ធ្វើឱ្យខូចសម្លេងឆ្នោតរបស់យើង។ *ការបោះឆ្នោតសំខាន់*។

2 Civic Center, #4338
San Rafael, CA 94913

ទូរស័ព្ទ៖ (208) 763-8737
អ៊ីមែល៖ contact@markmeuser.com
www.markmeuser.com
www.facebook.com/markpmeuser

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឈ្មោះព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ថ្លៃដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញឈ្មោះនៅលើសន្លឹកឆ្នោតដែរ។

សេចក្តីថ្លែងការណ៍របស់បេក្ខជន
ស្នងការហិរញ្ញវត្ថុ

- ក្នុងនាមជាមន្ត្រីសារពើពន្ធប្រមុខរបស់រដ្ឋ ប៉ម្រើការជាគណនេយ្យករ និងជាអ្នកកត់ត្រាបញ្ជីគណនេយ្យសម្រាប់មូលនិធិសាធារណៈទាំងអស់របស់រដ្ឋ។
- គ្រប់គ្រងប្រព័ន្ធប្រាក់ខែ និងច្បាប់ស្តីពីអចលនទ្រព្យដែលមិនទាន់បានជាកម្មសិទ្ធិ ព្រមទាំងធ្វើសវនកម្ម និងពិនិត្យមើលប្រតិបត្តិការរបស់រដ្ឋ។
- ជាសមាជិកក្រុមប្រឹក្សាភិបាលពន្ធដារស្នើរភាពរដ្ឋ ក្រុមប្រឹក្សាភិបាលគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលនិងគណៈកម្មការដទៃទៀត។

Betty T. Yee | ប្រជាធិបតេយ្យ

សូមអរគុណចំពោះបុព្វសិទ្ធិ និងឱកាសធ្វើជាស្នងការហិរញ្ញវត្ថុរដ្ឋដែលជាអ្នកឃ្លាំមើលសារពើពន្ធឯករាជ្យរបស់រដ្ឋ California។ ខ្ញុំមានមោទនភាពចំពោះសមិទ្ធផលរបស់ការិយាល័យខ្ញុំ ក្នុងអាណត្តិដំបូងរបស់ខ្ញុំ ដែលបានការពារចំណូលពន្ធរបស់យើង៖ គ្រប់គ្រងសាច់ប្រាក់របស់រដ្ឋប្រកបដោយប្រសិទ្ធិភាព ជៀសវាងការខ្ចីប្រាក់ពីខាងក្រៅដើម្បីទូទាត់វិក្ក័យបត្ររដ្ឋ California រកឃើញប្រាក់នៃមូលនិធិសាធារណៈជិត $4 ពាន់លានដែលបានប្រើប្រាស់ផ្សេងៗដោយគ្មានការអនុញ្ញាតិក្នុងអំឡុងពេលសវនកម្មស្ថាប័នរដ្ឋ និងស្ថាប័នមូលដ្ឋាន ធ្វើឱ្យប្រើសើឡើងនូវការធ្វើរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលថ្នាក់រដ្ឋ នឹងរដ្ឋាភិបាលមូលដ្ឋានដើម្បីបង្កើនតម្លាភាព និងធ្វើកំណែទម្រង់ដោយជោគជ័យនូវក្រុមប្រឹក្សាភិបាលពន្ធដាររដ្ឋ ដើម្បីធានាឱ្យមានការអនុវត្តន៍ដូចគ្នានៃច្បាប់ពន្ធរដ្ឋ និងការការពារសិទ្ធិរបស់អ្នកបង់ពន្ធ។ ទាក់ទងទៅនឹងការងារគោលនយោបាយរបស់ខ្ញុំក្នុងក្រុមប្រឹក្សា និងគណៈកម្មការជាច្រើន ខ្ញុំផ្តោតសំខាន់លើការផ្តល់សន្តិសុខ សោធននិវត្តន៍ដល់អ្នកធ្វើការវិស័យសាធារណៈ និងឯកជន និងការការពារបរិស្ថានដើម្បីគាំទ្រសិទ្ធិទទួលបានការប្រើប្រាស់ដីទំនេរសាធារណៈ និងឆ្នេរសមុទ្រ និងដើម្បីដោះស្រាយផលប៉ះពាល់សហគមន៍ពីគុណភាពខ្យល់ និងការកើនឡើងកម្រិតទឹកសមុទ្រ។ ដោយសម្លឹងឆ្ពោះទៅមុខ ខ្ញុំនឹងបន្តត្រៀមរដ្ឋ California សម្រាប់ឱនភាពសេដ្ឋកិច្ចណាមួយនាពេលខាងមុខ ក៏ដូចជាធ្វើជាសំលេងនាំមុខមួយលើផលប៉ះពាល់សេដ្ឋកិច្ចដល់ពលរដ្ឋ California ទាក់ទងនឹងការផ្លាស់ប្តូរសភាពនៃការងារ និងការប្រែប្រួលអាកាសធាតុសាកល។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់អ្នកអ្នកបោះឆ្នោតរដ្ឋ California អង្គការស្ត្រី សហគមន៍បរិស្ថាន អស់លោក លោកស្រីក្នុងវិស័យអគារ និងសំណង់ និងការអនុវត្តច្បាប់ ព្រមទាំងអ្នកផ្សេងទៀតដែលទទួលស្គាល់ភាពចាំបាច់នៃបទពិសោធន៍ហិរញ្ញវត្ថុក្នុងមូលដ្ឋាន និងក្នុងរដ្ឋរយៈពេល 35 ឆ្នាំរបស់ខ្ញុំ ក្នុងការស្នើសុំសម្រាប់ភាពយុត្តិធម៌ ការប្តេជ្ញាចិត្តចំពោះគណនេយ្យភាព និងវិន័យដ៏រឹងមាំនៅក្នុងការិយាល័យស្នងការហិរញ្ញវត្ថុរបស់រដ្ឋ។ ខ្ញុំនឹងមានកិត្តិយសក្រៃលែង ក្នុងការទទួលបានការបោះឆ្នោតគាំទ្ររបស់អ្នក។

16633 Ventura Blvd.,
Suite 1008
Encino, CA 91436

អ៊ីម៉ែល៖ info@bettyyee.com
www.bettyyee.com
Twitter: @BettyYeeforCA

Konstantinos Roditis | សាធារណរដ្ឋ

ការិយាល័យស្នងការហិរញ្ញវត្ថុគិតថាអ្នកមិនទាន់បង់ពន្ធគ្រប់គ្រាន់ទេ។ ពួកគេចង់យកពន្ធលើការណាត់ជួបវេជ្ជបណ្ឌិតរបស់អ្នក ការថែទាំកុមារ ការជួសជុលផ្ទះនិងរថយន្ត ការកាត់សក់ ។ ល ។ និង ។ល។ ពួកគេចង់យកពន្ធលើអ្វីទាំងអស់។ ជាលទ្ធផល អ្នកនឹងបង់ពន្ធរាប់រយ ឬរាប់ពាន់ដុល្លារបន្ថែមក្នុងមួយឆ្នាំ។ គ្មានពន្ធលើសេវាកម្ម និងពលកម្មទេ។ យើងមិនមានលទ្ធភាពបង់ទេ។ ក្នុងនាមជាស្នងការហិរញ្ញវត្ថុ ខ្ញុំនឹងតស៊ូដើម្បីធ្វើឱ្យរដ្ឋ California មានតម្លៃសមរម្យសម្រាប់ការរស់នៅ ដោយមិនស្វែងរកវិធីថ្មីដើម្បីយកពន្ធអ្នកទេ។ *បោះឆ្នោតគាំទ្រសំណើប្រជាមតិលេខ 6*៖ អ្នកនយោបាយខ្ជះខ្ជាយប្រាក់រាប់ពាន់លានដុល្លារ ហើយប្រើតែ 20% នៃមូលនិធិពន្ធប្រេងសម្រាប់ការជួសជុលផ្លូវថ្នល់។ យើងបង់បួនដងលើសរដ្ឋតិចសាស់ដើម្បីជួសជុលផ្លូវ។ យើងមានលុយ។ ក្នុងនាមជាស្នងការហិរញ្ញវត្ថុ ខ្ញុំនឹងបង្ហាញ និងបញ្ឈប់កិច្ចព្រមព្រៀងផ្នែកនយោបាយដែលពុករលួយ ហើយបញ្ចប់ការចំណាយខ្ជះខ្ជាយ ការលួចបន្លំ និងការរំលោភបំពាន។ *ដកមូលនិធិផ្លូវថ្នល់ចេញលឿនលឿន*៖ ក្នុងនាមជាស្នងការហិរញ្ញវត្ថុ ខ្ញុំនឹងធ្វើសវនកម្ម និងដកមូលនិធি HSR នៅថ្ងៃទីមួយតែម្តង។ *គោលនយោបាយឆ្លាតវៃគាំទ្រដល់បរិស្ថាន*៖ មិនខ្ជះខ្ជាយទឹក រាប់ពាន់លានហ្គាឡុង ហើយមិនព្រមរក្សាទឹកទុក តែបែជាស្វែងរកវិធីយកពន្ធលើពួកយើងដែលប្រើប្រាស់ទឹកច្រើនជាង 55 ហ្គាឡុង ក្នុងមួយថ្ងៃសម្រាប់គ្រួសារទាំងមូលរបស់យើង។ ខ្ញុំនឹងផ្តោតទៅលើដំណោះស្រាយ មិនមែនបង្កើនពន្ធឡើយ។ ដោយហេតុថាស្នងការហិរញ្ញវត្ថុគឺជាប្រធានហិរញ្ញវត្ថ (CFO) របស់រដ្ឋ California វាពិតជាសក្តិសមណាស់ដែលមានអ្នកជំនាញហិរញ្ញវត្ថុ និងអ្នកជំនួញដែលមានចក្ខុវិស័យ ហើយយល់ច្បាស់ពីសេដ្ឋកិច្ច ទំនួលខុសត្រូវសារពើពន្ធ និងតុល្យភាពថវិកា ធ្វើជាស្នងការហិរញ្ញវត្ថុរបស់អ្នកនោះ។ វាដល់ពេលហើយសម្រាប់ស្នងការហិរញ្ញវត្ថុដែលមិនគោលការណ៍ច្បាស់លាស់ និងឯករាជ្យភាព គ្មានសម្ព័ន្ធ គ្មានផលប្រយោជន៍ពិសេសសាជីវកម្មនោះ។ បោះឆ្នោតដើម្បីធ្វើឱ្យកាលីហ្វញ៉ាមានតំលៃសមរម្យ បោះឆ្នោតដើម្បីដំណោះស្រាយ មិនមែនការបង្កើនពន្ធទេ។ បោះឆ្នោតឲ្យ Konstantinos Roditis ធ្វើជាស្នងការហិរញ្ញវត្ថុ។

751 S. Weir Canyon Rd.,
Ste. 157-160
Anaheim, CA 92808

ទូរស័ព្ទ៖ (949) 607-8294
អ៊ីមែល៖ roditis@cacontroller.com
cacontroller.com
facebook.com/konroditis

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍ត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ថ្លៃដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ក៏អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញឈ្មោះនៅលើសន្លឹកឆ្នោតដែរ។

សេចក្តីថ្លែងការណ៍របស់បេក្ខជន
ហេរញ្ញិក

- ក្នុងនាមជាធនាគារិករបស់រដ្ឋ គ្រប់គ្រងការវិនិយោគរបស់រដ្ឋ និងគ្រប់គ្រងការលក់មូលបត្របំណុលរដ្ឋ និងកំណត់ចំណាំ។
- បម្រើការក្នុងគណៈកម្មការជាច្រើន ដែលភាគច្រើនទាក់ទងនឹងការធ្វើទីផ្សារមូលប័ត្របំណុល។
- បង់មូលនិធិរបស់រដ្ឋនៅពេលចំណាយដោយអ្នកត្រួតពិនិត្យ និងភ្នាក់ងាររដ្ឋដទៃ។

Greg Conlon | សាធារណរដ្ឋ

រដ្ឋ California ត្រូវការសាធារណរដ្ឋជនម្នាក់ដែលអាចអនុវត្តការទទួលខុសត្រូវផ្នែកសារពើពន្ធដោយប្រយ័ត្នប្រយែង ដើម្បីជួសជុលស្ថានភាពហិរញ្ញវត្ថុងាយរងគ្រោះរបស់រដ្ឋ។ និយោជិតសាធារណៈដែលទទួលបានសោធននិវត្តន៍សប្បុរសធម៌ បានបង្កឲ្យមានសោធននិវត្តន៍ដែលមិនត្រូវបានផ្តល់មូលនិធិដោយគ្មានការទទួលខុសត្រូវ និងបំណុលការថែទាំសុខភាពជិត $300 ពាន់លាន។ ហេរញ្ញិករដ្ឋ California បម្រើការនៅក្រុមប្រឹក្សាភិបាលផែនការសោធននិវត្តន៍រដ្ឋទាំងពីរ—CalPERS និង ប្រព័ន្ធចូលនិវត្តន៍របស់គ្រូបង្រៀនរដ្ឋរដ្ឋកាលីហ្វ័រញ៉ា (CalSTRS) ។ ខ្ញុំនឹង នាំយកបទពិសោធន៍របស់ខ្ញុំ "ដើម្បីធ្វើឲ្យការងារសម្រេច" ចំពោះគណៈកម្មការទាំងនេះ ដោយដោះស្រាយបំណុលសោធននិវត្តន៍ ដែលមិនទាន់បានផ្តល់ថវិកាដោយធ្វើការ ដើម្បីចាប់ផ្តើមផែនការវិភាគទានដែលបានកំណត់ថ្មីសម្រាប់និយោជិតថ្មី។ បទពិសោធន៍លើស 20 ឆ្នាំរបស់ខ្ញុំក្នុងនាមជាគណនីករសាធារណៈដែលបានបញ្ជាក់ គណនេយ្យករសាធារណៈដែលមានអាជ្ញាប័ណ្ណ (CPA) ម្នាក់ក្នុងក្រុមហ៊ុនគណនេយ្យសាធារណៈអន្តរជាតិ នឹងនាំមកនូវចំណេះដឹងផ្នែកហិរញ្ញវត្ថុដែលចាំបាច់ក្នុងការវិនិយោគដោយប្រុងប្រយ័ត្ននូវមូលនិធិរបស់រដ្ឋ California និងកែលម្អចំណាត់ថ្នាក់ឥណទានទាបរបស់រដ្ឋ។ ខ្ញុំក៏ធ្វើការ *ដើម្បីលុបបំបាត់ពន្ធលើប្រាក់ចំណូលពីសិទ្ធិប្រើឈ្មោះពាណិជ្ជកម្មរបស់រដ្ឋជាអប្បបរមា $800* ដើម្បីជួយចាប់ផ្តើមសហប្រតិបត្តិការដែរ។ ខ្ញុំមានបទពិសោធន៍វិស័យសាធារណៈដែលទាក់ទងនឹងការិយាល័យហិរញ្ញិករបស់រដ្ឋ។ បទពិសោធន៍នេះរួមមានទាំងការដំណើរការគណៈកម្មការសេវាសាធារណៈរដ្ឋ California ក្នុងនាមជាប្រធានគណៈកម្មការ និងបម្រើការនៅគណៈកម្មការដឹកជញ្ជូនរដ្ឋ California ។ ខ្ញុំក៏ដឹកនាំគណៈកម្មការហិរញ្ញវត្ថុនៃ ទីក្រុង Atherton ផងដែរ។ ខ្ញុំមានសញ្ញាបត្របរិញ្ញាបត្រពាណិជ្ជកម្មនៅសាកលវិទ្យាល័យ Utah, កម្មវិធីបណ្តុះបណ្តាលពាណិជ្ជកម្មប្រតិបត្តិនៅសាលាពាណិជ្ជកម្ម Haas នៅ UC Berkeley និងសញ្ញាបត្រ J.D. ពីសាកលវិទ្យាល័យ San Francisco ។ ខ្ញុំបម្រើការជាអ្នកបើកយន្តហោះកងទ័ពអាកាស។ ខ្ញុំបានទទួលការគាំទ្រជាច្រើនរួមមានជាភាគី គណបក្សសាធារណរដ្ឋនៃរដ្ឋ California និងអតីតលេខាធិការហិរញ្ញិកសហរដ្ឋអាមេរិក George P. Shultz ។ ខ្ញុំសូមឲ្យអ្នកជួយបោះឆ្នោត និងសន្យាថានឹងធ្វើការដើម្បីឲ្យ រដ្ឋ California ដ៏អស្ចារ្យរបស់យើង ឲ្យមានសេដ្ឋកិច្ចកាន់តែខ្លាំងក្លាថែមទៀត។

P.O. Box #2600
Menlo Park, CA 94026

ទូរស័ព្ទ៖ (650) 315-4956
អ៊ីមែល៖ greg@gregconlon.com
www.gregconlon.com
Facebook.com/gregconlonforstatetreasurer

Fiona Ma | ប្រជាធិបតេយ្យ

ក្នុងនាមជា CPA ម្នាក់ដែលមានបទពិសោធន៍អំពីច្បាប់ពន្ធ និងនៅក្នុងតុល្យភាពថវិកា ខ្ញុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីបម្រើការជាហេរញ្ញិករដ្ឋចាប់ពីថ្ងៃទី 1 ហើយនឹងអាចគ្រប់គ្រងការវិនិយោគរបស់រដ្ឋ California ដោយគណនេយ្យភាពពេញលេញ និងតម្លាភាព។ *ខ្ញុំបានធ្វើជាគណនេយ្យករជំនាញ (CPA) តាំងពីឆ្នាំ 1992, ហើយមាន B.S. ផ្នែកគណនេយ្យ, M.S. ផ្នែកពន្ធដារ និង MBA ផ្នែកហិរញ្ញវត្ថុ*។ ខ្ញុំតំណាងឲ្យ *ការត្រួតមើល & ថ្លឹងអំណាច និងគណនេយ្យភាពសាធារណៈ*។ នោះហើយជាមូលហេតុដែលខ្ញុំនាំឲ្យមានការផ្លាស់ប្តូរដ៏ធំមួយ ដើម្បីស្តារមកវិញនូវទំនុកចិត្តនៅក្នុងគណៈកម្មការសមភាពរបស់រដ្ឋ។ ខ្ញុំបានធ្វើឲ្យមានតុល្យភាពថវិកានៅថ្នាក់មូលដ្ឋាន នៅថ្នាក់រដ្ឋអំឡុងពេលវិបត្តិសេដ្ឋកិច្ចដ៏ធំ ហើយបានត្រួតពិនិត្យការប្រមូលចំណូលរដ្ឋចំនួន $60 ពាន់លាន។ ខ្ញុំនឹងបង្កើតកម្មវិធីទិញផ្ទះជាលើកដំបូងដ៏ម៉ាមួន ដើម្បីឱ្យមានលំនៅដ្ឋានកាន់តែងាយស្រួលសម្រាប់ប្រជាពលរដ្ឋកាលីហ្វញ៉ាទាំងអស់។ ខ្ញុំនឹងធ្វើការសម្រួលប្រាក់កម្ចីបំណុលខ្ពស់ដល់សិស្ស។ ខ្ញុំកើតមកមានបញ្ហាសុខភាពពីមុនស្រាប់ ហើយខ្ញុំយល់អំពីតម្រូវការបន្ទាន់ដោយផ្ទាល់ផ្នែកការថែទាំសុខភាពដែលមានគុណភាព មានលទ្ធភាពទទួលបាន និង *មានលទ្ធភាពចំណាយបាន*។ ដោយសារស្វាមីខ្ញុំជាអ្នកពន្លត់អគ្គីភ័យ ខ្ញុំដឹងជាមុននូវសារៈសំខាន់នៃការវិនិយោគលើក្រុមសង្គ្រោះដំបូងរបស់យើង។ ក្នុងនាមជាហិរញ្ញិករដ្ឋ ខ្ញុំនឹងមើលការខុសត្រូវការវិនិយោគនៅក្នុង *ផ្ទះសម្បែងដែលមានលទ្ធភាពចំណាយបាន ហេដ្ឋារចនាសម្ព័ន្ធ សាលាបឋម មន្ទីរពេទ្យ កិច្ចការពារបរិស្ថាន និងគមនាគមន៍*។ ខ្ញុំនឹងបន្តការពារលុយពន្ធរបស់យើង វិនិយោគដោយភាពឆ្លាតវៃដើម្បីធានានូវការទាញចំណូលវិជ្ជមាន និងធ្វើឲ្យប្រាកដថារដ្ឋាភិបាលធ្វើការប្រកបដោយ *គណនេយ្យភាព និងតម្លាភាព*។ ខ្ញុំមានមោទនភាពដែលមានការគាំទ្រពី *សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក Kamala Harris, សមាគមគ្រូបង្រៀនរដ្ឋ California, អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California និងសមាគមអាជីវកម្មខ្នាតតូចរដ្ឋ California*។ ខ្ញុំនឹងមានកិត្តិយសណាស់ក្នុងការទទួលបានការបោះឆ្នោតរបស់អ្នក។ អរគុណសំរាប់ការពិចារណារបស់អ្នក។

2244 Ione Street
Sacramento, CA 95864

ទូរស័ព្ទ៖ (415) 845-5450
អ៊ីមែល៖ fiona@fionama.com
FionaMa.com
facebook.com/CA.FionaMa

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះដោយព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ប្រាក់ដោយស្ម័គ្រចិត្តពីបេក្ខជន។ បេក្ខជន ដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្តីថ្លែងការណ៍របស់បេក្ខជន

អគ្គមេធាវី

- ក្នុងនាមជាប្រធានមន្ត្រីច្បាប់របស់រដ្ឋ ធានាថាច្បាប់រដ្ឋត្រូវបានអនុវត្ត និងសើបអង្កេតសកម្មភាពក្លែងបន្លំ ឬខុសច្បាប់។
- ដឹកនាំក្រសួងយុត្តិធម៌ ដែលផ្តល់សេវាកម្មច្បាប់ដល់រដ្ឋាភិបាលរបស់រដ្ឋ ហើយតំណាងឱ្យរដ្ឋក្នុងសំណុំរឿងក្តីតុលាការរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។
- មើលខុសត្រូវភ្នាក់ងារប្រតិបត្តិច្បាប់ រួមមានដូចជាមេធាវី និងនគរបាលស្រុកខោនធី។

Steven Bailey | សាធារណរដ្ឋ



ក្នុងនាមជាចៅក្រមចូលនិវត្តន៍នៃតុលាការកំពូលរដ្ឋ California ខ្ញុំដឹងពីរបៀបរក្សាឲ្យពលរដ្ឋកាលីហ្វូញ៉ា មានសុវត្ថិភាពពីបទឧក្រិដ្ឋ ហិង្សា ដែលបច្ចុប្បន្នកំពុងមានការកើនឡើងដោយសារតែច្បាប់គ្រោះថ្នាក់ចំនួនបីដែលបានអនុម័តនៅក្នុងឆ្នាំថ្មីៗនេះ—សំណើប្រជាមតិ 47, 57 និង AB 109 ។ ការពិសោធន៍ដ៏គ្រោះថ្នាក់ទាំងនេះ នាំទៅរកការដោះលែងជនល្មើសផ្លូវភេទមុនកាលកំណត់ កាត់បន្ថយទណ្ឌកម្មសម្រាប់បទល្មើសជាច្រើន និងកាត់បន្ថយ ឬលុបបំបាត់ឧបករណ៍សំខាន់ៗដែលប្រើប្រាស់ដោយចៅក្រមដើម្បីរក្សាឲ្យបទឧក្រិដ្ឋគ្រោះថ្នាក់—រួមទាំងសមាជិកជនពាល និងជនល្មើសដដែលៗ—នៅឆ្ងាយពីផ្ទះ និងភូមិសង្កាត់របស់យើង។ ស្ត្រី មនុស្សចាស់ និងយុវជន មានកំណើនក្លាយជាជនរងគ្រោះបទឧក្រិដ្ឋហិង្សា—បញ្ហានេះត្រូវតែបញ្ចប់។ អាទិភាពចម្បងរបស់ខ្ញុំក្នុងនាមជាអគ្គមេធាវី គឺសុវត្ថិភាព និងសន្តិសុខរបស់ពលរដ្ឋកាលីហ្វូញ៉ា ទាំងអស់។ ហេតុដូច្នេះហើយ អ្នកតស៊ូមតិជនរងគ្រោះពីបទឧក្រិដ្ឋ និងក្រុមប្រតិបត្តិច្បាប់ រួមមាន សហជនរងគ្រោះបទឧក្រិដ្ឋរដ្ឋ CA សម្ព័ន្ធការពារប៉ូលីស Los Angeles សមាគមនគរបាលរង Los Angeles សមាគមមន្ត្រីសន្តិភាពរដ្ឋ California នគរបាលខោនធី និងមេធាវីមណ្ឌល គាំទ្រខ្ញុំឲ្យធ្វើជាអគ្គមេធាវីបន្ទាប់របស់រដ្ឋ California ។ ក្នុងនាមជាចៅក្រមតុលាការកំពូលម្នាក់ ខ្ញុំឃើញជាមុន នៅពេលដែលប្រព័ន្ធយុត្តិធម៌ឧក្រិដ្ឋកម្មមានប្រសិទ្ធភាព ហើយឥឡូវនេះវាធ្វើឲ្យយើងខកចិត្ត។ ខ្ញុំដឹងច្បាស់អំពីអ្វីដែលត្រូវតែធ្វើដើម្បីការពារពលរដ្ឋកាលីហ្វូញ៉ា ពីបទឧក្រិដ្ឋហិង្សា រួមមាន ការធានាថាមនុស្សជាប់បទឧក្រិដ្ឋលែងមានលទ្ធភាពទទួលបានអាវុធ និងស្តារសុវត្ថិភាពជូនគ្រប់ភូមិសង្កាត់។ អគ្គមេធាវីត្រូវតែស្ថិតនៅខាងលើការប្រកាន់បក្សពួក។ នេះមិនមែនជាចម្លើយអំពីលទ្ធិប្រជាធិបតេយ្យ ឬចម្លើយអំពីសាធារណរដ្ឋទេ—វាគឺជាចម្លើយអំពីសិទ្ធិក្នុងការធានាថា ពលរដ្ឋកាលីហ្វូញ៉ា គ្រប់រូប អាចមានអារម្មណ៍ថាមានសុវត្ថិភាពនៅតាមដងផ្លូវ នៅកន្លែងធ្វើការ និងនៅតាមផ្ទះរបស់ពួកគេ។ ខ្ញុំមានកិត្តិយសណាស់ក្នុងការទទួលបានការបោះឆ្នោតរបស់អ្នក។

455 Capitol Mall, Suite 600
Sacramento, CA 95814

ទូរស័ព្ទ៖ (916) 936-2448
អ៊ីមែល៖ Judge@baileyforag.com
BaileyforAG.com
www.facebook.com/JudgeBaileyforAG

Xavier Becerra | ប្រជាធិបតេយ្យ

ក្នុងនាមជាអគ្គមេធាវី និងជាប្រធានមន្ត្រីប្រតិបត្តិច្បាប់របស់អ្នក ខ្ញុំនឹងប្រយុទ្ធប្រឆាំង—*និងយកឈ្នះ*—ជូនពលរដ្ឋកាលីហ្វូញ៉ា និងគុណតម្លៃរបស់យើង។ ខ្ញុំនឹងប្រឆាំងអ្នកជួញដូរផ្លូវភេទ សមាគម NRA, Big Oil, ធនាគារធំៗ និងរដ្ឋបាល Trump ។ ខ្ញុំនឹងកាត់ទោសជនពាលហិង្សាតាមដងផ្លូវ និងដកហូតយកកាំភ្លើងរាប់ពាន់ដើមចេញពីដងផ្លូវរបស់យើង។ ខ្ញុំនឹងប្រយុទ្ធប្រឆាំងមហាវិទ្យាល័យរកចំណូលតាមបែបជញ្ជក់ឈាមដែលលួចពីនិស្សិតរបស់យើង។ ខ្ញុំបានប្តឹង—*Trump និងឈ្នះ*—ដើម្បីបញ្ឈប់លោកពីការកាត់បន្ថយកិច្ចការពារគុណភាពខ្យល់របស់យើង និងការរឹតត្បឹតលទ្ធភាពទទួលបានការពន្យារកំណើតរបស់ស្ត្រី។ ខ្ញុំបានប្រយុទ្ធប្រឆាំង *និងឈ្នះ* ដើម្បីការពា Dreamers—ជនអន្តោប្រវេសន៍ដែលត្រូវបាននាំមកកាន់សហរដ្ឋអាមេរិកក្នុងនាមជាកុមារតូច។ ហើយខ្ញុំនៅក្នុងតុលាការដើម្បីការពារសិទ្ធិទទួលបានការថែទាំសុខភាពរបស់ពលរដ្ឋកាលីហ្វូញ៉ា។ ខ្ញុំប្រយុទ្ធប្រឆាំងនឹងសមរភូមិទាំងនេះដើម្បីពលរដ្ឋកាលីហ្វូញ៉ា ក្នុងនាមជាកូនប្រុសជនអន្តោប្រវេសន៍ ជាមនុស្សដំបូងក្នុងគ្រួសារខ្ញុំដែលបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ ពីព្រោះ *ពលរដ្ឋកាលីហ្វូញ៉ា ទាំងអស់* សមតែនឹងទទួលបានឱកាសទទួលបានជោគជ័យ។ បន្ទាប់ពីសាលាច្បាប់ ខ្ញុំបានធ្វើការជាមេធាវីជំនួយផ្នែកច្បាប់ដែលការពារក្តីជូនអ្នកជំងឺផ្លូវចិត្ត ហើយបន្ទាប់មកបម្រើជាអគ្គមេធាវីរងនៅក្នុងការិយាល័យដំបូងបំផុតដែលខ្ញុំដឹកនាំបច្ចុប្បន្ន។ បន្ទាប់មកខ្ញុំបានទៅសភាដើម្បីដឹកនាំការប្រយុទ្ធប្រឆាំងដើម្បីការពារសន្តិសុខសង្គម និងមេឌីឃារ។ ខ្ញុំកំពុងប្រយុទ្ធប្រឆាំងដើម្បីគុណតម្លៃរដ្ឋ California ពេញមួយជីវិតខ្ញុំ ហើយខ្ញុំនឹង *មិន* ដកការទាមទារវិញឡើយ ទោះបីវាជាអ្នកជួញដូរផ្លូវភេទ, Big Oil, សមាគម NRA, ឬ រដ្ឋបាលTrump ក៏ដោយ។ ខ្ញុំមានមោទនភាពដែលទទួលបានការគាំទ្រពីលោកអភិបាល Brown, គណបក្សប្រជាធិបតេយ្យ, ស៊ារ៉ាបក្លឹប California, ភាពជាឪពុកម្តាយដែលបានគ្រោងទុក (Planned Parenthood), សមមាគមប្រតិបត្តិច្បាប់រដ្ឋ California និងគិលានុប្បដ្ឋាករដ្ឋ California, គ្រូបង្រៀន និងអ្នកពន្លត់អគ្គីភ័យ។ ខ្ញុំមានកិត្តិយសណាស់ក្នុងការទទួលបានការបោះឆ្នោតរបស់អ្នក។

777 South Figueroa Street,
Suite 4050
Los Angeles, CA 90017

ទូរស័ព្ទ៖ (213) 250-3400
អ៊ីមែល៖ Info@XavierBecerra.com
XavierBecerra.com
@XavierBecerra

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ប្រាក់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្តីថ្លែងការណ៍របស់បេក្ខជន

ស្នងការធានារ៉ាប់រង

- ដឹកនាំក្រសួងធានារ៉ាប់រង ដែលអនុវត្តច្បាប់ធានារ៉ាប់រងរដ្ឋ California និងប្រកាន់ខ្ជាប់នូវបទបញ្ញត្តិដើម្បីអនុវត្តច្បាប់។
- ផ្តល់អាជ្ញាប័ណ្ណ ធ្វើនិយ័តកម្ម និងពិនិត្យក្រុមហ៊ុនធានារ៉ាប់រង។
- ឆ្លើយសំណួរសាធារណៈ និងពាក្យបណ្តឹងអំពីឧស្សាហកម្មធានារ៉ាប់រង។

Ricardo Lara | ប្រជាធិបតេយ្យ

ជូនចំពោះពលរដ្ឋ California, ខ្ញុំសរសេរដើម្បីចែករំលែកជាមួយអ្នកនូវជំនឿស្ទូល និងសាមញ្ញរបស់ខ្ញុំ ពោលគឺអ្វីដែលយើងមានដូចគ្នាគឺសំខាន់ជាងអ្វីដែលបែងចែកពួកយើង។ ម្តាយខ្ញុំគឺជាជាងកាត់ដេរ។ ឪពុកខ្ញុំគឺជាកម្មកររោងចក្រ។ ពួកគាត់ជឿជាក់លើគុណតម្លៃនៃការមានការធានារ៉ាប់រងលើផ្ទះដ៏សមរម្យដែលពួកគាត់ខិតខំធ្វើការដើម្បីទិញ និងលើរថយន្តដែលដឹកពួកគាត់ទៅកាន់កន្លែងការងារពួកគាត់។ ខណៈដែលពួកគាត់មានអាយុកាន់តែច្រើន ពួកគាត់បានលះបង់បន្តិចទៀត ដើម្បីទិញការធានារ៉ាប់រងអាយុជីវិត។ ពួកគាត់បានទិញវា ពីព្រោះពួកគាត់ដឹងថាពួកគាត់មិនចង់ឲ្យគ្រោះថ្នាក់ អគ្គីភ័យ ការចូលលួច ជំងឺធ្ងន់ធ្ងរ មកបំផ្លាញអ្វីៗគ្រប់យ៉ាងដែលពួកគាត់បានធ្វើការលះបង់នោះទេ។ ជារឿងក្រៀមក្រំ អស់រយៈពេលជាច្រើនឆ្នាំ ពួកគាត់មិនអាចមានលទ្ធភាពទិញការធានារ៉ាប់រងសុខភាពសម្រាប់កូនៗពួកគាត់បានឡើយ។ ក្នុងនាមជាសមាជិកព្រឹទ្ធសភារដ្ឋ California, ខ្ញុំបានចែងច្បាប់ដើម្បីផ្តល់ការធានារ៉ាប់រងសុខភាពដល់ក្មេងចំនួន 250,000 នាក់ ដែលពុំមានវា ដើម្បីកុំឲ្យឪពុកម្តាយពួកគេប្រឈមនឹងភាពក្ស័យធន ប្រសិនបើក្មេងនោះទទួលរងគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬមានជំងឺស្ទុះគ្ស្ទាញអ្វីមួយ។ ខ្ញុំមានសេចក្តីសោមនស្សយ៉ាងជ្រាលជ្រៅចំពោះសន្តិសុខដែលប្រជាជនត្រូវការ។ ខ្ញុំជឿជាក់ថា ទីផ្សារធានារ៉ាប់រងដែលមានសុខភាពល្អ ស្មោះត្រង់ និងមានការប្រកួតប្រជែង គឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយសំខាន់បំផុតក្នុងការផ្តល់សន្តិសុខដែលពួកយើងទាំងអស់គ្នាត្រូវការ។ ការងាររបស់ស្នងការធានារ៉ាប់រងរដ្ឋ California គឺមានពីរយ៉ាង ពោលគឺធ្វើឲ្យប្រាកដថា ការធានារ៉ាប់រងមានតម្លៃសមរម្យ ហើយប្រសិនបើយើងត្រូវការប្រើប្រាស់វា ការទាមទារសំណងរបស់យើងនឹងត្រូវបានដោះស្រាយយ៉ាងសមរម្យ។ ខ្ញុំមិនមានលុយធ្វើយុទ្ធនាការច្រើនដូចបេក្ខជនផ្សេងទៀតទេ។ ដូច្នេះ ខ្ញុំសូមអរគុណដល់អ្នកដែលអ្នកចំណាយពេលវេលាអានសារលិខិតនេះ និងពិចារណាអំពីបេក្ខភាពរបស់ខ្ញុំ។ ដោយក្តីស្មោះស្ម័គ្រ,
Ricardo Lara

3605 Long Beach Blvd.,
Suite 426
Long Beach, CA 90807

ទូរសព្ទ៖ (562) 427-2100
អ៊ីមែល៖ Ricardo@RicardoLara.com
RicardoLara.com
www.Facebook.com/Ricardo4CAIC

Steve Poizner | គ្មានគណបក្សអាទិភាព

ចាប់ពីឆ្នាំ 2007-2011 ខ្ញុំបានបម្រើការជាស្នងការធានារ៉ាប់រងរដ្ឋ California ហើយខ្ញុំកំពុងស្វែងរកការគាំទ្ររបស់លោកអ្នកសម្រាប់អាណត្តិទី 2 នៃសេវាសាធារណៈ។ *ហេតុអ្វីបានជាខ្ញុំជាអ្នកឯករាជ្យ*៖ ស្នងការធានារ៉ាប់រងរដ្ឋ California គឺជានិយ័តករដែលទាមទារឲ្យមានឯករាជ្យភាពពីក្រុមហ៊ុនធានារ៉ាប់រង និងនយោបាយគណបក្សបក្សព័ន្ធ។ ជាមួយការគាំទ្ររបស់លោកអ្នក ខ្ញុំនឹងជាបេក្ខជនឯករាជ្យដំបូងគេដែលត្រូវបានបោះឆ្នោតជ្រើសតាំងទូទាំងរដ្ឋនៅក្នុងប្រវត្តិសាស្ត្ररដ្ឋ California។ វានឹងត្រួសត្រាយផ្លូវសម្រាប់អ្នកដទៃទៀតដែលធុញទ្រាន់នឹងការឈ្លោះប្រកែក និងទាស់ទែងគ្នារបស់បក្សព័ន្ធ។ ខ្ញុំក៏នឹងបដិសេធចំពោះការផ្តល់វិភាគទានពីឧស្សាហកម្មធានារ៉ាប់រងសម្រាប់យុទ្ធនាការរបស់ខ្ញុំ ដូចដែលខ្ញុំបានធ្វើនៅក្នុងអាណត្តិទីមួយរបស់ខ្ញុំផងដែរ។ *សាវតាខ្ញុំ*៖ ខ្ញុំមានកំណត់ត្រាតាមដានដែលបង្ហាញពីភាពជោគជ័យរបស់ខ្ញុំនៅក្នុងវិស័យឯកជន ដែលចាប់ផ្តើម និងដឹកនាំក្រុមហ៊ុនបច្ចេកវិទ្យាឈានមុខគេអស់រយៈពេល 35 ឆ្នាំនៅរដ្ឋ California (ឧ. ក្រុមហ៊ុន SnapTrack របស់ខ្ញុំ បានបង្កើត GPS សម្រាប់ទូរស័ព្ទចល័ត) ហើយបច្ចុប្បន្ននេះ ខ្ញុំជាស្ថាបនិកនៃក្រុមហ៊ុនមិនរកប្រាក់ចំណេញដែលផ្តោតលើការពង្រីកសេដ្ឋកិច្ចច្នៃប្រឌិតនៅរដ្ឋ California ភាគខាងត្បូង។ *ហេតុអ្វីបានជាឥឡូវនេះឈរឈ្មោះមួយអាណត្តិទៀត?* ពលរដ្ឋកាលីហ្វូញ៉ា ប្រឈមនឹងបញ្ហាបន្ទាន់៖ ម្ចាស់ផ្ទះដែលមានការធានារ៉ាប់រងមិនគ្រប់គ្រាន់ បានប្រឈមនឹងការកើតឡើងនូវចំនួនភ្លើងឆេះព្រៃ និងទឹកជំនន់ ការកើនឡើងប្រាក់បុព្វលាភជាបន្តបន្ទាប់នៅក្នុងទីផ្សារធានារ៉ាប់រងសុខភាព និងការកើនឡើងនៃការគំរាមកំហែងផ្នែកសេដ្ឋកិច្ចពីឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត។ *កំណត់ត្រារបស់ខ្ញុំក្នុងនាមជាស្នងការធានារ៉ាប់រង*៖ យើងបានសង្គ្រោះអ្នកបើកបរ និងម្ចាស់ផ្ទះក្នុងតម្លៃទឹកប្រាក់ជិត $2 ពាន់លាន ពាក់ព័ន្ធនឹងអត្រាធានារ៉ាប់រងទាបជាងមុន ស្តារបាន $30 លាន សម្រាប់ជនរងគ្រោះភ្លើងឆេះព្រៃដែល ថែមលុយខ្ទះដោយក្រុមហ៊ុនធានារ៉ាប់រង; សង្គ្រោះអ្នកបង់ពន្ធ $17 លាន ដោយកាត់ជាអចិន្ត្រៃយ៍ 13% នៃថវិកា (នោះគឺជាលើកដំបូង និងគ្មានការបញ្ឈប់បុគ្គលិក!); ចាប់មនុស្សជាង 2500 នាក់សម្រាប់ការគៃបន្ទំធានារ៉ាប់រង (កំណត់ត្រា!); និងស្តារធានារ៉ាប់រងសម្រាប់អតិថិជនស្លូតត្រង់ បន្ទាប់ពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពបានលុបចោលគោលនយោបាយដោយខុសច្បាប់។

អ៊ីមែល៖ StevePoizner@gmail.com
www.StevePoizner.com

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

គណៈកម្មការនៃមណ្ឌលសមកម្មរបស់រដ្ថ CALIFORNIA

ខោនធីនៅក្នុងគណៈកម្មការនៃមណ្ឌលសមភាព



មណ្ឌល 1

Alpine, Amador, Butte, Calaveras, El Dorado, Fresno, Inyo, Kern, Kings, Lassen, Los Angeles, Madera, Mariposa, Merced, Modoc, Mono, Nevada, Placer, Plumas, Sacramento, San Bernardino, San Joaquin, Shasta, Sierra, Siskiyou, Stanislaus, Sutter, Tulare, Tuolumne, Yuba

មណ្ឌល 2

Alameda, Colusa, Contra Costa, Del Norte, Glenn, Humboldt, Lake, Marin, Mendocino, Monterey, Napa, San Benito, San Francisco, San Luis Obispo, San Mateo, Santa Barbara, Santa Clara, Santa Cruz, Solano, Sonoma, Tehama, Trinity, Yolo

មណ្ឌល 3

Los Angeles, San Bernardino, Ventura

មណ្ឌល 4

Imperial, Orange, Riverside, San Bernardino, San Diego

សេចក្តីថ្លែងការណ៍របស់បេក្ខជន

គណៈកម្មការពន្ធដារសមភាព

បម្រើការឱ្យគណៈកម្មការពន្ធដារសមភាព គណៈកម្មការពន្ធដារជាប់ឆ្នោតរបស់រដ្ឋដែល៖

- វាយតម្លៃទ្រព្យសម្បត្តិរបស់ផ្លូវរថភ្លើងនិយ័ត និងសេវាសាធារណៈជាក់លាក់ និងវាយតម្លៃ និងប្រមូលពន្ធពីរថយន្តបើកបរលើផ្លូវរថភ្លើងសាធារណៈ។
- មើលការខុសត្រូវការអនុវត្តការវាយតម្លៃរបស់អ្នកវាយតម្លៃខោនធីទាំង 58 របស់រដ្ឋ។
- វាយតម្លៃ និងប្រមូលពន្ធលើភេសជ្ជៈមានជាតិអាល់កុល និងរួមគ្នាគ្រប់គ្រងពន្ធលើអ្នកធានារ៉ាប់រង។

មណ្ឌល 1

Ted Gaines | សាធារណរដ្ឋ

ក្នុងនាមជាអ្នកតំណាងរបស់អ្នកនៅគណៈកម្មការពន្ធដារសមភាព ខ្ញុំនឹងធ្វើការដើម្បីការពារផលប្រយោជន៍របស់អ្នកបង់ពន្ធទាំងអស់រក្សាសេដ្ឋកិច្ចរបស់យើងឱ្យរឹងមំា និងបង្កើតការងារ។ ចំពោះក្រុមគ្រួសារដែលពិបាកធ្វើការច្រើនពេក ក្តីសុបិនរបស់រដ្ឋ California ត្រូវបានប្រែក្លាយទៅជាសុបិន្តអាក្រក់មួយដោយអ្នកនយោបាយ Sacramento ដែលមានការវិនិច្ឆ័យមិនល្អ និងអាទិភាពខុសឆ្គង។ ប្រាក់រាប់ពាន់លានដុល្លារបានចំណាយប្រាក់ច្រើនលើគម្រោងឆ្កួតៗ ដូចជា San Francisco-to-L.A ។ រថភ្លើងលឿនបង្ហាញថាគ្មាននរណាម្នាក់នៅក្នុង Sacramento កំពុងស្វែងរកអ្នកបង់ពន្ធឡើយ។ ខ្ញុំទទួលបានការគាំទ្រពីសមាគមអ្នកបង់ពន្ធ Howard Jarvis ពីព្រោះខ្ញុំការពារសំណើប្រ.មតិ 13 យ៉ាងមុតមាំ។ ខ្ញុំនឹងក្លាយជាអ្នកឃ្លាំមើលរបស់អ្នកហើយនឹងប្រយុទ្ធប្រឆាំងដើម្បីលុបចោលនូវពន្ធឧស្ម័ន និងរថយន្តថ្មីដែលហួសចំណាប់អារម្មណ៍ដែលបានប៉ះពាល់ដល់ហោប៉ៅរបស់គ្រួសារដែលមានជីវភាពមធ្យម។ ក្នុងនាមជាម្ចាស់អាជីវកម្មខ្នាតតូចគ្រួសារអាជីវកម្មរបស់ខ្ញុំផ្តល់ឱ្យខ្ញុំនូវបទពិសោធន៍ផ្ទាល់ជាមួយបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។ ក្នុងនាមជាអ្នកតស៊ូមតិអ្នកបង់ពន្ធខ្ញុំធ្វើការ ដើម្បីបន្ថយវិក្កយបត្រពន្ធរបស់អ្នកកែតម្រូវបទបញ្ជា និងលុបចោលការបិទផ្លូវទៅកាន់ការរីកចម្រើនការងារហើយនឹងបន្តធ្វើដូច្នេះនៅគណៈកម្មការពន្ធដារសមភាព។ ខ្ញុំនឹងប្រយុទ្ធប្រឆាំងដើម្បីលុបបំបាត់កាកសំណល់របស់រដ្ឋាភិបាល កាត់បន្ថយថវិកា និងបញ្ឈប់ការដំឡើងពន្ធដែលក្លែងបន្លំដូចជាថ្លៃឈ្នួល។ ខ្ញុំជាពលរដ្ឋកាលីហ្វូញ៉ា ជំនាន់ទីប្រាំ ប្តី និងឪពុក។ ខ្ញុំចង់ឱ្យកូនៗរបស់ខ្ញុំ និងរបស់អ្នកអាចមានលទ្ធភាពរស់នៅ ធ្វើការ និងចិញ្ចឹមគ្រួសាររបស់ពួកគេនៅទីនេះ។ ខ្ញុំនឹងមានកិត្តិយសណាស់ក្នុងការទទួលបាន ការបោះឆ្នោតរបស់អ្នក ហើយសន្យាថានឹងតស៊ូដើម្បីអ្នកដែលជាអ្នកបង់ពន្ធ។ ចូលមើល *www.tedgaines.com* ដើម្បីស្វែងយល់បន្ថែម និងដឹងពីមូលហេតុដែលក្រុមអ្នកបង់ពន្ធ និងអតីតអ្នកតស៊ូមតិអ្នកបង់ពន្ធនៅគណៈកម្មការពន្ធដារសមភាពគាំទ្រខ្ញុំ។ សូមអរគុណ។

1911 Douglas Blvd.
Ste. 85-122
Roseville, CA 95661

ទូរស័ព្ទ៖ (916) 827-6115
អ៊ីមែល៖ ted@tedgaines.com
tedgaines.com

Tom Hallinan | ប្រជាធិបតេយ្យ

គណៈកម្មការពន្ធដារសមភាពលែងចាំបាច់ទៀតហើយ។ ខ្ញុំនឹងធ្វើការដើម្បីបិទទ្វារវា។ ប្រសិនបើអ្នកយល់ស្រប ខ្ញុំនឹងអបអរការពិចារណារបស់អ្នក។ សូមអរគុណ, Tom Hallinan *www.tomhallinan.com*

P.O. Box 2145
Ceres, CA 95307

ទូរស័ព្ទ៖ (209) 324-6205
អ៊ីមែល៖ tom4boe@gmail.com
www.tomhallinan.com

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះដោយព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជន ដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្តីថ្លែងការណ៍របស់បេក្ខជន

គណៈកម្មការពន្ធដារសមភាព

មណ្ឌល 2

Malia Cohen | ប្រជាធិបតេយ្យ

កំពុងតែដំណើរការសម្រាប់គណៈកម្មការពន្ធដារសមភាព ដើម្បីដាក់ការប្រាក់សម្រាប់ប្រជាជនមុនការប្រាក់ពិសេស។ ក្នុងនាមជាប្រធានគណៈកម្មការត្រួតពិនិត្យទីក្រុង San Francisco ខ្ញុំបានធ្វើជាអ្នកតស៊ូមតិដែលមិនចេះភ័យខ្លាចសម្រាប់ប្រជាជនដែលកំពុងធ្វើការ ការពារប្រាក់ឈ្នួលអប្បបរមា $15, វិនិយោគនៅក្នុងផ្ទះសម្បែងដែលមានលទ្ធភាពចំណាយ ប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិបង្កើតកូន, និងតស៊ូមតិដើម្បីផ្តល់ជូនគ្រួសារមានប្រាក់ចំណូលទាបជាមួយនឹងការថែទាំសុខភាព។ ខ្ញុំគឺជាបេក្ខជនតែមួយរូបគត់នៅក្នុងការប្រណាំងប្រជែងនេះ ដែលមានបទពិសោធន៍ផ្នែកហិរញ្ញវត្ថុដែលត្រូវការដើម្បីទទួលលទ្ធផល។ ក្នុងនាមជាប្រធានគណៈកម្មការថវិកា និងហិរញ្ញវត្ថុ ខ្ញុំមើលការខុសត្រូវថវិកា $11 ពាន់លាន និងគ្រប់គ្រងវិធានការពន្ធ ថ្លៃឈ្នួល ប្រាក់ចំណូល ការអភិវឌ្ឍឡើងវិញ និងអចលនទ្រព្យរបស់ទីក្រុង។ ប្រសិនបើជាប់ឆ្នោត, ខ្ញុំនឹងនាំមកនូវ *តម្លាភាព គណេនយ្យភាព និងភាពយុត្តិធម៌* ជូនគណៈកម្មការពន្ធដារសមភាព និងជំរុញខ្លាំងក្លាដើម្បីបង្កើតនូវស្តង់ដារ និងបទបញ្ជាដែលទប់ស្កាត់ការកេងប្រវ័ញ្ចប្រព័ន្ធពន្ធលើអចលនទ្រព្យរបស់យើង។ ជាមួយនឹងបទពិសោធន៍ជាងបីទសវត្សរ៍ផ្នែកសេវាសាធារណៈ ខ្ញុំមានកំណត់ត្រាតាមដានបង្ហាញភ័ស្តុតាងអំពីការប្រាក់ពិសេស។ ខ្ញុំមានមោទនភាពដែលបាននាំមុខគេផ្នែកនីតិកម្មក្នុងការហាមប្រាមផលិតផលមានជាតិថ្នាំជក់នៅទីក្រុង San Francisco យកឈ្នះលើក្រុមហ៊ុនថ្នាំជក់ធំៗ Big Tobacco ដែលផ្សាយពាណិជ្ជកម្មដោយវិសមាមាត្រទៅកាន់យុវជន សហគមន៍ស្បែកខ្មៅ និងបុគ្គលដែលជា (Lesbian, Gay, Bisexual, Transgender, and Queer, LGBTQ+)។ ហេតុដូច្នេះហើយបានជាខ្ញុំត្រូវបានការគាំទ្រពី *សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក Kamala Harris, គណបក្សប្រជាធិបតេយ្យ California, អ្នកពន្លត់អគ្គីភ័យអាជីពរដ្ឋ California, សហព័ន្ធគ្រូបង្រៀនរដ្ឋ California, សមាគមគិលានុប្បដ្ឋាករដ្ឋ California, AFSCME California, Equality California,* និងមេដឹកនាំទូទាំងរដ្ឋ។ នៅក្នុងឱកាសប្រវត្តិសាស្ត្រនេះភាពជាអ្នកដឹកនាំដ៏រឹងមាំគឺសំខាន់ជាងពេលណាទាំងអស់។ ខ្ញុំត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលយកបញ្ហាប្រឈមបន្ទាន់ដែលប្រជាពលរដ្ឋកាលីហ្វូញ៉ា កំពុងជួបប្រទះ និងប្រយុទ្ធប្រឆាំងសម្រាប់ក្រុមគ្រួសារដែលកំពុងធ្វើការ។ ស្វែងយល់បន្ថែមនៅ *www.electmalia.com*។

2201 Broadway St., Suite M-2
Oakland, CA 94612

Tel: (415) 769-6285
E-mail: info@electmalia.com
Electmalia.com
Facebook.com/MaliaCohen

Mark Burns | សាធារណរដ្ឋ

វាគឺជាពេលវេលាដែលត្រូវបញ្ចប់ស្ថានភាពដដែលនៃ 'ពន្ធកាន់តែច្រើននឹងកែខៃបញ្ហារបស់យើង។' អ្នកបង់ពន្ធរដ្ឋ California មានបន្ទុកខ្ពស់បំផុតនៅសហរដ្ឋអាមេរិក។ ក្នុងនាមជាអ្នកគាំទ្រដ៏ស្មោះត្រង់ និងរយៈពេលវែងនៃសំណើប្រជាមតិ 13 និងសំណើប្រជាមតិ 60 & 90 (ការផ្ទេរមូលដ្ឋានពន្ធលើអចលនទ្រព្យសម្រាប់ព្រឹទ្ធាចារ្យ) ខ្ញុំនឹងធ្វើការដើម្បីធ្វើឲ្យប្រព័ន្ធយើងកាន់តែមានយុត្តិធម៌សម្រាប់អ្នកទាំងអស់គ្នា។ អស់រយៈពេល 32 ឆ្នាំកន្លងមកហើយ ខ្ញុំបានធ្វើការនៅក្នុងអាជីវកម្មអចលនទ្រព្យលំនៅដ្ឋាននៅ Silicon Valley និងមើលឃើញថាពន្ធលើអចលនទ្រព្យ និងពន្ធលើការលក់ឈានដល់កម្រិតដែលគួរតែគាំទ្រដល់រដ្ឋាភិបាលរដ្ឋ California បានល្អនៅពេលអនាគត និងដាក់បញ្ចូលអតិរេក និងធនបម្រុង។ ផ្ទុយមកវិញ យើងឃើញពីកិច្ចប្រឹងប្រែងជាប់ជានិច្ចក្នុងការដំឡើងពន្ធបន្ថែម និងដោយគ្មានគោលបំណងសំខាន់ ក្រៅតែពីដកយកមូលនិធិមកវិញ ដោយបានចំណាយកើនឡើង និងមានការប្តេជ្ញាចិត្តជ្រុលហួសហេតុពីតំណាងរាស្ត្រ និងអ្នកធ្វើច្បាប់។ ខ្ញុំនឹងប្រយុទ្ធដើម្បីកែលម្អគណនេយ្យភាព និងប្រសិទ្ធភាពនៅក្នុងគណៈកម្មការពន្ធដារសមភាព។ ខ្ញុំបានធ្វើជាប្រធានគណៈកម្មការមើលការខុសត្រូវពលរដ្ឋសម្រាប់មណ្ឌលសិក្សាធិការថ្នាក់ K–8 និងថ្នាក់ទី 9–12 នៅក្នុងសហគមន៍ខ្ញុំអស់រយៈពេលជិតមួយទសវត្សរ៍កន្លងមកហើយ។ ខ្ញុំបានប្រយុទ្ធប្រឆាំង (ពីរដង) នៅក្នុងខោនធីកំណើតខ្ញុំផ្ទាល់ ដើម្បីអភិរក្ស សំណើប្រ.មតិ 90 សម្រាប់ព្រឹទ្ធាចារ្យ។ ខ្ញុំទទួលបន្ទុកពន្ធលើអចលនទ្រព្យ និងផលប៉ះពាល់របស់វាទៅលើគ្រួសារ និងបុគ្គលជារៀងរាល់ថ្ងៃ។ លទ្ធភាពចំណាយលើផ្ទះសម្បែងប៉ះពាល់ទៅលើមនុស្សគ្រប់គ្នា និងមួយផ្នែកធំនៃពន្ធ លើអចលនទ្រព្យ។ វាគឺជាពេលដែលត្រូវជ្រើសរើសនរណាម្នាក់ដែលយល់ពីបញ្ហា ហើយនឹងខិតខំគ្រប់បែប យ៉ាងដើម្បីកាត់បន្ថយបន្ទុកដែលយើងទាំងអស់គ្នាប្រឈមនៅក្នុងការរស់នៅរដ្ឋ California។ សូមចូលមើល *www.burnsforboe2018.com* សម្រាប់ព័ត៌មានបន្ថែម។

1601 So. De Anza Blvd.,
Suite 150
Cupertino, CA 95014

ទូរស័ព្ទ៖ (408) 777-9997
អ៊ីម៉ែល៖ mark@markburns.com
www.burnsforBOE2018.com

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះដោយព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជន ដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្តីថ្លែងការណ៍របស់បេក្ខជន

គណៈកម្មការពន្ធដារសមភាព

មណ្ឌល 3

Tony Vazquez | ប្រជាធិបតេយ្យ

គ្មានសេចក្តីថ្លែងការណ៍របស់បេក្ខជនទេ។

G. Rick Marshall | សាធារណរដ្ឋ

ខ្ញុំជា CFO នៃបណ្តាញសកម្មភាពអ្នកបង់ពន្ធរដ្ឋ California ។ កិច្ចប្រឹងប្រែងរបស់យើងបានសង្គ្រោះលុយអ្នកបង់ពន្ធដែលមិនបានប្រាប់ ដោយជីកកកាយរកភាពខ្ជះខ្ជាយ និងអំពើពុករលួយនៅក្នុងការចំណាយសាធារណៈ។ នៅពេលជាប់ឆ្នោតជាគណៈកម្មការពន្ធដារសមភាពរដ្ឋ (BOE) ខ្ញុំនឹងធ្វើការដោយថ្លៃថ្នូរដើម្បីការងារលុយអ្នកបង់ពន្ធរបស់យើងពីភាពខ្ជះខ្ជាយ និងអំពើពុករលួយស្រដៀងគ្នានេះ។ ខ្ញុំគឺជាស្វាមី ឪពុក និងស្នងការផែនការ។ សំខាន់ជាងគេបំផុត ដូចអ្នកដែរ ខ្ញុំគឺជាអ្នកបង់ពន្ធម្នាក់។ ការការពារសុចរិតភាពនៃ BOE របស់យើងគឺខ្ពង់ខ្ពស់បំផុត។ ក្នុងនាមជាសមាជិក BOE មួយរូប មូលដ្ឋាននៃសេវារបស់ខ្ញុំនឹងជា “សេវាសាធារណៈ” មិនមែនជា “សេវាផ្ទាល់ខ្លួនឯង” ឡើយ។ វាដឹកនាំខ្ញុំនៅពេលរៃអង្គាសមូលនិធិសម្រាប់ Muscular Dystrophy ផ្តល់អំណោយជូនកូនអ្នកជាប់ពន្ធនាគារនៅថ្ងៃបុណ្យណូអែល និងត្រួតពិនិត្យបុរស និងស្ត្រីវ័យក្មេងតាមរយៈ Junior Achievement ។ នៅក្នុងឆ្នាំទាំងអស់របស់ខ្ញុំនៅក្នុងរដ្ឋាភិបាលមូលដ្ឋាន ដែលសេវាដំបូងគឺជាស្នងការទឹក ហើយបន្ទាប់មកទៀតជាស្នងការផែនការ ខ្ញុំមិន *ដែល* ធ្លាប់ស្ថិតក្រោមការសង្ស័យដោយការសើបអង្កេតដោយរដ្ឋ និង/ឬ សហព័ន្ធឡើយ។ ខ្ញុំមិនធ្លាប់ *ជា* គោលដៅនៃការសើបអង្កេតឧក្រិដ្ឋកម្មឡើយ។ *ភាពស្មោះត្រង់។ សុចរិតភាព។ តម្លាភាព។ សេវាសាធារណៈ។* វាគឺជាអ្វីដែល Rick Marshall សន្យាជូនអ្នក។ ខ្ញុំគាំទ្រការលុបបំបាត់ពន្ធលើហ្គាស និងប្រឆាំងពន្ធលើកញ្ចប់ទឹកភ្លៀងព្រិល។ ខ្ញុំនឹងការពារ និងគាំទ្រសំណើប្រ.មតិ 13។ ហេតុដូច្នេះហើយបានជា PAC នៃសមាគមអ្នកបង់ប្រាក់ Howard Jarvis បានផ្តល់កិត្តិយសដល់ខ្ញុំជាមួយនឹងការគាំទ្ររបស់ពួកគេ។ ចំណាត់ថ្នាក់នយោបាយបានធ្វើឲ្យអ្នកបរាជ័យ។ ប្រសិនបើអ្នកឈឺដោយសារតែនយោបាយជាធម្មតា ជាមួយរដ្ឋាភិបាលដែលខ្ជះខ្ជាយលុយពន្ធរបស់អ្នក—គិតពន្ធថ្លៃពេក ប៉ុន្តែដោះស្រាយបានតិចតួច—បោះឆ្នោតគាំទ្រ G. Rick Marshall ធ្វើជាគណៈកម្មការពន្ធដារសមភាពរដ្ឋ។ តើខ្ញុំអាចសុំការបោះឆ្នោតរបស់អ្នកបានទេ?

2390 Crenshaw Boulevard,
#409
Torrance, CA 90501

Tel: (310) 346-7425
E-mail: rick@grickmarshall.com
grickmarshall.com
www.facebook.com/grickmarshall

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះដោយព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជន ដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្ដីថ្លែងការណ៍របស់បេក្ខជន

គណៈកម្មការពន្ធដារសមភាព

មណ្ឌល 4

Mike Schaefer | ប្រជាធិបតេយ្យ

ជួប *Mike Schaefer* មានការសិក្សាល្អបំផុត មានបទពិសោធន៍ច្រើនបំផុត មានការអប់រំ UC Berkeley, Notre Dame, USC, San Diego State និង Georgetown មន្ត្រីច្បាប់នៃរដ្ឋាភិបាលក្រុង ខោនធី រដ្ឋ និងសហព័ន្ធពីព្រះរាជអាជ្ញាសមាជិកក្រុមប្រឹក្សាដល់ គណៈកម្មការមូលប័ត្រ និងជួញដូរ (SEC) និង California សើបអង្កេតមូលបត្រសមាជិកគណៈកម្មការសុខាភិបាលសាធារណៈ, គូប្រជែងដែលមានបទពិសោធន៍ទទួលបានជោគជ័យក្នុងការវាយតម្លៃអចលនទ្រព្យនៅចំពោះគណៈកម្មការពន្ធដារសមភាព។ ត្រូវបានគាំទ្រនៅក្នុងការបោះឆ្នោតមុនដោយមន្ត្រីនគរបាលសមាគមមន្ត្រីនគរបាលខោនធី។ គាំទ្រ *សមាគមអ្នកបង់ពន្ធ Howard Jarvis* ដែលការពារយើងទាំងអស់គ្នាពីការកើនឡើងដោយអយុត្តិធម៌នៅក្នុងពន្ធដារណាមួយរបស់យើង។ អ្នកដើមកំណើតនៃ San Diego ដែលជាអ្នកជំនួញដ៏មានការប្រកួតប្រជែងម្នាក់ដឹងពីរបៀបដែលត្រូវប្រុងប្រយ័ត្នថារដ្ឋាភិបាលគ្រប់ជាន់ថ្នាក់គោរពម្ចាស់ផ្ទះ និងអ្នកជំនួញតូចតាច។ វាគ្មិនញឹកញាប់នៅក្រុមពលរដ្ឋ។ មេដឹកនាំកាតូលិកសកម្ម។ កូនប្រុសជោគជ័យ Derek នៅក្នុងការគ្រប់គ្រងមហោស្រពតន្ត្រី Coachella (ជួបជាមួយក្រុម Beatle និង Rolling Stones)។ Mike បានធ្វើការជាមួយមេដឹកនាំមកពី Dr. Seuss រហូតដល់ Dr. Salk, លោកអភិបាល Brown & Brown រហូតដល់ Reagan; អ្នកសម្តែងចាប់ពី Bob Hope រហូតដល់គំរូអ្នកប្រដាល់ Archie Moore, LL Cool J, មិត្តរួមថ្នាក់ Frank Zappa, Debbie Reynolds។ ទទួលស្គាល់ទូទាំងប្រទេសសម្រាប់យុត្តិធម៌ក្នុងច្បាប់បោះឆ្នោតដែលទទួលខុសត្រូវចំពោះការចុះបញ្ជីឈ្មោះមិនតាមលំដាប់អក្សរក្រម នៃបេក្ខជននៅលើសន្លឹកឆ្នោតរដ្ឋ California តម្រូវឱ្យមានសមរភូមិលេងស្មើគ្នា។ អ្នកគាំទ្រ, San Diego បេសកកម្មសង្គ្រោះសត្វ។

4494 Mentone St. #12
San Diego, CA 92107

ទូរស័ព្ទ៖ (213) 479-6006
អ៊ីម៉ែល៖ oz.blueman@yahoo.com
equalization4.org

Joel Anderson | សាធារណរដ្ឋ

ចូលមើល *taxpayersforanderson.com* សម្រាប់ព័ត៌មានបន្ថែម។ នៅឆ្នាំ 1978, Howard Jarvis បានសរសេរសំណើប្រ.មតិ 13, ហើយបន្ទាប់ពីវាត្រូវបានអនុម័ត លោកបានបង្កើតសមាគមអ្នកបង់ពន្ធ Howard Jarvis ដើម្បីការពារសំណើប្រ.មតិ 13 និងអ្នកបង់ពន្ធពីគោលនយោបាយយកពន្ធដោយបំពាន។ (hjta.org) *Joel Anderson* ទទួលបានការគាំទ្រពីអ្នកការពារសំណើប្រ.មតិ 13 ឈានមុខគេរបស់រដ្ឋ California, សមាគមអ្នកបង់ពន្ធ Howard Jarvis ។ Anderson នឹងបន្តការពារសិទ្ធិសំណើប្រ.មតិ13 របស់យើង និងចូលរួមជាមួយគ្រួសារដែលកំពុងធ្វើការប្រឆាំងនឹងកំណើនពន្ធ ពីព្រោះបុគ្គលគ្រប់រូបសមតែនឹងទទួលបានការប្រព្រឹត្តជាមួយដោយស្មើភាព។ គេហៅលោកថា *"ដួងតារាសម្រាប់អ្នកបង់ពន្ធ"* ដោយប្រធានសមាគមអ្នកបង់ពន្ធ Howard Jarvis ហើយទទួលបានចំណាត់ថ្នាក់ច្បាប់ខ្ពស់បំផុតរបស់ក្រុម។ *លោកដឹកនាំការប្រឆាំងនឹងកំណើនពន្ធលើហ្គាស* ពីព្រោះវាគឺជារឿងត្រឹមត្រូវដែលត្រូវធ្វើ—ដើម្បីក្រោកឈរតំណាងឲ្យប្រជាជនដែលប្រឆាំងនឹងការផ្ដល់មូលនិធិចំពោះការប្រាប់អាថ៌កំបាំងការប្រាក់ពិសេស។ លោកទទួលបានចំណាត់ថ្នាក់កិត្តិយសខ្ពស់បំផុតពីសមាគមអ្នកបង់ពន្ធរដ្ឋ *California*, *សហព័ន្ធអាជីវកម្មឯករាជ្យជាតិ*និង *សភាពាណិជ្ជកម្មរដ្ឋ California* សម្រាប់ការងាររបស់លោកក្នុងការជួយឲ្យការងារ និងសេដ្ឋកិច្ចរីកចម្រើន។ លោកទទួលបានឈ្មោះថា *"អ្នកធ្វើច្បាប់ព្រឹទ្ធសភារដ្ឋ California ប្រចាំឆ្នាំ"* ដោយ *សមាគមអាជីវកម្មខ្នាតតូចរដ្ឋ California* និង *តុមូលអាជីវកម្មខ្នាតតូចរដ្ឋ California* សម្រាប់ភាពជាអ្នកដឹកនាំរបស់លោកដែលធ្វើការដើម្បីជំរុញអាជីវកម្មខ្នាតតូច និងបង្កើតឱកាសអាជីព។ លោកមានការទទួលស្គាល់ជាមួយនឹងពានរង្វាន់កិត្តិយសផ្នែក *"អ្នកធ្វើច្បាប់ប្រចាំឆ្នាំ"* *ចំនួនប្រាំមួយ* ពី *អតីតយុទ្ធជនអាមេរិក*, *ទាហានអាមេរិក*, *ក្រុមប្រឹក្សាអតីតយុទ្ធជនមេបញ្ជាការរដ្ឋ California*, *នាយកដ្ឋានអតីតយុទ្ធជនសង្គ្រាមក្រៅប្រទេសរដ្ឋ California*, *អតីតយុទ្ធជនអាមេរិកនៅវៀតណាម*, និង *សមាគមមន្ត្រីយោធាអាមេរិក* ក្រុមប្រឹក្សាធម្មនុញ្ញរដ្ឋ California ដើម្បីការពារអត្ថប្រយោជន៍អតីតយុទ្ធជន និងការពារពួកគេពីពន្ធអយុត្តិធម៌។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យពហុបច្ចេកវិទ្យារដ្ឋ California, Pomona ខណៈពេលធ្វើការពេញម៉ោងជាអ្នកវាយតម្លៃអចលនទ្រព្យសម្រាប់សមាគម ប្រាក់សន្សំ និងប្រាក់កម្ចីសហព័ន្ធទីមួយ Pomona ។ ការអប់រំ & បទពិសោធន៍—បេក្ខជនដែលមានលក្ខណៈសម្បត្តិពេញលេញបំផុតសម្រាប់ក្រុមប្រឹក្សាភិបាលពន្ធដារសមកម្ម ជាមួយនឹងបទពិសោធន៍អាជីវកម្មរាប់ទសវត្សរ៍ និងកំណត់ត្រាសាធារណៈដែលការពារអ្នកបង់ពន្ធ។

ទូរស័ព្ទ៖ (619) 204-2200
អ៊ីម៉ែល៖ ande434@cox.net
taxpayersforanderson.com

លំដាប់លេខរៀងនៃសេចក្ដីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះដោយព្រាវៗ។ សេចក្ដីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្ដល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្ដីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់ដោយស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជន ដែលមិនបានដាក់ស្នើសេចក្ដីថ្លែងការណ៍អាចមានលក្ខណៈគ្រប់គ្រាន់ ដើម្បីបង្ហាញនៅលើសន្លឹកឆ្នោត។

សេចក្តីថ្លែងការណ៍របស់បេក្ខជន

ស្នងការអប់រំសាធារណៈ (ការិយាល័យគ្មានបក្សព័ន្ធ)

- ក្នុងឋានៈជានាយកសាលាសាធារណៈរបស់រដ្ឋ ផ្តល់នូវទិសដៅគោលនយោបាយអប់រំដល់សាលារៀនក្នុងមូលដ្ឋាន ហើយធ្វើការជាមួយសហគមន៍អប់រំដើម្បីបង្កើនការបំពេញការងារផ្នែកអប់រំ។
- ដឹកនាំនាយកដ្ឋានអប់រំ និងអនុវត្តគោលនយោបាយដែលកំណត់ដោយក្រុមប្រឹក្សាអប់រំរបស់រដ្ឋ។
- បម្រើជាអតីតសមាជិកពេញច្បាប់នៃក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធអប់រំជាន់ខ្ពស់របស់រដ្ឋ។

Tony K. Thurmond

ខ្ញុំកំពុងឈរឈ្មោះសម្រាប់អ្នកមើលការខុសត្រូវរដ្ឋនៃការបង្រៀនសាធារណៈ ពីព្រោះខ្ញុំជឿថា សាលារៀនសាធារណៈដែលមានគុណភាពខ្ពស់គឺជាគន្លឹះទៅនឹងអនាគតរបស់ California។ ការអប់រំបានសង្គ្រោះជីវិតរបស់ខ្ញុំ ដោយអនុញ្ញាតឱ្យខ្ញុំយកឈ្នះលើការចាប់ផ្តើមបន្ទាបខ្លួន។ ខ្ញុំត្រូវបានចិញ្ចឹមដោយអ្នកម្តាយតែម្នាក់ឯងដែលបានធ្វើនិរប្រវេសន៍ពីប្រទេសប៉ាណាម៉ាឱ្យក្លាយជាគ្រូបង្រៀនម្នាក់។ គាត់បាត់បង់ការតស៊ូរបស់គាត់ទៅនឹងជម្ងឺមហារីក នៅពេលខ្ញុំមានអាយុទើបតែ 6 ឆ្នាំ ដូច្នេះខ្ញុំបានធំធាត់ដោយគិតថា មហាវិទ្យាល័យគឺមិនអាចឈានទៅដល់ឡើយ។ ប៉ុន្តែជាមួយជំនួយរបស់គ្រូបង្រៀន គាំទ្រ និងការអប់រំសាធារណៈដ៏រឹងមាំ ខ្ញុំបានក្លាយជាប្រធានក្រុមនិស្សិតនៅសាកលវិទ្យាល័យរបស់ខ្ញុំ និងបានបន្តរកបានសញ្ញាប័ត្រអនុបណ្ឌិតចំនួនពីរ។ ក្នុងនាមជាអ្នកគាំពារពេញមួយជីវិតសម្រាប់យុវជន និងគ្រួសារ ខ្ញុំបានចំណាយពេល 12 ឆ្នាំធ្វើការនៅសាលារៀន និងបានចាប់ផ្តើមអាជីពរបស់ខ្ញុំដំណើរការកម្មវិធីបន្ទាប់ពីសាលារៀន និងប្រឹក្សាយុវជនដែលស្ថិតក្នុងហានិភ័យ។ ខ្ញុំមានមោទនភាពបម្រើលើក្រុមប្រឹក្សាភិបាលមណ្ឌលសិក្សាធិការរួបរួម West Contra Costa, ក្រុមប្រឹក្សាក្រុង Richmond ហើយឥឡូវនេះក្នុងសភារដ្ឋ California។ ក្នុងនាមជាអ្នកមើលការខុសត្រូវ ខ្ញុំនឹងធ្វើការដើម្បីធានាថាកុមារនៅ California មានការចូលទៅកាន់សាលារៀននៅសង្កាត់ដែលមានគុណភាពខ្ពស់។ ដើម្បីសម្រេចបានការនោះ ខ្ញុំនឹង៖ 1) *ធ្វើទំនើបកម្មកម្មវិធីសិក្សារបស់យើង* ដើម្បីរៀបចំសិស្សសម្រាប់ការងារក្នុងការលូតលាស់ឆាប់រហ័សរបស់យើងនៅសេដ្ឋកិច្ចសហវត្សទី 21 នេះ —2) *ធ្វើឱ្យប្រសើរឡើងដល់ការអប់រំ* បណ្តុះបណ្តាលការងារវិជ្ជាជីវៈ ការបញ្ជាក់វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា—3) *វិនិយោគលើគ្រូបង្រៀនរបស់យើង* ដោយដំឡើងប្រាក់ឈ្នួលរបស់ពួកគេ ដោយផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈ និងដោយផ្តល់ឱ្យគ្រូបង្រៀននូវលំនៅដ្ឋានដែលល្មមអាចចំណាយបាន ដើម្បីឱ្យពួកគេអាចល្មមចំណាយបានក្នុងការរស់នៅក្នុងបណ្តាសហគមន៍កន្លែងដែលពួកគេបង្រៀន—4) *ផ្តល់អាទិភាពដល់ការគិតហ្មត់ចត់*មិនមែនបង្រៀនសម្រាប់ការធ្វើតេស្តឡើយ និង—5) *ប្រយុទ្ធប្រឆាំងដើម្បីបញ្ឈប់របៀបវារៈប្រឆាំងនឹងការអប់រំរបស់ Betsy DeVos* ពីក្មេងៗ California ដែលរងគ្រោះថ្នាក់។ ខ្ញុំត្រូវបានគាំទ្រដោយ *ព្រឹទ្ធបុរសសហរដ្ឋអាមេរិក Kamala Harris, គណបក្សប្រជាធិបតេយ្យ California, អ្នកមើលការខុសត្រូវបច្ចុប្បន្ន Tom Torlakson, សម្ព័ន្ធភាពជាឪពុកម្តាយ California ដែលបានគ្រោងទុក, Sierra Club, សមភាព California, Los Angeles Times, Sacramento Bee, គ្រូបង្រៀន, គិលានុបដ្ឋាយិកា, អ្នកពន្លត់អគ្គីភ័យ*និងច្រើនបន្ថែមទៀត។

P.O. Box 2145
Richmond, CA 94802

ទូរស័ព្ទ៖ (510) 859-3241
អ៊ីមែល៖ tony@tonythurmond.com
TonyThurmond.com
facebook.com/Tony.Thurmond

Marshall Tuck

ក្នុងនាំជាកូនប្រុសរបស់គ្រូបង្រៀនសាលារៀនសធារណៈ ផលិតផលរបស់សាលារៀនសាធារណៈ និងឪពុកម្តាយសាលារៀនសាធារណៈ ខ្ញុំជឿយ៉ាងមុតមាំលើអំណាចសាលារៀនសាធារណៈ។ ប៉ុន្តែសាលារៀនសាធារណៈ *រដ្ឋ California ត្រូវការការផ្លាស់ប្តូរដ៏ធំធេង* ដើម្បីផ្តល់ឱ្យសិស្ស *ទាំងអស់* នូវការអប់រំដែលពួកគេសមនឹងទទួលបាន។ ខ្ញុំកំពុងឈរឈ្មោះសម្រាប់អ្នកមើលការខុសត្រូវរដ្ឋ ពីព្រោះខ្ញុំបានដឹកនាំប្រព័ន្ធសាលារៀនសាធារណៈដែលបានផ្តល់ជូនលទ្ធផលពិតប្រាកដសម្រាប់កូនៗ។ ធ្វើការជាមួយគ្រូបង្រៀន និងឪពុកម្តាយ យើងបានដាក់ប្រាក់មូលនិធិបន្ថែមទៅបន្ទប់រៀន កាត់បន្ថយការិយាធិបតេយ្យ ហើយបានត្រៀមបម្រុងសិស្សច្រើនទៀតសម្រាប់មហាវិទ្យាល័យ និងអាជីព។ ខ្ញុំបានជួយបង្កើត 10 សាលាវិទ្យាល័យសាធារណៈថ្មីៗក្នុងសង្កាត់ដែលមានប្រាក់ចំណូលទាប ហើយ 8 សាលាក្នុងចំណោមវាត្រូវបានផ្តល់ចំណាត់ថ្នាក់ក្នុងចំណោមសាលាវិទ្យាល័យកំពូលៗនៅអាមេរិកដោយ *ព័ត៌មានសហរដ្ឋអាមេរិក និងរបាយការណ៍ពិភពលោក*។ នៅពេលខ្ញុំដឹកនាំកិច្ចប្រឹងប្រែងដើម្បីបង្វែរសាលារៀនសាធារណៈដែលកំពុងតស៊ូនៅទីក្រុង Los Angeles យើង *បានលើកកម្ពស់អត្រាបញ្ចប់ការសិក្សាឱ្យបានច្រើនជាង 60% ហើយមានការកែចំណែនផ្នែកសិក្សាធំបំផុតនៃប្រព័ន្ធសាលាធំៗ នៅរដ្ឋ California*។ "មហាវិទ្យាល័យមាតាបិតា" របស់យើង បានក្លាយជាគំរូទូទាំងរដ្ឋសម្រាប់ឲ្យឪពុកម្តាយចូលរួមកាន់តែច្រើននៅក្នុងការអប់រំកូនៗរបស់ពួកគេ។ ក្នុងនាមជាស្នងការអប់រំរដ្ឋ ខ្ញុំនឹងក្រោកឈរតតាំងនឹងអ្នកនយោបាយនៅ Sacramento *និង* Washington, DC ហើយធ្វើអ្វីដែលល្អបំផុតសម្រាប់សិស្សានុសិស្ស។ អាទិភាពរបស់ខ្ញុំគឺ៖ (1) ទទួលបានមូលនិធិបន្ថែមទៅក្នុងថ្នាក់រៀនក្នុងមូលដ្ឋាន និងកាត់បន្ថយការិយាធិបតេយ្យ និងកាកសំណល់ (2) ផ្តល់អំណាចដល់គ្រូបង្រៀន និងឪពុកម្តាយ ដើម្បីធ្វើការសម្រេចចិត្តលើការអប់រំបន្ថែម (3) ពង្រីកការបណ្តុះបណ្តាលអាជីព និងរៀបចំមហាវិទ្យាល័យដើម្បីធានាថា សិស្សទាំងអស់ត្រូវបានរៀបចំឱ្យជោគជ័យក្នុងសហវត្សទី 21 ។ សូមអានផែនការពេញលេញរបស់ខ្ញុំ នៅ *MarshallTuck.com* ។ តោះយើងផ្តល់ឱ្យកុមារ *ទាំងអស់* ក្នុង California នូវសាលារៀនសាធារណៈដែលពួកគេសមនឹងទទួលបាន។

20 Galli Drive, Suite A
Novato, CA 94949

ទូរស័ព្ទ៖ (657) 229-3579
អ៊ីមែល៖ marshalltuck@marshalltuck.com
www.MarshallTuck.com
www.facebook.com/TuckforCalifornia/

លំដាប់លេខរៀងនៃសេចក្តីថ្លែងការណ៍គឺត្រូវបានកំណត់ដោយការចាប់ឈ្នោះព្រាវៗ។ សេចក្តីថ្លែងការណ៍នៅលើទំព័រនេះ គឺត្រូវបានផ្តល់ដោយបេក្ខជន ហើយមិនត្រូវបានត្រួតពិនិត្យមើលភាពត្រឹមត្រូវឡើយ។ សេចក្តីថ្លែងការណ៍នីមួយៗត្រូវបានបញ្ជូន និងបង់យ៉ាងស្ម័គ្រចិត្តដោយបេក្ខជន។ បេក្ខជនដែលមិនបានដាក់ស្នើសេចក្តីថ្លែងការណ៍ អាចមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញខ្លួននៅលើសន្លឹកឆ្នោត។

ចៅក្រមតុលាការជាន់ខ្ពស់

សម្រាប់ព័ត៌មានបន្ថែមអំពីចៅក្រមយុត្តិធម៌ជាន់ខ្ពស់ និងនៃចៅក្រមយុត្តិធម៌ឧទ្ធរណ៍ ចូលមើល *www.voterguide.sos.ca.gov* ឬ *www.courts.ca.gov* ឬហៅទូរស័ព្ទ ឥតគិតថ្លៃ ខ្សែបណ្តាញអ្នកបោះឆ្នោត តាមលេខ (888) 345-4917។

នីតិវិធីនៃការបោះឆ្នោត

ស្ថិតក្រោមធម្មនុញ្ញរដ្ឋ California, យុត្តិធម៌នៃតុលាការជាន់ខ្ពស់ និងតុលាការឧទ្ធរណ៍គឺទទួលយកតាម ការបញ្ជាក់ដោយអ្នកបោះឆ្នោត។ សាធារណជនបោះឆ្នោត "គាំទ្រ" ឬ "ប្រឆាំង" លើថាតើរក្សាទុកចៅក្រមម្នាក់ ៗឬយ៉ាងណា។

ការិយាល័យយុត្ថាធិកាគឺគ្មានបក្សព័ន្ធ។

មុនពេលបុគ្គលម្នាក់អាចក្លាយជាចៅក្រមតុលាការខាងឧទ្ធរណ៍ រដ្ឋាភិបាលត្រូវតែប្រគល់ឈ្មោះបេក្ខជនទៅកាន់គណៈកម្មការវាយតម្លៃបេក្ខជននៃតុលាការ ដែលរួមមានសមាជិកសាធារណៈ និងមេធាវី។ គណៈកម្មការដឹកនាំការពិនិត្យឡើងវិញហ្មត់ចត់លើសាវតារ និងលក្ខណសម្បត្តិគ្រប់គ្រាន់របស់បេក្ខជនជាមួយការបញ្ជូលព័ត៌មានសហគមន៍ បន្ទាប់មកបញ្ជូនបន្តការវាយតម្លៃរបស់ខ្លួនលើបេក្ខជនទៅកាន់អភិបាលខេត្ត។

បន្ទាប់មកអភិបាលខេត្តពិនិត្យឡើងវិញការវាយតម្លៃរបស់គណៈកម្មការ និងជ្រើសតាំងបេក្ខជនជាផ្លូវការ ដែលលក្ខណសម្បត្តិគ្រប់គ្រាន់របស់ពួកគេ គឺប្រែប្រួលតាមមតិយោបល់សាធារណជន មុនពេលការប្រឡង និងការពិនិត្យឡើងវិញដោយគណៈកម្មការលើការតែងតាំងខាងតុលាការ។ គណៈកម្មការនោះរួមមាន ប្រធានអ្នកកាន់អំណាចតុលាការ California, អគ្គមេធាវី California, និងមន្ត្រីជាន់ខ្ពស់ដែលគ្រប់គ្រងលើចៅក្រមនៃតុលាការឧទ្ធរណ៍។ គណៈកម្មការតែងតាំងតុលាការ បន្ទាប់មក ត្រូវបញ្ជាក់ ឬបដិសេធការជ្រើសតាំង។ តែប្រសិនបើបានបញ្ជាក់ ទើបបេក្ខជនក្លាយជាអ្នកបម្រើការក្នុងចៅក្រម។

បន្ទាប់ពីការបញ្ជាក់ អ្នកកាន់អំណាចតុលាការត្រូវបានស្បថចូលក្នុងការិយាល័យ ហើយអាស្រ័យលើការអនុម័តរបស់អ្នកបោះឆ្នោតនៅការបោះឆ្នោតចៅហ្វាយខេត្តបន្ទាប់ និងនៅពេលបញ្ចប់នៃអាណត្តិនីមួយៗ។ អាណត្តិដែលបានចេញដោយ ធម្មនុញ្ញរដ្ឋ California សម្រាប់អ្នកកាន់អំណាចតុលាការនៃតុលាការជាន់ខ្ពស់ និងតុលាការឧទ្ធរណ៍ គឺ 12 ឆ្នាំ។ ចៅក្រមត្រូវបានបញ្ជាក់ដោយគណៈកម្មការលើការតែងតាំងខាងតុលាការ តែរហូតដល់ការបោះឆ្នោតចៅហ្វាយខេត្តបន្ទាប់ ដែលពេលវេលាណាមួយដែលពួកគេឈរឈ្មោះសម្រាប់ការរក្សាទុកនៃផ្នែកនៅសល់នៃអាណត្តិ បើមាន នៃអ្នកកាន់តំណែងមុខរបស់ពួកគេ ដែលនឹងមានរយៈពេលបួន ឬប្រាំបីឆ្នាំ។ (ក្រមបោះឆ្នោត ភាគ 9083។)

Carol A. Corrigan, សហការីចៅក្រម, តុលការជាន់ខ្ពស់ California

ការទទួលស្គាល់វិជ្ជាជីវៈមេធាវី៖ 1975

ការអប់រំ៖ J.D. សាកលវិទ្យាល័យ California, មហាវិទ្យាល័យច្បាប់ Hastings 1975; B.A., មហាវិទ្យាល័យ Holy Names 1970។

សាវតារច្បាប់វិជ្ជាជីវៈ: មេធាវីមណ្ឌលរងនៃខោនធី Alameda (1975–1985), រងជាន់ខ្ពស់ (1985–1987); សាស្ត្រចារ្យច្បាប់បន្ទាប់បន្សំ៖ សាកលវិទ្យាល័យ Notre Dame (2016–បច្ចុប្បន្ន); U.C. សាលារៀនច្បាប់ Berkeley (1984–1987 & 1989–1994); U.C. មហាវិទ្យាល័យច្បាប់ Hastings (1981–1987 & 1989–1991); សាកលវិទ្យាល័យ San Francisco សាលារៀនច្បាប់ (1987–1988); សាកលវិទ្យាល័យ Puget Sound សាលារៀនច្បាប់ (1981)។

សាវតារខាងតុលាការ៖ សហការីអ្នកកាន់អំណាចតុលាការ, តុលការជាន់ខ្ពស់ California, 2006–បច្ចុប្បន្ន; សហការីអ្នកកាន់អំណាចតុលាការ តុលាការឧទ្ធរណ៍ California, 1994–2006; ចៅក្រម, តុលការជាន់ខ្ពស់ ខោនធី Alameda, 1991–1994; ចៅក្រម, តុលាការក្រុង Oakland-Emeryville-Piedmont, 1987–1991; មហាវិទ្យាល័យ, មហាវិទ្យាល័យចៅក្រម California, 1989–បច្ចុប្បន្ន។

Leondra R. Kruger, សហការីចៅក្រមតុលាការ, តុលការជាន់ខ្ពស់ California

ការទទួលស្គាល់វិជ្ជាជីវៈមេធាវី៖ 2002

ការអប់រំ៖ សាលារៀនច្បាប់ Yale, J.D., 2001; សាកលវិទ្យាល័យ Harvard, A.B., 1997។

សាវតារផ្នែកច្បាប់អាជីព៖ ជំនួយការរងអគ្គមេធាវី, ការិយាល័យផ្តល់យោបល់ផ្នែកច្បាប់, ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក, 2013–2014; ជំនួយការអគ្គអ្នកដើរស្នើ និងអគ្គអ្នកដើរស្នើគោលការណ៍រងស្តីទី, ការិយាល័យអគ្គអ្នកដើរស្នើ, ក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក, 2007–2013; ជំនួយការសាស្ត្រាចារ្យវីស៊ីត, សាកលវិទ្យាល័យនៃសាលារៀនច្បាប់ Chicago ឆ្នាំ 2007; សហការី, Wilmer, Cutler, Pickering, Hale និង Dorr LLP, 2004–2006; ស្មៀនច្បាប់ទៅនឹងអ្នកកាន់អំណាចតុលាការនៃ តុលាការជាន់ខ្ពស់ John Paul Stevens, 2003–2004; ស្មៀនច្បាប់ទៅនឹងចៅក្រមតុលាការឧទ្ធរណ៍សហរដ្ឋអាមេរិក David S. Tatel, 2002–2003; សហការី, Jenner និង Block LLP, 2001–2002។

សាវតារខាងតុលាការ៖ សហការីចៅក្រមតុលាការ, តុលាការជាន់ខ្ពស់ California, 2015–បច្ចុប្បន្ន (ដែលបានតែងតាំងដោយ អភិបាលខេត្ត Jerry Brown និងដែលបានបញ្ជាក់ដោយគណៈកម្មការលើការតែងតាំងខាងតុលាការ)។

ការបោះឆ្នោតក្នុងរដ្ឋ California

ច្បាប់បោះឆ្នោតបឋមដោយបើកចំហរសម្រាប់បេក្ខជនកំពូលពីរនាក់ តម្រូវឱ្យចុះឈ្មោះបេក្ខជនទាំងពីរសម្រាប់ដំណែងតែងតាំងដោយអ្នកបោះឆ្នោត នៅលើសន្លឹកឆ្នោតតែមួយ។ ពីមុនត្រូវបានគេស្គាល់ថាជាការិយាល័យប្រកាន់បកព័ន្ធ ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោត គឺការិយាល័យអង្គនិតិបញ្ញត្តិរបស់រដ្ឋ ការិយាល័យសភាសហរដ្ឋអាមេរិក និងការិយាល័យធម្មនុញ្ញរបស់រដ្ឋ។

ទាំងនៅក្នុងការបោះឆ្នោតបឋមដោយបើកចំហរ និងការបោះឆ្នោតទូទៅ អ្នកអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយ ដោយមិនគិតពីគណបក្សអាទិភាពដែលអ្នកបានកំណត់យកនៅលើទម្រង់ចុះឈ្មោះបោះឆ្នោតរបស់អ្នកទេ។ នៅក្នុងការបោះឆ្នោតបឋម បេក្ខជនពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេ - មិនគិតពីគណបក្សអាទិភាព - នឹងបន្តទៅប្រកួតក្នុងការបោះឆ្នោតទូទៅ។ ទោះបីជាបេក្ខជនណាម្នាក់ទទួលបានសំឡេងភាគច្រើន (យ៉ាងហោចណាស់ 50 ភាគរយ +1) ក៏ដោយ ការបោះឆ្នោតទូទៅនៅតែត្រូវធ្វើ។

ប្រព័ន្ធបោះឆ្នោតបឋមដោយចំហរបស់រដ្ឋ California មិនអនុវត្តចំពោះបេក្ខជនដែលឈរឈ្មោះសម្រាប់ប្រធានាធិបតីអាមេរិក គណៈកម្មាធិការកណ្តាលនៃខោនធី ឬការិយាល័យក្នុងមូលដ្ឋានទេ។

បេក្ខជនដែលគេសរសេរបញ្ចូលឈ្មោះក្នុងសន្លឹកឆ្នោតសម្រាប់ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោតនៅតែអាចឈរឈ្មោះនៅក្នុងការបោះឆ្នោតបឋម។ ទោះជាយ៉ាងណាក៏ដោយ បេក្ខជនដែលគេសរសរបញ្ចូលឈ្មោះក្នុងសន្លឹកឆ្នោតអាចបន្តទៅការបោះឆ្នោតទូទៅបានតែក្នុងករណីដែលបេក្ខជននោះស្ថិតក្នុងចំណោមបេក្ខជនពីររូបដែលទទួលបានសម្លេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋមនោះ។ លើសពីនេះទៀត មិនមានដំណើរការតែងតាំងឯករាជ្យសម្រាប់ការបោះឆ្នោតទូទៅទេ។

ស្នងការអប់រំសាធារណៈគឺជាការិយាល័យមិនមែនបក្សព័ន្ធ។ ប្រសិនបើបេក្ខជនសម្រាប់ស្នងការអប់រំសាធារណៈទទួលបានសម្លេងភាគច្រើន (យ៉ាងហោចណាស់ 50 ភាគរយ +1) នៅក្នុងការបោះឆ្នោតបឋមនោះ បេក្ខជននោះនឹងត្រូវបានជាប់ឆ្នោត ហើយគ្មានធ្វើការបោះឆ្នោតទូទៅទៀតទេ។ អ្នកអាចរកព័ត៌មានបន្ថែមស្តីពីការិយាល័យគ្មានបក្សព័ន្ធនៅខាងក្រោម។

ច្បាប់រដ្ឋ California តម្រូវឱ្យបោះពុម្ពព័ត៌មានដូចខាងក្រោមនៅក្នុងមគ្គុទ្ទេសក៍នេះ។

ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោត

គណបក្សនយោបាយមិនមានសិទ្ធិតែងតាំងបេក្ខជនផ្លូវការសម្រាប់ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋមឡើយ។ បេក្ខជនដែលត្រូវបានតែងតាំងសម្រាប់ការិយាល័យដែលតែងតាំងដោយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបឋម គឺជាអ្នកដែលត្រូវបានតែងតាំងរបស់ពលរដ្ឋ ហើយមិនមែនជាបេក្ខជនជាផ្លូវការនៃគណបក្សណាមួយ នៅក្នុងការបោះឆ្នោតទូទៅនោះទេ។ បេក្ខជនសម្រាប់ការតែងតាំងទៅការិយាល័យដែលតែងតាំងដោយអ្នកបោះឆ្នោតត្រូវមានការបញ្ជាក់ពីគណបក្សអាទិភាពដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ឬការខ្វះគណបក្សអាទិភាពដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់របស់ខ្លួន នៅលើសន្លឹកឆ្នោត ប៉ុន្តែការកំណត់គណបក្សអាទិភាពត្រូវតែជ្រើសរើសដោយបេក្ខជន ហើយត្រូវបង្ហាញសម្រាប់តែជាព័ត៌មាននៃអ្នកបោះឆ្នោតតែប៉ុណ្ណោះ។ វាមិនមានន័យថាបេក្ខជនត្រូវតែងតាំង ឬគាំទ្រដោយគណបក្សដែលបានកំណត់ទេ ឬថាមានទំនាក់ទំនងរវាងគណបក្ស និងបេក្ខជន ហើយគ្មានបេក្ខជនណាដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោតត្រូវបានចាត់ទុកថាជាបេក្ខជនដែលត្រូវតែងតាំងជាផ្លូវការរបស់គណបក្សនយោបាយណាមួយឡើយ។ នៅក្នុងមគ្គុទេសក៍ព័ត៌មានអ្នកបោះឆ្នោតក្នុងខោនធី គណបក្សអាចចុះបញ្ជីបេក្ខជនសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតដែលបានទទួលការយល់ព្រមជាផ្លូវការពីគណបក្ស។

អ្នកបោះឆ្នោតណាមួយអាចបោះឆ្នោតជ្រើសរើសបេក្ខជនណាមួយសម្រាប់ការិយាល័យដែលត្រូវបានតែងតាំងដោយអ្នកបោះឆ្នោតប្រសិនបើពួកគេបំពេញតាមលក្ខណសម្បត្តិផ្សេងទៀតដែលតម្រូវឱ្យបោះឆ្នោតសម្រាប់ការិយាល័យនោះ។ អ្នកទទួលសម្លេងឆ្នោតពីររូបកំពូលក្នុងការបោះឆ្នោតបឋម បន្តទៅការបោះឆ្នោតសកលសម្រាប់ការិយាល័យដែលត្រូវតែងតាំងដោយអ្នកបោះឆ្នោត បើទោះបីជាបេក្ខជនទាំងពីរបានបញ្ជាក់ពីគណបក្សអាទិភាពដូចគ្នាក៏ដោយ។ គ្មានគណបក្សណាមានសិទ្ធិឱ្យបេក្ខជនដែលកំណត់គណបក្សអាទិភាពរបស់ខ្លួន បន្តទៅការបោះឆ្នោតទូទៅបានទេ លើកលែងតែបេក្ខជននោះស្ថិតក្នុងចំណោមបេក្ខជនពីររូបដែលទទួលបានសន្លឹកឆ្នោតច្រើនជាងគេនៅក្នុងការបោះឆ្នោតបឋម។

ការិយាល័យគ្មានបក្សព័ន្ធ

គណបក្សនយោបាយមិនមានសិទ្ធិតែងតាំងបេក្ខជនសម្រាប់ការិយាល័យគ្មានបក្សព័ន្ធ នៅក្នុងការបោះឆ្នោតបឋមទេ ហើយបេក្ខជននៅឯការបោះឆ្នោតបឋមមិនមែនជាបេក្ខជនជាផ្លូវការសម្រាប់គណបក្សណាមួយសម្រាប់ការិយាល័យជាក់លាក់នៅការបោះឆ្នោតសកលទេ។ បេក្ខជនសម្រាប់ការតែងតាំងឱ្យទៅការិយាល័យគ្មានបក្សព័ន្ធអាចមិនកំណត់គណបក្សអាទិភាព ឬខ្វះគណបក្សអាទិភាពរបស់ខ្លួននៅលើសន្លឹកឆ្នោត។ បេក្ខជនពីររូបដែលទទួលសម្លេងឆ្នោតច្រើនជាងគេក្នុងការបោះឆ្នោតបឋម នឹងបន្តទៅការបោះឆ្នោតទូទៅសម្រាប់ការិយាល័យគ្មានបក្សព័ន្ធ។

ការិយាល័យខោនធីបោះឆ្នោត

ខោនធី Alameda
(510) 272-6933
www.acgov.org/rov/index.htm

ខោនធី Alpine
(530) 694-2281
www.alpinecountyca.gov

ខោនធី Amador
(209) 223-6465
http://www.co.amador.ca.us/government/recorder-clerk

ខោនធី Butte
(530) 538-7761 or (800) 894-7761
(នៅក្នុងខោនធី Butte)
www.buttevotes.net

ខោនធី Calaveras
(209) 754-6376 ឬ (209) 754-6375
www.calaverasgov.us

ខោនធី Colusa
(530) 458-0500 ឬ (877) 458-0501
www.countyofcolusa.org/elections

ខោនធី Contra Costa
(925) 335-7800
www.contracostacore.us

ខោនធី Del Norte
(707) 465-0383 ឬ (707) 464-7216
www.co.del-norte.ca.us

ខោនធី El Dorado
(530) 621-7480 ឬ (800) 730-4322
www.edcgov.us/Elections

ខោនធី Fresno
(559) 600-8683
www.fresnovote.com

ខោនធី Glenn
(530) 934-6414
www.countyofglenn.net/dept/elections/welcome

ខោនធី Humboldt
(707) 445-7481
www.humboldtgov.org/elections

ខោនធី Imperial
(442) 265-1060 ឬ (442) 265-1074
www.co.imperial.ca.us

ខោនធី Inyo
(760) 878-0224
http://elections.inyocounty.us/

ខោនធី Kern
(661) 868-3590
www.kernvote.com

ខោនធី Kings
(559) 852-4401
www.countyofkings.com

ខោនធី Lake
(707) 263-2372
www.co.lake.ca.us/Government/Directory/ROV.htm

ខោនធី Lassen
(530) 251-8217
www.lassencounty.org/dept/registrar-voters-elections

ខោនធី Los Angeles
(800) 815-2666
www.lavote.net

ខោនធី Madera
(559) 675-7720 ឬ (800) 435-0509
www.votemadera.com

ខោនធី Marin
(415) 473-6456
marinvotes.org

ខោនធី Mariposa
(209) 966-2007
www.mariposacounty.org

ខោនធី Mendocino
(707) 234-6819
www.mendocinocounty.org/government/assessor-county-clerk-recorder-elections/elections

ខោនធី Merced
(209) 385-7541 ឬ (800) 561-0619
www.mercedelections.org

ខោនធី Modoc
(530) 233-6205
www.co.modoc.ca.us/departments/elections

ខោនធី Mono
(760) 932-5537 ឬ (760) 932-5530
monocounty.ca.gov/elections

ខោនធី Monterey
(831) 796-1499 ឬ (866) 887-9274
www.montereycountyelections.us/

ខោនធី Napa
(707) 253-4321
www.countyofnapa.org

ខោនធី Nevada
(530) 265-1298
http://www.mynevadacounty.com/1847/Elections-Voting

ខោនធី Orange
(714) 567-7600
www.ocvote.com

ខោនធី Placer
(530) 886-5650
www.placerelections.com

ខោនធី Plumas
(530) 283-6256 ឬ (844) 676-VOTE
www.countyofplumas.com

ខោនធី Riverside
(951) 486-7200
www.voteinfo.net

ខោនធី Sacramento
(916) 875-6451
www.elections.saccounty.net

San Benito ខោនធី
(831) 636-4016
sbcvote.us

San Bernardino ខោនធី
(909) 387-8300
www.sbcountyelections.com

San Diego ខោនធី
(858) 565-5800 ឬ (800) 696-0136
www.sdvote.com/

San Francisco ខោនធី
(415) 554-4375
sfelections.org

San Joaquin ខោនធី
(209) 468-2890 ឬ (209) 468-2885
www.sjcrov.org

San Luis Obispo ខោនធី
(805) 781-5228 ឬ (805) 781-5080
www.slovote.com

San Mateo ខោនធី
(650) 312-5222
www.smcare.org

Santa Barbara ខោនធី
(805) 568-2200
www.sbcvote.com

Santa Clara ខោនធី
(408) 299-8683 ឬ (866) 430-8683
www.sccvote.org

Santa Cruz ខោនធី
(831) 454-2060
www.votescount.com

Shasta ខោនធី
(530) 225-5730 ឬ (888) 560-8683
www.elections.co.shasta.ca.us

Sierra ខោនធី
(530) 289-3295
www.sierracounty.ca.gov

Siskiyou ខោនធី
(530) 842-8084 ឬ (888) 854-2000
ext. 8084
www.sisqvotes.org

Solano ខោនធី
(707) 784-6675
www.solanocounty.com/elections

Sonoma ខោនធី
(707) 565-6800
vote.sonoma-county.org

Stanislaus ខោនធី
(209) 525-5200
http://www.stanvote.com

Sutter ខោនធី
(530) 822-7122
www.suttercounty.org/elections

Tehama ខោនធី
(530) 527-8190
www.co.tehama.ca.us

Trinity ខោនធី
(530) 623-1220
www.trinitycounty.org/index.aspx?page=58

Tulare ខោនធី
(559) 624-7300
http://www.tularecoelections.org/elections/

Tuolumne ខោនធី
(209) 533-5570
www.co.tuolumne.ca.us/elections

Ventura ខោនធី
(805) 654-2664
www.venturavote.org

Yolo ខោនធី
(530) 666-8133
yoloelections.org

Yuba ខោនធី
(530) 749-7855
www.yubaelections.org

ការចុះឈ្មោះអ្នកបោះឆ្នោត

ប្រសិនបើអ្នកបានចុះឈ្មោះបោះឆ្នោតរួចហើយ អ្នកមិនចាំបាច់ចុះឈ្មោះម្តងទៀតឡើយ ***លើកលែងតែ*** អ្នកផ្លាស់ប្តូរឈ្មោះ អាស័យដ្ឋានផ្ទះ អាស័យដ្ឋានប្រៃសនីយ ឬប្រសិនបើអ្នកចង់ផ្លាស់ប្តូរ ឬ ប្រសិនបើអ្នកចង់ផ្លាស់ប្តូរបក្សនយោបាយមួយ។

អ្នកអាចចុះឈ្មោះបោះឆ្នោតលើបណ្តាញនៅ *RegisterToVote.ca.gov*ឬទូរស័ព្ទទៅខ្សែបណ្តាញអ្នកបោះឆ្នោតឥតគិតថ្លៃរបស់រដ្ឋលេខាធិការ តាមលេខ (888) 345-4917 ដើម្បីឱ្យគេផ្ញើសំបុត្រនូវពាក្យសុំមួយទៅអ្នក។

ពាក្យសុំចុះឈ្មោះអ្នកបោះឆ្នោតអាចរកបាននៅការិយាល័យប្រៃសណីយ៍ភាគច្រើន បណ្ណាល័យ ក្រុង និងការិយាល័យរដ្ឋាភិបាលខោនធី ការិយាល័យបោះឆ្នោតខោនធី និងការិយាល័យរដ្ឋលេខាធិការ California។

ការចុះឈ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ

តើអ្នកបានភ្លេចចុះឈ្មោះឬ? កុំបារម្ភអី! តើអ្នកដឹងថា អំឡុងរយៈពេលនៃ 14 ថ្ងៃ មុនពេលថ្ងៃបោះឆ្នោតរហូតដល់ និងរួមទាំងថ្ងៃបោះឆ្នោត អ្នកអាចទៅកាន់ការិយាល័យរបស់មន្ត្រីខោនធីរបស់អ្នក ឬមណ្ឌលបោះឆ្នោតដើម្បីចុះឈ្មោះមានលក្ខខណ្ឌដើម្បីបោះឆ្នោត? ដំណើរការនេះមានឈ្មោះថាការចុះឆ្មោះអ្នកបោះឆ្នោតមានលក្ខខណ្ឌ ការចុះឈ្មោះបោះឆ្នោតមានល័ក្ខខ័ណ្ឌ (CVR)។ នេះគឺជារបៀបដែលវាមានដំណើរការ៖

1. ចូលទៅកាន់ការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ឬមណ្ឌលបោះឆ្នោត—បញ្ជីពេញលេញនៃព័ត៌មានទំនាក់ទំនងខោនធីអាចរកបាននៅទីនេះ៖ *http://www.sos.ca.gov/elections/voting-resources/county-elections-offices/*
2. បំពេញប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោត ឬចុះឈ្មោះលើបណ្តាញលើ *RegisterToVote.ca.gov*
3. បោះឆ្នោតសន្លឹកឆ្នោតបណ្តោះអាសន្ន CVR នៅការិយាល័យបោះឆ្នោតខោនធី ឬមជ្ឈមណ្ឌលបោះឆ្នោតរបស់អ្នក

កាលណាមន្ត្រីការបោះឆ្នោតខោនធី ដំណើរការលិខិតបញ្ជាក់អំពីការចុះឈ្មោះ សម្រេចថាអ្នកមានលក្ខណសម្បត្តិគ្រប់គ្រាន់ដើម្បីនឹងចុះឈ្មោះ និងបញ្ជាក់អះអាងព័ត៌មានរបស់អ្នក ការចុះឈ្មោះក្លាយទៅជាអចិន្ត្រៃយ ហើយសន្លឹកឆ្នោតបណ្តោះអាសន្ន CVR នឹងត្រូវបានរាប់។

ដើម្បីស្វែងយល់បន្ថែមទៀត សូមចូលទៅ *http://www.sos.ca.gov/elections/voter-registration/conditional-voter-reg/*

មជ្ឈមណ្ឌលបោះឆ្នោតគឺអាចរកបានសម្រាប់អ្នកបោះឆ្នោតដែលកំពុងរស់នៅក្នុងខោនធី Madera, Napa, Nevada, Sacramento និង San Mateo។ ចូលមើល *VotersChoice.sos.ca.gov* ឬមើលទំព័រ 93 សម្រាប់ព័ត៌មានបន្ថែមនៅលើក្រមស្តីពី ជម្រើសរបស់អ្នកបោះឆ្នោត និងមជ្ឈមណ្ឌលបោះឆ្នោត។

ព័ត៌មានស្តីឯកជនភាពចុះឈ្មោះរបស់អ្នកបោះឆ្នោត

មានសុវត្ថិភាពនៅកម្មវិធីការចុះឈ្មោះអ្នកបោះឆ្នោតសម្ងាត់នៅផ្ទះ អ្នកបោះឆ្នោតមួយចំនួនដែលកំពុងប្រឈមនឹងដំណោះស្រាយដែលគម្រាមកំហែងដល់អាយុជីវិត (ឧទា. អំពើហិង្សាក្នុងគ្រួសារ ជនរងគ្រោះពីការឈ្លបចាប់) អាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ស្ថានភាពអ្នកបោះឆ្នោតសម្ងាត់។ សម្រាប់ព័ត៌មានបន្ថែម ទាក់ទងផ្នែកសុវត្ថិភាពរបស់ រដ្ឋលេខាធិការ នៅទូរស័ព្ទឥតគិតថ្លៃរបស់កម្មវិធី តាមលេខ (877) 322-5227 ឬចូលមើល *www.sos.ca.gov/registries/safe-home/*។

ឯកជនភាពនៃព័ត៌មានអ្នកបោះឆ្នោត៖ ព័ត៌មានអំពីសំបុត្របញ្ជាក់ការចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នកនឹងត្រូវបានប្រើដោយមន្ត្រីបោះឆ្នោតដើម្បីផ្ញើឱ្យអ្នកនូវព័ត៌មានផ្លូវការអំពីដំណើរការបោះឆ្នោត ដូចជាទីតាំងនៃកន្លែងបោះឆ្នោត និងបញ្ជា និងបេក្ខជននានាដែលនឹងលេចឡើងលើសន្លឹកឆ្នោត។ ការប្រើប្រាស់ព័ត៌មានការចុះឈ្មោះអ្នកបោះឆ្នោតសម្រាប់ពាណិជ្ជកម្ម គឺត្រូវបានហាមឃាត់ដោយច្បាប់ និងមានទោសកម្រិតមជ្ឈឹម។ ព័ត៌មានអ្នកបោះឆ្នោតប្រហែលជាត្រូវបានផ្តល់ទៅបេក្ខជនសម្រាប់មុខតំណែង គណៈកម្មាធិការវិធានការសន្លឹកឆ្នោត ឬជនដទៃទៀតសម្រាប់ការបោះឆ្នោត សម្រាប់គោលបំណងមានខ្លឹមសារ នយោបាយ និង រដ្ឋាភិបាលដូចបានសម្រេចដោយរដ្ឋលេខាធិការ។ ប័ណ្ណបើកបរ លេខសន្តិសុខសង្គម ឬ ហត្ថលេខារបស់អ្នក ដូចដែលបានបង្ហាញលើប័ណ្ណចុះឈ្មោះអ្នកបោះឆ្នោតរបស់អ្នក មិនត្រូវអាចបញ្ចេញសម្រាប់គោលបំណងទាំងនេះទេ។ ប្រសិនបើអ្នកមានសំណួរណាមួយអំពីការប្រើប្រាស់នូវព័ត៌មានអ្នកបោះឆ្នោត ឬចង់រាយការណ៍ពីការប្រើខុសដែលសង្ស័យនៃព័ត៌មានបែបនេះ សូមទូរស័ព្ទទៅខ្សែបណ្តាញអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការ តាមលេខ (888) 345-4917។

CALIFORNIA
VOTER'S CHOICE ACT

អនាគតនៃការបោះឆ្នោតក្នុង California

ចាប់ផ្តើមនៅឆ្នាំ 2018 អ្នកបោះឆ្នោតដែលបានចុះឈ្មោះទាំងអស់ក្នុងខោនធី Madera, Napa, Nevada, Sacramento, និង San Mateo នឹងទទួលបានសន្លឹកឆ្នោតរបស់ពួកគេតាមសំបុត្រ ក្នុងពេលប៉ុន្មានសប្តាហ៍មុនពេលពេលបោះឆ្នោត។ អ្នកបោះឆ្នោតនៅក្នុងខោនធីដែលចូលរួមនឹងមានជម្រើស 3 សម្រាប់របៀបបោះឆ្នោត៖

បោះឆ្នោតតាមសំបុត្រ៖ អ្នកអាចផ្ញើសន្លឹកឆ្នោតដែលបានបំពេញរបស់អ្នកឱ្យបានឆាប់តាមដែលអ្នកទទួលបាន។

ប្រអប់ទម្លាក់៖ អ្នកអាចទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរួចរបស់អ្នកនៅប្រអប់ទម្លាក់ខោនធីទាំងឡាយ ឱ្យឆាប់ៗនៅពេលអ្នកទទួលបានវា។ មិនចាំបាច់ត្រូវមានតែមនៅប្រអប់ទម្លាក់ឡើយ។

មជ្ឈមណ្ឌលបោះឆ្នោត៖ មជ្ឈមណ្ឌលបោះឆ្នោតនឹងប្តូរទីកន្លែងបោះឆ្នោត។ អ្នកអាចបោះឆ្នោតដោយខ្លួនឯងនៅមជ្ឈមណ្ឌលបោះឆ្នោតណាមួយនៅក្នុងខោនធីរបស់អ្នក។ មជ្ឈមណ្ឌលបោះឆ្នោតនឹងបើកសម្រាប់រយៈពេល 11 ថ្ងៃអប្បបរមា រហូតដល់ និងរួមបញ្ចូលទាំងថ្ងៃបោះឆ្នោត។

នៅមជ្ឈមណ្ឌលបោះឆ្នោតនីមួយៗ អ្នកអាច៖

- បោះឆ្នោតដោយផ្ទាល់
- ចុះឈ្មោះបោះឆ្នោត ឬធ្វើបច្ចុប្បន្នភាពការចុះឈ្មោះរបស់អ្នក
- ទម្លាក់សន្លឹកឆ្នោតដែលបានបំពេញរបស់អ្នក
- ទទួលបានសន្លឹកឆ្នោតជំនួស
- បោះឆ្នោតដោយប្រើម៉ាស៊ីនបោះឆ្នោតដែលអាចចូលប្រើបាន
- ទទួលបានជំនួយ និងសម្ភារៈបោះឆ្នោតជាពហុភាសា

ហេតុអ្វីមានការផ្លាស់ប្តូរ?

ក្រមស្តីពីជម្រើសរបស់អ្នកបោះឆ្នោតរដ្ឋ California បានក្លាយជាច្បាប់នៅក្នុងឆ្នាំ 2016 ដើម្បីធ្វើឱ្យការបោះឆ្នោតមានភាពងាយស្រួលនិងអាចចូលដំណើរការបាន។ អ្នកអាចជ្រើសរើសរបៀប នៅពេល និងទីកន្លែងដែលអ្នកបោះឆ្នោត។

តើខ្ញុំត្រូវបោះឆ្នោតនៅពេលណា?

អ្នកនឹងទទួលបានសន្លឹកឆ្នោតរបស់អ្នកនៅសំបុត្រ នៅប៉ុន្មានសប្តាហ៍មុនការបោះឆ្នោត។ បន្ទាប់ពីបំពេញសន្លឹកឆ្នោតរបស់អ្នករួច អ្នកអាចប្រគល់វាត្រឡប់តាមសំបុត្រ ឬនៅប្រអប់ទម្លាក់ខោនធី ឬមជ្ឈមណ្ឌលបោះឆ្នោតទាំងឡាយ។ មជ្ឈមណ្ឌលបោះឆ្នោតនឹងបើកសម្រាប់អប្បរមារយៈពេល 11 ថ្ងៃរហូតដល់ និងរួមបញ្ចូលថ្ងៃបោះឆ្នោត។

តើខ្ញុំស្វែងរកប្រអប់ទម្លាក់ ឬមជ្ឈមណ្ឌលបោះឆ្នោតនៅឯណា?

VotersChoice.sos.ca.gov

ចុះបើខ្ញុំមិនទទួលបានសន្លឹកឆ្នោតរបស់ខ្ញុំ?

ទៅកាន់មជ្ឈមណ្ឌលបោះឆ្នោតទាំងឡាយក្នុងខោនធីរបស់អ្នក ឬទូរស័ព្ទទៅមន្ត្រីការបោះឆ្នោតខោនធីរបស់អ្នកដើម្បីស្នើសុំការប្តូរ។

ចុះដូចម្តេចបើខ្ញុំមិននៅក្នុងខោនធីដែលចូលរួម?

ប្រសិនបើអ្នករស់នៅក្នុងខោនធីមួយដែលបច្ចុប្បន្នមិនបានចូលរួមក្នុងច្បាប់ស្តីពីជម្រើសរបស់អ្នកបោះឆ្នោត អ្នកនឹងបន្តបោះឆ្នោតដោយអ៊ីម៉ែល ឬនៅកន្លែងបោះឆ្នោត។ ទាក់ទងតាមលេខសម្រាប់អ្នកបោះឆ្នោតឥតគិតថ្លៃរបស់ រដ្ឋលេខាធិការ តាមលេខ (888) 345-4917 សម្រាប់ព័ត៌មានបន្ថែម។

អត្ថបទនៃសំណើច្បាប់គឺ *មិន* ត្រូវបានបោះពុម្ពចេញផ្សាយក្នុងមគ្គុទ្ទេសក៍នេះទេ។

ទោះបីជាយ៉ាងណា អត្ថបទឥឡូវអាចមើលបាននៅលើអ៊ីនធឺណិតតាម *http://voterguide.sos.ca.gov* ។

ប្រសិនបើអ្នកចង់បានសំណៅនៃអត្ថបទដែលបានបោះពុម្ពចេញផ្សាយ៖

សូមអ៊ីមែលទៅរដ្ឋលេខាធិការ *vigfeedback@sos.ca.gov*

សូមទាក់ទងខ្សែរទូរស័ព្ទអ្នកបោះឆ្នោតរបស់រដ្ឋលេខាធិការលេខ (888) 345-4917។

ជំនួយសម្រាប់អ្នកបោះឆ្នោតមានពិការភាព

ពិនិត្យមើលមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតរខោនធីរបស់អ្នក

មគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតខោនធីរបស់អ្នកនឹង៖

- ពិពណ៌នាអំពីវិធីដែលបុគ្គលមានពិការភាព អាចបោះឆ្នោតជាឯកជន និងដោយឯករាជ្យ
- បិទសញ្ញាកៅអីមានកង់ ប្រសិនបើកន្លែងបោះឆ្នោត គឺអាចចេញចូលបានដោយអ្នកបោះឆ្នោតមានពិការភាព

មគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោតជាសំឡេង និងអក្សរពុម្ពធំៗ

សៀវភៅមគ្គុទ្ទេសក៍ទាំងនេះគឺអាចរកបានដោយឥតគិតថ្លៃជាភាសាអង់គ្លេស ចិន ហិណ្ឌូ ជប៉ុន ខ្មែរ កូរ៉េ អេស្ប៉ាញ តាហ្គាឡុក ថៃ និងវៀតណាម។ ដើម្បីដាក់បញ្ជាសុំ៖

សូមទាក់ទងតាមខ្សែរទូរស័ព្ទអ្នកបោះឆ្នោតរបស់រដ្ឋ លេខាធិការលេខ (888) 345-4917

ទាញយកកំណែ MP3 អូឌីយ៉ូ នៅ *http://voterguide.sos.ca.gov/audio/kh*

ចូលមើល *http://voterguide.sos.ca.gov*

វិបសាយលទ្ធផលការបោះឆ្នោតរដ្ឋ

ចង់ឃើញថ្ងៃទី 6 ខែវិច្ឆិកា ឆ្នាំ 2018 លទ្ធផលការបោះឆ្នោតសាកល បន្ទាប់ពីការបោះឆ្នោត បិទនៅម៉ោង 8:00 យប់? ចូលមើល រ៉ុបសាយលទ្ធផលការបោះឆ្នោតរបស់ រដ្ឋលេខាធិការ California នៅ ***https://vote.sos.ca.gov/*** ។

វិបសាយលទ្ធផលការបោះឆ្នោតគឺត្រូវបានអាប់ដេតរៀងរាល់ប្រាំនាទីនៅយប់បោះឆ្នោត ជាលទ្ធផលរាយការណ៍ខោនធីទៅ រដ្ឋលេខាធិការ។ មន្ត្រីបោះឆ្នោតខោនធីធ្វើលទ្ធផលបោះឆ្នោតពាក់កណ្តាលផ្លូវការទៅ វិបសាយរបស់ រដ្ឋលេខាធិការ បន្ទាប់ពីការិយាល័យបោះឆ្នោតបិទនៅម៉ោង 8:00 យប់ ហើយបន្តធ្វើការអាប់ដេតនានានៅរៀងរាល់ពីរម៉ោងយ៉ាងតិចបំផុត រហូតទាល់សន្លឹកឆ្នោតនៅថ្ងៃបោះឆ្នោតត្រូវបានរាប់អស់។

ដោយច្បាប់ផ្តើមនៅថ្ងៃទី 8 ខែវិច្ឆិកា រហូតដល់ថ្ងៃទី 6 ខែធ្នូ ឆ្នាំ 2018 វិបសាយលទ្ធផលបោះឆ្នោតនឹងអាប់ដេតរៀងរាល់ថ្ងៃនៅម៉ោង 5:00 ល្ងាច នៅពេលខោនធីរាប់សន្លឹកឆ្នោតនៅសល់។

លទ្ធផលបោះឆ្នោតផ្លូវការនឹងត្រូវបានផ្សាយត្រឹមថ្ងៃទី 14 ខែធ្នូ ឆ្នាំ 2018 នៅ *www.sos.ca.gov/elections/*

កាលបរិច្ឆេទត្រូវចងចាំ!

ត្រូវចាំថា ទៅបោះឆ្នោត!

កន្លែងបោះឆ្នោតបើកទ្វារពីម៉ោង 7:00 ព្រឹករហូតដល់ម៉ោង 8:00 យប់នៅថ្ងៃបោះឆ្នោត!

ខែតុលា

អាទិត្យ	ច័ន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សៅរ៍
	1	2	3	4	5	6
7	8	9	10	11	12	13
14	15	16	17	18	19	20
21	22	23	24	25	26	27
28	29	30	31			

ថ្ងៃទី 8 ខែតុលា ឆ្នាំ 2018
ថ្ងៃទីមួយ ដើម្បីបោះឆ្នោតតាមសំបុត្រ។

ថ្ងៃទី 22 ខែតុលា ឆ្នាំ 2018
ថ្ងៃចុងក្រោយដើម្បីចុះឈ្មោះបោះឆ្នោត។ អ្នកអាចចុះឈ្មោះក្រោម "លក្ខខណ្ឌ" និងបោះឆ្នោតនៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក ក្រោយពី 15-ថ្ងៃនៃកាលបរិច្ឆេទផុតកំណត់ការចុះឈ្មោះអ្នកបោះឆ្នោត។

ថ្ងៃទី 30 ខែតុលា ឆ្នាំ 2018
ថ្ងៃចុងក្រោយដែលមន្ត្រីបោះឆ្នោតខោនធីនោះនឹងទទួលការដាក់សុំសម្រាប់ការបោះឆ្នោតតាមសំបុត្ររបស់អ្នកបោះឆ្នោតណាម្នាក់។

ខែវិច្ឆិកា

អាទិត្យ	ច័ន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សៅរ៍
				1	2	3
4	5	6	7	8	9	10
11	12	13	14	15	16	17
18	19	20	21	22	23	24
25	26	27	28	29	30	

ថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា ឆ្នាំ 2018
ថ្ងៃបោះឆ្នោត!

California Secretary of State
Elections Division
1500 11th Street
Sacramento, CA 95814

NONPROFIT
U.S. POSTAGE
PAID
CALIFORNIA
SECRETARY
OF STATE

OFFICIAL ELECTION MAIL
Authorized by the U.S. Postal Service

CALIFORNIA

ការបោះឆ្នោតសាកល

ពិនិត្យមើលស្ថានភាពបោះឆ្នោតលើអ៊ិនធឺណែតរបស់អ្នកបោះឆ្នោតនៅ *voterstatus.sos.ca.gov*

មគ្គុទ្ទេសក៍ព័ត៌មានអ្នកបោះឆ្នោតជាផ្លូវការ

ថ្ងៃអង្គារ ទី 6 ខែវិច្ឆិកា ឆ្នាំ 2018
ត្រូវចាំថា ទៅបោះឆ្នោត!
កន្លែងបោះឆ្នោតបើកទ្វារពីម៉ោង 7:00
ព្រឹករហូតដល់ម៉ោង 8:00 យប់

ថ្ងៃទី 8 ខែតុលា
ថ្ងៃទីមួយ ដើម្បីបោះឆ្នោតតាមសំបុត្រ។

ថ្ងៃទី 22 ខែតុលា*
ថ្ងៃចុងក្រោយដើម្បីចុះឈ្មោះបោះឆ្នោត។

ថ្ងៃទី 30 ខែតុលា
ថ្ងៃចុងក្រោយដែលមន្ត្រីបោះឆ្នោតខោនធីនឹងទទួលយកពាក្យសុំអ្នកបោះឆ្នោតណាមួយសម្រាប់សន្លឹកឆ្នោតបោះឆ្នោតតាមសំបុត្រ។

សម្រាប់ច្បាប់ចម្លងបន្ថែមនៃមគ្គុទ្ទេសក៍សម្រាប់ព័ត៌មានអ្នកបោះឆ្នោត ជាភាសាណាមួយខាងក្រោម សូមទូរស័ព្ទទៅ៖

English: (800) 345-VOTE (8683)
TTY/TDD: (800) 833-8683
Español/Spanish: (800) 232-VOTA (8682)
中文**/Chinese:** (800) 339-2857
हिन्दी**/Hindi:** (888) 345-2692
日本語**/Japanese:** (800) 339-2865
ខ្មែរ**/Khmer:** (888) 345-4917
한국어**/Korean:** (866) 575-1558
Tagalog: (800) 339-2957
ภาษาไทย**/Thai:** (855) 345-3933
Việt ngữ**/Vietnamese:** (800) 339-8163

សូមសរសេរអត្ថបទ *Vote* ទៅ GOVOTE (468683) ដើម្បីស្វែងរកទីតាំងនៃកន្លែងបោះឆ្នោតរបស់អ្នក។

អ្នកនៅតែអាចចុះឈ្មោះក្រោម "លក្ខខណ្ឌ" និងបោះឆ្នោតនៅការិយាល័យបោះឆ្នោតខោនធីរបស់អ្នក 15-ថ្ងៃក្រោយពីផុតកំណត់ការចុះឈ្មោះអ្នកបោះឆ្នោត។

ក្នុងកិច្ចប្រឹងប្រែងដើម្បីកាត់បន្ថយថ្លៃចំណាយការបោះឆ្នោត រដ្ឋសភារដ្ឋបានផ្តល់សិទ្ធិដល់រដ្ឋ និងបណ្តាខោនធីដើម្បីធ្វើសំបុត្រតែមគ្គុទ្ទេសក៍មួយប៉ុណ្ណោះទៅដល់គ្រួសារបោះឆ្នោតនីមួយៗ។ អ្នកអាចទទួលបានសំណៅបន្ថែមដោយទាក់ទងមន្ត្រីបោះឆ្នោតខោនធីរបស់អ្នកដោយទូរស័ព្ទទៅលេខ (888) 345-4917។

KHMER

OSP 18 145809